# ពី

# របបផ្តាច់ការ

# ទៅ

# ប្រជាធិបតេយ្យ

តាមគោលគំនិតអហិង្សា


## ជីន សាប

វិទ្យាស្ថានអាល់បឺតអាំងស្តាញ

The Albert Einstein Institution

*រូបថតក្របមុខ*

- *ខាងលើ : លោក ចន ប៊ឺគ ( Jon Bugge ) ©JonBugge*
- *ខាងក្រោម : លោក ខែម សុវណ្ណារា ©ខែមសុវណ្ណារា*

*រូបថតក្របក្រោយ*

- *លោក នីក វេស្ដូវ័រ ( Nick Westover ) ©NickWestover*

ជូនចំពោះមិត្ត រ៉ុង ឈុន

# បេសកកម្ម

# វិទ្យាស្ថានអាល់បឺតអាំងស្តាញ

បេសកកម្មនៃវិទ្យាស្ថានអាល់បឺតអាំងស្តាញ គឺជួយធ្វើអោយមានការរីកចំរើនដល់ការសិក្សាទូលំទូលាយ និងការប្រើប្រាស់អំពើអហិង្សាជាយុទ្ធសាស្ត្រ ក្នុងការដោះស្រាយទំនាស់នានាលើផែនដីនេះ ។

វិទ្យាស្ថាននេះប្តេជ្ញា ៖

- ការពារប្រជាធិបតេយ្យ សេរីភាព
- ប្រឆាំងនឹងការជិះជាន់ អំពើផ្តាច់ការ ការសំលាប់មនុស្សរង្គាល និង
- បន្ថយការពឹងផ្អែកទៅលើអំពើហិង្សា ក្នុងវិធានការនានា ។

បេសកកម្មនេះ សំរេចបានទៅតាមវិធានការបីយ៉ាង ៖

- ការជួយលើកទឹកចិត្តការស្រាវជ្រាវ ការសិក្សាអំពីវិធានការសំរាប់សកម្មភាពអហិង្សា និងការប្រើប្រាស់វិធានការនេះពីមុនៗក្នុងទំនាស់គ្រប់បែបយ៉ាង ។
- ការចែកចាយលទ្ធផលនៃការស្រាវជ្រាវនេះ ទៅសាធារណជន តាមរយៈ ការផ្សព្វផ្សាយ សន្និសីទ និងប្រព័ន្ធព័ត៌មាន ហើយនិង
- ការពិគ្រោះ ផ្តល់យោបល់ ដល់ក្រុមទាំងឡាយដែលមានទំនាស់អំពីផលដែលគេទទួលបានពីយុទ្ធសាស្ត្រនៃការប្រើអំពើអហិង្សា ។

អ្វីៗទាំងអស់នៅក្នុងសៀវភៅនេះ ស្ថិតនៅក្នុងវេទិកាសាធារណៈ
គឺគេអាចចំលងប្រើប្រាស់បាន ដោយពុំចាំបាច់មានការអនុញ្ញាតពីលោក ជីន សាប ឬ
អ្នកបកប្រែ ។ ប្រសិនបើលោកអ្នកចំលងវគ្គណាមួយក្នុងសៀវភៅនេះ
សូមមេត្តាបញ្ជាក់ប្រភពដើមអោយបានច្បាស់លាស់ ។ សូមអរគុណ ។

បោះពុម្ពលើកទីមួយ ខែឧសភា ឆ្នាំ២០០២
បោះពុម្ពលើកទីពីរ ខែមិថុនា ឆ្នាំ២០០៣

សៀវភៅ *"ពីរបបផ្តាច់ការទៅប្រជាធិបតេយ្យ"* បានត្រូវគេចេញផ្សាយជាលើកដំបូងបង្អស់
នៅទីក្រុងបាងកក ក្នុងឆ្នាំ១៩៩៣ ដោយក្រុមគណៈកម្មការ
សំរាប់កសាងលទ្ធិប្រជាធិបតេយ្យឡើងវិញនៅក្នុងប្រទេសភូមា
ក្នុងសហការជាមួយទស្សនាវដ្តីញូវអៀរ៉ា (The New Era Journal) (Khit Pyaing)។
តាំងពីពេលនោះមក គេបានបកប្រែសៀវភៅនេះចេញជាប្រាំបីភាសាយ៉ាងតិច
ហើយគេបានផ្សព្វផ្សាយនៅក្នុងប្រទេសសីបៀ ឥណ្ឌូនេស៊ី និងថៃ
ព្រមទាំងបណ្តាប្រទេសមួយចំនួនទៀត ។
នេះជាលើកទីមួយ ដែលសៀវភៅនេះចេញផ្សាយជាភាសាខ្មែរ បោះពុម្ពខែតុលា ២០០៥ ។

The Albert Einstein Institution
427 Newbury Street
Boston, MA 02115-1801, USA
Tel: USA+617-247-4882
Fax: USA+617-247-4035
E-mail: einstein@igc.org
Website: www.aeinstein.org

ISBN 1-880813-09-2 (ភាសាអង់គ្លេស)
ISBN 1-880813-13-0 (ភាសាខ្មែរ)

# ពីរបបផ្ដាច់ការ
# ទៅប្រជាធិបតេយ្យ

តាមគោលគំនិតអហិង្សា

# មាតិការឿង


កំណត់អ្នកបកប្រែ xiii

អារម្ភកថា xvi

ជំពូកទី ១

ប្រឈមមុខនឹងរបបផ្តាច់ការ ១

បញ្ហាដែលនៅមានបន្ត ៣

សេរីភាពតាមរយៈអំពើហិង្សា ៥

រដ្ឋប្រហារ ការបោះឆ្នោត អ្នកស្រោចស្រង់ពីបរទេស ៧

ការទទួលស្គាល់ការពិត ១០

ជំពូកទី ២

គ្រោះថ្នាក់នៃការចរចា ១៣

គុណសម្បត្តិ និងការខូចខាតនៃកិច្ចចរចា ១៤

ការចុះញ៉មតាមការចរចា ១៥

អំណាច និងយុត្តិធម៌នៅក្នុងកិច្ចចរចា ១៧

ការយល់ព្រមរបស់ពួកផ្តាច់ការ ១៨

តើសន្តិភាពបែបណា ២០

មូលហេតុសំរាប់សេចក្តីសង្ឃឹម ២០

ជំពូកទី ៣

ពេលណាអំណាចនឹងមកដល់ ២៣

រឿងព្រេងនិទានអំពីម្ចាស់ស្វា ២៣

ប្រភពចាំបាច់នានានៃអំណាចនយោបាយ ២៥
មណ្ឌលទាំងឡាយនៃអំណាចប្រជាធិបតេយ្យ ២៩

ជំពូកទី ៤
របបផ្តាច់ការមានចំណុចខ្សោយ ៣៣
ការសំគាល់រកមើលកែងជើងអាគីល ៣៣
ចំណុចខ្សោយរបស់របបផ្តាច់ការ ៣៤
ការវាយប្រហារទៅលើចំណុចខ្សោយនៃរបបផ្តាច់ការ ៣៦

ជំពូកទី ៥
ការប្រើប្រាស់អំណាច ៣៩
ដំណើរនៃការតស៊ូអហិង្សា ៤០
អាវុធនិងវិន័យអហិង្សា ៤១
ការបើកចំហ ភាពសំងាត់ និងឥរិយាបថត្រឹមត្រូវ ៤៥
ការប្រែប្រួលគ្រឹះអំណាច ៤៦
យន្តការបួនយ៉ាងសំរាប់ការប្រែប្រួល ៤៧
ឥទ្ធិពលប្រជាធិបតេយ្យនៃនយោបាយរើបម្រះ ៤៩
ភាពស្មុគស្មាញនៃការតស៊ូអហិង្សា ៥១

ជំពូកទី ៦
សេចក្តីត្រូវការអោយមានផែនការយុទ្ធសាស្រ្ត ៥៣
ការរៀបចំជាផែនការជាក់ស្តែង ៥៤
ឧបសគ្គក្នុងការរៀបចំផែនការ ៥៥
ពាក្យពេចន៍បួនសំខាន់ៗក្នុងការធ្វើផែនការយុទ្ធសាស្រ្ត ៥៩

ជំពូកទី ៧
ការរៀបចំជាយុទ្ធសាស្ត្រ ៦៣
ការជ្រើសរើសនយោបាយ ៦៥
ការរៀបចំផែនការដើម្បីលទ្ធិប្រជាធិបតេយ្យ ៦៦
ជំនួយពីក្រៅ ៦៧
ការរៀបចំយុទ្ធសាស្ត្រចំបង ៦៨
ការរៀបចំផែនការយុទ្ធសាស្ត្រសំរាប់យុទ្ធនាការ ៧១
ការផ្សព្វផ្សាយគំនិតមិនធ្វើសហការ ៧៤
ការបង្ក្រាបនិងវិធានការទប់ទល់ ៧៥
ការប្រកាន់ផែនការយុទ្ធសាស្ត្រអោយខ្ជាប់ ៧៦

ជំពូកទី ៨
ការអនុវត្តន៍នយោបាយរើបម្រះ ៧៩
ការតស៊ូសម្រាំង ៨០
ការតទល់ជានិមិត្តរូប ៨១
ការបែងចែកការទទួលខុសត្រូវ ៨៣
ការតំរង់ទៅរកអំណាចពួកផ្តាច់ការ ៨៤
ការប្រែប្រួលយុទ្ធសាស្ត្រ ៨៧

ជំពូកទី ៩
ការបំបែករបបផ្តាច់ការ ៨៩
ការពង្រីកសេរីភាព ៩១
ការបំបែករបបផ្តាច់ការ ៩៣
ការកាន់កាប់ជ័យជំនះដោយការទទួលខុសត្រូវ ៩៥

ជំពូកទី ១០
កិច្ចការជាមូលដ្ឋានសំរាប់ប្រជាធិបតេយ្យរឹងប៉ឹង ៩៧
ការគំរាមកំហែងពីរបបផ្តាច់ការថ្មី ៩៨
ការទប់ស្កាត់រដ្ឋប្រហារ ៩៩
ការព្រាងរដ្ឋធម្មនុញ្ញ ១០០
នយោបាយការពារជាតិតាមប្រជាធិបតេយ្យ ១០១
ការទទួលខុសត្រូវដ៏ល្អប្រសើរ ១០២
ឧបសម្ព័ន្ធ - មធ្យោបាយនៃសកម្មភាពអហិង្សា ១០៥
អំពីអ្នកនិពន្ធ ១២១
អំពីអ្នកបកប្រែ ១២៣

# កំណត់អ្នកបកប្រែ

គោលបំណងធំនៃកិច្ចការបកប្រែសំរួលនេះ នឹងបានសំរេចដូចប្រាថ្នា ប្រសិនបើការបោះពុម្ពផ្សព្វផ្សាយសៀវភៅរបស់លោកសាស្ត្រាចារ្យ ជីន សាប "ពីរបបផ្តាច់ការទៅប្រជាធិបតេយ្យ"ជាភាសាខ្មែរ អាចជួយជំរុញលើកទឹកចិត្ត អោយមានការត្រិះរិះពិចារណាអោយបានម៉ឺងម៉ាត់អំពីផែនការយុទ្ធសាស្ត្រ និងសកម្មភាពអហិង្សា ដែលអាចជួយទាញប្រទេសណាមួយអោយចេញផុតពីភាពក្រីក្រតោកយ៉ាក និងការចុះញ៉ម ។

ការវែកញែកប្រកែកគ្នាថា ប្រទេសណាមួយមានដំណើរការទៅមុខ ឬ ថយក្រោយប្រហែលជាពុំសូវសំខាន់ទេ ។ ការពិតនោះគឺប្រជាពលរដ្ឋប្រទេសក្រីក្រត្រូវឆ្លងកាត់ការឈឺចាប់ដែលមិនចាំបាច់ ។ ការរងទុក្ខវេទនាដែលប្រជាពលរដ្ឋបានទ្រាំទ្រ គួរតែជាការកន្ត្រាក់ដាស់ស្មារតីអោយភ្ញាក់រលឹក សំរាប់ប្រទេសក្រីក្រទាំងឡាយ ។ ព្រឹត្តិការណ៍នានាដែលមានកើតឡើងនៅក្នុងប្រទេសក្រីក្រ ហាក់ដូចជាពុំមានលក្ខណៈគោរព យោគយល់ ឬអាណិតអាសូរដល់ប្រជាពលរដ្ឋឡើយ ។

ប្រវត្តិសាស្ត្រប្រទេសក្រីក្រខ្លះពោរពេញទៅដោយ "បដិវត្តន៍" ដែលទទួលបរាជ័យ ។ សាច់រឿងដដែលៗចេះតែកើតមានឡើង មានតែតួឯកទេដែលផ្លាស់ប្តូរ ។ មតិរិះគន់ខ្លះអាចចាត់ទុកពួកអ្នកដឹកនាំទាំងនោះ ថាជាអភិជនមួយក្រុមដែលរវល់តែដណ្តើមគ្នាកាច់ចង្កូតកប៉ាល់ទីតាក់និច (Titanic) ។ ពួកគេមានចិត្តរីករាយនៅពេលឃើញពួកមេដឹកនាំចាស់រលត់រលាយ ហើយគេខិតខំធ្វើបែបណា ដើម្បីកុំអោយគូប្រជែងរបស់គេមានឱកាសក្លាយទៅជាអ្នកទទួលអំណាចបន្តនៅថ្ងៃមុខ ។ អ្នកទាំងនេះហាក់ដូចជារវល់ខ្លាំងណាស់ក្នុងការធ្វើយ៉ាងណា អោយគេបាននៅកាន់អំណាចយូរអង្វែងជាជាងធ្វើ អ្វីដើម្បីរំដោះប្រជាពលរដ្ឋអោយគេចផុតពីភាពក្រីក្រតោកយ៉ាក ទុក្ខវេទនា ហើយនិងពីការដឹកនាំដែលខ្វះប្រសិទ្ធភាព ។

គេអាចប្រៀបធៀបប្រជាពលរដ្ឋទៅកង្កែបក្នុងឆ្នាំងទឹកត្រជាក់ ដែលគេកំពុងតែបង្កាត់ភ្លើងដាំពីក្រោម ។ កង្កែបនេះប្រហែលជាកំពុងតែសំរបសំរួលខ្លួនទៅតាមកំដៅទឹក ដែលចេះតែកើនឡើងបន្តិចម្តងៗ ។ ទីបំផុត ការសំរបសំរួលដើម្បីរស់នេះនឹងធ្វើកង្កែបឆ្អិនស្លាប់ រើខ្លួនលោតចេញពីទឹកពុះពុំរួច ទោះបីជាពេលនោះ គេចង់រស់បែបណាក៏ដោយ ។ ប្រសិនបើគេត្រូវការឧទាហរណ៍ជាក់ស្តែងសំរាប់គ្រោះថ្នាក់នេះ គេពុំចាំបាច់សំឡឹងមើលឯណាវែងឆ្ងាយហួសពីប្រទេសចំប៉ាទេ ។ ប៉ុន្តែគេប្រហែលជាមើលពុំឃើញទេ ព្រោះប្រទេសចំប៉ាបានរលាយបាត់រូបរាងរួចយូរណាស់ទៅហើយ ។

ប្រហែលជាពេលវេលាដែលប្រជាពលរដ្ឋត្រូវធ្វើការរំដោះខ្លួនឯង ឈប់ពឹងផ្អែកលើអ្នកឯទៀតបានមកដល់ហើយ ។ ដូចដែលលោកសាស្ត្រាចារ្យ ជីន សាប បានស្រង់យកសំដីទៅដាក់ក្នុងសៀវភៅនេះថា "សេរីភាពមិនមែនបានដោយសេរីងាយស្រួល" ។ លោកបានស្នើជាទូទៅថា "ប្រជាពលរដ្ឋនឹងត្រូវតែរៀនអំពីរបៀបឆក់យកសេរីភាពនេះ ដោយខ្លួនឯង" (ទំព័រទី ១០៣) ។

គេឃើញមានកត្តាលើកទឹកចិត្ត សំរាប់អោយប្រជាពលរដ្ឋក្រីក្រធ្វើយ៉ាងនេះ និងរង្វាន់ជាច្រើនរង់ចាំ ប្រសិនបើប្រជាជាតិនេះមានជោគជ័យ ។ ប្រទេសក្រីក្រខ្លះមានដីធ្លីដែលមានជីវជាតិ ទឹកបឹង ទន្លេពាសពេញ និងចំនួនពលរដ្ឋតិចក្នុងមួយគីឡូម៉ែត្រការ៉េ ។ ទាំងនេះជាធនធានធម្មជាតិ និងកេរ្តិ៍មរតក ដែលរង់ចាំតែការគ្រប់គ្រងដ៏ល្អមួយ ។ អ្នកសេដ្ឋសាស្ត្រដែលមានឯកទេសខាងកាត់បន្ថយភាពក្រីក្រ លោកសាស្ត្រចារ្យ ជេវហ្វ្រី សាស់ (Jeffrey Sachs) បានជឿជាក់ថា ប្រទេសក្រីក្រខ្លះមានគុណសម្បត្តិជាច្រើន ដែលអាចធ្វើអោយប្រជាពលរដ្ឋទាំងអស់ មានជីវភាពរស់នៅជាមនុស្សក្នុងភាពថ្លៃថ្នូរ ។ ក្នុងផ្នែកអនុវត្តន៏វិញ សៀវភៅនេះបានផ្តល់នូវគំនិតជាច្រើនអំពីរបៀបតស៊ូយកសេរីភាព ដែលប្រជាពលរដ្ឋត្រូវការយ៉ាងខ្លាំងក្លា ដើម្បីចូលរួមក្នុងកិច្ចការទាំងឡាយ ដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅ ជារៀងរាល់ថ្ងៃរបស់គេ និងប្រយោជន៏ជាតិ ។ សៀវភៅនេះអាចជួយធ្វើអោយការអស់សង្ឃឹមក្លាយទៅជាមានសង្ឃឹម និងធ្វើអោយសេចក្តីសង្ឃឹមក្លាយជាការពិត ។

ការផ្សព្វផ្សាយសៀវភៅនេះជាភាសាខ្មែរបានចេញរួច ដោយសារតែមនុស្សមួយចំនួន ។ លោកសាស្ត្រាចារ្យ ជីន សាប បានកត់ត្រាគំនិតជាច្រើនទុកក្នុងសៀវភៅដែលអាចជួយអោយប្រជាពលរដ្ឋពិភពលោកកាន់កាប់វាសនាខ្លួនឯងវិញម្តង ។ លោកអាធ័រ អ៊ីដែលស្តាញ(Arthur Edelstein) នៃសកលវិទ្យាល័យកាលីហ្វ័រញ៉ា នៅប៊ឺរគ្លី (Berkeley) បានទាក់ទង ហើយផ្តល់អោយខ្ញុំ នូវឱកាសមួយដែលខ្ញុំពុំអាចបដិសេធបាន ដើម្បីជួយផ្សព្វផ្សាយគំនិត លោក ជីន សាប ជាភាសាខ្មែរ ។ ការបកប្រែជាភាសាខ្មែរនេះបានទទួលផលប្រយោជន៍ជាច្រើន ពីចំណេះអក្សរសាស្ត្រដ៏ជ្រៅជ្រះ របស់ព្រះភិក្ខុមួយអង្គ លោក លី សក្កា លោក មួង ណារ៉េត និង សហការីខ្ញុំមួយចំនួនទៀត ដែលបានជួយធ្វើការពិនិត្យពាក្យពេចន៍ ឃ្លាឃ្លោងយ៉ាងហ្មត់ចត់ ។ អ្នកជំនួយការខ្ញុំបានទទួលរ៉ាប់រងខាងការវាយអត្ថបទ និងរៀបចំអោយចេញជារូបភាពសៀវភៅ ។ មិត្តភ័ក្រ្តមួយចំនួននៅក្នុងស្រុកនិងបរទេស បានជួយលើកទឹកចិត្ត និងផ្តល់ជាធនធានសំរាប់បោះពុម្ពសៀវភៅនេះ ។ អ្នកជំនួយទាំងនោះ សុទ្ធតែជាអ្នកដែលប្តូរផ្តាច់ទៅលើលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សតាមសកម្មភាពអហិង្សា ។ ខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជគុណ និងអស់លោកអ្នកខាងលើទាំងអស់ដែលបានជួយជ្រោមជ្រែងគ្រប់ជ្រុងជ្រោយ ដើម្បីអោយសៀវភៅនេះចេញជារូបរាង ។ ទោះបីជាយ៉ាងណាក៏ដោយ កំហុសទាំងឡាយដែលមាននៅក្នុងសៀវភៅនេះ ស្ថិតនៅក្នុងការទទួលខុសត្រូវរបស់ខ្ញុំតែម្នាក់ឯងទាំងស្រុង ។

ខ្ញុំសូមចាត់ទុកស្នាដៃបកប្រែនេះជាការថ្លែងអំណរគុណដ៏ស្តួចស្តើងមួយ ចំពោះភរិយា និងកូនខ្ញុំទាំងពីរ ដែលបានគាំទ្រគំនិតនិងសកម្មភាពខ្ញុំជានិច្ច ដោយគ្មានលក្ខខណ្ឌ ។

*សមាជិកព្រឹទ្ធសភា អ៊ឹង ប៊ុនអាង*

អ្នកបកប្រែ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៥

# អារម្ភកថា

ខ្ញុំបានចាប់អារម្មណ៍រាប់ឆ្នាំមកហើយ ទៅលើរបៀបធ្វើយ៉ាងណា ដើម្បីបញ្ចៀស និងបំបាត់របបផ្តាច់ការ ។ ខ្ញុំរក្សាទុកអារម្មណ៍នេះ មួយផ្នែកដោយសារជំនឿថា មនុស្សលោកមិនគួរអោយរបបនេះ ជិះជាន់និងបំផ្លិចបំផ្លាញទាល់តែសោះ ។ ជំនឿនេះ កាន់តែមានកំរិតខ្លាំងឡើង តាមការអាននានាអំពីសារៈសំខាន់នៃសេរីភាពរបស់មនុស្ស អំពីលក្ខណៈនៃរបបផ្តាច់ការ (តាំងពីគំនិតលោកអារីស្តូត [Aristotle] ទៅដល់ ការវែកញែកអំពីផ្តាច់ការនិយម) និងប្រវត្តិនៃរបបផ្តាច់ការ (ជាពិសេសស្ថាប័នណាស៊ី [Nazi] និងស្តាលីន [Stalin] ) ។

ក្នុងរយៈពេលរាប់ឆ្នាំមកនេះ ខ្ញុំបានមានឱកាសជួបស្គាល់មនុស្ស ដែលបាន រស់ និងរងគ្រោះក្រោមអំណាចណាស៊ី រួមមានទាំងអ្នកដែលរស់ផុតជីវិតពីគុកទៀត ផង ។ នៅក្នុងប្រទេសន័រវ៉េ (Norway) ខ្ញុំបានជួបអ្នកដែលបានប្រឆាំងនឹងរបប ផ្តាច់ការហ្វាស៊ីស ហើយបានរួចជីវិត និងបានឮអំពីអ្នកដែលបាត់បង់ជីវិត ។ ខ្ញុំបាន និយាយជាមួយពួកជ្វិហ (Jews) ដែលបានគេចផុតពីកណ្តាប់ដៃណាស៊ី និងជាមួយ អ្នកដែលបានជួយរំដោះជីវិតអ្នករងគ្រោះទាំងនោះផង ។

គេអាចបានដឹងច្រើនអំពីអំពើឃោឃៅនៃរបបកុម្មុយនីស្តក្នុងប្រទេសនានា តាមការអានសៀវភៅ ជាងការទាក់ទងដោយផ្ទាល់ ។ ចំពោះខ្ញុំ អំពើឃោរឃៅនៃ របបទាំងនេះហាក់ដូចជាគួរអោយស្តាយ ជាពិសេស ដោយអំពើផ្តាច់ការនេះបានត្រូវ គេអនុវត្តក្នុងរូបភាពជាការរំដោះប្រជាពលរដ្ឋពីការជិះជាន់ និងការកេងប្រវ័ញ្ច ។ ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ តាមរយៈអ្នកធ្វើដំណើរពីប្រទេសផ្តាច់ការ ដូចជា ប៉ាណាម៉ា (Panama) ប៉ូឡូញ (Poland) ឈីលី (Chile) ទីបេ (Tibet) និងភូមា (Burma) យើងបានដឹងថា ភាពពិតជាក់ស្តែងនៃរបបផ្តាច់ការបច្ចុប្បន្ននេះ មានកំរិត

កាន់តែខ្លាំងឡើង ។ ពីអ្នកស្រុកទីបេដែលបានប្រយុទ្ធប្រឆាំងនឹងការឈ្លានពានរបស់ពួកចិនកុម្មុយនីស្ត និង ពួករុស្ស៊ីដែលបានជោគជ័យទៅលើរដ្ឋប្រហាររបស់ក្រុមជ្រុលនិយមក្នុងខែសីហាឆ្នាំ១៩៩១ ហើយនិងពួកថៃដែលបានរារាំង ដោយសន្តិវិធី មិនអោយរបបយោធាវិលត្រឡប់មកវិញ ខ្ញុំបានរៀនសូត្របន្ថែមអំពីការចេញលក្ខណៈសាហាវសន្ធឹមៗនៃរបបផ្តាច់ការ ។

សមានចិត្តអាណិតអាសូរ និងកំហឹងពុះពោរចំពោះអំពើសាហាវឃោរឃៅជាមួយនិងការស្ងើចសរសើរដល់វីរភាពដ៏នឹងហ្ន នៃបុរសស្ត្រីដ៏ក្លាហានដែលមិនគួរអោយជឿបាន កាន់តែមានកំរិតខ្លាំងឡើង នៅពេលគេធ្វើដំណើរទៅដល់ទីកន្លែងកើតហេតុ ។ គឺជាទីកន្លែងដែលនៅតែមានគ្រោះថ្នាក់ ប៉ុន្តែអ្នកក្លាហានទាំងនោះនៅតែក្រាញតស៊ូតទៅទៀត ។ ទីកន្លែងទាំងនោះមានជាអាទិ៍ ប្រទេសប៉ាណាម៉ា នៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ណូរីអ៊ីហ្គា (Noriega) , ដំបន់វីលនីអ៊ុស (Vilnius) លីធូអានៀ (Lithuania) ក្រោមការជិះជាន់របស់សូវៀត, ទីធ្លាធៀនណាមិន (Tiananmen Square) នៃទីក្រុងប៉េកាំង (Beijing) ដែលគេបានឃើញមហាបាតុកម្មដ៏អស្ចារ្យ ដើម្បីសេរីភាព និងការទៅដល់នៃកងរថក្រោះ ដែលបានបញ្ចប់រាត្រីនោះយ៉ាងឃោរឃៅ, ទីស្នាក់ការក្នុងព្រៃនៃក្រុមប្រជាធិបតេយ្យ នៅម៉ាណ័រផ្លូវ (Manerplaw) ក្នុងតំបន់“រំដោះភូមា” ។

ជួនកាល ខ្ញុំបានទៅដល់ទីកន្លែងដែលអ្នកទាំងនោះបានបូជាជីវិត ដូចជាដងគោមទូរទស្សន៍ និងទីកន្លែងកប់ខ្មោចនៅវិលនីអ៊ុស, សួនសាធារណៈនៅទីក្រុងរីហ្គា (Riga) ជាទីកន្លែងដែលគេបាញ់សំលាប់មនុស្សមួយចំនួន, មណ្ឌលហ្វេរ៉ារ៉ា (Ferrara) នៅផ្នែកខាងជើងប្រទេសអ៊ីតាលី ជាទីកន្លែងដែលពួកហ្វាស៊ីស តំរៀបពួកអ្នកប្រឆាំងជាជួរ មុននឹងបាញ់រះសំលាប់ចោល ហើយនិងទីកប់ខ្មោចដ៏សាមញ្ញមួយ នៅម៉ាណ័រផ្លូវ ដែលពោរពេញទៅដោយសពអ្នកតស៊ូក្មេងៗ ។ ការពិតដ៏អាណោចអាធ័មមួយនោះគឺ របបផ្តាច់ការនីមួយៗតែងតែបន្សល់ទុកនូវការបាត់បង់ជីវិត និងការខូចខាតបែបនេះ ។

ការកង្វល់ និងបទពិសោធន៍ទាំងនោះ បាននាំអោយមានសេចក្តីសង្ឃឹមដ៏មុឹងម៉ាត់ថា ការបញ្ចៀសរបបផ្តាច់ការនេះប្រហែលជាអាចធ្វើទៅបាន, និងការតស៊ូ

ដ៏ជោគជ័យប្រឆាំងនឹងរបបផ្តាច់ការ អាចសំរេចបានដោយពុំចាំបាច់សំលាប់គ្នាដោយរង្គាលទៅវិញទៅមក, ហើយថា គេអាចរំលំរបបផ្តាច់ការ ហើយរារាំងមិនអោយរបបផ្តាច់ការថ្មីមួយទៀត លេចចេញពីគំនរផេះទាំងនោះបាន ។

ខ្ញុំបានល្បងធ្វើវិភាគយ៉ាងហ្មត់ចត់ អំពីវិធានការដ៏មានប្រសិទ្ធភាពបំផុត ដើម្បីរុះរើរបបផ្តាច់ការ អោយបានជោគជ័យ ដោយពុំចាំបាច់បង្កអោយមានការខូចខាតខ្លាំង តាមរយៈការធ្វើអោយមានការបាត់បង់ជីវិតនិងការឈឺចាប់ ។ ក្នុងការធ្វើបែបនេះ ខ្ញុំបានពឹងផ្អែកទៅលើការសិក្សារាប់ឆ្នាំរបស់ខ្ញុំ អំពីរបបផ្តាច់ការនានា ចលនាប្រឆាំង បដិវត្តន៍ គំនិតនយោបាយ ប្រព័ន្ធគ្រប់គ្រងរដ្ឋ និងជាពិសេស អំពីការប្រយុទ្ធតស៊ូអហិង្សាដ៏ជាក់ស្តែង ។

សៀវភៅនេះ គឺជាលទ្ធផលនៃការសិក្សារបស់ខ្ញុំ ។ ខ្ញុំដឹងច្បាស់ថា ស្នាដៃនេះពុំទាន់បានល្អសុក្រិត ឥតខ្ចោះនោះឡើយ ។ ប៉ុន្តែលទ្ធផលនេះ ប្រហែលជាអាចផ្តល់នូវការណែនាំខ្លះៗ ដើម្បីជាជំនួយដល់ការគិតនិងការរៀបចំផែនការ ក្នុងការបង្កើតអោយចេញជាចលនារំដោះមួយ ដែលមានថាមពលនិងប្រសិទ្ធភាពខ្លាំងក្លា ។

ជាការចាំបាច់ និងយោងទៅតាមការជ្រើសរើសដ៏ហ្មត់ចត់ ខ្លឹមសារនៃការសិក្សាវិភាគក្នុងសៀវភៅនេះ នឹងផ្តោតទៅលើបញ្ហាជាទូទៅ ដែលពាក់ព័ន្ធនឹងការធ្វើយ៉ាងណា ដើម្បីរំលំរបបផ្តាច់ការ ហើយនិងបញ្ចៀសកុំអោយរបបផ្តាច់ការថ្មីមួយទៀតមកជំនួសបាន ។ ខ្ញុំពុំមានសមត្ថភាពគ្រប់គ្រាន់សំរាប់ធ្វើការវិភាគ និងធ្វើសំណើអោយបានពិស្តារ សំរាប់ប្រទេសណាមួយជាក់ស្តែងនោះឡើយ ។ ប៉ុន្តែសេចក្តីសង្ឃឹមរបស់ខ្ញុំនោះគឺ ការវិភាគសិក្សាជាទូទៅបែបនេះ ប្រហែលជាអាចមានប្រយោជន៍ដល់មនុស្សក្នុងប្រទេសជាច្រើន ដែលកំពុងតែប្រឈមមុខតទល់នឹងរបបផ្តាច់ការជាក់ស្តែង ។ អ្នកទាំងនោះត្រូវពិនិត្យថ្លឹងថ្លែងខ្លឹមសារ នៃការវិភាគក្នុងសៀវភៅនេះ សំរាប់ករណីពិសេសរបស់គេ ហើយសំរេចថា តើគេអាចលើកយក ឬក៏កែច្នៃសំណើសំខាន់ៗណាមួយក្នុងសៀវភៅនេះដល់កំរិតណាដែរ សំរាប់ការតស៊ូរំដោះរបស់គេ ។

ខ្ញុំមានការជាប់ជំពាក់គុណជាច្រើនក្នុងការសរសេរសៀវភៅនេះ ។ លោកប្រូស ចែងឃីន (Bruce Jenkins) អ្នកជំនួយការខ្ញុំបានជួយខ្ញុំជាច្រើន លើសពី

ការស្មាន ក្នុងការរកឃើញកំហុសនានា ក្នុងសៀវភៅនេះ និងការអោយយោបល់ក្នុងការពន្យល់គំនិតពិបាកៗអោយងាយស្រួលយល់ ជាពិសេស គំនិតដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ ។

ខ្ញុំក៏សូមអរគុណផងដែរ ចំពោះលោក ស្ទេហ្វិន កូឌី (Stephen Coady) ដែលបានជួយកែសំរួលពាក្យពេចន៍ និងអក្ខរាវិរុទ្ធ ។ បណ្ឌិត គ្រីស្តូហ្វ័រ គ្រូល័រ (Christopher Kruegler) និងលោក រូបឺត ហេលវី (Robert Helvey) បានផ្តល់នូវការរិះគន់និងយោបល់សំខាន់ៗជាច្រើន ។ លោកស្រីបណ្ឌិត ហេសិល ម៉ាហ្វីសុន (Hazel McFerson) និងលោកស្រីបណ្ឌិតប៉ាទ្រីស៊ីយ៉ា ផាកមិន(Patricia Parkman) បានផ្តល់អោយខ្ញុំ នូវព័ត៌មានអំពីការតស៊ូក្នុងទ្វីបអាហ្វ្រិក និងអាមេរិកខាងត្បូង ។ ថ្វីបើការសិក្សារបស់ខ្ញុំនេះបានទទួលផលប្រយោជន៍ជាច្រើនពីការគាំទ្រដ៏ប្រសើរទាំងនេះក្តី ការវិភាគ និងសេចក្តីសន្និដ្ឋានទាំងឡាយក្នុងសៀវភៅនេះ គឺជាការទទួលខុសត្រូវរបស់ខ្ញុំទាំងស្រុង ។

នៅក្នុងការវិភាគរបស់ខ្ញុំនេះ ពុំមានចំណុចណាមួយ ដែលខ្ញុំសន្មតថា ការតទល់ប្រឆាំងមេផ្តាច់ការទាំងឡាយជាការងាយស្រួល និងគ្មានការខូចខាតនោះឡើយ ។ ការតស៊ូគ្រប់ប្រភេទតែងតែមានបញ្ហាស្មុគស្មាញ និងខូចខាតខ្លះជានិច្ច ។ ការប្រយុទ្ធប្រឆាំងនឹងពួកផ្តាច់ការ នឹងនាំមកនូវការខូចខាតពុំខាន ។ ប៉ុន្តែសេចក្តីសង្ឃឹមរបស់ខ្ញុំនោះគឺ ការវិភាគក្នុងសៀវភៅនេះ នឹងជំរុញអោយអ្នកដឹកនាំការប្រឆាំងទាំងឡាយគិតគូរអំពីយុទ្ធសាស្ត្រ ដែលអាចជួយអោយកំលាំងរបស់គេកាន់តែមានប្រសិទ្ធភាពជាមួយគ្នានឹងការបន្ថយការខូចខាត ។

គេមិនគួរបកស្រាយការវិភាគក្នុងសៀវភៅនេះថា នៅពេលដែលរបបផ្តាច់ការមួយបានដួលរលំ បញ្ហាឯទៀតនឹងត្រូវចប់ដែរនោះទេ ។ ការរលំដួលនៃរបបមួយមិនមែននាំមកនូវរបបថ្មីមួយដ៏ល្អនោះឡើយ ។ ការនេះគ្រាន់តែបើកផ្លូវទៅរកកិច្ចការដ៏លំបាក និងការខ្នះខ្នែងដ៏យូរអង្វែងទៀត ដើម្បីស្ថាបនាអោយមានទំនាក់ទំនងសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ ដ៏ត្រឹមត្រូវ ហើយនិងបំបាត់ចោលនូវភាពអយុត្តិធម៌ និងការជិះជាន់ឯទៀត ។ ខ្ញុំសង្ឃឹមថា ការវិភាគដ៏ខ្លីក្នុងសៀវភៅនេះ អំពីរបៀបកំចាត់

របបផ្តាច់ការ នឹងអាចមានផលប្រយោជន៍ ក្នុងករណីទាំងឡាយណា ដែលមនុស្ស រស់នៅក្រោមការជិះជាន់ ហើយដែលអ្នកទាំងនោះមានបំណងចង់បានសេរីភាព ។

*ជីន សាប*

ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៣
វិទ្យាស្ថានអាល់បឺតអាំងស្តាញ
អគារលេខ ៤២៧ ផ្លូវញូវប៉ូរី ក្រុងបូស្តុន រដ្ឋម៉ាសាជូសិត ០២១១៥-១៨០១

# ជំពូកទី១

# ការប្រឈមមុខនឹងរបបផ្តាច់ការ

អស់រយៈពេលច្រើនឆ្នាំកន្លងទៅថ្មីៗនេះ របបផ្តាច់ការមួយចំនួន ដែលមានប្រភពក្នុងស្រុក និងក្រៅស្រុក បានដួលរលំ នៅពេលដែលជួបប្រឈមមុខជាមួយនឹងប្រជាពលរដ្ឋ ដែលមានស្មារតីរឹងប៉ឹង និងការប្រមូលគ្នាជាក្រុម ។ របបផ្តាច់ការខ្លះទាំងនោះហាក់ដូចជាមានភាពមាំមួន ដែលគ្មាននរណាអាចប៉ះពាល់បាន ប៉ុន្តែទីបំផុតពុំមានលទ្ធភាពប្រឈមមុខតទល់នឹងប្រជាពលរដ្ឋ ដែលសហការគ្នា រើបម្រះបដិសេធមិនធ្វើតាមបញ្ជា ខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងខាងសង្គមកិច្ច ។

តាំងពីឆ្នាំ១៩៨០ របបផ្តាច់ការមួយចំនួនបានដួលរលំ នៅចំពោះមុខការរើបម្រះអហិង្សា របស់ប្រជាពលរដ្ឋ នៅប្រទេសអេស្តូនៀ (Estonia) ឡាតវៀ (Latvia) លីធូអានៀ (Lithuania) ប៉ូឡូញ (Poland) អាឡឺម៉ង់ខាងកើត (East Germany)ឆេកូស្លូវ៉ាគី (Czechoslovakia) ស្លូវេនៀ (Slovenia) ម៉ាដាហ្គាស្កា (Madagascar) ម៉ាលី (Mali) បូលីវៀ (Bolivia) និងហ្វីលីពីន (Philippines) ។ ការប្រឆាំងអហិង្សាបានជំរុញអោយមានចលនាទៅរកលទ្ធិប្រជាធិបតេយ្យទៅមុខ នៅក្នុងប្រទេស នេប៉ាល់ (Nepal) សំប៊ៀ (Zambia) កូរ៉េខាងត្បូង (South Korea) ឈីលី (Chile) អាហ្សង់ទីន (Argentina) ហៃទី (Haiti) ប្រេស៊ីល (Brazil) អ៊ុយរូហ្គាយ (Uruguay) ម៉ាឡាវី (Malawi) ប៊ុលហ្គារី (Bulgaria) ហុងគ្រី (Hungary) ស្សៃរ៉េ (Zaire) នីហ្សេរី (Nigeria) និងតំបន់ផ្សេងៗនៃអតីតសហភាពសូវៀត (ដើរតួយ៉ាងសំខាន់ ក្នុងការធ្វើ

អោយពួកជ្រុលនិយមបរាជ័យក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារ ក្នុងខែសីហា ឆ្នាំ១៩៩១) ។

លើសពីនេះទៅទៀត នយោបាយរើបម្រះ[9] ពីសំណាក់ពលរដ្ឋ ក៏បានកើតឡើងក្នុងប្រទេសចិន ភូមា ទីបេ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះដែរ ។ ថ្វីបើការតស៊ូទាំងនោះពុំបាននាំមកនូវការបញ្ចប់របបផ្តាច់ការឬក៏ការកាន់កាប់ក៏ដោយ ក៏ការតស៊ូទាំងនោះបានបង្ហាញអោយសហគមន៍អន្តរជាតិឃើញ ភាពសាហាវនៃរបបជិះជាន់ ហើយបានផ្តល់អោយពលរដ្ឋទាំងនោះ នូវបទពិសោធន៍ដ៏មានតំលៃ សំរាប់ការតស៊ូបែបនេះ ។

ការដួលរលំនៃរបបផ្តាច់ការនៃប្រទេសទាំងប៉ុន្មានខាងលើនេះ ច្បាស់ជាពុំបានលុបបំបាត់នូវបញ្ហាទាំងឡាយដែលមាននៅក្នុងសង្គមទាំងនោះឡើយ ៖ ភាពក្រីក្រ ឧក្រិដ្ឋកម្ម កិច្ចការរដ្ឋបាលដែលពុំមានប្រសិទ្ធភាព និងការបំផ្លិចបំផ្លាញធម្មជាតិ ដែលជារឿយៗ ជាស្នាដៃនៃរបបឃោរឃៅទាំងនោះ ។ ប៉ុន្តែការដួលរលំនៃរបបទាំងនោះបានធ្វើអោយអ្នករងគ្រោះរួចពីការជិះជាន់ មានការធូរស្បើយ ហើយបើកផ្លូវអោយមានការកសាងសង្គមទាំងនោះឡើងវិញ ជាមួយនឹងនយោបាយប្រជាធិបតេយ្យ សេរីភាពបុគ្គល និងយុត្តិធម៌សង្គម ។

---

[9] លោករ៉ូបឺត ហែលវី (Robert Helvey) បានប្រើពាក្យនេះជាលើកដំបូង ។ “នយោបាយរើបម្រះ” គឺជាការតស៊ូអហិង្សា (បាតុកម្ម ការមិនធ្វើសហការ និងការធ្វើអន្តរាគមន៍) ដែលគេ អនុវត្តន៍យ៉ាងសកម្មយ៉ាងមានៈ សំរាប់គោលបំណងនយោបាយ ។ ពាក្យនេះគេបានប្រើជាដំបូង ដើម្បីបំបាត់ការយល់ច្រឡំ និងការយល់ខុសដែលកើតឡើងពីការចាត់ទុកការតស៊ូ អហិង្សាជាមួយនឹង “អំពើអហិង្សា” ក្នុងន័យសាសនា សីលធម៌ និងការនិយមសន្តិភាព ។ “ ការរើបម្រះ ” មានន័យថា គឺជាការតទល់នឹងអាជ្ញាធរដោយគ្រោងទុក តាមរយៈការមិនគោរព ដោយមិនចុះញ៉ម ។ “នយោបាយរើបម្រះ” រៀបរាប់អំពីសភាពការដែលគេធ្វើសកម្មភាព (នយោបាយ) ជាមួយនឹងគោលបំណង (អំណាចនយោបាយ)។ គេប្រើពាក្យនេះជាអាទិ៍ សំរាប់រៀបរាប់អំពីសកម្មភាពរបស់ប្រជាពលរដ្ឋ ដើម្បីដណ្តើមយកពីរបបផ្តាច់ការ នូវការគ្រប់គ្រងស្ថាប័នរដ្ឋបាល តាមរយៈការវាយប្រហារដោយឥតឈប់ឈរទៅលើប្រភពអំណាច ហើយ និងប្រើប្រាស់ការរៀបចំផែនការយុទ្ធសាស្រ្ត និងការដាក់អនុវត្តន៍ ។ នៅក្នុងសៀវភៅនេះ ពាក្យ “នយោបាយរើបម្រះ” “ការប្រឆាំងអហិង្សា ” និង “ការតស៊ូអហិង្សា ” មានន័យដូចគ្នា ថ្វីបើពាក្យទាំងពីរចុងក្រោយ ជាទូទៅនិយាយអំពីការតស៊ូ ដើម្បីគោលបំណងទូលំទូលាយ (បញ្ហាសង្គម សេដ្ឋកិច្ច ចិត្តសាស្រ្ត ជាដើម)។

# បញ្ហាដែលនៅមានបន្ត

ជាការពិត គេបានសង្កេតឃើញមានចរន្តទៅរកលទ្ធិប្រជាធិបតេយ្យ និង សេរីភាពនៅក្នុងពិភពលោក ក្នុងប៉ុន្មានទសវត្សកន្លងទៅនេះ ។ យោងទៅតាមអង្គការ ហ្វ្រីដុមហោស (Freedom House) ដែលបានចងក្រងជារៀងរាល់ឆ្នាំ នូវការសិក្សា អន្តរជាតិមួយ អំពីប្រភេទនៃសិទ្ធិនយោបាយនិងសេរីភាពស៊ីវិល ចំនួនប្រទេសទូទៅ ក្នុងលោក ដែលគេអាចចាត់ទុកថាមាន "សេរីភាព" បានកើនឡើងជាច្រើន ក្នុង រយៈពេល ៣០ឆ្នាំកន្លងទៅនេះ[២] ៖

| | សេរីភាពពេញលេញ | សេរីភាពខ្វះ | គ្មានសេរីភាព |
|---|---|---|---|
| **១៩៧៤** | ៤១ | ៤៨ | ៦៣ |
| **២០០៤** | ៨៩ | ៥៤ | ៤៩ |

ប៉ុន្តែ ចរន្តដ៏ល្អនេះ បានជួបប្រទះនឹងការរាំងស្ទះខ្លះ ដោយសារនៅមាន ពលរដ្ឋមួយចំនួនធំទៀត ដែលកំពុងរស់នៅក្រោមអំណាចផ្តាច់ការ ។ មកទល់នឹងខែមករា ឆ្នាំ១៩៩៣ ៣១ភាគរយនៃប្រជាពលរដ្ឋពិភពលោកដែលមានទាំងអស់ ៥.៤៥០លាន នាក់ បានរស់នៅក្នុងប្រទេសនិងដែនដី ដែលគេកំណត់ថា "គ្មានសេរីភាព"[៣] គឺជាទី កន្លែងដែលគេរាំងយ៉ាងតឹងតែងមិនអោយមានសិទ្ធិនយោបាយ និងសេរីភាព ស៊ីវិល ។ ក្នុងឆ្នាំ២០០៤ ប្រទេស ដែនដីចំនួន ៤៩កន្លែងនៅក្នុងប្រភេទ "គ្មានសេរីភាព" បាន ស្ថិតនៅក្រោមអំណាចផ្តាច់ការយោធា (ដូចជានៅប្រទេសភូមា និងស៊ូដាន [Sudan]) របបរាជានិយមផ្តាច់ការ (ដូចជា ប្រទេសសូឌីអារេប៊ីយ៉ា [Saudi Arabia] នេប៉ាល់

---

[២] ហ្វ្រីដុមហោស (Freedom House) *សេរីភាពក្នុងពិភពលោក : ការស្រង់ស្ថិតិប្រចាំឆ្នាំអំពី សិទ្ធិនយោបាយ និងសេរីភាពស៊ីវិល* (ញូវយ៉ក [New York] ហ្វ្រីដុមហោស ឆ្នាំ២០០៤) ។

[៣] ហ្វ្រីដុមហោស *សេរីភាពក្នុងពិភពលោក* ១៩៩៣ ទំព័រទី ៤ ។

[Nepal] និងប៊ូថាន [Bhutan]) គណបក្សនយោបាយផ្តាច់ការ (ដូចជាប្រទេសចិន និងកូរ៉េខាងជើង) ពួកឈ្លានពានបរទេស (ដូចជានៅទីបេ) ឬក៏ស្ថិតនៅក្នុងស្ថានភាពអន្តរកាល ។

ក្នុងពេលបច្ចុប្បន្ននេះ ប្រទេសជាច្រើនស្ថិតនៅក្នុងដំណាក់ការដែលមានការប្រែប្រួលយ៉ាងខ្លាំង ខាងសេដ្ឋកិច្ច នយោបាយ និងសង្គម ។ ថ្វីបើចំនួនប្រទេសដែលមានសេរីភាពពេញលេញ បានកើនឡើងក្នុងរយៈពេល៣០ឆ្នាំកន្លងទៅនេះក្តី ក៏នៅមានគ្រោះថ្នាក់ច្រើនទៀត ដោយសារប្រជាជាតិជាច្រើន ក្នុងដំណាក់ការដែលមានការប្រែប្រួលខ្លាំងនេះ នឹងវិវត្តន៍ថយក្រោយទៅរករបបផ្តាច់ការដែលមានរូបភាពថ្មី ។ ក្រុមយោធា ពួកបុគ្គលដែលមានមហិច្ឆតា អ្នកជាប់ឆ្នោត និងគណបក្សនយោបាយ នឹងខំខ្នះខ្នែងដាក់បង្ខំអោយគេឯទៀតធ្វើតាមបំណងរបស់ខ្លួន ។ ការធ្វើរដ្ឋប្រហារ ជាព្រឹត្តិការណ៍ដែលនឹងកើតមានឡើងជាធម្មតា ។ គេនឹងនៅតែរំលោភសិទ្ធិមនុស្ស និងសិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋមួយចំនួនធំតទៅទៀត ។

គឺជាសំណាងអាក្រក់ ដែលអតីតកាលនៅតែតាមជាប់ជាមួយយើង ។ បញ្ហារបបផ្តាច់ការមានកំរិតជ្រៅណាស់ ។ ប្រជាពលរដ្ឋក្នុងប្រទេសជាច្រើនបានឆ្លងកាត់បទពិសោធន៍រាប់ទសវត្ស ឬក៏សតវត្សនៃការជិះជាន់ ដែលមានប្រភពក្នុងស្រុកឬក៏ពីបរទេស ។ ជារឿយៗ ភាពចុះញ៉មដោយមិនតវ៉ាទៅអ្នកកាន់អំណាច បានក្លាយទៅជាការធម្មតា ។ នៅក្នុងករណីជ្រុលហួសហេតុ ស្ថាប័នសង្គម នយោបាយ សេដ្ឋកិច្ច ឬក៏សាសនា ដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់រដ្ឋ បានត្រូវគេធ្វើអោយចុះខ្សោយ ដាក់ជាចំណុះ ឬក៏ជំនួសដោយស្ថាប័នថ្មី ដែលរដ្ឋនិងគណបក្សកាន់អំណាចប្រើប្រាស់ដើម្បីគ្រប់គ្រងសង្គមទាំងមូល ។ ប្រជាពលរដ្ឋបានត្រូវគេបំបែកអោយទៅជាអង្គភាពតូចៗ (ក្លាយទៅជាមនុស្សឯកោមួយក្រុមដ៏ធំ) ដែលពុំអាចធ្វើការជាមួយគ្នា ដើម្បីអោយបានសេរីភាព និងអោយមានទំនុកទុកចិត្តគ្នាទៅវិញទៅមក ឬក៏ធ្វើការអ្វីមួយកើតដោយមហាជនខ្លួនឯង ។

គេអាចទស្សន៍ទាយផលវិបាកនៃការបំបែកនេះបានយ៉ាងច្បាស់លាស់ ។ ប្រជាពលរដ្ឋត្រូវចុះខ្សោយ ខ្វះការទុកចិត្តខ្លួនឯង ហើយគ្មានសមត្ថភាពនឹងតស៊ូ

ប្រឆាំង ។ ជារឿយៗ ប្រជាពលរដ្ឋមានការភ័យខ្លាច មិនហ៊ាននិយាយ សូម្បីជាមួយគ្រួសារនិងមិត្តភក្តិ អំពីការដែលគេស្អប់របបផ្តាច់ការ និងការដែលគេស្រេកឃ្លានចង់បានសេរីភាព ។ ជារឿយៗ អ្នកទាំងនោះមិនហ៊ានគិតគួរអោយមែនទែន អំពីការប្រឆាំងជាសាធារណៈឡើយ ។ គេនាំគ្នាចោទសួរថា តើគំនិតប្រឆាំងនេះនឹងមានប្រយោជន៍អ្វី? ម្ល៉ោះហើយ គេនឹងទទួលយក ការរងទុក្ខវេទនាដែលគ្មានន័យ និងអនាគតមួយដែលគ្មានសង្ឃឹម ។

សភាពការណ៍ក្នុងរបបផ្តាច់ការបច្ចុប្បន្ន ប្រហែលជាយ៉ាប់យ៉ឺនជាងពីពេលមុន ។ ក្នុងអតីតកាល អ្នកខ្លះប្រហែលជាបានសាកល្បងធ្វើការប្រឆាំង ។ ការប្រឆាំងរបស់មហាជន និងបាតុកម្មដែលមានរយៈពេលខ្លី បានកើតមានឡើង ។ ទឹកចិត្តប្រហែលជាពុះកញ្ជ្រោលភ្លៀវភ្លាមួយរយៈពេល ។ ពេលខ្លះទៀត បុគ្គលម្នាក់ៗនិងក្រុមតូចៗអាចធ្វើសកម្មភាពដ៏ក្លាហាន ប៉ុន្តែពុំបានផ្តល់ជាផលធំដុំ ក្រៅពីបង្ហាញគោលការណ៍ ឬក៏គ្រាន់តែជាការរើបម្រះ ។ ទោះបីជាបុព្វហេតុទាំងឡាយថ្លៃថ្លាបែបណាក៏ដោយ សកម្មភាពប្រឆាំងទាំងនោះ ជារឿយៗ មិនគ្រប់គ្រាន់ ដើម្បីបំបាត់ការភ័យខ្លាចរបស់ពលរដ្ឋ និងបំបាត់ទំលាប់គោរពតាមបញ្ជាគេ ដែលជាកត្តាចាំបាច់ដើម្បីរំលំរបបផ្តាច់ការ ។ គួរអោយអាណិតអាសូរ សកម្មភាពទាំងនោះ ប្រហែលជាបានត្រឹមតែបង្កើនការឈឺចាប់ និងការបាត់បង់ជីវិត មិនមែនជាការនាំទៅរកជ័យជំនះ ឬក៏សេចក្តីសង្ឃឹមទាល់តែសោះ ។

# សេរីភាពតាមរយៈអំពើហិង្សា

តើគេត្រូវធ្វើយ៉ាងណា ក្នុងកាលៈទេសៈបែបនេះ ? មធ្យោបាយជាក់ស្តែងនានា ហាក់ដូចជាពុំបានការ ។ ឧបសគ្គខាងរដ្ឋធម្មនុញ្ញនិងច្បាប់ ការវិនិច្ឆ័យរបស់តុលាការ និងមតិសាធារណជន ជាធម្មតាត្រូវបានពួកផ្តាច់ការបំភ្លេចចោល ។ គេអាចយល់បានអំពីការសន្និដ្ឋានដែលមានជារឿយៗថា ក្នុងការតបតទៅនឹងអំពើឃោរឃៅ ការធ្វើទារុណកម្ម ការបាត់ខ្លួនមនុស្ស និងឃាតកម្មនានា មានតែអំពើហិង្សា

ទេ ដែលអាចបញ្ចប់របបផ្តាច់ការបាន ។ ជួនកាល អ្នករងគ្រោះដែលក្តៅក្រហាយបានរៀបចំធ្វើការប្រយុទ្ធប្រឆាំងពួកផ្តាច់ការឃោរឃៅ ដោយប្រើមធ្យោបាយយោធា និងហិង្សាដែលគេអាចប្រមូលបាន ទោះបីជ័យជំនះមានកំរិតតិចតួចបែបណាក៏ដោយ ។ អ្នកទាំងនេះ ជារឿយៗ ចូលប្រយុទ្ធយ៉ាងក្លាហាន សុខចិត្តរងគ្រោះ និងលះបង់ជីវិត ។ ជួនកាល គេទទួលបានជោគជ័យដែលគួរអោយកត់សំគាល់ ប៉ុន្តែគេកម្រនឹងឈ្នះបានសេរីភាពណាស់ ។ ការបះបោរតាមអំពើហិង្សា អាចនឹងនាំអោយមានការសង្កត់សង្កិនដ៏ឃោរឃៅកាន់តែខ្លាំង ដែលជាហេតុធ្វើអោយប្រជាពលរដ្ឋអស់សង្ឃឹមជាងមុនទៅទៀត ។

ប៉ុន្តែទោះបីជាមធ្យោបាយហិង្សាមានលក្ខណៈល្អប្រសើរបែបណាក៏ដោយ គេដឹងអំពីចំណុចមួយយ៉ាងច្បាស់លាស់ ។ *តាមរយៈការដាក់ជំនឿទៅលើមធ្យោបាយហិង្សា គេបានជ្រើសរើសយកការតស៊ូមួយប្រភេទ ដែលពួកជិះជាន់មានប្រៀបស្ទើរគ្រប់ពេលវេលា* ។ ពួកផ្តាច់ការមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីអនុវត្តអំពើហិង្សាអោយបានខ្លាំងក្លា ។ ទោះបីជាពួកប្រជាធិបតេយ្យអាចបន្តមធ្យោបាយបែបនេះ ក្នុងរយៈពេលខ្លីឬយូរយ៉ាងណាក៏ដោយ ទីបំផុត គេពុំអាចជៀសផុតពីការពិតដ៏ជូរចត់អំពីការប្រើកំលាំងយោធានោះទេ ។ ពួកផ្តាច់ការមានប្រៀបខាងគ្រឿងអាវុធយោធា គ្រាប់រំសេវ ការដឹកជញ្ជូន និងកំលាំងទ័ព ស្ទើរគ្រប់កាលៈទេសៈ ។ ទោះជាមានសេចក្តីក្លាហានបែបណាក៏ដោយ ពួកប្រជាធិបតេយ្យពុំអាចប្រកួត (ស្ទើរគ្រប់ករណី) តាមបែបនេះបានឡើយ ។

នៅពេលដែលគេទទួលស្គាល់ថា ការបះបោរតាមកំលាំងយោធាធម្មតាពុំមានភាពជាក់ស្តែង អ្នកប្រឆាំងខ្លះបែរទៅគាំទ្រសង្គ្រាមឆ្មក់ព្រៃ ។ ប៉ុន្តែសង្គ្រាមឆ្មក់ព្រៃកម្រផ្តល់ផលប្រយោជន៍ ដល់ប្រជាពលរដ្ឋដែលគេជិះជាន់ ឬក៏អ្នកគាំទ្រលទ្ធិប្រជាធិបតេយ្យ ។ សង្គ្រាមព្រៃពុំអាចផ្តល់នូវការដោះស្រាយអោយច្បាស់លាស់ទេ ជាពិសេស នៅពេលដែលការខូចខាតក្នុងចំណោមប្រជាពលរដ្ឋអាចមានកំរិតធ្ងន់ធ្ងរ ។ មធ្យោបាយនេះគ្មានការធានាមិនអោយបរាជ័យនោះឡើយ ថ្វីបើគេមានទ្រឹស្តីគាំទ្រ និងការវែកញែកយុទ្ធសាស្ត្រ ហើយជួនកាលមានទាំងការគាំទ្រពីសំណាក់អន្តរជាតិ

ទៀតផងក៏ដោយ ។ ជារឿយៗ ការតស៊ូតាមព្រៃនេះ ត្រូវការពេលវេលាយូរអង្វែង ។ ប្រជាពលរដ្ឋច្រើនតែត្រូវខ្ចាតចេញពីទីលំនៅ ជាមួយនឹងការរងគ្រោះឈឺចាប់ឥតឧបមា ដោយសារតែពួកកាន់អំណាចផ្តាច់ការ ។

ទោះបីបានជោគជ័យក៏ដោយ ការតស៊ូសង្គ្រាមព្រៃ ជារឿយៗ នាំមកនូវផលវិបាកក្នុងរយៈពេលវែងឆ្ងាយ ។ ភ្លាមៗនោះ របបដែលគេវាយប្រហារ នឹងកាន់តែផ្តាច់ការឡើង ក្នុងការតបតរបស់គេ ។ ប្រសិនបើពួកទ័ពព្រៃបានទទួលជោគជ័យនៅទីបំផុត របបថ្មីដែលលេចចេញឡើង ច្រើនតែផ្តាច់ការជាងរបបមុន ដោយសារបុព្វហេតុពីរ ។ ទីមួយ គឺកំលាំងទ័ពមានកាន់តែច្រើន តាមការរួមបញ្ចូលគ្នា រវាងពួកយោធាព្រៃនិងពួកយោធាចាស់ ។ ទីពីរ នៅពេលតស៊ូ ឯករាជភាពនៃស្ថាប័នសង្គមនានាបានត្រូវចុះខ្សោយ ឬក៏ខូចខាត ។ អង្គការទាំងនេះ មានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ និងពង្រឹងសង្គមប្រជាធិបតេយ្យ ម្ល៉ោះហើយ គេមិនត្រូវអោយចុះខ្សោយទេ ។ ពួកអ្នកប្រឆាំងនឹងរបបផ្តាច់ការ គួរតែរិះរកមធ្យោបាយផ្សេងទៀត ។

# រដ្ឋប្រហារ ការបោះឆ្នោត អ្នកស្រោចស្រង់ពីបរទេស

រដ្ឋប្រហារយោធាប្រឆាំងនឹងរបបផ្តាច់ការហាក់ដូចជាមធ្យោបាយមួយ ដែលងាយស្រួល និងឆាប់បំផុត សំរាប់រំលំរបបឃោរឃៅ ។ ប៉ុន្តែមធ្យោបាយនេះ មានបញ្ហាធំៗមួយចំនួន ។ សំខាន់ជាងនេះទៅទៀត រដ្ឋប្រហាររក្សាទុកដដែល នូវការចែកអំណាចមិនត្រឹមត្រូវបច្ចុប្បន្ន រវាងប្រជាពលរដ្ឋ និងពួកថ្មីដែលគ្រប់គ្រងរដ្ឋបាល និងកងកំលាំងយោធារបស់គេ ។ ការដកយកបុគ្គលណាម្នាក់ ឬមនុស្សមួយក្រុមចេញពីតំណែងគ្រប់គ្រង ប្រហែលគ្រាន់តែជាការអនុញ្ញាតអោយក្រុមមួយទៀត មកចូលជំនួសតែប៉ុណ្ណោះ ។ ជាទ្រឹស្តី ក្រុមថ្មីនេះហាក់ដូចជាមានឥរិយាបថ (អាកប្បកិរិយា) ធូរជាងពួកមុន និងប្រហែលជាអនុញ្ញាតអោយមានកំណែទំរង់តាមលទ្ធិប្រជាធិបតេយ្យមួយកំរិត ។ ប៉ុន្តែ ការពិតប្រហែលជាផ្ទុយពីនេះទៅវិញ ។

ក្រោយពីបានពង្រឹងជំហរគេហើយ ក្រុមថ្មីអាចក្លាយទៅជាឃោរឃៅ ហើយ

និងមានមហិច្ឆតាជាងក្រុមចាស់ ។ បន្ទាប់មក ក្រុមថ្មីដែលប្រជាពលរដ្ឋបានដាក់សេចក្តីសង្ឃឹមទៅលើនេះ នឹងអាចធ្វើអ្វីទាំងអស់ទៅតាមចំណង់ ដោយគ្មានរវល់នឹងលទ្ធិប្រជាធិបតេយ្យ ឬក៏សិទ្ធិមនុស្ស ។ នេះគឺជាការដោះស្រាយបញ្ហារបបផ្តាច់ការដែលគេមិនអាចទទួលយកបាន ។

របបផ្តាច់ការមិនទទួលយកការបោះឆ្នោតថា ជាឧបករណ៍មួយដ៏សំខាន់ សំរាប់ការផ្លាស់ប្តូរខាងនយោបាយទេ ។ របបផ្តាច់ការខ្លះ ដូចជានៅលោកខាងលិច ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សូវៀត បានរៀបចំអោយមានការបោះឆ្នោត ដើម្បីអោយមានរូបភាពជាលក្ខណៈប្រជាធិបតេយ្យ ។ ប៉ុន្តែការបោះឆ្នោតទាំងនោះ គ្រាន់តែជាការស្រង់មតិដែលគេគ្រប់គ្រងយ៉ាងហ្មត់ចត់ ដើម្បីអោយសាធារណជនយល់ព្រមទទួលយកបេក្ខជន ដែលពួកផ្តាច់ការបានជ្រើសរើសយ៉ាងប្រយ័ត្នប្រយែងទុកជាមុន ។ ពួកផ្តាច់ការដែលស្ថិតនៅក្រោមការគាបសង្កត់ណាមួយ ជួនកាលអាចយល់ព្រមអោយមានការបោះឆ្នោត ប៉ុន្តែបន្ទាប់មក គេនឹងលែលកបន្លំសន្លឹកឆ្នោត ដើម្បីអោយពួកអាយ៉ងស៊ីវិលបានចូលទៅក្នុងរដ្ឋាភិបាលថ្មី ។ ប្រសិនបើបេក្ខជនក្រុមប្រឆាំងបានត្រូវគេអនុញ្ញាតអោយឈរឈ្មោះចូលប្រកួត ហើយជាប់ឆ្នោត ដូចជា នៅប្រទេសភូមាក្នុងឆ្នាំ១៩៩០ និងណៃសៀរី (Nigeria) ក្នុងឆ្នាំ១៩៩៣ លទ្ធផលនៃការបោះឆ្នោតបែបនេះអាចត្រូវគេបដិសេធ ហើយ“អ្នកឈ្នះ”នឹងត្រូវទទួលការសំឡុត ចាប់ខ្លួន ឬក៏អស់ជីវិត ។ ពួកផ្តាច់ការមិនមែនចូលចិត្តការបោះឆ្នោត ដែលអាចដកគេចេញពីបល្ល័ង្កនោះឡើយ ។

មនុស្សជាច្រើនដែលកំពុងរងគ្រោះក្រោមរបបផ្តាច់ការ ឬក៏រត់ចោលស្រុកដើម្បីជៀសអោយផុតពីកណ្តាប់ដៃពួកផ្តាច់ការ ពុំមានជំនឿថា អ្នកដែលគេជិះជាន់អាចរំដោះខ្លួនឯងកើតឡើយ ។ គេរំពឹងថា មានតែអ្នកឯទៀតទេ ដែលអាចជួយគេកើត ។ អ្នកទាំងនេះ ទុកចិត្តទៅលើកំលាំងពីក្រៅស្រុក ។ គេជឿថា មានតែជំនួយអន្តរជាតិទេ ដែលមានកំលាំងគ្រប់គ្រាន់ ដើម្បីរំលំរបបផ្តាច់ការ ។

ជួនកាល ការយល់ឃើញថា អ្នកដែលគេជិះជាន់ពុំអាចធ្វើអ្វីៗអោយមានប្រសិទ្ធភាព ជាការត្រឹមត្រូវក្នុងរយៈពេលមួយ ។ ជារឿយៗ អ្នកដែលគេជិះជាន់

មិនចង់ ហើយក៏ពុំអាចតស៊ូ ក្នុងរយៈពេលខ្លី ពីព្រោះអ្នកទាំងនោះគ្មានជំនឿទៅលើសមត្ថភាពរបស់ខ្លួនឯង ក្នុងការប្រឈមមុខតទល់នឹងរបបផ្តាច់ការដ៏ឃោរឃៅ ហើយគេមិនដឹងធ្វើយ៉ាងណា ដើម្បីជួយខ្លួនឯងកើត ។

ដូច្នេះ គេអាចយល់បានថា មនុស្សជាច្រើនបានដាក់សេចក្តីសង្ឃឹមទៅលើអ្នកដទៃ ក្នុងការរំដោះនេះ ។ កំលាំងពីក្រៅនេះ មានជាអាទិ៍អាចជា"មតិសាធារណជន" អង្គការសហប្រជាជាតិ ប្រទេសណាមួយ ឬក៏ការដាក់ទណ្ឌកម្មខាងសេដ្ឋកិច្ចនិងនយោបាយពីសំណាក់អន្តរជាតិ ។

រូបភាពបែបនេះហាក់ដូចជាធ្វើអោយគេស្រួលអារម្មណ៍ ប៉ុន្តែការរំពឹងលើអ្នកជួយពីក្រៅនេះ មានបញ្ហាច្រើន ។ ការទុកចិត្តបែបនេះអាចខុសស្រឡះ ។ ជាធម្មតា គ្មានបរទេសណាមកស្រោចស្រង់ទេ ហើយប្រសិនបើមានបរទេសណាមួយចូលមកធ្វើអន្តរាគមន៍មែន គេពុំអាចទុកចិត្តលើបរទេសនោះបានឡើយ ។

គេត្រូវបញ្ជាក់អំពីការពិតជាក់ស្តែង ដែលគេមិនចង់ដឹងឮ ពាក់ព័ន្ធទៅនឹងការពឹងផ្អែកលើអន្តរាគមន៍បរទេស ដូចខាងក្រោមនេះ ៖

- ជារឿយៗ ពួកបរទេសនឹងអត់អោន ឬក៏ជួយរបបផ្តាច់ការ ដើម្បីអោយបានផលប្រយោជន៍គេខាងសេដ្ឋកិច្ច ឬនយោបាយ ។
- ពួកបរទេសក៏អាចបោះបង់ចោលពួកអ្នកដែលគេជិះជាន់ ដើម្បីផលប្រយោជន៍អាថ៌កំបាំងមួយផ្សេងទៀត ជាជាងរក្សាពាក្យសន្យាថា ជួយធ្វើការរំដោះ ។
- ពួកបរទេសខ្លះនឹងប្រឆាំងតទល់របបផ្តាច់ការ ក្នុងករណីដែលគេចង់ត្រួតត្រាប្រទេសខាងផ្នែកសេដ្ឋកិច្ច នយោបាយ ឬក៏កំលាំងយោធា ។
- ពួកបរទេសអាចចូលរួមយ៉ាងសកម្ម ដើម្បីគោលបំណងល្អត្រឹមត្រូវ តែក្នុងករណីណាដែលចលនាតស៊ូក្នុងស្រុក បានធ្វើអោយរបបផ្តាច់ការផ្តើមរង្គោះរង្គើរួចទៅហើយ តាមរយៈការធ្វើអោយអន្តរជាតិចាប់អារម្មណ៍ទៅលើភាពឃោរឃៅរបស់របបនោះ ។

ជាធម្មតា របបផ្តាច់ការកើតមានឡើង ដោយសារការបែងចែកអំណាចផ្ទៃក្នុងនៅក្នុងស្រុក ។ ប្រជាពលរដ្ឋ និងសង្គមមានលក្ខណៈទន់ខ្សោយ ដែលពុំអាចបង្កបង្កើតជាបញ្ហាដល់របបផ្តាច់ការបាន ។ ថ្វីបើរបបផ្តាច់ការអាចបានចំណេញឬក៏ចុះទន់ខ្សោយ ដោយសារអំពើរបស់អន្តរជាតិ ជីវិតរបស់គេស្ថិតលើកត្តាក្នុងស្រុកស្ទើរតែទាំងស្រុង ។ ប៉ុន្តែការដាក់សំពាធអន្តរជាតិ អាចបានផលប្រយោជន៍ច្រើន នៅពេលដែលគេគាំទ្រចលនាតស៊ូក្នុងស្រុក ដែលមានកំលាំងខ្លាំង ។ ឧទាហរណ៍ ការធ្វើពហិការសេដ្ឋកិច្ចអន្តរជាតិ ការផ្តាច់សកម្មភាពអន្តរជាតិអ្វីមួយ ការដកទូត ការបណ្តេញចេញពីអង្គការអន្តរជាតិនានា ការថ្កោលទោសពីក្រុមនានានៃអង្គការសហប្រជាជាតិ ឬក៏អំពើណាមួយបែបនេះ អាចជាជំនួយយ៉ាងខ្លាំង ។ ប៉ុន្តែ ប្រសិនបើគ្មានចលនាតស៊ូផ្ទៃក្នុងអោយបានខ្លាំងក្លាទេនោះ អំពើបរទេសបែបនេះ ក៏ប្រហែលជាគ្មានដែរ ។

## ការទទួលស្គាល់ការពិត

ការធ្វើសេចក្តីសន្និដ្ឋានគឺជាការលំបាក ។ នៅពេលដែលគេចង់រំលំរបបផ្តាច់ការ អោយបានសំរេចដូចប្រាថ្នា ជាមួយនឹងការខូចខាតយ៉ាងតិចបំផុតនោះ គេមានកាតព្វកិច្ចបួន ដែលត្រូវធ្វើភ្លាមៗ ៖

- គេត្រូវពង្រឹងចលនាប្រជាពលរដ្ឋដែលស្ថិតនៅក្រោមការជិះជាន់អោយមានទឹកចិត្តម៉ឺងម៉ាត់ ការទុកចិត្តលើខ្លួនឯង និងទេពកោសល្យខាងការតស៊ូ ។
- គេត្រូវពង្រឹងឯករាជភាពនៃស្ថាប័ននានារបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្រោមការជិះជាន់ ។
- គេត្រូវបង្កើតអោយមានក្រុមប្រឆាំងផ្ទៃក្នុងដែលខ្លាំងក្លា ។
- គេត្រូវរៀបចំអោយមានផែនការយុទ្ធសាស្ត្រចំបងសំរាប់ការរំដោះ និងអនុវត្តផែនការនេះយ៉ាងប៉ិនប្រសប់ ។

ការតស៊ូរំដោះគឺជាពេលសំរាប់ការពឹងពាក់លើខ្លួនឯង ហើយនិងការពង្រឹងផ្ទៃក្នុងរបស់ក្រុមតស៊ូ ។ ដូចដែលលោក ឆាល ស្ទួតផាណេល (Charles Steward Parnell) បានស្រែកប្រកាស នៅពេលគេធ្វើយុទ្ធនាការកូដកម្មប្រឆាំងនឹងថ្លៃឈ្នួលផ្ទះ នៅប្រទេសអាយឡិន (Ireland) ក្នុងឆ្នាំ១៨៧៩ និង១៨៨០ ៖

"ការពឹងពាក់លើរដ្ឋាភិបាលជាការឥតប្រយោជន៍...អស់លោកអ្នកត្រូវរំពឹងតែទៅលើការតាំងចិត្តរបស់អស់លោកអ្នក...សូមជួយខ្លួនឯង ដោយឈរជាមួយគ្នា ...ពង្រឹងគ្នាឯងដែលទន់ខ្សោយ...ប្រមូលផ្តុំគ្នា រៀបចំខ្លួន... ហើយអស់លោកអ្នកត្រូវឈ្នះ...នៅពេលដែលអស់លោកអ្នកគិតរូវអោយគេដោះស្រាយបញ្ហានេះ ពេលនោះទើបបញ្ហានេះត្រូវគេដោះស្រាយបាន" ។

នៅចំពោះមុខកងកំលាំងដែលពឹងផ្អែកលើខ្លួនឯង ដែលមានយុទ្ធនាការល្អ សកម្មភាពដែលពោរពេញទៅដោយសេចក្តីក្លាហាននិងវិន័យ របបផ្តាច់ការនឹងត្រូវដួលរលំនៅទីបំផុត ។ ប៉ុន្តែលក្ខខណ្ឌទាំងបួនខាងលើ គឺជាការងារតិចបំផុតដែលគេត្រូវបំពេញ ។[៤]

ការពិគ្រោះខាងលើនេះបញ្ជាក់ថា ការរំដោះពីរបបផ្តាច់ការនៅទីបំផុត ស្ថិតនៅលើសមត្ថភាពប្រជាពលរដ្ឋក្នុងការរំដោះខ្លួនឯង ។ ករណីជោគជ័យនៃនយោបាយរើបម្រះ ឬក៏ការតស៊ូអហិង្សាដើម្បីផលប្រយោជន៍នយោបាយខាងលើនេះ មានន័យថា គេមានមធ្យោបាយសំរាប់អោយប្រជាពលរដ្ឋរំដោះខ្លួនឯង ប៉ុន្តែគេពុំទាន់បានយកមធ្យោបាយនោះទៅពង្រីកប្រើប្រាស់ ។ យើងនឹងពិនិត្យមើលមធ្យោបាយនេះ អោយបានពិស្តារ ក្នុងជំពូកខាងក្រោយ ។ ប៉ុន្តែជាដំបូង យើងគួរវិភាគអំពីវិធីចរចា ដែលគេថាអាចជាមធ្យោបាយមួយសំរាប់រុះរើរបបផ្តាច់ការ ។

---

[៤] ប៉ាទ្រីក សាស្សហ្វីល អូហេគហ្គាធី (Patrick Sarsfield O'Hegarty), *ប្រវត្តិសាស្ត្រនៃប្រទេសអាយឡិន (Ireland) ក្រោមសហព័ន្ធ, ១៨៨០-១៩២២*, ឡុនដុន (London) : មេធូន (Methuen) ទំព័រទី ៤៩០-៤៩១

# ជំពូកទី២

# គ្រោះថ្នាក់នៃការចរចា

នៅពេលគេប្រឈមមុខនឹងបញ្ហា ក្នុងការតទល់ជាមួយរបបផ្តាច់ការ (ដូចជា ក្នុងជំពូកទី ១) អ្នកខ្លះអាចវិលត្រឡប់ទៅរកការចុះញ៉ម ដោយស្ងៀមស្ងាត់ ។ អ្នកខ្លះទៀត ដោយមើលពុំឃើញថាគេអាចសំរេចបានលទ្ធិប្រជាធិបតេយ្យ អាចសន្និដ្ឋានថា គេត្រូវតែទទួលយកអ្វីដែលហាក់ដូចជា របបផ្តាច់ការអចិន្ត្រៃយ៍ជាមួយនឹងសេចក្តីសង្ឃឹមទៅលើ "ការផ្សះផ្សា" "ការសំរបសំរួល" និង "ការចរចា" ដែលគេប្រហែលជាអាចស្រោចស្រង់លក្ខណៈល្អខ្លះ ហើយបញ្ចប់អំពើឃោរឃៅ ។ ប្រសិនបើគេមើលសើៗ ដោយគ្មានមធ្យោបាយជាក់ស្តែងឯណាផ្សេងទៀត ការគិតបែបនេះ ហាក់ដូចជាសមរម្យដែរ ។

ការតស៊ូមែនទែនប្រឆាំងនឹងរបបផ្តាច់ការឃោរឃៅ មិនមែនមានលក្ខណៈងាយស្រួលទេ ។ ដូច្នេះហេតុអ្វីបានជាគេត្រូវដើរតាមផ្លូវនេះជាចាំបាច់ ? ហេតុអ្វីបានជាគេគ្រប់គ្នា មិនយោគយល់ រកមធ្យោបាយជួបគ្នា ចរចារកផ្លូវ ដើម្បីបញ្ចប់របបផ្តាច់ការសន្សឹមៗ ? ហេតុអ្វីបានជាពួកប្រជាធិបតេយ្យ មិនអាចអំពាវនាវអោយពួកផ្តាច់ការមានចិត្តមនុស្សធម៌ ហើយពន្យល់អោយអ្នកទាំងនោះបន្ថយការជិះជាន់របស់គេបន្តិចម្តងៗ ហើយទីបំផុត ឈានទៅរកការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ?

ជួនកាលគេពន្យល់ថា ការពិតមិនមែនមាននៅតែម្ខាងទេ ។ ពួកប្រជាធិបតេយ្យប្រហែលជាយល់ច្រឡំអំពីពួកផ្តាច់ការ ដែលប្រហែលជាធ្វើអំពើជិះជាន់ទាំងនោះ ដោយ

សុឆន្ទៈ ក្នុងកាលៈទេសៈដ៏លំបាកលំបិនមែន ។ ឬក៏អ្នកខ្លះយល់ថា ពួកផ្ដាច់ការនឹងសប្បាយចិត្តដកខ្លួនចេញពីស្ថានការណ៍ដ៏លំបាកដែលប្រទេសពើបប្រទះ ប្រសិនបើគេបានទទួលការលើកទឹកចិត្ត ឬក៏ផលប្រយោជន៍អ្វីមួយ ។ គេរិះកញ្ចែកថា គេអាចអោយពួកផ្ដាច់ការ នូវការដោះស្រាយ"ឈ្នះ-ឈ្នះ"មួយ ដែលគូបដិបក្សទាំងអស់បានចំណេញរៀងៗខ្លួន ។ គេអាចពន្យល់ថា គ្រោះថ្នាក់ និងការឈឺចាប់នៃការតស៊ូបន្ត ប្រហែលមិនមែនជាការចាំបាច់ ប្រសិនបើពួកប្រឆាំងយល់ព្រមដោះស្រាយទំនាស់ដោយសន្តិវិធីតាមការចរចា (ដែលអ្នកជំនាញការ ឬក៏រដ្ឋាភិបាលមួយទៀតអាចជួយបាន) ។ តើការនេះមិនប្រសើរជាងការតស៊ូដ៏លំបាកលំបិន តាមរយៈការតស៊ូអហិង្សា ឬក៏សង្គ្រាមយោធាទេឬ ?

# គុណសម្បត្តិ និងចំណុចខ្សោយនៃកិច្ចចរចា

ការចរចាជាឧបករណ៍ដ៏មានប្រយោជន៍មួយ ក្នុងការដោះស្រាយបញ្ហាទំនាស់ប្រភេទខ្លះ ហើយគេមិនត្រូវទាត់ចោល ក្នុងករណីណាដែលសមរម្យ ។ ក្នុងស្ថានការណ៍ដែលមិនពាក់ព័ន្ធទៅនឹងបញ្ហាជាមូលដ្ឋាន ដែលគេអាចផ្សះផ្សាបាន កិច្ចចរចាអាចជាមធ្យោបាយសំខាន់ ដើម្បីដោះស្រាយទំនាស់ ។ កូដកម្មរបស់កម្មករដែលទាមទារឡើងប្រាក់ខែ ជាឧទាហរណ៍ដ៏ល្អសំរាប់ចរចាដោះស្រាយទំនាស់ ។ ដំណោះស្រាយដែលអាចលេចចេញពីការចរចានេះ គឺការព្រមព្រៀងគ្នាយកកំរិតឡើងប្រាក់ខែមួយដែលនៅចន្លោះកំរិតដែលគូចរចាទាំងពីរទាមទារ ។ ប៉ុន្តែទំនាស់ការងារជាមួយនឹងសហជីព មានលក្ខណៈខុសពីទំនាស់ពាក់ព័ន្ធនឹងវត្តមានបន្តនៃរបបផ្ដាច់ការឃោរឃៅ ឬក៏ការបង្កើតអោយមានសេរីភាពនយោបាយ ។

នៅពេលដែលគេត្រូវដោះស្រាយបញ្ហាសំខាន់ ពាក់ព័ន្ធទៅនឹងគោលការណ៍សាសនា សេរីភាពមនុស្ស ឬក៏អនាគតទាំងមូលនៃការអភិវឌ្ឍសង្គម កិច្ចចរចាពុំអាចផ្ដល់នូវដំណោះស្រាយ ដែលជាទីពេញចិត្តសំរាប់គូភាគីទាំងសងខាងនោះឡើយ ។ ចំពោះបញ្ហាជាគ្រឹះខ្លះ គេពុំគួរទទួលយកការសំរបសំរួលទេ ។ មានតែការផ្លាស់ប្ដូរ

អំណាចទៅអោយពួកប្រជាធិបតេយ្យទេ ដែលអាចការពារបញ្ហាដែលជាគ្រោះ ។ ការផ្លាស់ប្តូរនេះ នឹងកើតមានឡើងតាមរយៈការតស៊ូ ពុំមែនកិច្ចចរចាទេ ។ ប៉ុន្តែការនេះមិនមែនមានន័យថា គេមិនគួរប្រើកិច្ចចរចានោះឡើយ ។ ចំណុចសំខាន់នៅទីនេះ គឺថាកិច្ចចរចាមិនមែនជាមធ្យោបាយជាក់ស្តែង ដើម្បីរំលំរបបផ្តាច់ការដែលខ្លាំងក្លា ក្នុងករណីដែលក្រុមប្រជាធិបតេយ្យពុំមានកំលាំងប្រឆាំងដ៏ស្វិតស្វាញនោះទេ ។

ជួនកាល កិច្ចចរចាប្រហែលមិនមែនជាជំរើសមួយទៀតផង ។ ពួកផ្តាច់ការដែលក្តាប់អំណាចយ៉ាងខ្ជាប់ ប្រហែលជាមិនព្រមចរចាជាមួយនឹងភាគីអ្នកប្រជាធិបតេយ្យឡើយ ។ ឬមួយក៏នៅពេលដែលកិច្ចចរចាបានចាប់ផ្តើម អ្នកចរចាខាងប្រជាធិបតេយ្យប្រហែលជាត្រូវបាត់ខ្លួន ហើយបាត់ដំណឹងសូន្យឈឹងតែម្តង ។

# ការចុះញ៉មតាមការចរចា

បុគ្គលនិងក្រុមទាំងឡាយដែលប្រឆាំងនឹងរបបផ្តាច់ការ ហើយគាំទ្រកិច្ចចរចាជារឿយៗ តែងមានហេតុផលល្អត្រឹមត្រូវ ។ ជាពិសេស នៅពេលដែលការតស៊ូតាមសង្គ្រាមបានកើតមានឡើងរាប់ឆ្នាំ ប្រឆាំងនឹងរបបផ្តាច់ការឃោរឃៅ ហើយពុំបានជ័យជំនះផ្តាច់ព្រ័ត្រ គេអាចយល់បានថា អ្នកទាំងនោះ ទោះជាមានខ្សែបន្ទាត់នយោបាយលំអៀងទៅខាងណាក៏ដោយ ក៏ចង់បានសន្តិភាពដែរ ។ ក្នុងករណីនេះ ការចរចានឹងក្លាយទៅជាបញ្ហានៅក្នុងចំណោមអ្នកប្រជាធិបតេយ្យ ជាពិសេស នៅពេលដែលពួកផ្តាច់ការមានកំលាំងយោធាខ្លាំងលើសលប់ ហើយក្រុមតស៊ូពុំអាចទ្រាំទ្រការវិនាសខូចខាតតទៅទៀតបាន ។ នៅពេលនោះ គេនឹងមានចំណង់យ៉ាងខ្លាំងក្លារិះរកមធ្យោបាយផ្សេងទៀត ដែលអាចជួយស្រោចស្រង់គោលបំណងរបស់ក្រុមប្រជាធិបតេយ្យ ស្របគ្នានឹងការបញ្ចប់នូវអំពើហិង្សាទៅវិញទៅមក ។

ការផ្តល់សន្តិភាពពីរបបផ្តាច់ការ តាមរយៈកិច្ចចរចាជាមួយនឹងក្រុមប្រជាធិបតេយ្យ កំរនឹងបានដោយសុទ្ធចិត្តណាស់ ។ ក្នុងករណីនេះ អំពើហិង្សាអាចចប់ភ្លាម ប្រសិនបើមេផ្តាច់ការបញ្ចប់សង្គ្រាមប្រឆាំងនឹងប្រជាពលរដ្ឋដោយឯកឯង ។

ពួកនេះអាចផ្តើមគំនិត ដោយពុំចាំបាច់មានការចរចា រៀបចំអោយមានការគោរពភាពថ្លៃថ្នូរ និងសិទ្ធិមនុស្សឡើងវិញ ដោះលែងអ្នកទោសនយោបាយ បញ្ចប់ការធ្វើទារុណកម្ម ផ្អាកសកម្មភាពយោធា ដកខ្លួនចេញពីរង្វង់រដ្ឋាភិបាល ហើយថ្លែងសុំទោសទៅប្រជាពលរដ្ឋ ។

ក្នុងករណីដែលរបបផ្តាច់ការមានកំលាំងខ្លាំងក្លា ហើយការតស៊ូនៅតែរំខានគេតទៅទៀត ពួកផ្តាច់ការប្រហែលជាចង់ចរចាជាមួយនឹងក្រុមប្រឆាំង ដើម្បីអោយក្រុមនេះចុះញ៉ម ក្នុងរូបភាពថាជាការសាង“សន្តិភាព” ។ ការអំពាវនាវអោយមានការចរចា អាចជាការគួរអោយចាប់អារម្មណ៍ ប៉ុន្តែគ្រោះថ្នាក់ធ្ងន់នឹងអាចលេចចេញឡើង នៅក្នុងបន្ទប់ចរចា ។

ផ្ទុយទៅវិញ នៅពេលក្រុមប្រឆាំងមានកំលាំងខ្លាំងក្លា ហើយរបបផ្តាច់ការស្ថិតនៅក្រោមការគំរាមកំហែងមែនទែន ពួកផ្តាច់ការប្រហែលជាសុំធ្វើការចរចា ដើម្បីស្រោចស្រង់អំណាចនិងទ្រព្យសម្បត្តិអោយបានច្រើន ទៅតាមការដែលអាចធ្វើទៅបាន ។ ក្នុងករណីនេះ ពួកប្រជាធិបតេយ្យពុំគួរជួយមេផ្តាច់ការអោយសំរេចតាមបំណងរបស់គេនោះទេ ។

ក្រុមអ្នកប្រជាធិបតេយ្យ គួរតែប្រុងប្រយ័ត្នអន្ទាក់ ដែលមេផ្តាច់ការរៀបចំដាក់ចូលទៅក្នុងកម្មវិធីចរចា ។ ការសុំអោយមានកិច្ចចរចា នៅពេលដែលពាក់ព័ន្ធនឹងបញ្ហាគ្រឹះខាងសេរីភាពនយោបាយ ប្រហែលគ្រាន់តែជាការខំខ្នះខ្នែងរបស់ពួកផ្តាច់ការ ដើម្បីលួងលោមអោយពួកប្រជាធិបតេយ្យ ចុះចាញ់ដោយសន្តិវិធី នៅពេលដែលអំពើហិង្សារបស់របបផ្តាច់ការនៅតែមានជាបន្តទៅទៀត ។ នៅក្នុងទំនាស់បែបនេះ តួនាទីដ៏សមរម្យតែមួយនៃកិច្ចចរចា ប្រហែលជាអាចកើតមានឡើងក្នុងវគ្គបញ្ចប់នៃការតស៊ូយ៉ាងប្តូរផ្តាច់ នៅពេលដែលអំណាចរបស់ពួកផ្តាច់ការបានត្រូវខូចខ្ទេចខ្ទីហើយពួកនេះចរចារិះរកផ្លូវទៅកាន់ព្រលានយន្តហោះ ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន ។

# អំណាច និងយុត្តិធម៌នៅក្នុងកិច្ចចរចា

ប្រសិនបើការវិនិច្ឆ័យបែបខាងលើនេះ នៅតែមានលក្ខណៈមិនសូវតឹងតែង ប្រឆាំងនឹងការចរចាទេនោះ ប្រហែលជាគេគួរតែបន្ថយមនោសញ្ចេតនារើរវាយ ទៅលើផលប្រយោជន៍នៃកិច្ចចរចានេះខ្លះហើយ ។ គេត្រូវតែគិតគូរអោយបានហ្មត់ចត់ថា តើគេត្រូវអនុវត្តកិច្ចចរចានេះបែបណា ?

"កិច្ចចរចា"ពុំមែនមានន័យថា គូភាគីអង្គុយចុះ ក្នុងលក្ខណៈស្មើភាពគ្នា ហើយពិគ្រោះគ្នា ដើម្បីដោះស្រាយបញ្ហាដែលនាំអោយមានទំនាស់រវាងគេទាំងពីរនាក់នោះទេ ។ គេត្រូវចងចាំអំពីការពិតពីរយ៉ាង ។ ទីមួយ អ្វីដែលនឹងសំរេចនៅទីបញ្ចប់ ដាក់ចូលទៅក្នុងកិច្ចព្រមព្រៀង ពុំមែនអាស្រ័យទៅលើភាពសមរម្យត្រឹមត្រូវនៃយោបល់ និងគោលបំណងណានោះទេ ។ ទីពីរ អ្វីដែលនឹងមាននៅក្នុងកិច្ចព្រមព្រៀងនេះ គឺអាស្រ័យទៅលើកំលាំងនៃភាគីនីមួយៗ ។

គេត្រូវគិតដល់សំណួរពិបាកៗមួយចំនួន ។ តើភាគីនីមួយៗអាចធ្វើអ្វីខ្លះ នៅថ្ងៃក្រោយ ដើម្បីអោយបានសំរេចដូចគោលបំណង ប្រសិនបើគេពុំបានជោគជ័យ ពុំព្រមព្រៀងគ្នានៅលើតុចរចា ? តើភាគីនីមួយៗអាចធ្វើអ្វីខ្លះ ក្រោយពីមានកិច្ចព្រមព្រៀងរួចហើយ ប្រសិនបើគេមិនគោរពតាមពាក្យសន្យា ហើយប្រើកំលាំងបាយ សំរេចតាមគោលបំណងរបស់គេ ថ្វីបើគេមានកិច្ចព្រមព្រៀងរួចទៅហើយក៏ដោយ ?

ការយល់ព្រមគ្នាដែលគេបានសំរេចតាមការចរចា មិនមែនស្ថិតនៅលើការវែកញែកថាអ្វីខុសអ្វីត្រូវនោះទេ ។ ថ្វីបើកត្តាទាំងនោះ នឹងត្រូវគេយកទៅពិគ្រោះជាញឹកញាប់ លទ្ធផលមែនទែននៃការចរចា លេចចេញពីការយល់ឃើញអំពីកំលាំងរៀងខ្លួននៃគូភាគីទាំងពីរ ។ តើក្រុមអ្នកប្រជាធិបតេយ្យអាចធ្វើអ្វីខ្លះ ដើម្បីកុំអោយគូចរចាបដិសេធការទាមទារយ៉ាងតិចបំផុតរបស់គេ ? តើពួកផ្តាច់ការអាចធ្វើអ្វីខ្លះ ដើម្បីអោយបាននៅកាន់អំណាចដដែល ហើយបន្សាបកំលាំងពួកប្រជាធិបតេយ្យ ? គេអាចនិយាយម្យ៉ាងទៀតថា ប្រសិនបើគេបានកិច្ចព្រមព្រៀងមួយ កិច្ចព្រមព្រៀងនេះ ច្រើនតែជាលទ្ធផលនៃការវាយតំលៃរបស់ភាគីមួយអំពីសមត្ថភាពកំលាំងនៃភាគីមួយទៀត

ការប្រៀបធៀបកំលាំងរបស់គូភាគីទាំងពីរ រួចហើយទើបគេគិតអំពីការដែលគេអាច បញ្ចប់ការតស៊ូដោយចំហនេះ ។

គេក៏ត្រូវតែប្រយ័ត្នអំពីអ្វីដែលភាគីទាំងពីរសុខចិត្តលះបង់ចោល ដើម្បីអោយបានសំរេចកិច្ចព្រមព្រៀងមួយ ។ ក្នុងកិច្ចចរចាដែលមានជោគជ័យ គេតែងឃើញមានការសំរបសំរួល បន្ថយសារៈសំខាន់នៃយោបល់ដែលគេមានខុសគ្នា ។ ភាគីនីមួយៗបានទទួលមួយចំណែកនៃអ្វីដែលគេចង់បាន ហើយលះបង់គោលបំណងរបស់គេមួយចំណែក ។

ក្នុងករណីដែលគេប្រទះនឹងរបបផ្តាច់ការដ៏ខ្លាំងក្លា តើកំលាំងគាំទ្រប្រជាធិបតេយ្យត្រូវលះបង់អ្វីខ្លះ អោយទៅពួកផ្តាច់ការ ? តើគោលបំណងពួកផ្តាច់ការអ្វីខ្លះ ដែលកំលាំងប្រជាធិបតេយ្យនឹងទទួលយក ? តើពួកប្រជាធិបតេយ្យនឹងអោយទៅពួកផ្តាច់ការ (ជាគណបក្សនយោបាយ ឬជាក្រុមមេទ័ព) នូវតួនាទីជាអចិន្ត្រៃយ៍សមស្របតាមរដ្ឋធម្មនុញ្ញ នៅក្នុងរដ្ឋាភិបាលថ្មីដែរឬទេ ? តើការធ្វើបែបនេះ មានលក្ខណៈប្រជាធិបតេយ្យត្រង់ណាទៅ ?

ប្រសិនបើគេសន្មតថា កិច្ចចរចាមានដំណើរល្អប្រសើរ គេត្រូវចោទសួរជាចាំបាច់ថា តើគេនឹងបានសន្តិភាពបែបណាដែរ ? តើជីវភាពរស់នៅនឹងបានល្អប្រសើរ ឬក៏យ៉ាប់យ៉ឺនជាងមុន ប្រសិនបើពួកប្រជាធិបតេយ្យផ្តើម ឬក៏បន្តការតស៊ូ ?

## ការយល់ព្រមរបស់ពួកផ្តាច់ការ

ពួកផ្តាច់ការប្រហែលជាមានមូលហេតុ និងគោលបំណងមួយចំនួន ដែលជំរុញអោយមានការជិះជាន់គេ ៖ អំណាច បុណ្យស័ក្តិ ទ្រព្យសម្បត្តិ ការកែទំរង់សង្គមជាដើម ។ គេត្រូវតែចងចាំថា គេនឹងបាត់បង់នូវមូលហេតុ និងគោលបំណងទាំងនោះ ប្រសិនបើគេបាត់បង់ការត្រួតត្រារបស់គេ ។ ដូច្នេះ ក្នុងការចរចា ពួកផ្តាច់ការ នឹងខិតខំថែរក្សាគោលបំណងរបស់គេទាំងនេះ ។

ទោះជាពួកផ្តាច់ការសន្យាបែបណា នៅក្នុងកិច្ចព្រមព្រៀង គេមិនគួរភ្លេចថា

ពួកផ្តាច់ការអាចសន្យាអ្វីទាំងអស់ ដើម្បីអោយគូបដិបក្សយល់ព្រមបន្ទន់ឥរិយាបថ រួចហើយទើបគេរំលោភទាំងកំរោល ទៅលើកិច្ចព្រមព្រៀងនោះតែម្តង ។

ប្រសិនបើពួកប្រជាធិបតេយ្យយល់ព្រមផ្អាកការតស៊ូប្រឆាំង ដើម្បីអោយបានធូរស្បើយពីការជិះជាន់ គេប្រហែលជាខកចិត្តយ៉ាងខ្លាំងជាពុំខាន ។ ការផ្អាកការតស៊ូកម្របន្ថយការជិះជាន់ណាស់ ។

នៅក្រោយពេលដែលកំលាំងប្រឆាំងផ្ទៃក្នុង និងអន្តរជាតិដកខ្លួនថយហើយនោះ ពួកផ្តាច់ការប្រហែលជាបង្កើនការជិះជាន់ និងអំពើហិង្សាអោយខ្លាំងជាងមុន ។ ការដួលរលំនៃការតស៊ូរបស់ប្រជាពលរដ្ឋ ជារឿយៗ គឺជាការដកយកចេញនូវកំលាំងទប់ទល់ ដែលធ្លាប់តែគាបមិនអោយពួកផ្តាច់ការប្រព្រឹត្តអំពើឃោរឃៅខ្លាំងពេក ។ ពេលនោះ ពួកផ្តាច់ការ នឹងចាត់វិធានការកំចាត់អ្នកណាក៏បានតាមចំណង់ចិត្ត ។ លោក គ្រិស្ណាឡាល់ ស្រ៊ីថារានី (Krishnalal Shridharani)[៥] បានសរសេរថា ៖ “ពួកផ្តាច់ការមានអំណាចធ្វើទុក្ខ នៅត្រង់តែកន្លែងណា ដែលយើងគ្មានកំលាំងទប់ទល់” ។

ការតស៊ូដោយមិនចរចា គឺជាការចាំបាច់សំរាប់ការផ្លាស់ប្តូរ នៅក្នុងទំនាស់ដែលពាក់ព័ន្ធបញ្ហាគ្រឹះ ។ ស្ទើរតែគ្រប់ករណី ការតស៊ូត្រូវតែបន្ត ដើម្បីដកពួកផ្តាច់ការចេញពីអំណាចអោយទាល់តែបាន ។ ជ័យជំនះ ជារឿយៗ មិនអាស្រ័យទៅលើការចរចាទេ ប៉ុន្តែស្ថិតនៅលើការប៉ិនប្រសប់ ក្នុងការប្រើមធ្យោបាយដែលមានប្រសិទ្ធភាព ។ គំនិតតស៊ូរបស់យើង ដែលយើងនឹងពិនិត្យពិគ្រោះយ៉ាងពិស្តារបន្តិចទៀតនេះ គឺនយោបាយរើបម្រះ ឬក៏ការតស៊ូអហិង្សា ដែលជាមធ្យោបាយដ៏ខ្លាំងក្លាបំផុត សំរាប់អ្នកទាំងឡាយណាដែលតស៊ូដើម្បីសេរីភាព ។

---

[៥] គ្រិស្ណាឡាល់ ស្រ៊ីថារានី (Krishnalal Shridharani) *សង្គ្រាមដោយគ្មានហិង្សា : ការសិក្សាអំពីមធ្យោបាយលោក គន្ធី (Gandhi) និងជោគជ័យ*, ញូវយ៉ក (New York)៖ហារខត ប្រេស (Harcourt Brace) ១៩៣៩ និងបោះពុម្ពឡើងវិញនៅក្រុងញូវយ៉ក និងឡុនដុនៈ ហ្គាលិន ប៉ុឋ្លីសស៊ីង (Garland Publishing) ឆ្នាំ ១៩៧២ ទំព័រទី ២៦០ ។

# តើសន្តិភាពបែបណា

ប្រសិនបើពួកផ្តាច់ការ និងពួកប្រជាធិបតេយ្យនិយាយអំពីសន្តិភាព គេត្រូវគិតអោយបានល្អិតល្អន់ ដោយសារការនេះទាក់ទងនឹងគ្រោះថ្នាក់ ។ អ្នកដែលប្រើពាក្យ "សន្តិភាព" មិនមែនមានន័យថា អ្នកនោះចង់បានសន្តិភាពដែលប្រកបដោយសេរីភាព និងយុត្តិធម៌នោះឡើយ ។ ការចុះញ៉មទៅតាមការសង្កត់សង្កិនដ៏ឃោរឃៅ និងនៅស្ងាត់ស្ងៀម នៅចំពោះមុខពួកផ្តាច់ការកាចសាហាវដែលបានធ្វើទារុណកម្មដល់ពលរដ្ឋរាប់ម៉ឺននាក់ មិនមែនជាសន្តិភាពទេ ។ អ៊ីត្លែរតែងអំពាវនាវអោយមានសន្តិភាព ដែលមានន័យថា គេត្រូវចុះញ៉មទៅតាមបំណងរបស់ខ្លួន ។ សន្តិភាពរបស់ពួកផ្តាច់ការ ជារឿយៗ មិនខុសពីសន្តិភាពនៅក្នុងគុក ឬនៅប៉ាឆាខ្មោចនោះឡើយ ។

នៅមានគ្រោះថ្នាក់ផ្សេងៗទៀត ។ ពួកអ្នកចរចាដែលមានគោលបំណងល្អត្រឹមត្រូវជួនកាល យល់ច្រឡំ អំពីគោលបំណងនៃកិច្ចចរចា និងដំណើរការកិច្ចចរចា ។ លើសពីនេះទៅទៀត ពួកអ្នកចរចាប្រជាធិបតេយ្យ ឬក៏ពួកឯកទេសបរទេសខាងកិច្ចចរចាដែលសុខចិត្តជួយក្នុងការចរចា ក្នុងពេលមួយរំពេចនោះ អាចជួយផ្តល់ដល់ពួកផ្តាច់ការនូវភាពត្រឹមត្រូវតាមច្បាប់ជាតិនិងអន្តរជាតិ ដែលពួកផ្តាច់ការបានបាត់បង់ ដោយសារការរំលោភកាន់កាប់រដ្ឋ ការរំលោភលើសិទ្ធិមនុស្ស និងអំពើឃោរឃៅនានា ។ ប្រសិនបើគេគ្មានភាពត្រឹមត្រូវតាមច្បាប់ដែលគេត្រូវការយ៉ាងខ្លាំងទេនោះ ពួកផ្តាច់ការមិនអាចបន្តការគ្រប់គ្រងរដ្ឋ ដោយគ្មានទីបញ្ចប់នោះឡើយ ។ ដូច្នេះ ពួកដែលគាំទ្រសន្តិភាព មិនគួរផ្តល់ភាពត្រឹមត្រូវតាមច្បាប់ ទៅពួកនោះទេ ។

# មូលហេតុសំរាប់សេចក្តីសង្ឃឹម

ដូចដែលបានវិភាគពីមុនរួចហើយ ពួកអ្នកដឹកនាំក្រុមប្រឆាំង ប្រហែលជាបង្ខំចិត្ត ងាកទៅរកកិច្ចចរចា ដោយសារការអស់សង្ឃឹមទៅលើការតស៊ូប្រជាធិបតេយ្យ ។ ប៉ុន្តែ គេអាចកែអារម្មណ៍អស់កំលាំងអស់ទឹកចិត្តនោះបាន ។ របបផ្តាច់ការមិនអាច

នៅបន្តគ្មានទីបញ្ចប់បានឡើយ ។ ពលរដ្ឋដែលរស់នៅក្រោមរបបផ្តាច់ការ មិនចាំបាច់នៅតែទន់ខ្សោយនោះទេ ហើយពួកផ្តាច់ការក៏មិនត្រូវគេអនុញ្ញាតអោយនៅក្តាប់អំណាចរហូតបានដែរ ។ លោកអារីស្តូត (Aristotle) បានកត់សំគាល់ជាយូរណាស់មកហើយថា ៖ "... របបផ្តាច់ការមានអាយុខ្លីជាងស្ថាប័ននានាឯទៀតទាំងអស់... ទីបំផុតរបបផ្តាច់ការរស់នៅមិនបានយូរទេ" ។[៦] របបផ្តាច់ការជំនាន់ថ្មីក៏មានលក្ខណៈទន់ខ្សោយនេះដែរ ។ គេអាចធ្វើអោយចំណុចខ្សោយទាំងនេះកាន់តែខ្សោយឡើង ហើយពេលនោះ អំណាចពួកផ្តាច់ការនឹងត្រូវបែកខ្ទេចខ្ទី ។ (នៅក្នុងជំពូកទី ៤ យើងនឹងពិនិត្យមើលចំណុចខ្សោយទាំងនេះអោយបានពិស្តារ ។)

ប្រវត្តិសាស្ត្រថ្មីៗនេះបានបង្ហាញអោយគេឃើញពីភាពទន់ខ្សោយរបស់របបផ្តាច់ការ ហើយបញ្ជាក់ថា ពួកនេះអាចដួលរលំក្នុងរយៈពេលដ៏ខ្លី ។ នៅពេលដែលគេត្រូវការពេល ១០ឆ្នាំ ពីឆ្នាំ១៩៨០ ទៅ១៩៩០ ដើម្បីទំលាក់របបផ្តាច់ការកុម្មុនីស្តនៅប្រទេសប៉ូឡូញ(Poland), របបផ្តាច់ការអាល្លឺម៉ង់ខាងកើត(East Germany) និងឆេកូស្លូវ៉ាគី(Czechoslovakia) បានដួលរលំ ក្នុងរយៈពេលតែប៉ុន្មានអាទិត្យប៉ុណ្ណោះ ។ ក្នុងប្រទេសអែលសាវ៉ាដ័រ(El Savador) និងហ្គូតេម៉ាឡា (Guatemala) ក្នុងឆ្នាំ១៩៤៤ ការតស៊ូប្រឆាំងនឹងពួកផ្តាច់ការយោធាត្រូវការតែ ២អាទិត្យ ។ របបយោធាដ៏ខ្លាំងក្លានៃព្រះចៅអធិរាជសាហ៍នៃប្រទេសអ៊ីរ៉ង់(Iran) បានត្រូវចុះខ្សោយតែប៉ុន្មានខែប៉ុណ្ណោះ ។ របបផ្តាច់ការម៉ារកូស(Marcos) នៃប្រទេសហ្វីលីពីន(The Philippines) បានដួលរលំ នៅចំពោះមុខកំលាំងប្រជាពលរដ្ឋ ក្នុងរយៈពេលតែប៉ុន្មានអាទិត្យក្នុងឆ្នាំ១៩៨៦ - រដ្ឋាភិបាលអាមេរិកបានដោះដៃលះបង់ចោលប្រធានាធិបតីម៉ារកូសភ្លាម នៅពេលដែលគេឃើញកំលាំងក្រុមប្រឆាំងលេចចេញឡើងខ្លាំង ។ ការល្បងធ្វើរដ្ឋប្រហារពីសំណាក់ពួកតឹងតែង ក្នុងសហភាពសូវៀតក្នុងខែសីហាឆ្នាំ១៩៨១ បានត្រូវនយោបាយ

---

[៦] អារីស្តូត (Aristotle), *នយោបាយ*, ប្រែសំរួលដោយ ត.អ.ស៊ីនក្លែរ (T.A. Sinclair), (ហាមន់ស្វត [Harmond Sworth] មីដលសេច [Middlesex], ប្រទេសអង់គ្លេស, និង បាល់ទីម័រ [Baltimore], ម៉ារីឡែន [Maryland] : ផេនគួវេន ប៊ុក [Penguin Books] ឆ្នាំ ១៩៧៥ [១៩៦២]), សៀវភៅទី ៥ ជំពូកទី ១២ ទំព័រទី ២៣១ និងទី ២៣២ ។

រើបម្រះខ្ទប់ជាប់ក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ។ តាំងពីពេលនោះមក រដ្ឋនានាជាច្រើន ដែលសហភាពសូវៀតបានគ្រប់គ្រងជាយូរណាស់មកហើយនោះ ក៏បានងើបឡើង ហើយក៏បានឯករាជ្យក្នុងរវាងប៉ុន្មានថ្ងៃ អាទិត្យ និងខែតែប៉ុណ្ណោះ ។

គំនិតចាស់មួយដែលថា មធ្យោបាយហិង្សាតែងតែមានប្រសិទ្ធភាពឆាប់រហ័ស ហើយមធ្យោបាយអហិង្សាតែងតែត្រូវការពេលយូរអង្វែង គឺជាការយល់ច្រឡំ ។ ថ្វីបើគេប្រហែលជាត្រូវការពេលវេលាច្រើន សំរាប់ការប្រែប្រួលក្នុងស្ថានការណ៍និងសង្គម ការប្រយុទ្ធមែនទែនប្រឆាំងរបបផ្តាច់ការ ជួនកាល អាចកើតឡើងក្នុងរយៈពេលដ៏ខ្លីតាមរយៈការតស៊ូអហិង្សា ។

កិច្ចចរចាមិនមែនជាច្រកដើរតែមួយ ក្រៅពីការបង្កសង្គ្រាមយ៉ាងហិនហោចនិងការអស់សង្ឃឹមចុះញ៉មនោះឡើយ ។ ឧទាហរណ៍ខាងលើ និងក្នុងជំពូកទី ១ បានបង្ហាញអោយឃើញថា គេនៅមានមធ្យោបាយមួយទៀតសំរាប់អ្នកទាំងឡាយណាដែលចង់បានសន្តិភាព *និង* សេរីភាព ៖ ការរើបម្រះនយោបាយ ។

## ជំពូកទី៣

# ពេលណាអំណាចនឹងមកដល់

ការសំរេចបានសង្គមមួយដែលមានសេរីភាពនិងសន្តិភាព មិនមែនជាការងាយស្រួលទេ ។ ការនេះតំរូវអោយមានទេពកោសល្យដ៏ជ្រៅជ្រះ ខាងយុទ្ធវិធី ការរៀបចំជាអង្គការ និងផែនការ ។ សំខាន់បំផុត ការនេះតំរូវអោយមានអំណាច ។ ពួកប្រជាធិបតេយ្យពុំអាចមានសង្ឃឹមថា នឹងរំលំរបបផ្តាច់ការ ហើយរៀបចំអោយមានសេរីភាពនយោបាយ ប្រសិនបើគេពុំអាចប្រើប្រាស់អំណាចរបស់ខ្លួនឯងផ្ទាល់ ដោយប្រសិទ្ធភាព ។

ប៉ុន្តែ តើគេអាចធ្វើការនេះបាន តាមបែបបទណាទៅ ? តើអំណាចប្រភេទណាដែលក្រុមប្រជាធិបតេយ្យប្រឆាំងអាចប្រមូលផ្តុំ ដែលមានកំរិតគ្រប់គ្រាន់សំរាប់រំលំរបបផ្តាច់ការ និងបណ្តាញយោធា-ប៉ូលិសដ៏ទូលំទូលាយរបស់គេ ? ចំលើយទៅនឹងសំណួរនេះ ស្ថិតនៅលើការយល់អំពីអំណាចនយោបាយ ដែលគេច្រើនតែភ្លេច ។ ការចេះដឹងអំពីអំណាចនយោបាយនេះ មិនមែនជាការលំបាកទាល់តែសោះ ។ ការពិតជាមូលដ្ឋានខ្លះ មានលក្ខណៈសាមញ្ញ ហើយងាយយល់ជាទីបំផុត ។

## រឿងព្រេងនិទានអំពីម្ចាស់ស្វា

រឿងព្រេងនិទានចិនមួយដែលរៀបរៀងដោយលោក លីវ ជី(Liu-Ji) ក្នុង

សតវត្សទី ១៤ បានបញ្ជាក់យ៉ាងគ្រប់គ្រាន់ អំពីការមិនយល់នូវអ្វីជាអំណាចនយោបាយ ។[៧]

នៅក្នុងរបបសក្តិភូមិមួយនៃរជ្ជកាលជូ(Chu) មានបុរសចំណាស់ម្នាក់ មានជីវិតរស់នៅបានដោយសារការចិញ្ចឹមស្វាមួយចំនួនដែលបំរើគាត់ ។ អ្នកស្រុកហៅគាត់ថា "ជូកុង(ju gong)" (ម្ចាស់ស្វា) ។

ជារៀងរាល់ព្រឹក ជូកុងកោះប្រជុំស្វាទាំងអស់ ហើយបញ្ជាអោយស្វាដែលចាស់ជាងគេ ដឹកនាំស្វាទាំងឡាយទៅឡើងភ្នំ ដើម្បីប្រមូលផ្លែឈើនានា ។ បទបញ្ជានោះគឺ ស្វានីមួយៗត្រូវតែប្រគល់អោយទៅតាចាស់នេះចំនួន ១០ភាគរយនៃអ្វីដែលពួកវាប្រមូលបាន ។ ស្វាណាដែលមិនអនុវត្តតាមបញ្ជានេះទេ នឹងត្រូវវាយរំពាត់យ៉ាងឃោរឃៅ ។ ស្វាទាំងនោះបានទទួលរងគ្រោះយ៉ាងឈឺចាប់ ប៉ុន្តែពុំហ៊ានរអ៊ូរទាំ ។

ថ្ងៃមួយ កូនស្វាមួយបានសួរទៅស្វាឯទៀតថា "តើតាចាស់នេះជាអ្នកដាំដើមឈើទាំងនោះមែនទេ ?" ស្វាឯទៀតតបថា "មិនមែនទេ ! ដើមឈើទាំងនោះដុះតាមធម្មជាតិ" ។ កូនស្វានោះបានសួរតទៅទៀតថា "ហេតុអ្វីបានជាយើងមិនអាចបេះផ្លែឈើទាំងនោះ ដោយគ្មានការអនុញ្ញាតពីតានេះ ?" ។ ស្វាឯទៀតតបថា "បាន, យើងអាចធ្វើបាន" ។ កូនស្វាក៏សួរជាបន្តទៀត "បើដូច្នេះ ហេតុអ្វីបានជាយើងគួរពឹងផ្អែកទៅលើតានេះ ? ហេតុអ្វីបានជាយើងទាំងអស់គ្នាត្រូវតែបំរើគាត់ ?" ។

នៅមុនពេលកូនស្វានេះនិយាយចប់ ស្វាឯទៀតទាំងអស់ក៏ភ្ញាក់ខ្លួនព្រើត ។

ដល់យប់ងងឹត នៅពេលដឹងថាតាចាស់ដេកលង់លក់ទៅហើយនោះ ពួកស្វាក៏នាំគ្នារុះរើ ហើយរំលំទ្រុងដែលតាចាស់ដាក់ឃុំស្វាទាំងនោះ ។ វានាំគ្នាប្រមូលផ្លែឈើទាំងអស់ ដែលជូកុងរក្សាទុកក្នុងឃ្លាំង ហើយនាំគ្នារត់ចូលព្រៃរហូត ។ នៅទីបំផុត តាចាស់ក៏បានស្លាប់បាត់បង់ជីវិត ដោយសារការអត់ឃ្លាន ។

---

[៧] រឿងនេះដែលមានចំណងជើងដើមថា "ការត្រួតត្រាដោយយុទ្ធវិធី" ស្រង់ចេញពីយូលីហ្សី (Yu-li-zi) និពន្ធដោយលីវជី (Liu-Ji) ឆ្នាំ១៣១១-១៣៧៥ បកប្រែដោយស៊ីដនីតៃ ដែលរក្សា សិទ្ធិគ្រប់យ៉ាង ។ យូលីហ្សីជាឈ្មោះក្លែងក្លាយរបស់លីវជី។អត្ថបទប្រែសំរួលនេះបោះពុម្ពផ្សាយជាលើកដំបូង ក្នុងព្រឹត្តិប័ត្រឈ្មោះ *"ការដាក់ទណ្ឌកម្មអហិង្សា : ដំណឹងពីវិទ្យាស្ថាន អាល់ប៊ីត អាំងស្តាញ* (ខាំប្រ៊ីដ ម៉ាសាឈូសិត) ខ្សែ ៤ លេខ ៣ (រដូវត្រជាក់ ឆ្នាំ១៩៩២-១៩៩៣) ទំព័រទី ៣ ។

លោក យូ លីស៊ី(Yu-li-zi) បានពោលថា "អ្នកខ្លះនៅក្នុងលោកនេះ ត្រួតត្រាមនុស្ស ដោយប្រើយុទ្ធវិធីបំភាន់គេ មិនយោងទៅលើគោលការណ៍ត្រឹមត្រូវទេ ។ តើអ្នកទាំងនោះមិនដូចតាម្ចាស់ស្វានេះទេឬ ? អ្នកទាំងនោះមិនដឹងអំពីការយល់ច្រឡំរបស់ខ្លួនឯង ។ ដូច្នេះ នៅពេលណាដែលក្រុមអ្នកដែលត្រូវគេបោកភ្ញាក់ខ្លួនឡើង យុទ្ធវិធីបំភាន់របស់គេក៏អស់មានប្រសិទ្ធភាពភ្លាម ។"

## ប្រភពចាំបាច់នានានៃអំណាចនយោបាយ

គោលការណ៍នេះគឺងាយស្រួលយល់ ។ ពួកផ្តាច់ការត្រូវការជំនួយពីអ្នកដែលគេត្រួតត្រា ។ ប្រសិនបើគ្មានជំនួយនេះទេ គេក៏ពុំអាចគ្រប់គ្រង និងបន្តប្រភពនៃអំណាចនយោបាយរបស់គេឡើយ ។

ប្រភពនានានៃអំណាចនយោបាយមានជាអាទិ៍ ៖

- *អំណាចអាជ្ញាធរ* គឺជាជំនឿក្នុងចំណោមប្រជាពលរដ្ឋថា របបនេះមានភាពស្របច្បាប់ ហើយថាគេមានកាតព្វកិច្ច គោរពតាមបញ្ជារបស់អ្នកគ្រប់គ្រង ។
- *ធនធានមនុស្ស* គឺជាចំនួន និងសារៈសំខាន់នៃមនុស្ស និងក្រុមទាំងឡាយ ដែលគោរព ធ្វើសហការ ឬក៏ផ្តល់ជំនួយដល់អ្នកត្រួតត្រា ។
- *ទេពកោសល្យ និងចំណេះដឹង* ដែលរបបនេះត្រូវការ ដើម្បីអនុវត្តវិធានការណាមួយ ហើយដែលផ្តល់អោយដោយបុគ្គល និងក្រុមមនុស្ស ដែលធ្វើសហការ ។
- *កត្តាអរូបីយ៍* គឺជាកត្តាពាក់ព័ន្ធទៅនឹងចិត្តសាស្ត្រ និងមនោគមវិជ្ជា ដែលជំរុញអោយមនុស្សធ្វើតាមបញ្ជា និងជួយទ្រទ្រង់អ្នកត្រួតត្រា ។
- *សម្បត្តិធនធាន* គឺជាកំរិតដែលអ្នកគ្រប់គ្រង អាចត្រួតត្រា និងប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ ប្រព័ន្ធសេដ្ឋកិច្ច ហើយនិង ឧបករណ៍សំរាប់ការទាក់ទង និងការដឹកជញ្ជូន ។

- *ការដាក់ទោស* គឺជាការដាក់ទណ្ឌកម្ម តាមការគំរាម ឬក៏អនុវត្ត ម៉ឹងម៉ាត់ ទៅលើអ្នកដែលមិនធ្វើតាមបញ្ជា និងមិនធ្វើសហការ ដើម្បីអោយមានការចុះញ៉ម និងសហប្រតិបត្តិការដែលរបបនេះ ត្រូវការ ដើម្បីរស់ និងដើម្បីអនុវត្តវិធានការរបស់គេ ។

ប៉ុន្តែប្រភពទាំងនេះ អាស្រ័យទៅលើការទទួលយករបបនេះ ទៅលើការចុះញ៉ម និងការធ្វើតាមបញ្ជារបស់ប្រជាពលរដ្ឋ ហើយនិងទៅលើសហប្រតិបត្តិការរបស់ប្រជាពលរដ្ឋ និងស្ថាប័ននានាក្នុងសង្គម ។ គេពុំអាចធានាអោយមានលក្ខណៈទាំងអស់នេះរហូតទៅបានទេ ។

សហប្រតិបត្តិការ ការធ្វើតាមបញ្ជានិងការគាំទ្រ នឹងពង្រឹងប្រភពអំណាចដែលគេត្រូវការ ហើយនឹងពង្រីកអំណាចនៃរដ្ឋាភិបាលណាមួយ ។

ផ្ទុយទៅវិញ ការឈប់សហប្រតិបត្តិការជាមួយពួកផ្តាច់ការ ពីសំណាក់ប្រជាពលរដ្ឋនិងស្ថាប័ននានា នឹងបន្ថយឬក៏ប្រហែលជាផ្តាច់ប្រភពនៃអំណាច ដែលអ្នកគ្រប់គ្រងពឹងផ្អែក ។ ប្រសិនបើគ្មានប្រភពអំណាចទាំងនោះទេ អំណាចរបស់ក្រុមត្រួតត្រានឹងចុះខ្សោយ ហើយទីបំផុតនឹងរលាយដោយស្វ័យប្រវត្តិ ។

ជាធម្មតា ពួកផ្តាច់ការឆាប់ញ្ញោច ទៅលើសកម្មភាព និងគំនិតនានាដែលគំរាមកំហែងដល់លទ្ធភាពនៃការចាត់ចែងស្រេចតែចិត្តរបស់គេ ។ ដូច្នេះ ពួកផ្តាច់ការនឹងគំរាមកំហែង ដាក់ទណ្ឌកម្មជនទាំងឡាយណា ដែលធ្វើកូដកម្ម ឬមិនសហការ ។ ប៉ុន្តែ ការនេះមិនមែនចប់តែត្រឹមនេះទេ ។ ការជិះជាន់ ឬក៏អំពើឃោរឃៅ មិនច្បាស់ជាអាចធ្វើអោយមានការចុះញ៉ម ឬក៏សហការឡើងវិញពីសំណាក់អ្នកភ្ញាក់រលឹក ដើម្បីអោយរបបនេះមានដំណើរការទៅមុខទៀតឡើយ ។

ទោះបីមានការជិះជាន់យ៉ាងណាក៏ដោយ ប្រសិនបើគេអាចបន្ថយ ឬក៏ផ្តាច់ប្រភពនៃអំណាចទាំងនេះបានយូរ លទ្ធផលដំបូង អាចបង្កអោយមានភាពស្រពិចស្រពិលមិនច្បាស់លាស់ និងភាពច្របូកច្របល់ក្នុងរបបផ្តាច់ការ ។ អ្វីដែលនឹងកើតមានយ៉ាងច្បាស់ជាបន្តទៀតនោះ គឺការចុះថយអំណាចរបស់ពួកផ្តាច់ការ ។ ក្រោយមក ការព្យួរប្រភពអំណាចអាចធ្វើអោយរបបផ្តាច់ការគាំង គ្មានដំណើរការ ហើយក្នុងករណីតឹង

តែងមែនទែន របបផ្តាច់ការនឹងត្រូវដួលរលំ ។ អំណាចរបស់ពួកផ្តាច់ការនឹងរលត់ឆាប់ឬក៏លឿន ក៏អាស្រ័យទៅលើការបង្អត់ប្រភពអំណាច ។

ដូច្នេះ កំរិតនៃសេរីភាពឬក៏អំពើផ្តាច់ការនៅក្រោមរដ្ឋាភិបាលណាមួយ ភាគច្រើនអាស្រ័យទៅលើការតាំងចិត្តរបស់ប្រជាពលរដ្ឋ ថាតើគេចង់បានសេរីភាពដល់កំរិតណា ហើយថាតើគេមានចំណង់ និងសមត្ថភាពកំរិតណា ដើម្បីតទល់នឹងពួកផ្តាច់ការដែលចង់ជិះជាន់គេ ។

ផ្ទុយនឹងយោបល់ជាទូទៅ របបផ្តាច់ការពឹងពាក់ទៅលើប្រជាពលរដ្ឋ និងសង្គមដែលគេកាន់កាប់ ។ ដូចដែលអ្នកប្រាជ្ញនយោបាយ ខាល ដឺច(Karl W Deutsch) បានកត់សំគាល់នៅក្នុងឆ្នាំ១៩៥៣ ៖

"អំណាចផ្តាច់ការមានកំរិតខ្លាំង តែនៅក្នុងករណីណាដែលគេមិនចាំបាច់ប្រើប្រាស់អំណាចអោយញឹកញាប់ ។ ប្រសិនបើគេប្រើអំណាចផ្តាច់ការនោះជាប្រចាំប្រឆាំងនឹងប្រជាពលរដ្ឋ គេប្រហែលជាមិនអាចស្ថិតនៅក្នុងអំណាចបានយូរទេ ។ ដោយសាររបបផ្តាច់ការទាំងនេះត្រូវការអំណាច សំរាប់គ្រប់គ្រងប្រជាពលរដ្ឋច្រើនជាងប្រភេទរដ្ឋាភិបាលឯទៀត របបបែបនេះត្រូវការយ៉ាងខ្លាំង អោយមានទំលាប់ធ្វើតាមបញ្ជាគេ ក្នុងចំណោមប្រជាពលរដ្ឋ ។ លើសពីនេះទៅទៀត គេត្រូវតែពឹងផ្អែកទៅលើការគាំទ្រដ៏សកម្ម យ៉ាងហោចណាស់ ពីសំណាក់ក្រុមប្រជាពលរដ្ឋមួយចំនួនធំ ក្នុងករណីដែលគេត្រូវការ ។"[៨]

លោក ចន អូស្ទីន (John Austin) អ្នកប្រាជ្ញខាងច្បាប់ជាតិអង់គ្លេសនៅសតវត្សទី ១៩ បានរៀបរាប់អំពីស្ថានការណ៍ ដែលរបបផ្តាច់ការតទល់នឹងប្រជាពលរដ្ឋដែលមិនសប្បាយចិត្ត ។ លោក អូស្ទីនបានពន្យល់ថា ប្រសិនបើប្រជាពលរដ្ឋភាគច្រើនតាំងចិត្តថា នឹងរំលំរដ្ឋាភិបាល ហើយសុខចិត្តទ្រាំទ្រការសង្កត់សង្កិន ដើម្បីសំរេចការ

---

[៨] ខាលដឺច (Karl W. Deutsch) "ស្នាមប្រេះនៅក្នុងថ្ម" នៅក្នុងសៀវភៅចងក្រងដោយ ខាល ហ្វ្រេដរិក (Carl J. Friedrich) *ផ្តាច់ការនិយម* (ខាំប្រ៊ីដ ម៉ាសាឈូសិត រោងពុម្ពសាកលវិទ្យាល័យហាវ៉ាដ (Harvard, ១៩៥២) ទំព័រទី ៣១៣-៣១៤ ។

នេះ កំលាំងនៃរដ្ឋាភិបាលដែលរាប់បញ្ចូលទាំងពួកគាំទ្រគេផងនោះ ពុំអាចការពាររដ្ឋាភិបាលដែលពលរដ្ឋស្អប់មិនគាំទ្របានឡើយ ទោះបីរដ្ឋាភិបាលនេះបានទទួលជំនួយពីបរទេសក៏ដោយ ។ លោកអូស្ទីនបានសន្និដ្ឋានថា ពុំមាននរណាម្នាក់អាចបង្ខំប្រជាពលរដ្ឋដែលរើបម្រះ អោយវិលទៅរកការគោរពធ្វើតាមបញ្ជា ក្រោមការគ្រប់គ្រងជាអចិន្ត្រៃយ៍បានឡើយ ។[៩]

លោក នីកូឡូ ម៉ាកាវ៉េលី្ល (Niccolo Machiavelli) បានពន្យល់តាំងពីយូរណាស់មកហើយថា ព្រះអង្គម្ចាស់ "...ដែលមានសាធារណជនជាសត្រូវ មិនអាចមានការកក់ក្ដៅទេ ។ ហើយនៅពេលដែលអំពើឃោរឃៅរបស់ទ្រង់កាន់តែខ្លាំង ពេលនោះ របបគ្រប់គ្រងរបស់ទ្រង់ក៏ចុះខ្សោយទៅតាមនោះដែរ" ។[១០]

គេបានឃើញការលើកយកគំនិតនយោបាយដ៏ជ្រៅជ្រះនេះ ទៅអនុវត្តដោយជាក់ស្ដែង ក្នុងករណីតស៊ូរបស់ក្រុមវីរជនណរវ៉េ(Norway) ប្រឆាំងនឹងការកាន់កាប់ស្រុករបស់ពួកណាស៊ី ។ ដូចដែលបានរៀបរាប់ក្នុងជំពូកទី ១ ប្រជាពលរដ្ឋប៉ូឡូញ (Poland) អាល្លឺម៉ង់ ឆេកូស្លូវ៉ាគី និងអ្នកឯទៀតដ៏ក្លាហាន បានប្រឆាំងតទល់នឹងការឈ្លានពាននិងរបបផ្ដាច់ការរបស់ពួកកុម្មុយនីស្ដ ហើយនៅទីបំផុត បានជួយអោយរបបគ្រប់គ្រងកុម្មុយនីស្ដដួលរលំក្នុងទ្វីបអឺរ៉ុប ។ មែនទែនទៅ ព្រឹត្តិការណ៍ទាំងនេះមិនមែនជារឿងថ្មីទេ ។ ករណីប្រឆាំងតទល់ដោយអហិង្សា បានចាប់មានឡើង យ៉ាងហោចណាស់ តាំងពីឆ្នាំ៤៩៤មុនគ្រឹស្ដសករាជ នៅពេលដែលប្រជាពលរដ្ឋសាមញ្ញជាទាសករសំរេចចិត្ត ឈប់ធ្វើសហប្រតិបត្តិការជាមួយនឹងពួករ៉ូមដែលជាម្ចាស់ត្រួត

---

[៩] ចន អូស្ទីន (John Austin) *មេរៀនអំពីច្បាប់ឬក៏ទស្សនវិជ្ជាអំពីច្បាប់វិជ្ជមាន* (ការផ្សាយលើកទី ៥ ពិនិត្យ និងកែសំរួលដោយរ៉ូបឺត ខាំបិល [Robert Campbell], ពីរខ្សែ ក្រុងឡុនដុន : ចន ម៉ារាយ [John Murray] ឆ្នាំ ១៩១១ [១៨៦១], ខ្សែទី១ ទំព័រទី ២៩៦ ។)

[១០] នីកូឡូ ម៉ាកាវ៉ាល្លី (Niccolo Machiavelli) អត្ថាធិប្បាយអំពីសៀវភៅលើកដំបូង ១០របស់លីវី (Livy) *នៅក្នុងអត្ថាធិប្បាយនៃ នីកូឡូ ម៉ាកាវ៉ាល្លី ឡុនដុន* : រ៉ូលេជ (Routledge) និង ឃីហ្គិន ផោល (Kegan Paul) ឆ្នាំ ១៩៥០ ខ្សែទី១ ទំព័រទី ២៥៤

ត្រា ។[១១] ការតស៊ូអហិង្សាបានត្រូវប្រជាពលរដ្ឋយកទៅប្រើប្រាស់ ក្នុងពេលខុសៗគ្នា ជាទូទៅក្នុងទ្វីបអាស៊ី អាហ្វ្រិក អាមេរិក អូស្ត្រាលី កោះប៉ាស៊ីហ្វិកទាំងឡាយ និងទ្វីបអឺរ៉ុប ។

ដូច្នេះកត្តាសំខាន់៣ ដែលកំណត់ថា តើគេអាចគ្រប់គ្រង ឬមិនគ្រប់គ្រងអំណាចរដ្ឋាភិបាលបានដល់កំរិតណា គឺ ៖

១- កំរិតនៃ*ទឹកចិត្ត*ប្រជាពលរដ្ឋក្នុងការចង់ដាក់សំពាធទៅលើអំណាចរដ្ឋ

២- កំរិត*កំលាំង*ស្ថាប័ន និងអង្គការឯករាជនានា របស់ពលរដ្ឋដែលចង់ដកប្រភពអំណាចចេញ ក្នុងពេលស្របគ្នា និង

៣- កំរិត*លទ្ធភាព* ប្រជាពលរដ្ឋដែលអាចដកការយល់ព្រម និងជំនួយរបស់គេពីរដ្ឋាភិបាល ។

# មណ្ឌលទាំងឡាយនៃអំណាចប្រជាធិបតេយ្យ

លក្ខណៈមួយនៃសង្គមប្រជាធិបតេយ្យ គឺវត្តមាននៃអង្គការឬក្រុមក្រៅរដ្ឋាភិបាលដែលឯករាជដាច់ចេញពីរដ្ឋ ។ អង្គការទាំងនេះ មានជាអាទិ៍ ក្រុមគ្រួសារ ស្ថាប័នសាសនា សមាគមវប្បធម៌ ក្លឹបកីឡា វិទ្យាស្ថានសេដ្ឋកិច្ច សហជីព សមាគមនិស្សិត គណបក្សនយោបាយ ភូមិ សមាគមអ្នករស់នៅជិតខាងគ្នា ក្លឹបសួនច្បារ អង្គការសិទ្ធិមនុស្ស ក្រុមភ្លេង សង្គមអក្សរសិល្ប៍ និងក្រុមឯទៀតៗ ។ អង្គការទាំងនេះមានសារៈសំខាន់ក្នុងការបំរើគោលបំណងខ្លួនឯង ហើយនិងជួយបំពេញសេចក្តីត្រូវការរបស់សង្គមដែរ ។

លើសពីនេះទៅទៀត អង្គការទាំងនេះមានសារៈសំខាន់ខាងនយោបាយ ។

[១១] សូមអានសៀវភៅ ជីន សាប (Gene Sharp), *នយោបាយនៃសកម្មភាពអហិង្សា* បូស្តុន (Boston) : ផតទ័រ សាជិន (Porter Sargent) ឆ្នាំ ១៩៧៣ ទំព័រទី ៧៥ ហើយនិងសៀវភៅឯទៀតដែលមានឧទាហរណ៍ជាប្រវត្តិសាស្ត្រជាច្រើន ។

គេផ្តល់ជាមូលដ្ឋានឬវេទិកា ដែលប្រជាពលរដ្ឋអាចបញ្ចេញឥទ្ធិពល ទៅលើទិសដៅនៃដំណើរវិវត្តន៍របស់សង្គមទាំងមូល ហើយតទល់នឹងអង្គការឬរដ្ឋាភិបាលណា ដែលគេឃើញថា បានធ្វើអ្វីប៉ះពាល់ ដោយអយុត្តិធម៌ ទៅលើផលប្រយោជន៍ សកម្មភាព និងគោលបំណងរបស់គេ ។ ពួករស់នៅឯកោ ដែលមិនមែនជាសមាជិកនៃក្រុមណាមួយនោះ ច្រើនតែពុំអាចមានឥទ្ធិពលអ្វីខ្លាំងក្លាទៅលើសង្គម កុំថាឡើយដល់រដ្ឋាភិបាល ហើយច្បាស់ជាគ្មានអានុភាពអ្វីទៅលើរបបផ្តាច់ការសោះឡើយ ។

ដូច្នេះ ប្រសិនបើពួកផ្តាច់ការអាចដកទុកភាពស្វយ័តនិងសេរីភាពរបស់អង្គការទាំងឡាយនេះ ប្រជាពលរដ្ឋក៏បាត់បង់ជំនួយតាមនោះដែរ ។ ប្រសិនបើអង្គការទាំងនេះធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់រដ្ឋអំណាច ឬក៏ត្រូវជំនួសដោយអង្គការផ្សេងដែលគេអាចត្រួតបាន របបផ្តាច់ការអាចប្រើអង្គការទាំងនេះ អោយទៅជិះជាន់សមាជិកនានា និងផ្នែកណាមួយនៃសង្គមនោះ ។

ប៉ុន្តែ ប្រសិនបើគេអាចរក្សាឬក៏ទាក់ទាញយកមកវិញនូវស្វ័យភាព និងសេរីភាពនៃស្ថាប័នឯករាជស៊ីវិលទាំងនោះ (អោយស្ថិតនៅក្រៅការត្រួតត្រារបស់រដ្ឋាភិបាល) ស្ថាប័នទាំងនោះនឹងមានប្រយោជន៍យ៉ាងខ្លាំងដល់ការអនុវត្តន៍នយោបាយរើបម្រះ ។ លក្ខណៈរួមមួយដែលមានក្នុងឧទាហរណ៍ អំពីករណីរបបផ្តាច់ការដែលបានធ្លាក់ចុះខ្សោយ គឺការអនុវត្តន៍ដ៏ក្លាហាននិងស្រុះគ្នានូវនយោបាយរើបម្រះ ដោយប្រជាពលរដ្ឋ និងស្ថាប័ននានារបស់គេ ។

ដូចដែលបញ្ជាក់រួចមកហើយ មណ្ឌលអំណាចទាំងនេះជាស្ថាប័នគ្រឹះ ដែលប្រជាពលរដ្ឋប្រើប្រាស់ ដើម្បីដាក់សំពាធឬក៏ទប់ទល់នឹងការត្រួតត្រាផ្តាច់ការ ។ នៅក្នុងពេលអនាគត មណ្ឌលទាំងនេះនឹងក្លាយទៅជាផ្នែកមួយនៃរចនាសម្ព័ន្ធចំបងដែលគេពុំអាចកាត់ចោលបាន សំរាប់សង្គមសេរីមួយ ដើម្បីការតស៊ូរំដោះអោយបានជោគជ័យ ។

ប្រសិនបើរបបផ្តាច់ការបានទទួលជ័យជំនះ ក្នុងការរំលំឬក៏ត្រួតត្រាអង្គការឯករាជទាំងនោះ ពួកអ្នកប្រយុទ្ធតស៊ូត្រូវតែបង្កើតក្រុមសង្គម និងស្ថាប័នឯករាជថ្មីៗ ឬក៏ធ្វើយ៉ាងណាទាក់ទាញអង្គការដែលនៅសេសសល់ អោយចូលមកនៅក្រោមការកាន់

កាប់តាមបែបប្រជាធិបតេយ្យវិញ ។ ក្នុងឱកាសបដិវត្តន៍នៅប្រទេសហុងគ្រី (Hungary) ឆ្នាំ១៩៥៦-១៩៥៧ ក្រុមប្រឹក្សាប្រជាធិបតេយ្យជាច្រើន បានលេចចេញឡើង ហើយបានទាំងចាប់ដៃគ្នារៀបចំជាប្រព័ន្ធសហព័ន្ធនៃស្ថាប័ននានាផង ។ ក្នុងប្រទេសប៉ូឡូញនៅចុងទសវត្ស១៩៨០ ពួកកម្មករបានរក្សាទុកសាខាសហជីព"សូលីដារីធី" (Solidarity សាមគ្គី) មួយចំនួនខុសច្បាប់ ហើយក្នុងករណីខ្លះ បានក្តាប់យកសហជីពជាផ្លូវការរបស់ពួកកុម្មុយនីស្តបានទៀតផង ។ ការលូតលាស់ខាងស្ថាប័នបែបនេះ អាចមានឥទ្ធិពលនយោបាយដ៏សំខាន់ៗជាច្រើន ។

ជាការពិតណាស់ ទាំងនេះពុំមែនមានន័យថា ការធ្វើអោយខ្សោយនឹងរំលំរបបផ្តាច់ការ ជាការងាយស្រួលទេ ឬថាការល្បងណាមួយនឹងសុទ្ធតែបានជោគជ័យនោះឡើយ ។ ការនេះច្បាស់ជាពុំមែនមានន័យថា ការតស៊ូនឹងប្រព្រឹត្តទៅដោយគ្មានការខូចខាត ពីព្រោះអ្នកទាំងឡាយដែលនៅតែបំរើពួកផ្តាច់ការនឹងវាយប្រហារបកមកវិញ ក្នុងការប្រឹងប្រែងរបស់គេ ដើម្បីបង្ខំអោយប្រជាពលរដ្ឋផ្តើមធ្វើសហការនិងធ្វើតាមបញ្ជាគេឡើងវិញ ។

*ប៉ុន្តែ ការយល់ឃើញជ្រៅជ្រះអំពីអំណាចខាងលើនេះ មានន័យថាការបាក់បែកនៃរបបផ្តាច់ការ គឺជាព្រឹត្តិការណ៍ដែលអាចកើតឡើង ។* ជាពិសេស របបផ្តាច់ការមានលក្ខណៈច្បាស់លាស់មួយចំនួន ដែលធ្វើអោយរបបនេះទន់ខ្សោយ នៅចំពោះមុខនយោបាយរើបម្រះមួយដែលគេអនុវត្តយ៉ាងប៉ិនប្រសប់ ។ យើងនឹងពិនិត្យរែកញែកលក្ខណៈទាំងនោះអោយបានពិស្តារ ។

# ជំពូកទី៤

# របបផ្តាច់ការមានចំណុចខ្សោយ

ជារឿយៗ របបផ្តាច់ការមានរូបភាពជារបបមិនខ្សោយ ។ ភ្នាក់ងារសំងាត់ យោធា ប៉ូលិស កំលាំងយោធា គុក មន្ទីរទារុណកម្ម និងក្រុមប្រហារជីវិត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សដ៏មានអំណាចមួយចំនួនតូច ។ ពួកផ្តាច់ការ ជារឿយៗ ប្រើប្រាស់ទ្រព្យសម្បត្តិជាតិ មានជាអាទិ៍ លុយកាក់ ធនធានធម្មជាតិ និងកំលាំងផលិតកម្មយ៉ាងខ្ជះខ្ជាយ និងដើម្បីបំពេញបំណងខ្លួនឯង ។

ក្នុងការប្រៀបធៀប កំលាំងប្រឆាំងប្រជាធិបតេយ្យ ជារឿយៗ ហាក់ដូចជាខ្សោយសំបើមណាស់ គ្មានប្រសិទ្ធភាព ហើយគ្មានអំណាចអ្វីទាំងអស់ ។ ការយល់ឃើញអំពីភាពខ្លាំងក្លា តទល់នឹងភាពឥតអំណាចបែបនេះ ធ្វើអោយការប្រឆាំងពុំអាចមានប្រសិទ្ធភាព ។

ប៉ុន្តែសាច់រឿងនេះនៅមិនទាន់ចប់សព្វគ្រប់ទេ ។

## ការសំគាល់រកមើលកែងជើងអាគីល (Achilles)

រឿងព្រេងមួយក្នុងអក្សរសិល្ប៍ក្រិក (Greece) បុរាណ បានបញ្ជាំងយ៉ាងប៉ិនប្រសប់ អោយគេឃើញចំណុចខ្សោយនៃអ្វីដែលគេថាមិនទាន់ខ្សោយ ។ អាគីលជាអ្នកចំបាំងមួយរូបដែលល្បីឈ្មោះថា គ្មាននរណាអាចធ្វើអោយគេរបួស ហើយពុំមានដាវណាមួយអាចមុតស្បែកគេបានឡើយ ។ កាលនៅជាទារក ម្តាយរបស់អាគីលបាន

យកកូនទៅមុជទឹកក្នុងទន្លេទិព្វមួយឈ្មោះស្ទីក(Styx) ដែលបានធ្វើអោយស្បែកស្វិតកាប់មិនមុត ។ ប៉ុន្តែគេនៅមានបញ្ហាមួយ ។ ដោយសារម្តាយត្រូវកាន់កែងជើងកូនពេលមុជទឹក ដើម្បីកុំអោយរសាត់តាមចរន្តទឹក ទឹកទន្លេទិព្វនោះពុំបានជ្រាបចូលទៅការពារត្រង់កន្លែងកែងជើងនេះទេ ។ នៅពេលដែលអាគីលពេញវ័យ គេហាក់ដូចជាបុរសដែលគ្មានអាវុធសត្រូវណាអាចធ្វើអោយរបួសបានឡើយ ។ ប៉ុន្តែ នៅក្នុងសង្គ្រាមប្រឆាំងនឹងទីក្រុងត្រយ (Troy) ដោយធ្វើតាមបញ្ជារបស់មនុស្សម្នាក់ដែលដឹងអំពីចំណុចខ្សោយនេះ ទាហានសត្រូវមួយរូបបានបាញ់ព្រួញតម្រង់ទៅរកកែងជើងអាគីលដែលគ្មានអ្វីការពារ ដែលជាកន្លែងតែមួយដែលអាចធ្វើអោយអាគីលរបួស ។ របួសនេះបានធ្វើអោយអាគីលបាត់បង់ជីវិត ។ រហូតមកទល់ថ្ងៃនេះ ពាក្យអង់គ្លេស "Achilles' heel" (កែងជើងអាគីល) បានត្រូវគេប្រើ នៅពេលគេនិយាយអំពីចំណុចខ្សោយរបស់មនុស្ស ផែនការ ឬក៏ស្ថាប័នណាមួយ ដែលគេគ្មានមធ្យោបាយការពារប្រសិនបើគូសត្រូវវាយប្រហារចំកន្លែងនោះ ។

គេអាចអនុវត្តគោលការណ៍ដូចគ្នានេះ ទៅលើរបបផ្តាច់ការឃោរឃៅទាំងឡាយ ។ គេអាចឈ្នះរបបនេះបានដោយឆាប់រហ័ស ហើយខូចខាតតិច ប្រសិនបើគេដឹងច្បាស់អំពីចំណុចខ្សោយ ហើយផ្តោតការវាយប្រហារទៅលើតែចំណុចខ្សោយទាំងនោះ ។

# ចំណុចខ្សោយរបស់របបផ្តាច់ការ

ចំណុចខ្សោយរបបផ្តាច់ការមានជាអាទិ៍ដូចតទៅ ៖

១- ការបន្ថយ ឬការផ្អាកសហប្រតិបត្តិការ ពីសំណាក់មនុស្ស ក្រុម និងស្ថាប័នទាំងឡាយ ដែលគេត្រូវការដើម្បីអោយប្រព័ន្ធទាំងមូលមានដំណើរការ ។

២- សេចក្តីត្រូវការឬឥទ្ធិពលនៃផែនការចាស់ អាចរារាំងមិនអោយគេអនុវត្តផែនការថ្មីដែលមិនស៊ីសង្វាក់គ្នា ។

៣- ប្រព័ន្ធការងារអាចក្លាយទៅជាទំលាប់ ធ្វើអោយការប្រែប្រួលទៅតាមស្ថានការណ៍ថ្មីៗ ពុំបានឆាប់រហ័ស ។

៤- បុគ្គលិក និងធនធានដែលបានបែងចែកទៅតាមការងារបច្ចុប្បន្ន ហើយនោះពុំអាចផ្លាស់ប្តូរភ្លាមៗ ទៅតាមសេចក្តីត្រូវការថ្មីៗ ។

៥- អ្នកនៅក្រោមបង្គាប់ ដែលខ្លាចផ្គាប់ចិត្តចៅហ្វាយនាយមិនបាន ប្រហែលជាមិនហ៊ានធ្វើរបាយការណ៍ពិត ឬក៏អោយព័ត៌មានគ្រប់សព្វ ដែលពួកផ្តាច់ការត្រូវការ ដើម្បីសំរេចចិត្តអោយបានត្រឹមត្រូវ ។

៦- មនោគមវិជ្ជាអាចចុះខ្សោយ ហើយជំនឿនិងនិមិត្តរូបនៃរបបមួយប្រហែលជាត្រូវរង្គោះរង្គើ ។

៧- ប្រសិនបើមនោគមវិជ្ជាណាមួយមានកំរិតខ្លាំង ហើយមានឥទ្ធិពលទៅលើអ្វីដែលគេយល់ថា ជាការពិត ការប្រកាន់ខ្ជាប់យកមនោគមវិជ្ជានេះ អាចរារាំងមិនអោយគេចាប់អារម្មណ៍ទៅលើស្ថានការណ៍ និងសេចក្តីត្រូវការជាក់ស្តែង ។

៨- ប្រសិទ្ធភាព និងសមត្ថភាពនៃរដ្ឋបាលដែលចុះខ្សោយ ឬបទបញ្ជាត្រួតត្រាហួសហេតុ អាចធ្វើអោយផែនការ និងការអនុវត្តន៍នានាពុំមានប្រសិទ្ធភាព ។

៩- ទំនាស់ផ្ទៃក្នុង ការប្រកួតប្រជែង និងការប្រទូស្តរាយផ្ទាល់ខ្លួន អាចនឹងធ្វើអោយមានការខូចខាត ឬក៏ស្ទះកិច្ចប្រតិបត្តិការនៃរបបផ្តាច់ការ ។

១០- បញ្ញវ័ន្តនិងនិស្សិត អាចរំជើបរំជួលក្នុងការឆ្លើយតបទៅតាមស្ថានការណ៍ ការគាបសង្កត់ និងការបង្ក្រាប ។

១១- សាធារណជន បន្ទាប់ពីមួយរយៈពេល អាចមានអារម្មណ៍លែងរវីរវល់ មានការសង្ស័យ និងអាចប្រទូស្តរាយនឹងរបបនេះ ។

១២- ទំនាស់ខាងជាតិសាសន៍ វណ្ណៈ វប្បធម៌ និងតំបន់ អាចមានកំរិតកាន់តែខ្លាំងឡើង ។

១៣- ឋានានុក្រមអំណាចនៃរបបផ្តាច់ការ តែងតែមិនសូវមានស្ថិរភាព ហើយ

ជួនកាល ស្ថិរភាពនេះអាចមានកំរិតខ្លាំង ។ បុគ្គលនីមួយៗ មិននៅកាន់តំណែងដដែលៗ ប៉ុន្តែអាចឡើងចុះ ឬក៏ត្រូវគេដកចេញតែម្តង ហើយជំនួសដោយអ្នកផ្សេងទៀត ។

១៤- ផ្នែកខ្លះនៃក្រុមប៉ូលិស ឬក៏កម្លាំងយោធា ប្រហែលជាអាចចាត់ការដើម្បីសំរេចគោលបំណងផ្ទាល់ខ្លួន ទោះបីជាត្រូវប្រឆាំងនឹងរបបផ្តាច់ការក៏ដោយ មានជាអាទិ៍ ការធ្វើរដ្ឋប្រហារជាដើម ។

១៥- ប្រសិនបើរបបផ្តាច់ការនេះថ្មីថ្មោង គេត្រូវការពេលវេលា ដើម្បីពង្រឹងខ្លួនអោយបានមាំមួន ។

១៦- ដោយសារបញ្ហាមានច្រើន ហើយអ្នកសំរេចការមានតិច ផែនការនយោបាយនានា និងការអនុវត្តន៍ខុស ប្រហែលជាកើតឡើងជាញឹកញាប់ ។

១៧- ប្រសិនបើគេចង់ជៀសវាងពីគ្រោះថ្នាក់បែបនេះ ហើយរំលែកការត្រួតត្រា និងការសំរេចចិត្តអោយទៅអ្នកដទៃខាងក្រោម ការត្រួតត្រាលើអំណាចកំពូលប្រហែលជាត្រូវចុះអន់ខ្សោយទៅតាមនោះដែរ ។

# ការវាយប្រហារទៅលើចំណុចខ្សោយនៃរបបផ្តាច់ការ

ជាមួយនឹងការដឹងអំពីចំណុចខ្សោយ ដែលរបបផ្តាច់ការច្បាស់ជាមាន ក្រុមប្រជាធិបតេយ្យប្រឆាំងអាចរិះរកមធ្យោបាយបំប៉ោង “កែងជើងអាគីល” ដើម្បីអោយប្រព័ន្ធផ្តាច់ការមានការកែប្រែខ្លាំង ឬក៏បំបែករំលាយប្រព័ន្ធនោះតែម្តង ។

ដូច្នេះ គេអាចមានសេចក្តីសន្និដ្ឋានដ៏ច្បាស់លាស់មួយ៖ ថ្វីបើគេមានរូបភាពខ្លាំងក្លា របបផ្តាច់ការទាំងអស់សុទ្ធតែមានចំណុចខ្សោយមួយចំនួន ការខ្វះប្រសិទ្ធភាពផ្ទៃក្នុង ការប្រកួតឈ្នានីសបុគ្គល ការខ្វះប្រសិទ្ធភាពជាស្ថាប័ន និងទំនាស់គ្នាក្នុងចំណោមផ្នែកផ្សេងៗនៃរដ្ឋបាល ។ ចំណុចខ្សោយទាំងនេះ ក្នុងរយៈពេលមួយ អាចធ្វើអោយរបបផ្តាច់ការមិនសូវមានប្រសិទ្ធភាព ហើយរងគ្រោះពីការប្រែប្រួល និងពី

ការតស៊ូ ដែលគេរៀបចំឡើងយ៉ាងច្បាស់លាស់ ។ របបផ្តាច់ការច្បាស់ជាពុំអាច បាន ជោគជ័យទៅលើអ្វីៗទាំងអស់ ដែលគេចង់បាននោះឡើយ ។ ឧទាហរណ៍ មានពេល ខ្លះ សូម្បីតែពាក្យបញ្ជាផ្ទាល់របស់អ៊ីត្លែរ ក៏ត្រូវគេផ្អិបទុកចោលដែរ ពីព្រោះអ្នកដែល នៅខាងក្រោមបានបដិសេធ មិនព្រមយកទៅអនុវត្ត ។ ពេលខ្លះ របបផ្តាច់ការ ប្រហែលជា អាចដួលរលំយ៉ាងឆាប់រហ័ស ដូចដែលយើងបានសង្កេតឃើញរួចមក ហើយ ។

ការនេះមិនមែនមានន័យថា គេអាចរំលំរបបផ្តាច់ការបាន ដោយគ្មានគ្រោះ ថ្នាក់និងការខូចខាតទេ ។ វិធានការនីមួយៗដើម្បីសេរីភាព នឹងមានគ្រោះថ្នាក់ ហើយ និងការឈឺចាប់ ព្រមទាំងត្រូវការពេលវេលាផងដែរ ។ ហើយគ្មានវិធានការណា មួយ ដែលអាចធានាអោយបានជោគជ័យដ៏ឆាប់រហ័សគ្រប់កាលៈទេសៈនោះឡើយ ។ ប៉ុន្តែ ប្រភេទនៃការតស៊ូដែលផ្តោតទៅលើចំណុចខ្សោយនៃរបបផ្តាច់ការ ដែលគេ ដឹងច្បាស់នោះ អាចបានទទួលជោគជ័យ ជាងគំរោងតស៊ូណាដែលប្រឈមមុខតទល់ ជាមួយចំណុចខ្លាំងនៃរបបផ្តាច់ការ ។ សំណួរនៅពេលនេះគឺ តើគេអាចធ្វើការតស៊ូ នេះ*តាមបែបណា ?*

# ជំពូកទី៥

# ការប្រើប្រាស់អំណាច

នៅក្នុងជំពូកទី ១ យើងបានកត់សំគាល់ថា ការតស៊ូតាមកំលាំងយោធាប្រឆាំងនឹងរបបផ្តាច់ការ ពុំបានវាយប្រហារទៅចំកន្លែងណាដែលរបបនេះខ្សោយ ប៉ុន្តែនៅត្រង់កន្លែងដែលរបបនេះខ្លាំងជាទីបំផុតទៅវិញ ។ នៅពេលដែលគេជ្រើសរើសទៅប្រកួតតាមកំលាំងទ័ព ការផ្គត់ផ្គង់គ្រឿងអាវុធ បច្ចេកទេសខាងប្រើអាវុធជាដើម ចលនាប្រឆាំងហាក់ដូចជាបានដាក់ខ្លួនឯងអោយចាញ់ប្រៀបគេរួចទៅហើយ ។ របបផ្តាច់ការច្បាស់ជាអាចប្រមូលផ្តុំធនធានបែបនេះ បានច្រើនជាងពួកប្រឆាំងស្ទើរគ្រប់កាលៈទេសៈ ។ យើងក៏បានពិគ្រោះហើយដែរ អំពីគ្រោះថ្នាក់នៃការពឹងផ្អែកទៅលើកំលាំងបរទេស សំរាប់ការរំដោះនេះ ។ នៅក្នុងជំពូកទី ២ យើងបានពិនិត្យមើលបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងបញ្ហាពឹងផ្អែកទៅលើកិច្ចចរចា ដើម្បីកំចាត់របបផ្តាច់ការ ។

ដូច្នេះ តើគេអាចនៅមានមធ្យោបាយណាទៀត ដែលអាចផ្តល់អោយក្រុមប្រជាធិបតេយ្យប្រឆាំង នូវភាពមានប្រៀប ហើយនិងជួយអោយគេបំប៉ោងចំណុចខ្សោយនៃរបបផ្តាច់ការ ? តើបច្ចេកទេសបែបណាដែលអាចអនុវត្តទ្រឹស្តីនៃអំណាចនយោបាយ ដែលយើងពិគ្រោះនៅក្នុងជំពូកទី ៣ ? ជំរើសផ្សេងមួយ គឺនយោបាយរើបម្រះ ។

នយោបាយរើបម្រះមានលក្ខណៈដូចតទៅ ៖

- ជៀសវាងមិនប្រើកំលាំងបាយនិងអាវុធ និងមធ្យោបាយឯទៀត ដែលរបប ផ្តាច់ការនិយមប្រើប្រាស់ ។
- ធ្វើអោយរបបផ្តាច់ការ មានការលំបាកក្នុងការតបត ។
- ធ្វើអោយចំណុចខ្សោយទាំងឡាយនៃរបបផ្តាច់ការ មានកំរិតកាន់តែខ្លាំង ហើយ ផ្តាច់ប្រភពអំណាចរបបនេះ ។
- រៀបចំជាសកម្មភាព ដែលគេអាចយកទៅអនុវត្តបានយ៉ាងទូលំទូលាយ ប៉ុន្តែ ក៏អាចផ្តោតទៅលើគោលបំណងណាមួយដ៏ច្បាស់លាស់ដែរ ។
- ធ្វើអោយមេផ្តាច់ការគិតខុស ហើយនិងចាត់វិធានការខុស ។
- នយោបាយរើបម្រះនេះអាចពឹងផ្អែកទៅលើប្រជាពលរដ្ឋទាំងមូល ក្រុមសង្គម និងស្ថាប័ននានា យ៉ាងមានប្រសិទ្ធភាព ក្នុងការតស៊ូបញ្ចប់អំពើជិះជាន់ដ៏ ឃោរឃៅរបស់មនុស្សមួយក្រុមតូច ។
- ជួយផ្សព្វផ្សាយអំពីការបែងចែកអំណាចដ៏មានប្រសិទ្ធភាពនៅក្នុងសង្គម ដើម្បី សំរួលដល់ការបង្កើតនិងការថែរក្សាអោយសង្គមប្រជាធិបតេយ្យ មានដំណើរ ការទៅអនាគត ។

# ដំណើរនៃការតស៊ូអហិង្សា

ដូចជាកំលាំងយោធាដែរ គេអាចប្រើនយោបាយរើបម្រះ ដើម្បីអាចសំរេច បាននូវគោលបំណងមួយចំនួន រាប់ចាប់ពីការខ្នះខ្នែងរុញអោយគូបដិបក្សអនុវត្ត វិធានការផ្សេង ទៅការបង្កើតឱកាសសំរាប់អោយមានការដោះស្រាយទំនាស់ដោយ សន្តិវិធី ឬក៏ទៅដល់ការធ្វើអោយរបបគូបដិបក្សរលំ ។ ប៉ុន្តែនយោបាយរើបម្រះមាន ដំណើរការខុសគ្នា ពីការប្រើអំពើហិង្សា ។ ថ្វីបើវិធីទាំងពីរនេះ ជាឧបករណ៍សំរាប់ ធ្វើការតស៊ូ វិធីនេះធ្វើតាមបែបបទខុសពីគ្នា ហើយចេញជាលទ្ធផលផ្សេងពីគ្នា ។ គេបានដឹងច្បាស់ហើយអំពីរបៀប និងផលវិបាកនៃទំនាស់ហិង្សារួចហើយ ។ គេប្រើ គ្រឿងអាវុធសំរាប់គំរាមកំហែង ធ្វើអោយមានរបួស ការបាត់បង់ជីវិត ហើយនិង

ការរំលំចោលអ្វីៗទាំងអស់ ។

ការតស៊ូអហិង្សាមានភាពស្មុគស្មាញខ្លាំងជាង ហើយមានវិធីតស៊ូច្រើនបែបជាងការប្រើអំពើហិង្សា ។ ក្នុងការតស៊ូនេះ គេប្រើអាវុធខាងចិត្តសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយ ដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងស្ថាប័នផ្សេងៗក្នុងសង្គម ។ គេបានស្គាល់វិធីទាំងនេះ ថាជាបាតុកម្មប្រឆាំង កូដកម្ម ការមិនធ្វើសហប្រតិបត្តិការ ពហិការ ការមិនសប្បាយចិត្ត ហើយនិងអំណាចប្រជាពលរដ្ឋ ។ ដូចដែលបានកត់សំគាល់ពីមុនរួចហើយ រដ្ឋាភិបាលទាំងអស់អាចគ្រប់គ្រងបាន តែនៅពេលណាដែលគេបានទទួលជំនួយពីប្រភពអំណាចផ្សេងៗរបស់គេ ដែលគេត្រូវការ ហើយដែលចេញពីសហប្រតិបត្តិការ ការចុះញ៉ម និងការធ្វើតាមបញ្ជាពីសំណាក់ប្រជាពលរដ្ឋ និងស្ថាប័ននានានៃសង្គម ។ នយោបាយរើបម្រះ មិនដូចការប្រើហិង្សាទេ គឺជាអាវុធតែមួយសំរាប់កាត់ផ្តាច់ប្រភពអំណាចរបបផ្តាច់ការទាំងនោះ ។

# អាវុធនិងវិន័យអហិង្សា

កំហុសមួយដែលយុទ្ធនាការនយោបាយរើបម្រះពីមុនៗបានធ្វើ គឺការពឹងផ្អែកទៅលើតែវិធីមួយ ឬពីរ ដូចជា កូដកម្ម និងបាតុកម្មធំៗ ។ ការពិត វិធីមានច្រើនប្រភេទសំរាប់អ្នករៀបចំយុទ្ធនាការប្រឆាំង យកទៅអនុវត្តតាមត្រូវការ ។

គេបានដឹងច្បាស់អំពីវិធីប្រមាណ ២០០បែប ហើយនៅមានច្រើនទៀត ។ វិធីទាំងនេះចែកចេញជា បីក្រុមធំៗ ៖ បាតុកម្មប្រឆាំងនិងការពន្យល់ណែនាំ ការមិនធ្វើសហប្រតិបត្តិការ និងការធ្វើអន្តរាគមន៍ ។ វិធីបាតុកម្មប្រឆាំង និងការពន្យល់ណែនាំដោយអហិង្សា គឺការធ្វើបាតុកម្មជានិមិត្តរូប មានជាអាទិ៍ ការដើរជាក្បួន និងការប្រមូលផ្តុំគ្នាដោយស្ងាត់ស្ងៀម (មានប្រមាណ ៥៤វិធី) ។ ការមិនធ្វើសហការមានបីប្រភេទ ៖ ក) មិនសហការសង្គមកិច្ច (១៦វិធី), ខ) មិនសហការសេដ្ឋកិច្ចមានជាអាទិ៍ ពហិការ (២៦វិធី) និងកូដកម្ម (២៣វិធី), និង គ) មិនសហការ នយោបាយ (៣៨វិធី) ។ អន្តរាគមន៍អហិង្សាតាមបែបចិត្តសាស្ត្រ រាងកាយ សង្គមកិច្ច សេដ្ឋកិច្ច

ឬក៏នយោបាយ ដូចជាការអត់អាហារ ការកាន់កាប់ទីកន្លែងណាមួយដោយអហិង្សា និងរដ្ឋាភិបាលទន្ទឹម (ការបង្កើតជារដ្ឋាភិបាលមួយទៀត ស្របគ្នានឹងរដ្ឋាភិបាលផ្តាច់ការ) ស្ថិតនៅក្នុងក្រុមទី៣ ។ បញ្ជីដែលមាន ១៩៨វិធី មានភ្ជាប់នៅខាងចុងនៃសៀវភៅនេះ ។

ការជ្រើសរើសយ៉ាងហ្មត់ចត់ យកវិធីទាំងនោះទៅអនុវត្តអោយបានសព្វទិសទី ទៅតាមគំរោងយុទ្ធសាស្ត្រមួយដ៏ច្បាស់លាស់ ធ្វើអោយរបបមិនត្រឹមត្រូវណាមួយ រាប់បញ្ចូលទាំងរបបផ្តាច់ការផងដែរ មានការរង្គោះរង្គើ ។

ផ្ទុយនឹងវិធានការយោធា គេអាចផ្តោតវិធីនៃការតស៊ូអហិង្សាទាំងនេះដោយផ្ទាល់ ទៅលើបញ្ហានានាដែលគេតំរង់ចង់បាន ។ ឧទាហរណ៍ ដោយសារបញ្ហារបបផ្តាច់ការ ច្រើនជាបញ្ហានយោបាយ ការតស៊ូអហិង្សាប្រភេទនយោបាយនឹងមានសារៈសំខាន់ខ្លាំង ។ វិធីទាំងនេះមានជាអាទិ៍ ការមិនអោយភាពត្រឹមត្រូវតាមច្បាប់ទៅពួកផ្តាច់ការ និងការមិនធ្វើសហការជាមួយរបបអ្នកទាំងនេះ ។ គេក៏អាចប្រើវិធីមិនធ្វើសហការនេះក្នុងផែនការពិសេសណាមួយដែរ ។ ជារឿយៗ ដោយស្ងាត់ស្ងៀម និងសំងាត់ គេប្រហែលជាអាចធ្វើអោយការអនុវត្តន៍ផែនការផ្តាច់ការណាមួយរអាក់រអួល និងខាតពេលវេលា ។ ជួនកាលទៀត គេអាចប្រកែកមិនធ្វើតាមបញ្ជា និងធ្វើកូដកម្ម-បាតុកម្មប្រឆាំងពេញមុខជាសាធារណៈ ។

ផ្ទុយទៅវិញ ប្រសិនបើចំណុចខ្សោយនៃរបបផ្តាច់ការមានការប៉ះពាល់ដល់សេដ្ឋកិច្ច ឬក៏ប្រជាពលរដ្ឋរអ៊ូរទាំខ្លាំងអំពីបញ្ហាសេដ្ឋកិច្ច សកម្មភាពអោយរាំងស្ទះសេដ្ឋកិច្ច ដូចជា ពហិការ ឬក៏កូដកម្ម អាចជាវិធីដ៏មានប្រសិទ្ធភាព សំរាប់ក្រុមតស៊ូ ។ ការខំខ្នះខ្នែងរបស់ពួកផ្តាច់ការ ដើម្បីកេងប្រវ័ញ្ចយកចំណេញពីប្រព័ន្ធសេដ្ឋកិច្ចអាចពើបប្រទះនឹងកូដកម្មជាទូទៅ ការធ្វើការយឺតៗ និងការប្រកែកមិនធ្វើសហការ ឬក៏ការគេចខ្លួនរបស់អ្នកជំនាញការដែលរបបនេះត្រូវការជាចាំបាច់ ។ គេអាចប្រើប្រាស់ប្រភេទនៃកូដកម្មមួយចំនួន នៅក្នុងផ្នែកសំខាន់ៗនៃការផលិត នៃការដឹកនាំ នៃការផ្គត់ផ្គង់វត្ថុធាតុដើម និងក្នុងការចែកចាយផលិតផល ។

វិធីខ្លះនៃការតស៊ូអហិង្សាតំរូវអោយគេធ្វើសកម្មភាពនានា ដែលគេពុំធ្លាប់

ធ្វើ ដូចជា ការដើរចែកខិតប័ណ្ណ ការបោះពុម្ពផ្សាយដោយសំងាត់ ការអត់អាហារ ការអង្គុយចុះនៅតាមផ្លូវ ។ មនុស្សខ្លះពិបាកធ្វើសកម្មភាពបែបនេះ លើកលែងតែក្នុងកាលៈទេសៈពិសេសមែនទែន ។

វិធីតស៊ូអហិង្សាខ្លះទៀត តំរូវអោយមនុស្សម្នាបន្តធ្វើកិច្ចការផ្សេងៗជាធម្មតា ប៉ុន្តែតាមបែបបទផ្សេងទៀត ។ ឧទាហរណ៍ គេអាចនាំគ្នាចូលធ្វើការដូចធម្មតា ដោយមិនធ្វើកូដកម្ម ប៉ុន្តែ ដោយចេតនា គេនាំគ្នាធ្វើការយឺតៗ ឬក៏មិនសូវអោយមានប្រសិទ្ធភាពដូចធម្មតា ។ គេនាំគ្នាធ្វើ "ខុស" ដោយចេតនា ច្រើនជាងពេលមុនៗ ។ ខ្លះទៀតអាចក្លាយទៅជា "ឈឺ" ហើយ "មិនអាច" ទៅធ្វើការក្នុងពេលណាមួយ ឬក៏គេអាចបដិសេធមិនធ្វើការ ។ គេអាចនាំគ្នាទៅសូត្រធម៌ក្នុងព្រះវិហារ នៅពេលដែលការធ្វើបែបនេះ មិនត្រឹមតែបញ្ជាក់អំពីជំនឿខាងសាសនាទេ តែជាជំនឿខាងនយោបាយទៀត ។ គេអាចធ្វើសកម្មភាពដើម្បីការពារពួកក្មេងៗអោយផុតពីការឃោសនារបស់របបផ្តាច់ការ តាមការរៀនសូត្រនៅផ្ទះ ឬក៏តាមសាលារៀនលួចលាក់ ។ គេអាចបដិសេធមិនចូលជាសមាជិកនៃអង្គការដែលរបបផ្តាច់ការ "ស្នើ" ឬក៏តំរូវ ហើយដែលគេមិនចូលដោយស្មោះស្ម័គ្រក្នុងពេលមុនៗ ។ ភាពប្រហាក់ប្រហែលគ្នានៃវិធីទាំងនេះ ទៅនឹងសកម្មភាពធម្មតារបស់ប្រជាពលរដ្ឋ ហើយនិងការប្រែប្រួលបន្តិចបន្តួចពីជីវភាពសព្វដងរបស់គេ អាចធ្វើអោយការចូលរួមក្នុងសកម្មភាពរំដោះប្រជាជាតិបែបនេះ កាន់តែងាយស្រួលឡើងសំរាប់អ្នកទាំងនោះ ។

ដោយសារការតស៊ូអហិង្សា និងអំពើហិង្សា មានភាពខុសគ្នាយ៉ាងខ្លាំងក្នុងការអនុវត្តន៍ សូម្បីតែអំពើហិង្សាបន្តិច ក្នុងឱកាសយុទ្ធនាការនយោបាយរើបម្រះ ក៏អាចបង្កើតអោយមានផលវិបាកដែរ ពីព្រោះអំពើហិង្សាតែបន្តិចនេះ អាចធ្វើអោយការតស៊ូកែប្រែ ទៅជាប្រភេទដែលពួកផ្តាច់ការមានប្រៀបជាងដីខ្លាំងក្លា (សង្គ្រាមយោធា) ។ វិន័យអហិង្សា គឺជាកត្តាដ៏សំខាន់សំរាប់ជ័យជំនះ ហើយគេត្រូវតែប្រកាន់អោយខ្ជាប់ ថ្វីបើពួកផ្តាច់ការនិងភ្នាក់ងាររបស់គេប្រើអំពើឃោរឃៅ ញុះញង់អោយមានហិង្សាបែបណាក៏ដោយ ។

ការប្រកាន់យកវិន័យអហិង្សាអោយជាប់ ក្នុងការតទល់ជាមួយនឹងគូបដិបក្ស

ហិង្សា នឹងសំរួលអោយយន្តការបួនយ៉ាងសំរាប់ការផ្លាស់ប្តូរ ក្នុងការតស៊ូអហិង្សាអោយមានដំណើរការទៅមុខបាន (វិភាគខាងក្រោម) ។ វិន័យអហិង្សា ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរនៅក្នុងដំណើរការនយោបាយជូជិស៊ូ(Jiu-Jitsu) ។ នៅក្នុងដំណើរការនេះ អំពើឃោរឃៅយ៉ាងច្បាស់ក្រឡែតនៃរបបផ្តាច់ការ ប្រឆាំងនឹងពួកអហិង្សា នឹងនាំអោយមានផលវិបាកបកត្រឡប់ទៅពួកផ្តាច់ការវិញ ធ្វើអោយមានការមិនសប្បាយចិត្តផ្ទៃក្នុងនៃពួកផ្តាច់ការ និងនាំអោយការគាំទ្រពួកអហិង្សាមានកំរិតកាន់តែខ្លាំងឡើង ក្នុងចំណោមប្រជាពលរដ្ឋដែលធ្លាប់គាំទ្ររបបផ្តាច់ការនោះ។

ប៉ុន្តែ នៅក្នុងករណីខ្លះទៀត គេប្រហែលជាមិនអាចជៀសអោយផុតពីអំពើហិង្សាមួយកំរិតតូច ប្រឆាំងនឹងរបបផ្តាច់ការ ។ អារម្មណ៍មួរម៉ៅនិងការស្អប់របបនេះ អាចនាំអោយមានអំពើហិង្សាផ្ទុះឡើង ។ ឬក្រុមខ្លះនៃពួកតស៊ូប្រហែលជាមិនចង់លះបង់ចោលអំពើហិង្សា ថ្វីបើគេយល់អំពីសារៈសំខាន់នៃការតស៊ូអហិង្សាក៏ដោយ ។ ក្នុងករណីទាំងនេះ គេពុំចាំបាច់លះបង់ចោលនយោបាយរើបម្រះនោះទេ ។ ប៉ុន្តែជាការចាំបាច់ គេត្រូវបែងចែកសកម្មភាពហិង្សា អោយដាច់ចេញឆ្ងាយពីសកម្មភាពអហិង្សា ។ គេគួរធ្វើបែបនេះតាមផ្នែកភូមិសាស្ត្រ ក្រុមផ្សេងៗ ការកំណត់ពេលវេលា និងតាមបញ្ហានីមួយៗ ។ ប្រសិនបើមិនដូច្នោះទេ អំពើហិង្សាអាចមានផលវិបាកយ៉ាងខ្លាំងទៅលើការប្រើប្រាស់នយោបាយរើបម្រះ ដែលជាឧបករណ៍ដ៏ខ្លាំងក្លាសំរាប់ឈានទៅរកជោគជ័យអោយបានច្រើនជាង ។

ប្រវត្តិសាស្ត្របានបង្ហាញអោយឃើញថា នៅពេលគេគិតគ្រោងទុកជាមុនថានឹងមានការបាត់បង់ជីវិតនិងរបួសនៅក្នុងនយោបាយរើបម្រះ ការខូចខាតទាំងនោះមានកំរិតតិចជាងឆ្ងាយពីការខូចខាតក្នុងសង្គ្រាមយោធា ។ លើសពីនេះទៅទៀត ការតស៊ូបែបនេះ ពុំបាននាំទៅរកការកាប់សំលាប់គ្នា និងអំពើឃោរឃៅ ដោយគ្មានទីបញ្ចប់នោះឡើយ ។

ការតស៊ូអហិង្សាតំរូវអោយមាន ហើយច្រើនតែធ្វើអោយមាន ការឈប់ (ឬការទប់ស្កាត់) ខ្លាចរដ្ឋាភិបាលនិងសកម្មភាពជិះជាន់ហិង្សា ។ ការឈប់ខ្លាច ឬការទប់ស្កាត់ការភ័យខ្លាច គឺជាកត្តាសំខាន់ក្នុងការរំលំអំណាចពួកផ្តាច់ការ ដែលមាន

ទៅលើប្រជាពលរដ្ឋទូទៅ ។

# ការបើកចំហ ភាពសំងាត់ និងសវិយាបថត្រឹមត្រូវ

ភាពសំងាត់ ការបោកប្រាស់ ហើយនិងការឃុបឃិតគ្នាជាសំងាត់ បានបង្កើតជាបញ្ហាដ៏លំបាកសំរាប់ចលនាដែលប្រើសកម្មភាពអហិង្សា ។ ជារឿយៗ គេមិនអាចលាក់អោយជិត មិនអោយប៉ូលិស និងភ្នាក់ងារសំងាត់ដឹងអំពីគោលបំណង និងផែនការទេ ។ តាមការយល់ឃើញរបស់ចលនាតស៊ូ ភាពសំងាត់មិនគ្រាន់តែជាឫសគល់នៃការភ័យខ្លាចទេ តែជាកត្តាដែលជួយបន្ថែមទៅលើការភ័យខ្លាច ដែលធ្វើអោយខូចស្មារតីតស៊ូ ហើយបន្ថយចំនួនមនុស្សដែលអាចចូលរួមក្នុងសកម្មភាពណាមួយ ។ ភាពសំងាត់នេះក៏អាចជួយបន្ថែមទៅលើការសង្ស័យ និងការចោទប្រកាន់គ្នា ជារឿយៗ មិនសមហេតុសមផល ក្នុងចំណោមចលនាតស៊ូ អំពីថាតើនរណាជាភ្នាក់ងារសំងាត់ស៊ើបការណ៍អោយគូបដិបក្ស ។ ការនេះប្រហែលជាអាចប៉ះពាល់ដល់លទ្ធភាពរបស់ចលនាតស៊ូ ក្នុងការប្រកាន់ខ្ជាប់នូវអំពើអហិង្សា ។ ផ្ទុយទៅវិញ ការបើកចំហអោយគេដឹងអំពីគោលបំណងនិងផែនការនៃការតស៊ូ មិនត្រឹមតែមានផលល្អទៅវិញទេ ប៉ុន្តែនឹងជួយអោយគេឃើញថា មែនទែនទៅ ចលនាតស៊ូមានកំលាំងខ្លាំងក្លាជាទីបំផុត ។ តាមការពិត បញ្ហានេះស្មុគស្មាញជាងអ្វីដែលគេបាននិយាយខាងលើ ហើយមានសកម្មភាពតស៊ូមួយចំនួនធំ ដែលតំរូវអោយមានការលាក់បាំង ។ គេត្រូវការអោយមានការវិភាគដ៏ជ្រៅជ្រះមួយ ក្នុងចំណោមអ្នកទាំងឡាយណាដែលយល់ដឹងច្បាស់ អំពីថាមពលនៃការតស៊ូអហិង្សា ហើយនិងមធ្យោបាយរបស់ពួកផ្តាច់ការសំរាប់ការតាមដានស៊ើបអង្កេត នៅក្នុងស្ថានការណ៍ពិសេសណាមួយ ។

ការបោះពុម្ពផ្សព្វផ្សាយជាសំងាត់ ការប្រើប្រាស់វិទ្យុផ្សាយសំលេងក្រៅច្បាប់ ហើយនិងការប្រមូលយកព័ត៌មានសំងាត់អំពីប្រតិបត្តិការរបស់របបផ្តាច់ការ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពពិសេសមួយចំនួនតូច ដែលតំរូវអោយមានភាពសំងាត់ជាទីបំផុត ។

ការប្រកាន់ខ្ជាប់នូវឥរិយាបថត្រឹមត្រូវ ក្នុងសកម្មភាពអហិង្សា គឺជាការចាំបាច់ក្នុងគ្រប់ដំណាក់ការនៃទំនាស់ ។ កត្តាខ្លះ ដូចជា ការមិនភ័យខ្លាច និងការប្រកាន់ខ្ជាប់នូវវិន័យអហិង្សា គឺជាការចាំបាច់គ្រប់ពេលវេលា ។ គេត្រូវចងចាំថា ជារឿយៗ គេត្រូវការចំនួនមនុស្សយ៉ាងច្រើន ដើម្បីកែប្រែអ្វីមួយ ។ ប៉ុន្តែ គេអាចប្រមូលអ្នកដែលគេទុកចិត្តអោយបានច្រើនបែបនេះ តែតាមរយៈការប្រកាន់ខ្ជាប់នូវឥរិយាបថខ្ពង់ខ្ពស់ត្រឹមត្រូវ ក្នុងចលនាតស៊ូ ។

# ការប្រែប្រួលគ្រឹះអំណាច

អ្នកយុទ្ធសាស្រ្តត្រូវតែចងចាំថា នៅក្នុងទំនាស់ដែលគេអនុវត្តនយោបាយរើបម្រះ ទីលានតស៊ូមានការប្រែប្រួលមិនឈប់ឈរ ដោយសារគូបដិបក្សនឹងធ្វើសកម្មភាពតបតគ្នាទៅវិញទៅមក ឥតឈប់ឈរ ។ គ្មានអ្វីដែលស្ថិតនៅនឹងថ្កល់នោះទេ ។ ទំនាក់ទំនងអំណាចរវាងភាគីទាំងពីរ នឹងមានការប្រែប្រួលយ៉ាងឆាប់រហ័សជានិច្ច ។ ការនេះកើតមានឡើង ដោយសារពួកប្រឆាំងនៅតែបន្តការទប់ទល់ដោយអហិង្សា ថ្វីបើភាគីម្ខាងទៀតចេះតែបង្ក្រាបជិះជាន់បែបណាក៏ដោយ ។

ការប្រែប្រួលនៃកំរិតអំណាចរបស់ភាគីប្រកួតទាំងសងខាង នៅក្នុងកាលៈទេសៈទំនាស់បែបនេះ ប្រហែលជាខ្លាំងជាងហើយលឿនជាងទំនាស់ហិង្សា ហើយនឹងជំរុញអោយចេញជាលទ្ធផលប្លែកៗ ដែលមានន័យខ្លឹមសារនយោបាយច្រើន ។ ដោយសារការប្រែប្រួលទាំងនេះ សកម្មភាពពិសេសណាមួយរបស់ក្រុមតស៊ូ ប្រហែលជាមានផលវែងឆ្ងាយ ដែលអាចធ្វើអោយភាគីណាមួយ កាន់តែមាំឡើងឬក៏ចុះខ្សោយ ។

លើសពីនេះទៅទៀត តាមរយៈសកម្មភាពរបស់គេ ក្រុមអហិង្សាប្រហែលជានឹងមានឥទ្ធិពលខ្លាំងទៅលើការកើនឡើង ឬក៏ចុះថយនៃកំលាំងបដិបក្ស ។ ឧទាហរណ៍ ក្រុមតស៊ូអហិង្សាដ៏មានវិន័យនិងសេចក្តីក្លាហាន ក្នុងការប្រឈមមុខអំពើឃោរឃៅរបស់ពួកផ្តាច់ការ អាចធ្វើអោយកងទាហាននិងអ្នកគាំទ្រពួកផ្តាច់ការ មានអារម្មណ៍មិនស្រួល មិនសប្បាយចិត្ត ហើយអាចក្លាយទៅជាក្រុមដែលពួកផ្តាច់ការលែងទុក

ចិត្តបាន ហើយនៅក្នុងករណីខ្លាំងមែនទែន អាចនាំអោយមានការបះបោរផ្ទៃក្នុង ។ ការប្រឆាំងបែបនេះ ក៏អាចនាំមកនូវការផ្ដន្ទាទោសកាន់តែខ្លាំងទៅលើរបបផ្ដាច់ការ ពីសំណាក់អន្តរជាតិដែរ ។ លើសពីនេះទៅទៀត ការអនុវត្តន៍នយោបាយរើបម្រះដ៏ឈ្លៀសវៃ ដ៏មានវិន័យ អាចជំរុញអោយមានការចូលរួមក្នុងចលនាតស៊ូកាន់តែច្រើនឡើងៗ ពីសំណាក់អ្នកដែលជាធម្មតាគាំទ្រពួកផ្ដាច់ការ ឬក៏ជាទូទៅ នៅជាអព្យាក្រឹតក្នុងទំនាស់នេះ ។

# យន្តការបួនយ៉ាងសំរាប់ការប្រែប្រួល

ការតស៊ូអហិង្សានាំមកនូវការប្រែប្រួលបួនយ៉ាង ។ យន្តការទីមួយបានកើតមានឡើង ប៉ុន្តែយ៉ាងកម្រ ។ នៅពេលដែលទឹកចិត្តសមាជិកនៃក្រុមផ្ដាច់ការពុះកញ្ជ្រោល ដោយសារគេឃើញទុក្ខវេទនាពីការជិះជាន់ទៅលើពួកប្រឆាំងអហិង្សាដ៏ក្លាហាន ឬក៏គេប្រែចិត្តយល់ថា បុព្វហេតុនៃការតស៊ូមានលក្ខណៈត្រឹមត្រូវ អ្នកទាំងនោះអាចនឹងទទួលយកបាននូវគោលបំណងរបស់ក្រុមតស៊ូ ។ យន្តការនេះមានឈ្មោះហៅថា *ការប្ដូរក្រុម* ។ ថ្វីបើករណីនៃការប្ដូរក្រុម ទៅរកការតស៊ូអហិង្សា បានកើតមានឡើង ព្រឹត្តិការណ៍នេះកម្រណាស់ ហើយនៅក្នុងទំនាស់ជាច្រើន ការនេះមិនកើតមានឡើងទេ ឬក៏កើតមានឡើងតែបន្តិចបន្តួចប៉ុណ្ណោះ ។

អ្វីដែលកើតឡើងជាញឹកញយ គឺការតស៊ូអហិង្សាបានផ្លាស់ប្ដូរស្ថានការណ៍ទំនាស់ និងសង្គមដល់កំរិតមួយដែលពួកផ្ដាច់ការ ពុំអាចធ្វើអ្វីទៅតាមចំណង់ចិត្តដូចពេលមុន ។ នេះគឺជាការផ្លាស់ប្ដូរពាក់ព័ន្ធនឹងអំណាចនៃភាគីទាំងពីរដែលបង្កើតអោយមានយន្តការទាំងបីទៀត ៖ ការយោគយល់ ការបង្ខំដោយអហិង្សា និងការបែកខ្ញែក ។ តើយន្តការណាមួយនឹងកើតមានឡើងនោះ អាស្រ័យទៅលើការប្រែប្រួលនៃទំនាក់ទំនងអំណាច ដែលធ្វើអោយពួកប្រជាធិបតេយ្យមានប្រៀប ។

ប្រសិនបើបញ្ហាជាក់ស្ដែងណាមួយមិនមែនជាបញ្ហាសំខាន់ណាស់ណាទេនោះ ពួកផ្ដាច់ការមិនចាត់ទុកការទាមទាររបស់ក្រុមប្រឆាំង នៅក្នុងយុទ្ធនាការដ៏មានកំរិត

មួយ ថាជាការគំរាមកំហែង ហើយការប្រកួតគ្នាត្រង់បញ្ហានេះ អាចធ្វើអោយមានការប្រែប្រួលខ្លះទៅលើទំនាក់ទំនងអំណាច ។ ក្នុងករណីនេះ គេអាចបញ្ចប់ទំនាស់នេះបានភ្លាម តាមកិច្ចព្រមព្រៀងមួយដែលមានការយោគយល់សំរបសំរួលគ្នា ។ គេហៅយន្តការនេះថា *ការយោគយល់* ។ គេដោះស្រាយបញ្ហាកូដកម្មជាច្រើនតាមយន្តការនេះ ឧទាហរណ៍ គូភាគីទាំងសងខាងបានសំរេចគោលបំណងខ្លះ ប៉ុន្តែគ្មានគូភាគីណាមួយបានទទួលអ្វីៗទាំងអស់ដែលគេចង់បាននោះទេ ។ រដ្ឋាភិបាលអាចយល់ឃើញថា ការបញ្ចប់ទំនាស់បែបនេះ នឹងមានផលប្រយោជន៍ល្អ ដូចជា ការធ្វើអោយស្ថានការណ៍ធូរស្រាល ការបង្កើតអោយមានរូបភាពថា "សមរម្យ" ឬក៏ដុសខាត់រូបភាពរបបនេះ លើផ្ទៃអន្តរជាតិ ។ ដូច្នេះ ជាការសំខាន់គេត្រូវប្រុងប្រយ័ត្ន ក្នុងការជ្រើសរើសយកបញ្ហាដែលគេអាចទទួលដោះស្រាយ តាមយន្តការ ការយោគយល់នេះ ។ ការតស៊ូដើម្បីរំលំរបបផ្តាច់ការមិនមែនជាបញ្ហាបែបនេះទេ ។

ការតស៊ូអហិង្សាអាចមានកំរិតខ្លាំងក្លាជាងអ្វីដែលយន្តការប្តូរក្រុម ឬក៏ការយោគយល់ បានបង្ហាញអោយគេឃើញ។ ការមិនសហការនិងការរើបម្រះរបស់ប្រជាពលរដ្ឋក៏អាចផ្លាស់ប្តូរស្ថានការណ៍សង្គម និងនយោបាយ ជាពិសេស ទំនាក់ទំនងអំណាចដែលអាចធ្វើអោយមានការខូចខាតដល់សមត្ថភាពរបស់ពួកផ្តាច់ការ ក្នុងការគ្រប់គ្រងកិច្ចការ សេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយរវាងរដ្ឋាភិបាលនិងសង្គម ។ កងកំលាំងយោធារបស់ពួកផ្តាច់ការ ប្រហែលជាចុះខ្សោយ គេលែងទុកចិត្តបាន រហូតដល់ពួកនោះលែងធ្វើតាមបញ្ជា មិនព្រមបង្ក្រាបពួកតស៊ូ ។ ថ្វីបើពួកមេដឹកនាំផ្តាច់ការស្ថិតនៅក្នុងតំណែងដដែល ហើយនៅតែប្រកាន់ខ្ជាប់យកគោលបំណងដើមរបស់គេ លទ្ធភាពរបស់គេក្នុងការធ្វើអ្វីមួយអោយមានប្រសិទ្ធភាព បានត្រូវគេដកហូតចេញ ។ នេះគឺជាអ្វីដែលគេហៅថា *ការបង្ខំអហិង្សា* ។

នៅក្នុងស្ថានការណ៍ដ៏ខ្លាំងក្លាខ្លះទៀត លក្ខណៈដែលធ្វើអោយមានការបង្ខំដោយអហិង្សាមានជាបន្តទៅទៀត ។ ក្នុងខណៈនោះ ពួកដឹកនាំផ្តាច់ការបាត់បង់នូវលទ្ធភាពចាត់ចែង ហើយរចនាសម្ព័ន្ធរបស់គេក៏ដួលរលំ ។ ការមិនសហការ និងការរើបម្រះនៃពួកតស៊ូ មានប្រសិទ្ធភាពពេញលេញ រហូតដល់កំរិតមួយដែលធ្វើអោយ

ពួកផ្តាច់ការពុំអាចគ្រប់គ្រងគេបានទាល់តែសោះ ។ រដ្ឋបាលរបស់ពួកផ្តាច់ការបដិសេធមិនព្រមធ្វើតាមបញ្ជាថ្នាក់ដឹកនាំ ។ ទាហាន និងប៉ូលិសរបស់ពួកផ្តាច់ការនាំគ្នាបះបោរ ។ ប្រជាពលរដ្ឋ ឬអ្នកដែលធ្លាប់គាំទ្ររបបផ្តាច់ការ ប្រកាសមិនទទួលស្គាល់ពួកដឹកនាំផ្តាច់ការ ដោយអះអាងថា ពួកនេះពុំមានសិទ្ធិគ្រប់គ្រងទាល់តែសោះ ។ ដូច្នេះ ជំនួយ និងការធ្វើតាមបញ្ជាពីមុនក៏អស់មានទៅដែរ ។ យន្តការទីបួននៃការប្រែប្រួល *ការបែកខ្ញែក* នៃប្រព័ន្ធផ្តាច់ការមានលក្ខណៈពេញលេញ ដែលធ្វើអោយរបបផ្តាច់ការគ្មានទាំងកំលាំងសំរាប់ចុះញ៉ម ។ របបនេះបានមកដល់ពេលដួលរលំបែកខ្ញែក ។

ក្នុងការរៀបចំអោយមានយុទ្ធសាស្ត្រសំរាប់ការរំដោះ គេគួរតែចងចាំយន្តការទាំងបួននេះ ។ ជួនកាលយន្តការទាំងនេះចាប់ដំណើរការដោយឯកឯង ។ ប៉ុន្តែការជ្រើសរើសយកយន្តការមួយឬច្រើន មកធ្វើជាគោលសំរាប់ការផ្លាស់ប្តូរនៅក្នុងទំនាស់ នឹងអាចធ្វើអោយគេមានលទ្ធភាពរៀបចំជាយុទ្ធសាស្ត្រពិសេស សំរាប់អនុវត្ត ។ ការជ្រើសរើសយកយន្តការណាមួយ នឹងអាស្រ័យទៅលើកត្តាជាច្រើន មានជាអាទិ៍ កំរិតអំណាចនៃក្រុមទាំងឡាយដែលប្រកួតគ្នា ឥរិយាបថ ហើយនិងគោលបំណងនៃក្រុមដែលធ្វើការតស៊ូអហិង្សា ។

## ឥទ្ធិពលប្រជាធិបតេយ្យនៃនយោបាយរើបម្រះ

ផ្ទុយទៅនឹងអំពើហិង្សា ដែលពង្រឹងអំណាចមនុស្សតែមួយក្រុម ការប្រើមធ្យោបាយតស៊ូអហិង្សា នឹងធ្វើអោយសង្គមនយោបាយ មានលក្ខណៈប្រជាធិបតេយ្យ ។

ផ្នែកមួយនៃឥទ្ធិពលប្រជាធិបតេយ្យនេះ មានលក្ខណៈ ដែលមិនអនុញ្ញាតអោយមានអំពើឃោរឃៅ ។ គឺថា ផ្ទុយទៅនឹងមធ្យោបាយយោធា មធ្យោបាយអហិង្សានេះ ពុំបានផ្តល់នូវឧបករណ៍សំរាប់ជិះជាន់អ្នកនៅក្រោមបញ្ជារបស់គណៈដឹកនាំដែលគេអាចបង្វិលអោយប្រឆាំងនឹងប្រជាពលរដ្ឋ ដើម្បីបង្កើតឬបន្តរបបផ្តាច់ការនោះទេ។ ពួកអ្នកដឹកនាំចលនានយោបាយរើបម្រះ អាចប្រើឥទ្ធិពលនិងដាក់សំពាធទៅលើអ្នកដើរតាម ប៉ុន្តែគេមិនអាចចាប់អ្នកទាំងនោះទៅដាក់គុក ឬប្រហារជីវិត

នៅពេលដែលគេជំទាស់ ឬក៏គេជ្រើសយកមេដឹកនាំឯទៀតនោះឡើយ ។

ផ្នែកមួយទៀតនៃឥទ្ធិពលប្រជាធិបតេយ្យនេះគឺមានលក្ខណៈវិជ្ជមាន ។ គឺមានន័យថា ការតស៊ូអហិង្សានឹងផ្ដល់ដល់ប្រជាពលរដ្ឋនូវមធ្យោបាយតស៊ូមួយ ដែលគេអាចយកទៅប្រើដើម្បីការពារសេរីភាពរបស់គេ តទល់នឹងរបបផ្ដាច់ការណាមួយ ។ ខាងក្រោមនេះ គឺជាឥទ្ធិពលប្រជាធិបតេយ្យល្អមួយចំនួននៃការតស៊ូអហិង្សា ៖

- បទពិសោធន៍ក្នុងការតស៊ូអហិង្សានាំអោយប្រជាពលរដ្ឋមានការទុកចិត្តទៅលើខ្លួនឯង ក្នុងការតទល់ជាមួយនឹង ការគំរាមនិងសមត្ថភាពបង្ក្រាបទាំងហិង្សា ។
- ការតស៊ូអហិង្សាផ្ដល់នូវមធ្យោបាយសំរាប់ការមិនធ្វើសហការនិងការរើបម្រះ ដែលប្រជាពលរដ្ឋអាចប្រើ សំរាប់ទប់ទល់នឹងការត្រួតត្រាដោយគ្មានប្រជាធិបតេយ្យ ពីសំណាក់របបផ្ដាច់ការណាមួយ ។
- នៅចំពោះមុខការគ្រប់គ្រងតាមការជិះជាន់ គេអាចប្រើការតស៊ូអហិង្សា សំរាប់ហាត់រៀនអនុវត្តសេរីភាពប្រជាធិបតេយ្យ ដូចជាសេរីភាពខាងការនិយាយ សេរីភាពខាងការផ្សព្វផ្សាយ អង្គការឯករាជនិងសេរីភាពនៃការប្រជុំគ្នា ។
- ដូចដែលបានវែកញែកពីលើ ការតស៊ូអហិង្សាអាចជាជំនួយយ៉ាងខ្លាំងដល់ការរស់រានមានជីវិត ការបង្កើតឡើងវិញ និងការពង្រឹងនៃក្រុមឯករាជ និងស្ថាប័ននានានៃសង្គមមនុស្ស ។ ទាំងនេះសុទ្ធតែមានផលប្រយោជន៍ សំរាប់លទ្ធិប្រជាធិបតេយ្យ ដោយសារកត្តាទាំងនេះ មានលទ្ធភាពប្រមូលផ្ដុំអំណាចប្រជាពលរដ្ឋ ហើយដាក់កំរិតទៅលើអំណាចរបស់ពួកណាដែលចង់ក្លាយទៅជាពួកផ្ដាច់ការ ។
- ការតស៊ូអហិង្សាអាចផ្ដល់ជាមធ្យោបាយ ដែលប្រជាពលរដ្ឋអាចប្រើដើម្បីបញ្ចេញអំណាចប្រឆាំងនឹងការជិះជាន់ តាមរយៈសកម្មភាពប៉ូលិសនិងយោធានៃរដ្ឋាភិបាលផ្ដាច់ការ ។
- ការតស៊ូអហិង្សាអាចផ្ដល់ជាវិធានការផ្សេងៗ ដែលប្រជាពលរដ្ឋ

និងស្ថាប័នឯករាជ អាចប្រើប្រាស់ ដើម្បីជាប្រយោជន៍ដល់លទ្ធិប្រជាធិបតេយ្យ ទៅបន្ថយឬកាត់ផ្តាច់ប្រភពអំណាចនៃអ្នកដឹកនាំ ដែលជាការគំរាមកំហែងដល់លទ្ធភាពពួកដឹកនាំដែលចង់បន្តការជិះជាន់ ។

# ភាពស្មុគស្មាញនៃការតស៊ូអហិង្សា

ដូចដែលយើងបានដឹងអំពីការវែកញែកនេះរួចហើយ ការតស៊ូអហិង្សា គឺជាមធ្យោបាយដ៏ស្មុគស្មាញ សំរាប់សកម្មភាពសង្គមមនុស្ស ដែលពាក់ព័ន្ធទៅនឹងវិធីជាច្រើន ទៅយន្តការសំរាប់ការប្រែប្រួលមួយចំនួន ហើយនិងការតំរូវអោយមានឥរិយាបថច្បាស់លាស់មួយចំនួន ។ ដើម្បីអោយមានប្រសិទ្ធភាព ជាពិសេស នៅពេលដែលគេតទល់ជាមួយនឹងរបបផ្តាច់ការ នយោបាយរើបម្រះតំរូវអោយមានផែនការ និងការរៀបចំខ្លួនអោយបានហ្មត់ចត់ ។ អ្នកចូលរួមទាំងឡាយត្រូវយល់អំពីអ្វីដែលគេត្រូវធ្វើ ។ ធនធានដែលគេត្រូវការក៏ត្រូវតែមាន ។ ពួកអ្នករៀបចំយុទ្ធសាស្រ្ត ត្រូវធ្វើការវិភាគ រិះរកមធ្យោបាយធ្វើអោយការតស៊ូអហិង្សានេះមានប្រសិទ្ធភាពខ្លាំងជាទីបំផុត ។ ឥឡូវនេះ យើងបង្វែរការយកចិត្តទុកដាក់របស់យើងទៅរកកត្តាដ៏សំខាន់ចុងក្រោយនេះ ៖ សេចក្តីត្រូវការអោយមានការរៀបចំផែនការយុទ្ធសាស្រ្ត ។

# ជំពូកទី៦

# សេចក្តីត្រូវការអោយមានផែនការយុទ្ធសាស្ត្រ

យុទ្ធនាការនយោបាយរើបម្រះប្រឆាំងនឹងរបបផ្តាច់ការ អាចផ្តើមឡើងទៅតាមបែបបទមួយចំនួន ។ ក្នុងអតីតកាល ការតស៊ូទាំងឡាយស្ទើរតែពុំមានការរៀបចំ ហើយកើតមានឡើងដោយចៃដន្យ ។ ការកើតទុក្ខមិនសុខចិត្តជាក់ស្តែង ដែលបាននាំទៅអោយមានសកម្មភាពប្រឆាំង មានលក្ខណៈច្រើនប្រភេទ ប៉ុន្តែជារឿយៗ មានអំពើឃោរឃៅ ការចាប់ខ្លួន ឬការសំលាប់មនុស្សដែលគេគោរព ផែនការឬក៏ការបញ្ជាអោយបង្រ្កាប ការខ្វះស្បៀងអាហារ ការប្រមាថជំនឿសាសនា ឬក៏ថ្ងៃខួបនៃព្រឹត្តិការណ៍ណាមួយខាងលើនេះ ។ ជួនកាល របបផ្តាច់ការប្រព្រឹត្តអំពើណាមួយដែលធ្វើអោយពលរដ្ឋក្តៅក្រហាយ ហើយគេក៏នាំគ្នាផ្តើមធ្វើសកម្មភាព ដោយពុំដឹងថាការបះបោរនោះនឹងត្រូវចប់តាមបែបណា ។ ក្នុងពេលខ្លះទៀត បុគ្គលដ៏ក្លាហានម្នាក់ ឬក៏មនុស្សមួយក្រុមតូចអាចចាប់ផ្តើមធ្វើសកម្មភាពមួយ ដែលទាក់ទាញបានការគាំទ្រយ៉ាងខ្លាំង ។ អ្នកឯទៀតអាចសំគាល់ឃើញថា ការកើតទុក្ខមិនសុខចិត្តណាមួយនោះ ក៏ជាបទពិសោធន៍អាក្រក់ដែលគេបានឆ្លងកាត់ដែរ ម្ល៉ោះហើយ គេក៏អាចចូលរួមក្នុងការតស៊ូនោះទៅ ។ ជួនកាល ការអំពាវនាវអោយមានការប្រឆាំងនឹងអ្វីមួយ ជាពិសេស ពីសំណាក់មនុស្សមួយក្រុមតូច ឬក៏មនុស្សម្នាក់អាចទាក់ទាញការគាំទ្រដ៏ធំធេង ដែលគេស្មានមិនដល់ ។

នៅពេលដែលការឆ្លើយតបតភ្លាមៗបែបនេះ មានលក្ខណៈល្អប្រសើរខ្លះនោះ

ការនេះជារឿយៗមានគុណវិបត្តិមួយចំនួន ។ ជាញឹកញាប់ ក្រុមតស៊ូប្រជាធិបតេយ្យ ពុំបានគិតគូរអោយបានដិតដល់ អំពីការតបតដ៏ឃោរឃៅនៃរបបផ្ដាច់ការទេ ម៉្លោះហើយ គេរងគ្រោះយ៉ាងដំណំ ហើយការតស៊ូក៏រលំទៅដែរ ។ ជួនកាល ការដែលគ្មានផែនការគ្រោងទុកជាមុនរបស់ពួកប្រជាធិបតេយ្យ បានបណ្ដាលអោយការសំរេចចិត្តសំខាន់ៗកើតឡើងជាយថាហេតុ ដែលនាំទៅរកផលវិបាកយ៉ាងខ្លាំង ។ សូម្បីតែនៅពេលដែលរបបជិះជាន់បានត្រូវដួលរលំ ការដែលគ្មានការរៀបចំជាផែនការអំពីបែបបទប្ដូរទៅរកលទ្ធិប្រជាធិបតេយ្យ បាននាំទៅអោយរបបផ្ដាច់ការថ្មីមួយទៀតកើតមានឡើង ។

# ការរៀបចំជាផែនការជាក់ស្ដែង

នៅពេលអនាគត សកម្មភាពប្រជាពលរដ្ឋដែលគ្មានការគ្រោងទុក នឹងច្បាស់ជាដើរតួសំខាន់ក្នុងការបះបោរប្រឆាំងនឹងរបបផ្ដាច់ការ ។ ប៉ុន្តែ ឥឡូវនេះគេអាចគិតគូរ អំពីមធ្យោបាយនានាដែលមានប្រសិទ្ធភាពជាទីបំផុតដើម្បីរំលំរបបផ្ដាច់ការ វិភាគមើលពេលវេលាដែលស្ថានការណ៍នយោបាយនិងអារម្មណ៍ប្រជាពលរដ្ឋនឹងឡើងដល់កំរិត និងជ្រើសរើសរបៀបផ្ដើមយុទ្ធនាការ ។ គេត្រូវការអោយមានការគិតគូរដ៏ហ្មត់ចត់ *ដោយផ្អែកទៅលើការវាយតំលៃស្ថានការណ៍ជាក់ស្ដែង* និងអំពីលទ្ធភាពរបស់ប្រជាពលរដ្ឋ ដើម្បីជ្រើសរើសយកមធ្យោបាយណាដែលសមស្របទៅតាមកាលៈទេសៈ ហើយមានប្រសិទ្ធភាពការតស៊ូយកសេរីភាព ។

ប្រសិនបើគេចង់បានសំរេចអ្វីមួយ គេគួរតែរៀបចំជាគំរោងការថាតើគេត្រូវធ្វើសកម្មភាពអ្វីខ្លះ ។ ប្រសិនបើគោលបំណងនោះសំខាន់ដល់កំរិតណា ផលវិបាកនៃបរាជ័យក៏ធ្ងន់ធ្ងរ ហើយការរៀបចំជាផែនការក៏មានសារៈសំខាន់ ទៅតាមកំរិតនោះដែរ ។ ការរៀបចំផែនការយុទ្ធសាស្ត្រ នឹងជួយអោយគេប្រើប្រាស់ធនធានដែលគេអាចប្រមូលបាន ដោយមានប្រសិទ្ធភាពជាទីបំផុត ។ នេះគឺជាផលប្រយោជន៍ពិត ជាពិសេស សំរាប់ចលនាប្រជាធិបតេយ្យ ដែលមានការខ្វះខាតធនធាន ហើយ

និងគ្រោះថ្នាក់ដែលអ្នកគាំទ្រត្រូវប្រឈមមុខ ក្នុងការរំលំរបបផ្តាច់ការដ៏ខ្លាំងក្លា ។ ផ្ទុយទៅវិញ របបផ្តាច់ការជាធម្មតាមានទ្រព្យសម្បត្តិ កំលាំងជាក្រុម ហើយនិងលទ្ធភាពច្រើនក្នុងការប្រើអំពើឃោរឃៅ ។

"ការរៀបចំជាផែនការយុទ្ធសាស្ត្រ" ទីនេះ មានន័យថា ការគិតគូររៀបចំជាសកម្មភាពមួយចំនួន ដែលអាចកែប្រែស្ថានការណ៍បច្ចុប្បន្ន ទៅរកស្ថានការណ៍អនាគតដែលគេចង់បាន ។ សំរាប់ការពិភាក្សានៅពេលនេះ ការនេះមានន័យថាពីរបបផ្តាច់ការទៅអនាគតប្រព័ន្ធប្រជាធិបតេយ្យ ។ ផែនការដើម្បីសំរេចនូវគោលបំណងនេះ ជាធម្មតា មានការរៀបយុទ្ធនាការជាច្រើន ដែលនឹងត្រូវអនុវត្តតាមលំដាប់លំដោយ ហើយនិងការរៀបចំជាសកម្មភាពនានាឯទៀត សំរាប់ពង្រឹងប្រជាពលរដ្ឋនិងសង្គមដែលគេជិះជាន់ ហើយនិងដើម្បីធ្វើអោយរបបផ្តាច់ការចុះខ្សោយ ។ ចូរកត់សំគាល់ថា គោលបំណងនៅពេលនេះ មិនមែនគ្រាន់តែរំលំរបបផ្តាច់ការបច្ចុប្បន្នទេ គឺមានថែមទាំងការរៀបចំអោយមានប្រព័ន្ធប្រជាធិបតេយ្យផងដែរ ។ យុទ្ធសាស្ត្រចំបងមួយដែលដាក់កំរិតគោលដៅ ត្រឹមតែរំលំរបបផ្តាច់ការបច្ចុប្បន្ន អាចមានគ្រោះថ្នាក់ ដោយសាររបបផ្តាច់ការមួយថ្មីអាចកើតមានឡើង ក្រោយពីរបបផ្តាច់ការចាស់ដួលរលំ ។

## ឧបសគ្គក្នុងការរៀបចំផែនការ

អ្នកគាំទ្រសេរីភាពខ្លះនៅក្នុងពិភពលោកនេះ ពុំបានប្រើប្រាស់សមត្ថភាពរបស់គេអោយពេញលេញ ដើម្បីដោះស្រាយបញ្ហា ថាតើគេអាចសំរេចបានការរំដោះតាមបែបណា ។ អ្នកទាំងនោះកម្រ នឹងយល់អំពីសារៈសំខាន់ជាទីបំផុតនៃការរៀបចំផែនការយុទ្ធសាស្ត្រដោយប្រុងប្រយ័ត្ន មុននឹងគេចេញធ្វើសកម្មភាព ។ ដូច្នេះហើយបានជាគេស្ទើរតែពុំបានរៀបចំផែនការយុទ្ធសាស្ត្រនេះទាល់តែសោះ ។

ហេតុអ្វីបានជាមនុស្សដែលមានការយល់ឃើញវែងឆ្ងាយ ក្នុងការទាមទារសេរីភាពនយោបាយមកជូនប្រជាពលរដ្ឋ កម្ររៀបចំអោយមានផែនការយុទ្ធសាស្ត្រ

ដើម្បីសំរេចតាមគោលដៅ ? គឺជាការគួរអោយស្តាយ ជាញឹកញយ មនុស្សជាច្រើន លើសលុបនៅក្នុងក្រុមប្រជាធិបតេយ្យប្រឆាំង ពុំបានយល់ច្បាស់អំពីសេចក្តីត្រូវការ អោយមានការរៀបចំផែនការយុទ្ធសាស្ត្រ ឬក៏ពុំមានទំលាប់រៀនសូត្រខាងការគិតតាម ក្បួនយុទ្ធសាស្ត្រ ។ នេះគឺជាកិច្ចការលំបាក ។ ដោយសារពួកផ្តាច់ការតាមរុកគួនជា ដរាប និងដោយសារការទទួលខុសត្រូវដ៏លើសលុបជារៀងរាល់ពេលវេលា អ្នកដឹក នាំក្រុមតស៊ូ ជារឿយៗ ពុំមានសុវត្ថិភាព ឬពេលវេលា ដើម្បីបណ្តុះបណ្តាលការគិត តាមក្បួនយុទ្ធសាស្ត្រនេះទេ ។ ម្ល៉ោះហើយទំលាប់ធម្មតារបស់គេនោះ គឺគ្រាន់តែ បញ្ចេញប្រតិកម្មទៅលើអ្វីដែលរបបផ្តាច់ការផ្តួចផ្តើម ។ ករណីនេះ ក្រុមប្រឆាំងតែង តែស្ថិតនៅក្នុងស្ថានភាពការពារ រក្សាទុកនូវសេរីភាពដែលបានសំរេចរួចហើយ ឬក៏ អាចទប់បន្ថយល្បឿននៃការត្រួតត្រារបស់ពួកផ្តាច់ការ ឬក៏បង្កបង្កើតជាបញ្ហាសំរាប់ ផែនការថ្មីៗ ដែលរបបផ្តាច់ការដាក់អនុវត្ត ។

បុគ្គលនៅក្រុមខ្លះទៀត ប្រហែលជាមិនយល់អំពីសេចក្តីត្រូវការអោយមាន ផែនការវែងឆ្ងាយទូលំទូលាយមួយ សំរាប់ចលនារំដោះនេះទេ ។ គេមានគំនិតយ៉ាង ងាយស្រួលថា ប្រសិនបើគេគ្រាន់តែប្រកាន់អោយខ្ជាប់នូវគោលបំណងរបស់គេ ហើយ ទ្រាំតស៊ូអោយបានយូរបន្តិចទៅ គេនឹងបានទទួលជោគជ័យតាមបែបណាមួយ ។ អ្នក ខ្លះទៀតសន្មតថា ប្រសិនបើគេគ្រាន់តែរស់នៅទៅតាមគោលការណ៍ និងឧត្តមគតិ របស់គេ នៅចំពោះមុខការលំបាកទាំងឡាយ គេបានធ្វើអ្វីៗទាំងអស់ ដែលគេអាច ធ្វើបានរួចទៅហើយ ។ ការអនុវត្តន៍គោលបំណងមនុស្សធម៌ និងការស្មោះត្រង់ទៅ លើឧត្តមគតិ គឺជាការគួរអោយសរសើរមែនហើយ ប៉ុន្តែនៅមានការខ្វះខាតខ្លាំង ណាស់សំរាប់ការបញ្ចប់របបផ្តាច់ការ និងការទទួលបានសេរីភាព ។

ពួកអ្នកប្រឆាំងនឹងរបបផ្តាច់ការផ្សេងទៀត ប្រហែលជាយល់យ៉ាងងាយថា ប្រសិនបើគេប្រើអំពើហិង្សាអោយបានគ្រប់គ្រាន់ សេរីភាពនឹងមកដល់ ។ ប៉ុន្តែ ដូច ដែលបានកត់សំគាល់រួចមកហើយ ការប្រើអំពើហិង្សា មិនមែនជាការធានាអោយ មានជោគជ័យទេ ។ ជាជាងការរំដោះ មធ្យោបាយហិង្សាអាចនាំទៅរកបរាជ័យ សោកនាដកម្មដ៏សង្វេគ ឬក៏ផលវិបាកទាំងពីរ ។ ក្នុងករណីជាច្រើន របបផ្តាច់ការ

មានលទ្ធភាពច្រើនសំរាប់ការតស៊ូហិង្សា ហើយពួកប្រជាធិបតេយ្យកម្រមានប្រៀប លើពួកផ្តាច់ការខាងកំលាំងយោធាណាស់ ។

នៅមានសកម្មជនមួយចំនួនទៀត ដែលធ្វើសកម្មភាពទៅតាមអ្វីដែលគេមាន អារម្មណ៍ថាគេគួរធ្វើ ។ ប៉ុន្តែមធ្យោបាយទាំងនេះ មិនត្រឹមតែបញ្ជាក់អោយគេឃើញ អំពីការអោយតំលៃទៅលើខ្លួនឯងហួសហេតុពេកទេនោះ គឺ ថែមទាំងពុំបានផ្តល់នូវ ការណែនាំណាមួយ សំរាប់រៀបចំអោយមានគំរោងការចំបង ដើម្បីរំដោះ ។

សកម្មភាពដែលស្ថិតនៅលើ“គំនិតល្អ”របស់បុគ្គលណាម្នាក់នោះ ក៏មានកំរិត តិចតួចដែរ ។ អ្វីដែលគេត្រូវការ គឺសកម្មភាពដែលពឹងផ្អែកទៅលើការគិតគូរយ៉ាង ហ្មត់ចត់ អំពី“ជំហានបន្តបន្ទាប់ទាំងឡាយ” ដែលគេត្រូវការដើម្បីរំលំរបបផ្តាច់ការ ។ ប្រសិនបើគ្មានការវិភាគតាមយុទ្ធសាស្រ្ត អ្នកដឹកនាំការតស៊ូ ជារឿយៗ មិនដឹងថាតើ ជំហានបន្តបន្ទាប់នោះគួរជាអ្វីទេ ពីព្រោះគេពុំបានគិតគូរអោយបានហ្មត់ចត់ អំពី ជំហ៊ានបន្តបន្ទាប់ច្បាស់លាស់ សំរាប់ទៅរកជោគជ័យ ។ ការបែកប្រាជ្ញា និងគំនិត ល្អៗសុទ្ធតែជាកត្តាសំខាន់ ប៉ុន្តែគេត្រូវប្រើកត្តាទាំងនោះ ដើម្បីជំរុញអោយស្ថានភាព យុទ្ធសាស្រ្តកំលាំងប្រជាធិបតេយ្យមានដំណើរការទៅមុខ ។

ដោយគេដឹងយ៉ាងច្បាស់អំពីសកម្មភាពជាច្រើនដែលគេអាចអនុវត្តប្រឆាំងនឹង របបផ្តាច់ការ ហើយដោយសារគេមិនអាចសំរេចថា គេផ្តើមធ្វើអ្វីនៅពេលណានោះ អ្នកខ្លះអោយយោបល់ថា “ចាត់ការធ្វើសកម្មភាពទាំងអស់ក្នុងពេលជាមួយគ្នា” ។ គំនិត នេះប្រហែលជាមានប្រយោជន៍ ប៉ុន្តែគេពុំអាចអនុវត្តបានទេ ជាពិសេស ប្រសិនបើ ចលនាតស៊ូនោះនៅទន់ខ្សោយ ។ លើសពីនេះទៅទៀត វិធានការបែបនេះ ពុំបាន ផ្តល់នូវការណែនាំអំពីទីកន្លែងដែលគេផ្តើម ផ្នែកដែលគេគួរផ្តោតការខំខ្នះខ្នែង ហើយ និងរបៀបប្រើប្រាស់ធនធានដែលគេមិនសូវមាន ។

បុគ្គលនិងក្រុមឯទៀតប្រហែលជាយល់ អំពីការចាំបាច់អោយមានផែនការ ខ្លះ ប៉ុន្តែអ្នកទាំងនោះគិតបានត្រឹមតែផែនការរយៈពេលខ្លី ឬយុទ្ធវិធីគោល ។ គេប្រហែល ជាមិនយល់ថា ផែនការរយៈពេលវែងជាការចាំបាច់ ឬជាការគេអាចធ្វើបានឡើយ ។ ជួនកាល គេប្រហែលជាមិនអាចគិត ហើយវិភាគទៅតាមក្បួនយុទ្ធសាស្រ្ត បណ្តោយ

អោយខួរក្បាលគេរំខានជាញឹកញាប់ដោយបញ្ហាមិនសំខាន់ ហើយជាប់រវល់នឹងតបត ទៅនឹងអំពើតួបដិបក្ស ជាជាងធ្វើសកម្មភាពផ្តួងផ្តើម ។ ដោយសារគេចំណាយថាមពល ច្រើនពេក ទៅលើសកម្មភាពរយៈពេលខ្លី អ្នកដឹកនាំទាំងនោះ ជារឿយៗ ពុំបាន ពិចារណារិះរកវិធានការជាជំរើសឯទៀត ដែលអាចតំរង់ការខ្នះខ្នែងជាទូទៅ ដើម្បី អោយឆាប់ទៅដល់ទីដៅនោះឡើយ ។

ករណីឯទៀតដែលអាចកើតឡើងដែរនោះ គឺចលនាប្រជាធិបតេយ្យខ្លះ មិន ធ្វើផែនការយុទ្ធសាស្ត្រពិស្តារដើម្បីរំលំរបបផ្តាច់ការទេ គេសុខចិត្តផ្តោតអារម្មណ៍ទៅ លើបញ្ហាភ្លាមៗ ដោយសារបុព្វហេតុផ្សេងទៀត ។ ក្នុងចិត្តរបស់គេ គេពុំមានជំនឿ ថា ការខំខ្នះខ្នែងរបស់គេអាចបញ្ចប់របបផ្តាច់ការបានឡើយ ។ ដូច្នេះហើយ ការរៀប ចំជាផែនការសំរាប់គោលបំណងនេះ បានត្រូវគេចាត់ទុកថា ជាការបង្ខាតពេល ឬក៏ ជាការពុំមានប្រយោជន៍ ។ អ្នកដែលតស៊ូដើម្បីសេរីភាព តទល់នឹងរបបផ្តាច់ការ យោរយៅ ជារឿយៗ ពើបប្រទះនឹងកំលាំងយោធានិងប៉ូលិសដ៏សំបើម ដែលធ្វើ អោយគេយល់ថា ពួកផ្តាច់ការអាចធ្វើអ្វីទាំងអស់តាមចំណង់ ។ ដោយគេខ្វះសេចក្តី សង្ឃឹមពិតប្រាកដ អ្នកទាំងនោះ នៅតែតទល់ប្រឆាំងរបបផ្តាច់ការ ដោយសារបុព្វ ហេតុសីលធម៌ ឬប្រវត្តិសាស្ត្រ ។ ថ្វីបើគេមិនទទួលសារភាពក៏ដោយ ប្រហែលជាគេ ពុំដែលទទួលស្គាល់ក្នុងខ្លួនគេផ្ទាល់ថា សកម្មភាពទាំងឡាយហាក់ដូចជាគ្មានសង្ឃឹម ។ ដូច្នេះហើយ ចំពោះអ្នកទាំងនេះ ការរៀបចំផែនការយុទ្ធសាស្ត្រពិស្តារសំរាប់ពេល វែងឆ្ងាយ ពុំមានន័យខ្លឹមសារអ្វីទេ ។

ការពុំបានធ្វើផែនការយុទ្ធសាស្ត្រនេះ ជារឿយៗ ផ្តល់នូវផលវិបាកដ៏ធ្ងន់ធ្ងរ ៖ កំលាំងគេចុះខ្សោយ សកម្មភាពគេពុំមានប្រសិទ្ធភាព ថាមពលខាតបង់ទៅលើបញ្ហា តូចតាច គេមិនប្រើភាពមានប្រៀប ពេលស្ថានការណ៍ហុចអោយ ហើយការធ្វើ ពលិកម្មណាមួយពុំបានផលប្រយោជន៍ ។ ប្រសិនបើពួកប្រជាធិបតេយ្យមិនធ្វើផែនការ តាមយុទ្ធសាស្ត្រទេនោះ គេប្រហែលជាពុំអាចសំរេចបំណងរបស់គេបានឡើយ ។ ការជ្រើសរើសយកសកម្មភាពចំរុះមួយចំនួន ដែលគ្មានផែនការអោយបានត្រឹមត្រូវ នឹងមិនជួយជំរុញអោយការខ្នះខ្នែងតស៊ូមានដំណើរទៅមុខកើតឡើយ ។ ផ្ទុយទៅវិញ

ការនេះប្រហែលជាបណ្តោយអោយរបបផ្តាច់ការបង្កើនការត្រួតត្រានិងអំណាចរបស់គេទៅវិញទេ ។

គឺជាការគួរអោយស្តាយ ពីព្រោះការដែលគេកម្រៀបចំអោយមានជាផែនការសំរាប់រំដោះ អោយបានពិស្តារត្រឹមត្រូវ បានជួយធ្វើអោយរបបផ្តាច់ការបង្ហាញរូបភាពមាំទាំជាងការពិតមែនទែន ។ ពួកនេះអាចមានជីវិតរស់នៅរាប់ឆ្នាំ ឬក៏រាប់ទសវត្សលើសពីរយៈពេលដែលគេគួរនឹងរស់ ។

# ពាក្យពេចន៏បួនសំខាន់ៗក្នុងការធ្វើផែនការយុទ្ធសាស្ត្រ

ដើម្បីជួយអោយយើងគិតតាមក្បួនយុទ្ធសាស្ត្រ ការយល់អោយច្បាស់អំពីនិយមន័យនៃពាក្យជាមូលដ្ឋានបួន គឺជាការចាំបាច់ ។

*យុទ្ធសាស្ត្រចំបង :* គឺជាគោលគំនិត ដែលដើរតួជាកត្តាទំនាក់ទំនង និងចាត់ចែងអំពីការប្រើប្រាស់ធនធាន ដែលក្រុមមួយមានទាំងអស់ (សេដ្ឋកិច្ច មនុស្សទឹកចិត្ត នយោបាយ និងអង្គភាពនានាជាដើម) សំរាប់សំដៅទៅរកការសំរេចបំណងនៅក្នុងទំនាស់មួយ ។

យុទ្ធសាស្ត្រចំបង ជាមួយនឹងការយកចិត្តទុកដាក់ទៅលើគោលបំណងរបស់ក្រុម និងធនធាន សំរេចជ្រើសរើសយកវិធានការ (ដូចជា ការធ្វើសង្គ្រាមយោធាតាមបែបសាមញ្ញធម្មតា ឬក៏ជាការតស៊ូអហិង្សា) សំរាប់អនុវត្តក្នុងការដោះស្រាយទំនាស់ ។ ក្នុងការធ្វើផែនការយុទ្ធសាស្ត្រចំបងនេះ អ្នកដឹកនាំក្រុមតស៊ូ ត្រូវវាយតម្លៃនិងធ្វើផែនការថា តើគេនឹងដាក់សំពាធ និងឥទ្ធិពលបែបណាទៅលើគូបដិបក្ស ។ លើសពីនេះទៅទៀត យុទ្ធសាស្ត្រចំបង មានរួមទាំងការសំរេចចិត្តអំពីកាលៈទេសៈសមស្របនិងការកំណត់ពេលវេលា សំរាប់ផ្តើមយុទ្ធនាការដំបូង និងបន្តបន្ទាប់ ។

យុទ្ធសាស្ត្រចំបងរៀបចំជាគ្រឹះ សំរាប់ជ្រើសរើសយុទ្ធសាស្ត្រខ្ញីៗបន្ថែមទៀតសំរាប់ការតស៊ូ ។ យុទ្ធសាស្ត្រចំបងក៏សំរេចដែរ អំពីការបែងចែកកិច្ចការទៅក្រុមណាមួយ និងបែងចែកធនធានអោយគេយកទៅប្រើប្រាស់សំរាប់ការតស៊ូនេះ ។

*យុទ្ធសាស្ត្រ* : គឺជាគំនិតអំពីរបៀបយកជោគជ័យសំរាប់គោលបំណងណាមួយ នៅក្នុងកិច្ចតស៊ូ តាមការអនុវត្តន៍ក្នុងវង្វង់យុទ្ធសាស្ត្រចំបង ដែលគេជ្រើសរើស ។ យុទ្ធសាស្ត្រមានការពាក់ព័ន្ធទៅនឹងការសំរេចចិត្ត ថាតើគេគួរបើកការប្រយុទ្ធណាមួយដែរឬទេ នៅពេលណា តាមវិធីបែបណា ហើយនិងរបៀបធ្វើអោយមានប្រសិទ្ធភាពជាអតិបរិមា ក្នុងការតស៊ូដើម្បីអ្វីមួយនៅទីបញ្ចប់ ។ គេបានប្រៀបធៀបយុទ្ធសាស្ត្រទៅនឹងគំនិតរបស់សិល្បករនៅក្នុងខួរក្បាល ឯផែនការយុទ្ធសាស្ត្រ ជាគំនូសរបស់ស្ថាបត្យករនៅលើក្រដាស ។[១២]

យុទ្ធសាស្ត្រអាចរាប់បញ្ចូលការខ្នះខ្នែងបង្កើតអោយមានស្ថានការណ៍យុទ្ធសាស្ត្រដ៏មានប្រយោជន៍ រហូតដល់កំរិតមួយដែលគូបដិបក្សអាចមើលឃើញយ៉ាងច្បាស់ថាការតទល់គ្នាដោយចំហ នឹងនាំអោយគេបរាជ័យ ម៉្លោះហើយ គេចុះចាញ់ដោយពុំចាំបាច់តតាំង ។ ប្រសិនបើគេនៅតែចង់តទល់ ស្ថានការយុទ្ធសាស្ត្រដ៏ល្អនោះ នឹងច្បាស់ជាជួយអោយអ្នកប្រឆាំងឈ្នះក្នុងការតស៊ូ ។ យុទ្ធសាស្ត្រក៏ពាក់ព័ន្ធផងដែរជាមួយនឹងការធ្វើយ៉ាងណា ដើម្បីយកជ័យជំនះដែលគេបានទទួលហើយនោះ ទៅប្រើប្រាស់ជាបន្តទៀត ។

សំរាប់ដំណើរនៃការតស៊ូ ផែនការយុទ្ធសាស្ត្រ គឺជាគំនិតគ្រឹះអំពីរបៀបពង្រីកបំបែកចេញជាយុទ្ធនាការ និងអំពីថាតើផ្នែកនីមួយៗទាំងនោះ ចូលរួមស៊ីសង្វាក់គ្នាបែបណា ដើម្បីជំរុញទៅរកការសំរេចគោលបំណងរួម ។ ការនេះទាក់ទងទៅនឹងការប៉ិនប្រសប់ក្នុងការចាត់តាំងក្រុមសកម្ម អោយអនុវត្តប្រតិបត្តិការតូចៗជាបន្ត ។ ការធ្វើផែនការយុទ្ធសាស្ត្រដែលល្អ ត្រូវគិតគូរអំពីសេចក្តីត្រូវការ ដើម្បីជោគជ័យក្នុងការអនុវត្តន៍មធ្យោបាយណាមួយក្នុងការតស៊ូ ។ មធ្យោបាយនីមួយៗមានសេចក្តីត្រូវការខុសពីគ្នា ។ ប៉ុន្តែ ការគ្រាន់តែបំពេញ“សេចក្តីត្រូវការ” នេះពុំទាន់គ្រប់គ្រាន់ទេ ដើម្បីអោយច្បាស់ថាបានជោគជ័យ ។ គេត្រូវការមានកត្តាផ្សេងៗទៀតជាបន្ថែម ។

ក្នុងការរៀបចំជាយុទ្ធសាស្ត្រ ពួកប្រជាធិបតេយ្យ ត្រូវកំណត់គោលបំណង

---

[១២] រូបឺត ហិលវ៊ី (Robert Helvey) ទាក់ទងដោយផ្ទាល់ថ្ងៃ១៩ខែសីហាឆ្នាំ១៩៩៣ ។

នានាអោយច្បាស់លាស់ ហើយសំរេចថា តើគេនឹងវាស់កំរិតប្រសិទ្ធភាពនៃការខំខ្នះខ្នែងដើម្បីជោគជ័យនោះ តាមបែបណា ។ ការធ្វើបែបនេះ នឹងអនុញ្ញាតអោយអ្នកយុទ្ធសាស្ត្រដឹងច្បាស់អំពីអ្វីដែលគេត្រូវការ ដើម្បីសំរេចគោលបំណងនីមួយៗ ។ ការតំរូវអោយមានភាពច្បាស់លាស់បែបនេះ ក៏ជាកត្តាដ៏សំខាន់ក្នុងការរៀបចំផែនការ យុទ្ធវិធីនោះដែរ ។

គេប្រើយុទ្ធវិធីនិងវិធានការ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ ។ *យុទ្ធវិធី* ទាក់ទងទៅនឹងការប្រើប្រាស់កំលាំងក្រុមយ៉ាងប៉ិនប្រសប់ ដើម្បីទាក់ទាញយកប្រៀប នៅក្នុងស្ថានការណ៍តូចណាមួយ ។ យុទ្ធវិធី គឺជាសកម្មភាពខ្លីមួយ ដែលគេប្រើសំរាប់អោយបានសំរេចគោលបំណងតូចមួយ ។ ការជ្រើសរើសយកយុទ្ធវិធីណាមួយ អាស្រ័យទៅលើគំនិតថា តើគេអាចប្រើប្រាស់ធនធានដែលគេមានបែបណា ដើម្បីអោយមានប្រសិទ្ធភាព ក្នុងដំណាក់ការដ៏ខ្លីណាមួយ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនេះ ។ ដើម្បីអោយមានប្រសិទ្ធភាពខ្ពស់ គេត្រូវជ្រើសរើសយុទ្ធវិធី និងរៀនរបៀបអនុវត្តណាដែលអាចជួយអោយគេសំរេចបាន នូវគោលបំណងយុទ្ធសាស្ត្រ ។ ផលដែលបានពីយុទ្ធវិធីដែលមិនជួយអោយគេបានជោគជ័យក្នុងគោលបំណងយុទ្ធសាស្ត្រ ប្រហែលជា នៅទីបំផុត ក្លាយទៅជាការខាតបង់ថាមពលក្រុម ។

ដូច្នេះ យុទ្ធវិធីពាក់ព័ន្ធនឹងសកម្មភាពដ៏ខ្លីដែលស្របទៅនឹងយុទ្ធសាស្ត្រទូទៅក៏ដូចជា យុទ្ធសាស្ត្រដែលសមស្របទៅនឹងយុទ្ធសាស្ត្រចំបងដែរ ។ យុទ្ធវិធីតែងតែភ្ជាប់ទៅនឹងការប្រយុទ្ធផ្ទាល់ នៅពេលដែលយុទ្ធសាស្ត្ររួមបញ្ចូលទាំងគំនិតទូលំទូលាយ ។ គេយល់ថា យុទ្ធវិធីគ្រាន់តែជាផ្នែកមួយនៃយុទ្ធសាស្ត្រទូទៅសំរាប់សង្គ្រាម ឬក៏ជាវគ្គមួយនៃយុទ្ធនាការណាមួយតែប៉ុណ្ណោះ ។ ប្រៀបធៀបទៅនឹងយុទ្ធសាស្ត្រ គេប្រើយុទ្ធវិធីសំរាប់ពេលខ្លីជាង ឬក៏ក្នុងផ្នែកតូចជាង (ទីកន្លែង ស្ថាប័នណាមួយ ជាដើម) ឬក៏ជាមួយមនុស្សតិច ឬក៏សំរាប់សំរេចវត្ថុបំណងបន្ទាប់បន្សំ ។ នៅក្នុងសកម្មភាពអហិង្សា ការខុសគ្នារវាងគោលបំណងរបស់យុទ្ធវិធី និងគោលបំណងរបស់យុទ្ធសាស្ត្រប្រហែលជាអាចអាស្រ័យលើការសំរេចថា តើសកម្មភាពដែលគេជ្រើសរើសមានគោលបំណងតូចឬធំ ។

គេជ្រើសរើសការវាយប្រហារដោយប្រើយុទ្ធវិធី ដើម្បីជួយអោយបានសំរេច គោលបំណងយុទ្ធសាស្ត្រ ។ ការប្រយុទ្ធដោយប្រើយុទ្ធវិធី គឺជាឧបករណ៍របស់អ្នកយុទ្ធសាស្ត្រសំរាប់បង្កើតអោយមានស្ថានភាពល្អប្រសើរ សំរាប់ការវាយប្រហារផ្តាច់ព្រ័ត្រទៅលើបដិបក្ស ។ ដូច្នេះ អ្នកដែលទទួលខុសត្រូវខាងរៀបចំផែនការ និងអនុវត្តយុទ្ធវិធី ត្រូវតែមានទេពកោសល្យខាងការវាយតម្លៃស្ថានការណ៍ ហើយជ្រើសរើសវិធានការដ៏សមស្របជាទីបំផុតសំរាប់យុទ្ធនាការ ។ អ្នកទាំងឡាយឯទៀតដែលចូលរួមក្នុងប្រតិបត្តិការ ត្រូវទទួលការបណ្តុះបណ្តាលអំពីការអនុវត្តន៍បែបបទ ដែលគេជ្រើសរើស និងវិធានការទាំងនោះ ។

*វិធានការ :* និយាយអំពីអាវុធ ឬក៏ឧបករណ៍សំរាប់សកម្មភាពណាមួយ ។ ក្នុងករណីបែបបទ សំរាប់ការតស៊ូអហិង្សា ឧបករណ៍ទាំងនោះមានជាអាទិ៍ សកម្មភាពមួយចំនួន (ដូចជា បែបបទជាច្រើននៃការធ្វើកូដកម្ម ពហិការ ការមិនធ្វើសហការនយោបាយ) ដែលបានរៀបរាប់ក្នុងជំពូកទី ៥ ។ (សូមមើលឧបសម្ព័ន្ធ) ។

ការរៀបចំអោយមានផែនការយុទ្ធសាស្ត្រមួយ ដែលមានការទទួលខុសត្រូវ និងមានប្រសិទ្ធភាព អាស្រ័យទៅលើការគិតគូរយ៉ាងហ្មត់ចត់ក្នុងការជ្រើសរើសយកយុទ្ធសាស្ត្រចំបង យុទ្ធសាស្ត្រ យុទ្ធវិធី និងវិធានការ ។

មេរៀនសំខាន់នៃការពិភាក្សាវែកញែកនេះ គឺគេត្រូវប្រើបញ្ញាក្នុងការធ្វើផែនការយុទ្ធសាស្ត្រ ដើម្បីរើបម្រះចេញពីរបបផ្តាច់ការ ។ ការដែលគេពុំបានធ្វើផែនការតាមបែបឈ្លាសវៃ អាចនាំទៅរកមហន្តរាយ នៅពេលដែលការប្រើប្រាស់ប្រាជ្ញាដ៏មានប្រសិទ្ធភាព ក្នុងការរៀបចំជាផ្លូវតាមយុទ្ធសាស្ត្រដោយប្រើប្រាស់ធនធានដែលគេមានដ៏ប៉ិនប្រសប់ នឹងជំរុញអោយសង្គមឈានទៅរកសេរីភាព និងប្រជាធិបតេយ្យ ។

# ជំពូកទី៧

# ការរៀបចំជាយុទ្ធសាស្ត្រ

ដើម្បីធ្វើអោយបានជ័យជំនះកាន់តែច្បាស់ អ្នកដឹកនាំក្រុមតស៊ូត្រូវតែរៀបចំអោយមានផែនការយ៉ាងពិស្តារ ដែលអាចពង្រឹងស្មារតីអ្នករងគ្រោះ ដែលអាចធ្វើអោយរបបផ្តាច់ការចុះខ្សោយ និងរលំ ហើយកសាងប្រជាធិបតេយ្យដែលមាំទាំ ។ ដើម្បីសំរេចបានផែនការបែបនេះ គេត្រូវអោយមានការវិភាគស្ថានការណ៍អោយបានច្បាស់លាស់ និងជ្រើសរើសមធ្យោបាយនានា សំរាប់សកម្មភាពដ៏មានប្រសិទ្ធភាព ។ ជាមួយនឹងលទ្ធផលនៃការវិភាគដ៏ហ្មត់ចត់នេះ គេនឹងអាចរៀបចំអោយមានយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រសំរាប់យុទ្ធនាការ ដើម្បីអោយបានសំរេចយកសេរីភាព ។ ថ្វីបើពាក់ព័ន្ធគ្នា ការរៀបចំយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រសំរាប់យុទ្ធនាការ ជាវិធីពីរខុសគ្នា ។ ក្រោយពីគេបានរៀបចំជាយុទ្ធសាស្ត្រចំបងហើយ ទើបគេអាចធ្វើផែនការយុទ្ធសាស្ត្រសំរាប់យុទ្ធនាការ ដើម្បីពង្រឹងនិងសំរេចគោលបំណងដែលមានបញ្ជាក់ក្នុងយុទ្ធសាស្ត្រចំបង ។

ការរៀបចំយុទ្ធសាស្ត្រសំរាប់ការតស៊ូ តំរូវអោយគេយកចិត្តទុកដាក់ទៅលើសំនួរ និងកិច្ចការជាច្រើន ។ នៅពេលនេះ យើងនឹងបង្ហាញនូវកត្តាសំខាន់ៗដែលគេត្រូវពិចារណា នៅក្នុងរង្វង់យុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រសំរាប់យុទ្ធនាការ ។ ប៉ុន្តែការរៀបចំផែនការយុទ្ធសាស្ត្រ តំរូវអោយអ្នកធ្វើផែនការសំរាប់ការតស៊ូ មានការយល់ដឹងអំពីស្ថានការណ៍ទំនាស់ ដែលពាក់ព័ន្ធទៅនឹងកត្តាកំលាំងមនុស្ស ប្រវត្តិសាស្ត្រ

រដ្ឋាភិបាល យោធា វប្បធម៌ សង្គម នយោបាយ ចិត្តសាស្ត្រ សេដ្ឋកិច្ច ហើយនិង អន្តរជាតិ ។ គេអាចរៀបចំជាយុទ្ធសាស្ត្របានសំរាប់តែករណីតស៊ូ ហើយនិងមូលដ្ឋាន នៃការតស៊ូដែលមានលក្ខណៈច្បាស់លាស់ ។

ជាការសំខាន់ ដំបូងអ្នកដឹកនាំប្រជាធិបតេយ្យ និងអ្នកធ្វើផែនការយុទ្ធសាស្ត្រ ត្រូវវិភាគអំពីគោលបំណងនានា និងសារៈសំខាន់នៃបុព្វហេតុ ។ តើគោលបំណង ទាំងនេះ សមស្រប ហើយគំរូវអោយមានការតស៊ូដ៏ខ្លាំងក្លាមែនឬ ? ការសំរេចអំពី គោលបំណងមែនទែននៃការតស៊ូ គឺជាការចាំបាច់ ។ យើងបានវែកញែករួចហើយ ថា ការរំលំរបបផ្តាច់ការ ឬក៏ការបណ្តេញមេផ្តាច់ការបច្ចុប្បន្ន ចេញពីអំណាចពុំគ្រប់ គ្រាន់ទេ ។ គោលបំណងនៃការតស៊ូបែបនេះ ត្រូវមានការបង្កើតអោយមានសង្គម សេរី ស្របនឹងគោលការណ៍រដ្ឋាភិបាលប្រជាធិបតេយ្យមួយ ។ ការយល់ច្បាស់អំពី ចំណុចនេះ នឹងមានអានុភាពទៅលើការរៀបចំជាយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រ ជាបន្តបន្ទាប់ងទៀត ។

ជាពិសេស អ្នកធ្វើផែនការយុទ្ធសាស្ត្រ ត្រូវឆ្លើយសំនួរសំខាន់ៗ ដូចជា៖

- តើឧបសគ្គអ្វីដែលរារាំងមិនអោយគេបានទទួលសេរីភាព ?
- តើកត្តាអ្វីខ្លះដែលនឹងជួយអោយបានទទួលសេរីភាព ?
- តើរបបផ្តាច់ការមានចំណុចខ្លាំងណាខ្លះ ?
- តើចំណុចខ្សោយរបស់របបផ្តាច់ការមានអ្វីខ្លះ ?
- តើចំណុចខ្សោយនៃប្រភពអំណាចរបបផ្តាច់ការមានដល់កំរិតណាដែរ ?
- តើចំណុចខ្លាំងនៃក្រុមប្រជាធិបតេយ្យ និងប្រជាពលរដ្ឋជាទូទៅមាន អ្វីខ្លះ ?
- តើក្រុមប្រជាធិបតេយ្យមានចំណុចខ្សោយអ្វីខ្លះ ? ហើយគេដោះស្រាយ ចំណុចខ្សោយទាំងនោះបែបណាទៅ ?
- តើភាគីឯទៀតមានជំហរយ៉ាងណាដែរ ? ភាគីឯទៀតនេះពុំទាន់ពាក់ព័ន្ធ នឹងទំនាស់ទេ ប៉ុន្តែគេប្រហែលជាបានជួយ ឬក៏ប្រហែលជាជួយរបប ផ្តាច់ការ ឬក៏ចលនាប្រជាធិបតេយ្យ ។ ប្រសិនបើដូច្នេះមែន តើគេអាច

ជួយតាមបែបណាដែរ ?

# ការជ្រើសរើសមធ្យោបាយ

នៅក្នុងយុទ្ធសាស្ត្រចំបង អ្នកធ្វើផែនការត្រូវជ្រើសរើសយកមធ្យោបាយតស៊ូសំខាន់ៗ សំរាប់ប្រើប្រាស់ក្នុងទំនាស់ ។ គេត្រូវវិភាគមើលគុណសម្បត្តិ និងការខ្វះខាតនៃជំរើសទាំងឡាយសំរាប់ការតស៊ូ មានជាអាទិ៍ ការច្បាំងតទល់តាមកំលាំងយោធា ការធ្វើសង្គ្រាមឆ្មក់ព្រៃ នយោបាយរើបម្រះ ឬក៏មធ្យោបាយឯទៀត ។

ក្នុងការជ្រើសរើសនេះ អ្នកធ្វើយុទ្ធសាស្ត្រត្រូវពិចារណាសំនួរខ្លះដូចខាងក្រោម ៖ តើពួកប្រជាធិបតេយ្យមានសមត្ថភាពប្រើមធ្យោបាយនេះដែរឬទេ ? តើមធ្យោបាយដែលជ្រើសរើសនេះ នឹងប្រើកំលាំងប្រជាពលរដ្ឋដែលគេជិះជាន់ដែរឬទេ ? តើមធ្យោបាយនេះ ផ្តោតទៅលើចំណុចខ្សោយនៃរបបផ្តាច់ការ ឬក៏ជាការវាយប្រហារទៅលើចំណុចខ្លាំងរបស់គេ ? តើមធ្យោបាយទាំងនោះ នឹងជួយអោយក្រុមប្រជាធិបតេយ្យមានការទុកចិត្តលើខ្លួនឯងកាន់តែខ្លាំង ឬក៏មធ្យោបាយទាំងនោះតំរូវអោយមានការពឹងផ្អែកទៅលើភាគីទីបី ឬក៏ជំនួយពីបរទេស ? តើការប្រើប្រាស់មធ្យោបាយដែលជ្រើសរើសនោះ មានប្រវត្តិបទពិសោធន៍បែបណាខ្លះ ក្នុងការរំលំរបបផ្តាច់ការ ? តើមធ្យោបាយទាំងនោះ នឹងបង្កើនឬក៏បន្ថយការខូចខាត និងមហន្តរាយដែលអាចកើតមានឡើង ក្នុងការប្រឆាំងតទល់នៅថ្ងៃមុខដែរឬទេ ? ប្រសិនបើគេសន្មតថា គេបានជោគជ័យក្នុងការរំលំរបបផ្តាច់ការ តើមធ្យោបាយតស៊ូដែលគេបានជ្រើសរើស នឹងមានឥទ្ធិពលបែបណាទៅលើប្រភេទរដ្ឋាភិបាលថ្មី ដែលនឹងលេចចេញពីការតស៊ូ ? គេត្រូវតែជៀសវាងសកម្មភាពប្រភេទណាមួយ ដែលពុំមានប្រយោជន៍នៅក្នុងយុទ្ធសាស្ត្រចំបងដែលគេរៀបចំឡើង ។

ក្នុងជំពូកមុនៗ យើងបានវែកញែកថា នយោបាយរើបម្រះផ្តល់នូវការមានប្រៀបយ៉ាងខ្លាំង ទៅលើមធ្យោបាយតស៊ូឯទៀត ។ ពួកអ្នកយុទ្ធសាស្ត្រត្រូវពិនិត្យមើលស្ថានការណ៍ទំនាស់របស់គេហើយសំរេច ថាតើ នយោបាយរើបម្រះនឹងផ្តល់នូវចំលើយ

វិជ្ជមានទៅលើសំនួរទាំងឡាយខាងលើនេះដែរឬទេ ។

# ការរៀបចំផែនការដើម្បីលទ្ធិប្រជាធិបតេយ្យ

គេគួរតែចងចាំថា ក្នុងការប្រឆាំងនឹងរបបផ្តាច់ការ គោលបំណងនិងយុទ្ធសាស្ត្រចំបង ពុំមែនមានត្រឹមតែរំលំមេផ្តាច់ការនោះទេ គឺរៀបចំអោយមានប្រព័ន្ធប្រជាធិបតេយ្យមួយ ហើយធ្វើអោយរបបផ្តាច់ការថ្មីមួយទៀតងើបមិនរួច ។ ដើម្បីសំរេចគោលបំណងបែបនេះ មធ្យោបាយដែលគេជ្រើសរើសសំរាប់ការតស៊ូ ត្រូវតែជួយធ្វើអោយមានការប្រែប្រួល ក្នុងការបែងចែកអំណាចនៅក្នុងសង្គម ។ នៅក្រោមរបបផ្តាច់ការប្រជាពលរដ្ឋ និងសង្គមស៊ីវិល មានសភាពទន់ខ្សោយណាស់ ហើយរដ្ឋាភិបាលមានអំណាចខ្លាំងពេក ។ ប្រសិនបើគ្មានការផ្លាស់ប្តូរអោយមានតុល្យភាពអំណាចទេនោះ អ្នកត្រួតត្រាមួយក្រុមទៀត ប្រសិនបើគេចង់ អាចក្លាយទៅជាពួកផ្តាច់ការដូចក្រុមចាស់ ។ ដូច្នេះហើយ បានជាគេមិនស្វាគមន៍“បដិវត្តន៍ព្រះបរមរាជវាំង” ឬក៏រដ្ឋប្រហារទេ ។

នយោបាយរើបម្រះជួយអោយមានការបែងចែកដ៏សមរម្យមួយ នូវអំណាចពិតប្រាកដ តាមរយៈការប្រមូលផ្តុំក្នុងសង្គមមនុស្ស ដើម្បីប្រឆាំងនឹងរបបផ្តាច់ការដូចដែលបានពិភាក្សានៅក្នុងជំពូកទី ៥ ។ វិធីនេះអាចកើតមានឡើងទៅតាមបែបបទមួយចំនួន ។ ការបង្កើនអោយមានសមត្ថភាពតស៊ូអហិង្សាមានន័យថា លទ្ធភាពរបបផ្តាច់ការដើម្បីការជិះជាន់ហិង្សា លែងសូវមានប្រសិទ្ធភាព ក្នុងការគំរាមកំហែងនិងទាក់ទាញអោយមានការចុះញ៉មពីសំណាក់ប្រជាពលរដ្ឋ ។ នៅពេលនោះប្រជាពលរដ្ឋនឹងមានមធ្យោបាយដ៏ខ្លាំងក្លាសំរាប់តទល់ ហើយជួនកាល រារាំងអំណាចមេផ្តាច់ការទៀតផង ។ លើសពីនេះទៅទៀត ការប្រមូលផ្តុំយកកំលាំងប្រជាពលរដ្ឋតាមរយៈនយោបាយរើបម្រះ នឹងពង្រឹងស្ថាប័នឯករាជនានានៅក្នុងសង្គម ។ គេពុំអាចភ្លេចយ៉ាងឆាប់រហ័ស នូវការដែលគេបានបញ្ចេញអំណាចដ៏មានប្រសិទ្ធភាពម្តងរួចមកហើយនោះទេ ។ ចំណេះដឹង និងទេពកោសល្យដែលគេបានទទួលក្នុងការតស៊ូនឹងពង្រឹងប្រជាពលរដ្ឋ មិនបណ្តោយអោយពួកដែលអាចក្លាយទៅជាអ្នកផ្តាច់ការ គ្រប់

គ្រងតាមការសង្កត់សង្កិនបានដោយងាយ ។ ការប្រែប្រួលនៃតុល្យភាពអំណាចបែបនេះ នៅទីបំផុត នឹងប្រហែលជាធ្វើអោយមានការកសាងសង្គមប្រជាធិបតេយ្យមួយដែលរឹងមាំ ។

# ជំនួយពីក្រៅ

ជាផ្នែកមួយនៃការរៀបចំយុទ្ធសាស្ត្រចំបង ការវិភាគទៅលើតួនាទីនៃក្រុមតស៊ូខាងក្នុង និងសំពាធពីខាងក្រៅ ដើម្បីរំលំរបបផ្តាច់ការ គឺជាការចាំបាច់ ។ ក្នុងការវែកញែកនេះ យើងបានពន្យល់រួចហើយថា កំលាំងសំខាន់នៃការតស៊ូត្រូវតែចេញពីផ្ទៃក្នុង ។ ប្រសិនបើគេបានជំនួយអន្តរជាតិ ជំនួយនោះនឹងជំរុញអោយការតស៊ូផ្ទៃក្នុង មានកំរិតខ្លាំងបន្ថែមទៅតាមនោះដែរ ។

ដើម្បីជាការបន្ថែមដ៏គួរសមមួយ គេអាចធ្វើការខ្នះខ្នែងប្រមូលផ្តុំមតិអន្តរជាតិអោយប្រឆាំងនឹងរបបផ្តាច់ការ នៅក្នុងបុព្វហេតុមនុស្សធម៌ សីលធម៌ ឬក៏សាសនា ។ គេអាចខ្នះខ្នែងអោយមានការដាក់ទណ្ឌកម្មទៅលើរបបផ្តាច់ការ ខាងការទូត នយោបាយ និងសេដ្ឋកិច្ច ពីសំណាក់រដ្ឋាភិបាលនានានិងអង្គការអន្តរជាតិ ។ ទណ្ឌកម្មទាំងនោះអាចមានទ្រង់ទ្រាយជាសេដ្ឋកិច្ច ការឈប់ផ្តល់គ្រឿងសញ្ញុធយោធា ការបន្ថយកំរិតទទួលស្គាល់ខាងការទូត ឬក៏ផ្តាច់ចំណងទូតទាំងស្រុង ការហាមឃាត់មិនអោយមានជំនួយសេដ្ឋកិច្ច និងការធ្វើវិនិយោគនៅក្នុងប្រទេសផ្តាច់ការ ការបណ្តេញរដ្ឋាភិបាលផ្តាច់ការពីអង្គការអន្តរជាតិនានា និងពីផ្នែកផ្សេងៗនៃអង្គការសហប្រជាជាតិ ។ លើសពីនេះ គេអាចផ្តល់ជំនួយអន្តរជាតិ ដូចជា ការទ្រទ្រង់ខាងលុយកាក់ និងទូរគមនាគមន៍ទៅអោយពួកប្រជាធិបតេយ្យដោយផ្ទាល់ ។

# ការរៀបចំយុទ្ធសាស្ត្រចំបង

បន្ទាប់ពីការវិភាគមើលស្ថានការណ៍ ការជ្រើសរើសមធ្យោបាយ ហើយនិងការសំរេចអំពីតួនាទីរបស់ជំនួយបរទេសរួចហើយ អ្នករៀបចំយុទ្ធសាស្ត្រចំបង នឹងព្រាងអំពីបែបបទ ដែលគេនឹងប្រើក្នុងការតស៊ូ ។ ផែនការដ៏ទូលំទូលាយនេះ នឹងនិយាយតាំងពីស្ថានការណ៍បច្ចុប្បន្ន ទៅដល់ការរំដោះ និងប្រព័ន្ធប្រជាធិបតេយ្យក្នុងពេលអនាគត ។ ក្នុងការរៀបចំយុទ្ធសាស្ត្រចំបងនេះ អ្នកធ្វើផែនការត្រូវតែសួរខ្លួនឯងនូវសំនួរមួយចំនួន ។ សំនួរទាំងប៉ុន្មានខាងក្រោមនេះ (មានលក្ខណៈមិនទូទៅដូចសំនួរពីមុន) ទាក់ទងនឹងការពិចារណាដែលគេត្រូវការ ក្នុងការរៀបចំយុទ្ធសាស្ត្រចំបង ដើម្បីការតស៊ូតាមរយៈនយោបាយរើបម្រះ ។

- តើពេលណាទៅដែលល្អប្រសើរសំរាប់គេផ្តើមការតស៊ូដែលនឹងមានរយៈពេលយូរអង្វែង ?
- តើប្រជាពលរដ្ឋដែលគេជិះជាន់ អាចពង្រឹងការទុកចិត្តលើខ្លួនឯង និងប្រមូលផ្តុំកំលាំងគ្រប់គ្រាន់ ដើម្បីធ្វើសកម្មភាពតទល់នឹងរបបផ្តាច់ការ យ៉ាងហោចណាស់ក៏មានកំរិតបន្តិចបន្តួចជាលើកដំបូងដែរឬទេ ?
- តើគេអាចតំឡើងលទ្ធភាពរបស់ប្រជាពលរដ្ឋតាមបែបណា សំរាប់ការអនុវត្តន៍មធ្យោបាយមិនធ្វើសហការ និងរើបម្រះ ទៅតាមដំណើរការពេលវេលា និងបទពិសោធន៍ ?
- តើគោលបំណងនៃយុទ្ធនាការខ្លីៗ ជាបន្តបន្ទាប់ មានអ្វីខ្លះ សំរាប់គ្រប់គ្រងសង្គមតាមបែបប្រជាធិបតេយ្យ និងរារាំងរបបផ្តាច់ការ ?
- តើគេមានស្ថាប័នឯករាជ ដែលរួចពីកណ្តាប់ដៃរបបផ្តាច់ការ ហើយដែលគេអាចប្រើក្នុងការតស៊ូដើម្បីសេរីភាពដែរឬទេ ?
- តើស្ថាប័នបែបណាមួយនៅក្នុងសង្គម ដែលគេអាចរំដោះចេញពីការត្រួតត្រារបស់ពួកផ្តាច់ការ ឬក៏ថាតើស្ថាប័នបែបណាដែលគេត្រូវបង្កើតជាថ្មី ដើម្បី

បំពេញសេចក្តីត្រូវការ ហើយនិងបង្កើតអោយមានបរិយាកាសប្រជាធិបតេយ្យ ទោះបីជារបបផ្តាច់ការនៅតែមានជាបន្ត ?

- តើគេអាចពង្រឹងកំលាំងផ្ទៃក្នុងនៃក្រុមអ្នកតស៊ូតាមបែបណា ?
- តើគេអាចបណ្តុះបណ្តាលអ្នកចូលរួមសកម្មភាពតាមបែបណា ?
- តើគេត្រូវការធនធានបែបណាខ្លះ (លុយកាក់ គ្រឿងសម្ភារៈជាដើម) សំរាប់ការតស៊ូពីដើមដល់ចប់ ?
- តើគេអាចប្រើនិមិត្តរូបបែបណាមួយ ដែលមានប្រសិទ្ធភាពជាងគេបំផុត ក្នុងការប្រមូលផ្តុំប្រជាពលរដ្ឋ ?
- តើគេអាចធ្វើអោយប្រភពនៃអំណាចរបបផ្តាច់ការចុះខ្សោយបន្តិចម្តងៗ រហូតដល់អស់តែម្តង តាមមធ្យោបាយប្រភេទណា និងក្នុងដំណាក់ការណាខ្លះ ?
- តើត្រូវធ្វើបែបណា ដើម្បីអោយប្រជាពលរដ្ឋដែលងើបប្រឆាំងតទល់ អាចក្រាញធ្វើការរើបម្រះផង ហើយនិងប្រកាន់ខ្ជាប់នូវវិន័យអហិង្សាផង ?
- តើសង្គមអាចបន្តការងារ ដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់គេនៅក្នុងដំណាក់ការនៃទំនាស់តាមបែបណា ?
- នៅពេលដែលជ័យជំនះកំពុងឈានមកដល់ តើក្រុមតស៊ូប្រជាធិបតេយ្យអាចបន្តការកសាងស្ថាប័នជាមូលដ្ឋាន អោយសង្គមក្រោយរបបផ្តាច់ការតាមបែបណា ដើម្បីធ្វើអោយការឆ្លងពីរបបមួយទៅរបបមួយបានរលូន ?

គេត្រូវតែចងចាំថា មានផែនការច្រើន ដែលគេអាចរៀបចំអនុវត្តឡើង ដើម្បីរើបម្រះពីរបបផ្តាច់ការ ។ ការតស៊ូនីមួយៗ ដើម្បីរំលំរបបផ្តាច់ការនិងរៀបចំជាប្រព័ន្ធប្រជាធិបតេយ្យ នឹងមានលក្ខណៈខុសៗគ្នា ។ ពុំមានស្ថានការណ៍ពីរដូចគ្នាបេះបិទនោះឡើយ ។ របបផ្តាច់ការនីមួយៗ នឹងមានលក្ខណៈពិសេសខ្លះ ហើយសមត្ថភាពរបស់ពលរដ្ឋដែលទាមទារសេរីភាព ក៏មានលក្ខណៈខុសគ្នាដែរ ។ អ្នកធ្វើផែនការយុទ្ធសាស្ត្រចំបងដើម្បីការតស៊ូតាមនយោបាយរើបម្រះ ត្រូវមានការយល់ដឹងអោយបានច្បាស់ មិនត្រឹមតែអំពីស្ថានការណ៍ទំនាស់ណាមួយជាពិសេសទេ គឺគេត្រូវ

យល់ដឹងអំពីមធ្យោបាយដែលគេជ្រើសរើស សំរាប់ធ្វើការតស៊ូនោះទៀតផង ។[១៣]

នៅពេលដែលយុទ្ធសាស្ត្រចំបងសំរាប់ការតស៊ូ បានរៀបចំយ៉ាងហ្មត់ចត់ហើយនោះ គេមានមូលហេតុល្អមួយចំនួន សំរាប់ផ្សព្វផ្សាយអោយគេដឹងអំពីយុទ្ធសាស្ត្រនេះ ។ ចំនួនមនុស្សជាច្រើនដែលគេត្រូវការអោយចូលរួម ប្រហែលជាមានចំណង់និងលទ្ធភាពចូលរួម ប្រសិនបើគេយល់យ៉ាងច្បាស់លាស់អំពីគំនិតជាទូទៅ ហើយនិងការណែនាំ ។ ការដឹងបែបនេះអាចមានឥទ្ធិពលល្អប្រសើរណាស់ទៅលើទឹកចិត្តសំរាប់ការយល់ព្រមចូលរួម និងអនុវត្តទៅតាមគំរោងការ ។ ក្នុងករណីណាក៏ដោយពួកផ្តាច់ការនឹងបានដឹងអំពីយុទ្ធសាស្ត្រចំបងនេះដោយត្រួសៗ ហើយការដឹងបែបនេះអាចធ្វើអោយមេផ្តាច់ការពុំសូវហ៊ានសាហាវឃោរឃៅ ក្នុងការជិះជាន់ប្រជាពលរដ្ឋដោយគេដឹងថា អំពើរបស់គេអាចជះឥទ្ធិពលអាក្រក់តាមផ្លូវនយោបាយមកវិញ ។ ការដឹងអំពីលក្ខណៈសំខាន់ណាមួយនៃយុទ្ធសាស្ត្រចំបងក៏អាចមានអានុភាព នាំអោយមានការមិនសប្បាយចិត្ត និងការរត់ចេញពីរបបផ្តាច់ការដែរ ។

នៅពេលដែលគេព្រមព្រៀងគ្នាអនុវត្តផែនការយុទ្ធសាស្ត្រចំបង ដើម្បីរំលំរបបផ្តាច់ការនិងរៀបចំជាប្រព័ន្ធប្រជាធិបតេយ្យហើយនោះ ជាការចាំបាច់ ក្រុមគាំទ្រប្រជាធិបតេយ្យទាំងឡាយ ត្រូវតែគោរពអនុវត្តតាមគំរោងការ ។ មានតែក្នុងកាលៈទេសៈដ៏កម្រប៉ុណ្ណោះ ដែលការតស៊ូគួរតែប្រែប្រួលពីគំរោងដើម ។ នៅពេលដែលគេមានភស្តុតាងច្បាស់លាស់ថា យុទ្ធសាស្ត្រចំបងដែលគេបានជ្រើសរើសពីមុនមានការយល់ច្រឡំ ឬក៏កាលៈទេសៈនៃការតស៊ូបានប្រែប្រួលយ៉ាងខ្លាំង អ្នកធ្វើផែនការប្រហែលជាត្រូវកែយុទ្ធសាស្ត្រចំបងឡើងវិញ ។ នៅពេលនោះ គេគួរតែ នៅក្រោយ

---

[១៣] សូមអានការសិក្សានេះយ៉ាងពិស្តារ នៅក្នុងសៀវភៅរបស់ ជីន សាប *នយោបាយនៃសកម្មភាពអហិង្សា* បូស្តុន ម៉ាសាឈូសិត ផតទ័រ សាជិន ឆ្នាំ ១៩៧៣ និងសៀវភៅ ភីទ័រ អាកាមិន (Peter Ackerman) និងគ្រីស្តូហ្វ័រ គ្រូហ្វ័រ (Christopher Kruegler) *ទំនាស់អហិង្សាតាមយុទ្ធសាស្ត្រ* វែសផត (Westport) ខនណិកទីគិត (Connecticut) : ប្រាហ្គ័រ (Praeger) ឆ្នាំ ១៩៩៤ សូមអានផងដែរ ការតស៊ូអហិង្សា : ការអនុវត្តន៍សតវត្សទី២០ និងផលប្រយោជន៍ ក្នុងសតវត្សទី២១ ដោយជីន សាប នឹងចេញផ្សាយពេលក្រោយ ។

ពេលដែលគេបានធ្វើការវិភាគដ៏ហ្មត់ចត់ឡើងវិញ ហើយរៀបចំ និងអនុម័តផែនការយុទ្ធសាស្ត្រចំបងថ្មីដែលត្រឹមត្រូវ ។

# ការរៀបចំផែនការយុទ្ធសាស្ត្រសំរាប់យុទ្ធនាការ

ទោះបីជាយុទ្ធសាស្ត្រចំបងដែលគេបានរៀបចំហើយនោះ មានលក្ខណៈល្អប្រសើរអាចរំលំរបបផ្តាច់ការ និងលើកតំកើងប្រជាធិបតេយ្យបានក៏ដោយ ក៏យុទ្ធសាស្ត្រចំបងតែមួយមិនអាចអនុវត្តដោយខ្លួនឯងទេ ។ គេត្រូវរៀបចំអោយមានយុទ្ធសាស្ត្រជាក់ស្តែង ដើម្បីរៀបចំជាយុទ្ធនាការសំខាន់ៗ ក្នុងការធ្វើអោយអំណាចពួកផ្តាច់ការចុះខ្សោយ ។ យុទ្ធសាស្ត្រទាំងនេះ នឹងមានរួមបញ្ចូល និងបំភ្លឺអោយមានយុទ្ធវិធីមួយចំនួន ដែលគេរៀបចំឡើង ដើម្បីវាយប្រហារអោយបានខ្លាំងទៅលើរបបផ្តាច់ការ ។ គេត្រូវតែជ្រើសរើសយុទ្ធវិធី និងមធ្យោបាយជាក់ស្តែងទាំងឡាយ អោយបានហ្មត់ចត់ ដើម្បីអោយយុទ្ធវិធីទាំងនោះ សំរេចបាននូវគោលបំណងនៃយុទ្ធសាស្ត្រណាមួយ ។ នៅក្នុងជំពូកនេះ យើងនឹងពិគ្រោះតែអំពីកំរិតយុទ្ធសាស្ត្រ ។

អ្នកយុទ្ធសាស្ត្រដែលធ្វើផែនការសំរាប់យុទ្ធនាការសំខាន់ៗ ក៏ដូចជាអ្នករៀបចំផែនការយុទ្ធសាស្ត្រចំបងដែរ ត្រូវមានការយល់ឃើញអោយច្បាស់លាស់អំពីលក្ខណៈនិងបែបបទនៃប្រតិបត្តិការ ដែលគេជ្រើសរើសសំរាប់ការតស៊ូ ។ ដូចមេទ័ពដែលត្រូវយល់អំពីរចនាសម្ព័ន្ធនៃកងកំលាំង យុទ្ធវិធី លក្ខណៈពង្រាយទ័ព គ្រឿងសញ្ជុរុធ និងលក្ខណៈភូមិសាស្ត្រជាដើម ដើម្បីរៀបចំជាយុទ្ធសាស្ត្រយោធា អ្នករៀបចំផែនការសំរាប់នយោបាយរើបម្រះ ក៏ត្រូវយល់អោយច្បាស់អំពីប្រភេទ និងគោលការណ៍យុទ្ធសាស្ត្រនៃការតស៊ូអហិង្សាដែរ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការចេះដឹងអំពីការតស៊ូអហិង្សា ការយកចិត្តទុកដាក់ទៅលើសេចក្តីស្នើទាំងឡាយនៅក្នុងសៀវភៅនេះ ហើយនិងចំលើយទៅលើសំនួរទាំងឡាយដែលចោទសួរនៅទីនេះ ពុំមែនជាការបង្កើតបានយុទ្ធសាស្ត្រដោយឯកឯងទេ ។ ការរៀបចំជាយុទ្ធសាស្ត្រដើម្បីការតស៊ូ នៅតែតំរូវអោយមានគំនិតច្នៃប្រឌិតដែលប្រកបដោយការដឹងយល់ច្បាស់លាស់

ទៀត ។

នៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីយុទ្ធនាការតស៊ូដ៏ច្បាស់លាស់ណាមួយ ហើយនិងដើម្បីបង្កើនអោយមានការតស៊ូរំដោះក្នុងពេលវែងឆ្ងាយ អ្នកយុទ្ធសាស្ត្រដើម្បីនយោបាយរើបម្រះ ត្រូវតែគិតគូរអំពីបញ្ហាជាច្រើន ដែលមានខ្លះដូចខាងក្រោមនេះ ៖

- ការសំរេចចិត្តអំពីគោលដៅច្បាស់លាស់សំរាប់យុទ្ធនាការ និងផលប្រយោជន៍សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រចំបង ។
- ការគិតគូរលំអិតអំពីមធ្យោបាយ ឬក៏អាវុធផ្នែកនយោបាយ ដែលគេអាចប្រើប្រាស់ដ៏មានប្រសិទ្ធភាព ដើម្បីអនុវត្តយុទ្ធសាស្ត្រដែលគេជ្រើសរើស ។ នៅក្នុងផែនការទូទៅសំរាប់យុទ្ធនាការណាមួយ គេត្រូវពិនិត្យហើយកំណត់ថា តើយុទ្ធវិធីនិងមធ្យោបាយណាមួយដែលគេគួរប្រើ ដើម្បីដាក់សំពាធនិងបន្ថយប្រភពអំណាចរបបផ្តាច់ការ ។ គេត្រូវចងចាំថា ការសំរេចបាននូវគោលបំណងធំៗ គឺជាលទ្ធផលនៃការសម្រាំង និងអនុវត្តជំហានតូចៗជាក់ស្តែង ដោយប្រុងប្រយ័ត្ន ។
- ការសំរេចចិត្តថា តើបញ្ហាសេដ្ឋកិច្ចគួរតែភ្ជាប់ទៅនឹងការតស៊ូនយោបាយជាទូទៅដែរឬទេ ឬក៏ភ្ជាប់តាមបែបបទណា? ប្រសិនបើបញ្ហាសេដ្ឋកិច្ចជាកត្តាសំខាន់នៅក្នុងការតស៊ូ គេត្រូវតែប្រុងប្រយ័ត្នក្នុងការអះអាងថាគេអាចដោះស្រាយបញ្ហាសេដ្ឋកិច្ចទាំងនោះបាន ក្រោយពីរបបផ្តាច់ការរលំ។ ប្រសិនបើមិនដូច្នោះទេ ការខកចិត្តនិងការមិនសប្បាយចិត្ត នឹងកើតមានឡើងប្រសិនបើគេពុំមានការដោះស្រាយភ្លាមៗ នៅពេលដែលគេឆ្លងទៅរកសង្គមប្រជាធិបតេយ្យ ។ ការខកចិត្តទាំងនេះអាចសំរួលអោយមានការលេចឡើងនូវកំលាំងផ្តាច់ការថ្មីមួយ ដែលសន្យាថានឹងកំចាត់បញ្ហាសេដ្ឋកិច្ចនេះអោយបាន ។
- ការសំរេចគិតទុកជាមុនអំពីប្រភេទនៃរចនាសម្ព័ន្ធដឹកនាំ និងប្រព័ន្ធទំនាក់ទំនង ដែលមានប្រសិទ្ធភាពជាទីបំផុតសំរាប់ផ្តើមការតស៊ូ ។ តើគេអាចប្រើ

ប្រាស់មធ្យោបាយណា ដើម្បីធ្វើការសំរេចចិត្តនានា និងការទាក់ទងគ្នា ហើយផ្តល់ជាការណែនាំដល់អ្នកតស៊ូទាំងឡាយ និងប្រជាពលរដ្ឋជាទូទៅ នៅពេលដែលគេកំពុងតស៊ូ ?

- ការផ្សព្វផ្សាយព័ត៌មានអំពីការតស៊ូ ទៅអោយប្រជាពលរដ្ឋ ទៅកងកំលាំងរបបផ្តាច់ការ ហើយនិងប្រព័ន្ធព័ត៌មានអន្តរជាតិ ។ របាយការណ៍ និងការអះអាងអ្វីមួយគួរតែមានលក្ខណៈពិតជាក់ស្តែងជានិច្ច ។ ការនិយាយបំផ្លើស និងការអះអាងដោយគ្មានមូលដ្ឋាន នឹងធ្វើអោយជំនឿទៅលើក្រុមតស៊ូចុះខ្សោយ ។
- ផែនការនានាសំរាប់សកម្មភាពពង្រឹងការទុកចិត្តខ្លួនឯង ការអប់រំ សេដ្ឋកិច្ច និងនយោបាយ ដើម្បីបំពេញសេចក្តីត្រូវការរបស់ក្រុមតស៊ូ នៅពេលតទល់គ្នាមកដល់ ។ គំរោងការទាំងនេះអាចអនុវត្ត ដោយអ្នកដែលពុំមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងសកម្មភាពទាំងឡាយនៃក្រុមតស៊ូ ។
- ការសំរេចអំពីប្រភេទជំនួយបរទេស ដែលគេត្រូវការក្នុងការគាំទ្រយុទ្ធនាការណាមួយ ឬក៏ការតស៊ូរំដោះជាទូទៅ ។ តើគេអាចប្រមូលជំនួយពីក្រៅអោយមានប្រសិទ្ធភាពខ្លាំង តាមបែបណា ហើយប្រើប្រាស់តាមបែបណា ដើម្បីកុំអោយការតស៊ូផ្ទៃក្នុងពឹងផ្អែកទៅលើកត្តាពីក្រៅដែលមិនច្បាស់លាស់ ? គេត្រូវប្រុងប្រយ័ត្ន ថាតើក្រុមខាងក្រៅណាមួយដែលអាចជាជំនួយត្រឹមត្រូវច្បាស់លាស់ ដូចជា អង្គការក្រៅរដ្ឋាភិបាល (ចលនាសង្គម ក្រុមសាសនា ឬនយោបាយ ក្រុមសហជីពជាដើម) រដ្ឋាភិបាលបរទេសនានា ឬក៏អង្គការសហប្រជាជាតិ និងអង្គភាពផ្សេងៗរបស់គេ ។

លើសពីនេះទៅទៀត អ្នករៀបចំការតស៊ូ ត្រូវអោយមានវិធានការរក្សាសណ្តាប់ធ្នាប់ និងបំពេញសេចក្តីត្រូវការខាងទំនាក់ទំនងសង្គមរបស់កងកំលាំងខ្លួន នៅពេលធ្វើការតស៊ូ តទល់នឹងការត្រួតត្រារបស់ពួកផ្តាច់ការ ។ ការនេះមិនគ្រាន់តែបង្កើតអោយមានរចនាសម្ព័ន្ធប្រជាធិបតេយ្យឯករាជជាជំរើសផ្សេងៗទៀត និងបំពេញសេចក្តីត្រូវការមែនទែនទេ គឺនឹងជួយបន្ថយតម្លៃនៃការអះអាងណាមួយ ដែលថា គេត្រូវ

ធ្វើការបង្ក្រាបយ៉ាងឃោរឃៅ ដើម្បីកុំអោយមានភាពច្របូកច្របល់ និងស្ថានការណ៍គ្មានច្បាប់ទំលាប់ (ដែលពួកផ្តាច់ការនិយមប្រើ) ។

# ការផ្សព្វផ្សាយគំនិតមិនធ្វើសហការ

ដើម្បីអោយបាននយោបាយរើបម្រះដ៏ជោគជ័យមួយប្រឆាំងនឹងអំពើផ្តាច់ការ ការយល់ច្បាស់របស់ប្រជាពលរដ្ឋអំពីគំនិតមិនធ្វើសហការ គឺជាការសំខាន់ ។ ដូចដែលបានបង្ហាញក្នុងរឿង"ម្ចាស់ស្វា"(សូមអានជំពូកទី ៣) គេអាចយល់អំពីគោលគំនិតនេះយ៉ាងងាយស្រួល ៖ ប្រសិនបើគេមានចំនួនអ្នកក្រោមបង្គាប់គ្រប់គ្រាន់ដែលបដិសេធ មិនព្រមធ្វើសហការអោយបានយូរ ប្រឆាំងនឹងការជិះជាន់ ប្រព័ន្ធផ្តាច់ការនឹងត្រូវចុះខ្សោយ ហើយទីបំផុតត្រូវតែដួលរលំ ។

អ្នកដែលរស់នៅក្រោមរបបផ្តាច់ការប្រហែលជាបានដឹងឮអំពីគំនិតនេះ ពីប្រភពផ្សេងៗ ។ ទោះជាយ៉ាងណាក៏ដោយ កំលាំងប្រជាធិបតេយ្យគួរតែរៀបចំផ្សព្វផ្សាយ ធ្វើយ៉ាងណាអោយប្រជាពលរដ្ឋទទួលយកគោលគំនិតមិនធ្វើសហការនេះ ។ គេគួរតែផ្សព្វផ្សាយរឿង"ម្ចាស់ស្វា" ឬក៏រឿងណាឯទៀតដែលមានលំនាំខ្លឹមសារដូចគ្នានេះ ក្នុងចំណោមសង្គមមនុស្ស ។ គេអាចងាយយល់រឿងនិទានបែបនេះ ។ នៅពេលដែលគេទទួលបាននូវគំនិតមិនសហការជាទូទៅនេះហើយ ប្រជាពលរដ្ឋនឹងអាចយល់អំពីខ្លឹមសារនៃការអំពាវនាវ សុំអោយគេអនុវត្តការមិនធ្វើសហការជាមួយនឹងពួកផ្តាច់ការ ។ អ្នកទាំងនោះអាចមានគំនិតផ្តួចផ្តើមជាប្រភេទផ្សេងៗនៃការមិនធ្វើសហការ នៅក្នុងស្ថានការណ៍ថ្មីៗ ។

ថ្វីបើការផ្សព្វផ្សាយគំនិត ព័ត៌មាន និងបញ្ហាការផ្សេងៗសំរាប់ការតស៊ូ មានការលំបាក នៅក្នុងរបបផ្តាច់ការ ជារឿយៗ អ្នកប្រជាធិបតេយ្យអាចធ្វើកិច្ចការទាំងនេះបាន ។ សូម្បីតែនៅក្រោមរបបណាស៊ី(Nazi) និងកុម្មុយនីស្ត ពួកតស៊ូនៅតែមានលទ្ធភាពទាក់ទង មិនត្រឹមតែគ្នាឯងឯទៀតៗទេ គឺទាក់ទងទាំងក្រុមសាធារណជនទូលំទូលាយ តាមរយៈការបោះពុម្ពផ្សាយកាសែត ខិតប័ណ្ណ សៀវភៅ ដោយលួចលាក់

ហើយប៉ុន្មានឆ្នាំក្រោយនេះ គេអាចចេញផ្សាយជាខ្សែអាត់សំលេង និងរូបភាពថែមទៀតផង ។

ដោយសារគេបានធ្វើផែនការយុទ្ធសាស្ត្រទុកជាមុននោះ គេអាចរៀបចំ ហើយផ្សព្វផ្សាយការណែនាំទូទៅដ៏មានប្រសិទ្ធភាព សំរាប់ការតស៊ូ ។ ការណែនាំទាំងនេះអាចនិយាយអំពីបញ្ហា និងស្ថានភាពនានា ដែលប្រជាពលរដ្ឋគួរធ្វើការប្រឆាំងនិងឈប់ធ្វើសហការ ហើយនិងរបៀបធ្វើសកម្មភាពទាំងនោះ ។ ដូច្នេះ ទោះបីជាការទាក់ទងពីក្រុមអ្នកដឹកនាំប្រជាធិបតេយ្យបានត្រូវគេកាត់ផ្តាច់ ហើយគេពុំអាចបានទទួលការណែនាំច្បាស់លាស់ណាមួយជាបន្តទៀតក៏ដោយ ប្រជាពលរដ្ឋនឹងបានដឹងរបៀបចាត់ការអំពីបញ្ហាសំខាន់ៗរួចស្រេចទៅហើយ ។ ការណែនាំទាំងនេះនឹងមានបញ្ជូលផងដែរ នូវរបៀបពិនិត្យមើល“ការណែនាំក្រុមតស៊ូ”ក្លែងក្លាយណាមួយ ដែលអាចចេញពីមជ្ឈដ្ឋានប៉ូលិស ដែលគេរៀបចំឡើង ដើម្បីបង្កើតជាការញុះញង់អោយក្រុមតស៊ូតបតខុស ។

# ការបង្ក្រាបនិងវិធានការទប់ទល់

អ្នករៀបចំយុទ្ធសាស្ត្រត្រូវវិភាគមើលការឆ្លើយតប និងការជិះជាន់ដែលអាចកើតមានឡើង ជាពិសេស កំរិតហិង្សានៃរបបផ្តាច់ការទៅលើសកម្មភាពនានារបស់ក្រុមតស៊ូប្រជាធិបតេយ្យ ។ ជាចាំបាច់ គេត្រូវសំរេចអំពីរបៀបទប់ទល់ តបត ឬក៏ជៀសវាងការបង្ក្រាបដែលកាន់តែខ្លាំង ដោយមិនចុះញ៉ម ។ យោងទៅតាមយុទ្ធវិធីសំរាប់កាលៈទេសៈនីមួយៗ គេត្រូវចេញសេចក្តីព្រមានដ៏សមរម្យទៅប្រជាពលរដ្ឋ និងអ្នករួមតស៊ូ អំពីអំពើបង្ក្រាបបន្ថែមពីសំណាក់ពួកផ្តាច់ការ ដើម្បីអោយអ្នកទាំងនោះដឹងអំពីគ្រោះថ្នាក់នៃការចូលរួមក្នុងការតស៊ូ ។ ប្រសិនបើការបង្ក្រាបមានកំរិតខ្លាំងក្លា គេគួររៀបចំអោយមានជំនួយពេទ្យនៅប្រចាំការសំរាប់អ្នកតស៊ូដែលរងរបួស ។

ដោយបានគិតទុកជាមុនអំពីការបង្ក្រាប អ្នកយុទ្ធសាស្ត្រត្រូវគិតគូរអំពីការប្រើយុទ្ធវិធី និងមធ្យោបាយនានា ដែលអាចជួយអោយបានសំរេចវត្ថុបំណងនៃយុទ្ធនាការ

ឬក៏ការរំដោះ ដែលនឹងជៀសវាងឬក៏មានការបង្ក្រាបដ៏តិចជាទីបំផុត ។ ឧទាហរណ៍ ការដង្ហែក្បួនបាតុកម្មតាមផ្លូវថ្នល់ប្រឆាំងនឹងរបបផ្តាច់ការតឹងរ៉ឹង ប្រហែលជាធ្វើអោយមានការរំជើបរំជួលចិត្ត ប៉ុន្តែអំពើនេះ ក៏អាចនាំមកនូវការបាត់បង់ជីវិតបាតុកររាប់ពាន់នាក់ដែរ ។ ទោះជាយ៉ាងនេះក៏ដោយ ការខូចខាតយ៉ាងខ្លាំងរបស់ពួកបាតុករក្នុងករណីនេះ ប្រហែលជាពុំបានបន្ថែមការគាបសង្កត់បន្ថែម ទៅលើរបបផ្តាច់ការជាជាងការនៅផ្ទះ ការធ្វើកូដកម្ម និងអំពើមិនធ្វើសហការពីសំណាក់មន្ត្រីរដ្ឋការពាសពេញស្រុកនោះទេ ។

ប្រសិនបើគេត្រូវការអោយមានសកម្មភាពបង្កហេតុ ដែលអាចនាំអោយមានការខូចខាតខ្លាំង នៅក្នុងគោលបំណងយុទ្ធសាស្ត្រណាមួយនោះ គេត្រូវតែគិតគូរអោយបានហ្មត់ចត់អំពីផលវិបាក និងផលចំណេញពីសកម្មភាពនេះ ។ តើប្រជាពលរដ្ឋនិងក្រុមអ្នកតស៊ូនឹងប្រកាន់វិន័យ និងឥរិយាបថ អហិង្សានៅក្នុងការតស៊ូបែបនេះបានដែរឬទេ ? តើគេអាចទប់ទល់នឹងការបង្កហេតុអោយមានអំពើហិង្សាបានដែរឬទេ ? អ្នករៀបចំត្រូវធ្វើផែនការអំពីមធ្យោបាយដែលគេអាចអនុវត្ត ដើម្បីរក្សាវិន័យអហិង្សា និងរក្សាការតស៊ូ នៅចំពោះមុខអំពើឃោរឃៅ ។ តើគេអាចចាត់វិធានការនានាដូចជា ការប្រកាសសន្យា សេចក្តីថ្លែងការណ៍នយោបាយ ខិត្តប័ណ្ណអំពីវិន័យ របៀបដឹកនាំបាតុកម្ម ការធ្វើពហិការពីសំណាក់មនុស្សនិងក្រុមដែលគាំទ្រហិង្សា បានដែរឬទេ ? មេដឹកនាំទាំងឡាយគួរតែចងចាំជានិច្ចអំពីវត្តមាននៃ“ពួកភ្នាក់ងារបង្កហេតុ” ដែលមានបេសកកម្មញុះញង់អោយពួកបាតុករប្រើអំពើហិង្សា ។

# ការប្រកាន់ផែនការយុទ្ធសាស្ត្រអោយខ្ជាប់

នៅពេលដែលគេមានផែនការយុទ្ធសាស្ត្រដ៏ល្អរួចហើយនោះ ពួកកំលាំងប្រជាធិបតេយ្យពុំគួរបែកអារម្មណ៍ ដោយសារតែការផ្លាស់ប្តូរបន្តិចបន្តួចរបស់ពួកផ្តាច់ការដែលអាចធ្វើអោយគេចង់ងាករេពីយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រសំរាប់យុទ្ធនាការពិសេសណាមួយទេ ។ ការងាករេនេះនឹងធ្វើអោយគេផ្តោតអារម្មណ៍ ទៅ

លើសកម្មភាពធំៗនៃបញ្ហាមិនសំខាន់ទៅវិញ ។ គេមិនគួរបណ្ដោយអោយទឹកចិត្តក្នុងពេលភ្លាមៗនោះ (ដូចជាការរំជើបរំជួលចិត្តដោយសារអំពើឃោរឃៅថ្មីៗរបស់ពួកផ្ដាច់ការ) បង្វែរអារម្មណ៍របស់ក្រុមអោយឃ្លាតចេញពីយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រយុទ្ធនាការទេ ។ អំពើឃោរឃៅដែលពួកផ្ដាច់ការប្រព្រឹត្តឡើង ប្រហែលជាដើម្បីបង្កហេតុ អោយកំលាំងប្រជាធិបតេយ្យលះបង់ចោលផែនការដែលគេបានរៀបចំដ៏ល្អទុករួចមកហើយ ហើយបែរទៅប្រើអំពើហិង្សា ដើម្បីអោយពួកផ្ដាច់ការបានជ័យជំនះកាន់តែងាយស្រួល ។ ប្រសិនបើគេយល់ថាការវែកញែកជាមូលដ្ឋានមានលក្ខណៈសមរម្យហើយ មុខងាររបស់ក្រុមគាំទ្រប្រជាធិបតេយ្យ គឺចាប់អនុវត្តពីដំណាក់ការមួយទៅដំណាក់ការមួយ ។ ជាការពិត ការប្រែប្រួលខាងយុទ្ធវិធី និងគោលបំណងតូចៗ នឹងអាចកើតឡើង ហើយអ្នកដឹកនាំពូកែតែងតែត្រៀមខ្លួនជានិច្ចដើម្បីទាញយកផលប្រយោជន៍ទៅតាមកាលៈទេសៈ ។ គេមិនគួរយល់ច្រឡំអំពីការកែខៃទាំងនេះ ជាមួយនឹងគោលបំណងទាំងឡាយនៃយុទ្ធសាស្ត្រចំបង និងគោលបំណងនៃវគ្គយុទ្ធនាការណាមួយ ។ ការអនុវត្តន៍ដោយប្រុងប្រយ័ត្ននូវយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រនានាសំរាប់យុទ្ធនាការណាមួយដែលគេបានសម្រាំង នឹងជួយយ៉ាងខ្លាំងអោយបានជោគជ័យ ។

# ជំពូកទី៨

# ការអនុវត្តន៍នយោបាយបើ បម្រះ

នៅក្នុងស្ថានការណ៍ដែលប្រជាពលរដ្ឋ មានអារម្មណ៍អស់សង្ឃឹម និងភិតភ័យ កិច្ចការដំបូងសំរាប់សាធារណជនត្រូវតែមានភាពគ្រោះថ្នាក់តិច ហើយមានលក្ខណៈពង្រឹងស្មារតី និងការទុកចិត្តលើខ្លួនឯង ។ សកម្មភាពទាំងនេះ មានជាអាទិ៍ ការស្លៀកពាក់ខុសប្លែកពីធម្មតា ដែលអាចអោយគេដឹងជាសាធារណៈអំពីយោបល់ជំទាស់ណាមួយ ហើយនិងអាចផ្តល់ឱកាសអោយមហាជនឯទៀតចូលរួម ក្នុងការសំដែងមតិប្រឆាំងនេះដែរ ។ ក្នុងករណីឯទៀតៗ បញ្ហាក្រៅពីនយោបាយ ដែលហាក់ដូចជាតូចតាច (ដូចជា ការទាមទារអោយមានទឹកស្អាតសំរាប់ប្រើប្រាស់) អាចក្លាយទៅជាទិសដៅសំខាន់មួយសំរាប់សកម្មភាពជាក្រុម ។ អ្នកយុទ្ធសាស្ត្រគួរតែជ្រើសរើសយកបញ្ហាណាមួយ ដែលមនុស្សភាគច្រើនទទួលស្គាល់ថា ជាបញ្ហាសំខាន់ ហើយដែលគេពុំអាចបដិសេធចោលបាន ។ ជោគជ័យដែលបានមកពីការធ្វើយុទ្ធនាការខ្លីៗបែបនេះ មិនត្រឹមតែអាចជួយដោះស្រាយការមិនសប្បាយចិត្តក្នុងចំណោម អំពីបញ្ហាទាំងនោះទេ ប៉ុន្តែអាចធ្វើអោយប្រជាពលរដ្ឋជឿថា គេអាចមានអំណាច ។

យុទ្ធសាស្ត្រភាគច្រើននៃយុទ្ធនាការនៅក្នុងការតស៊ូពេលយូរអង្វែង *ពុំគួរ* សំដៅទៅរកការដួលរលំភ្លាមៗនៃរបបផ្តាច់ការទេ ប៉ុន្តែគួរតែសំរេចអោយបានគោលបំណងតូចៗទៅវិញ ។ ហើយរាល់យុទ្ធនាការពុំចាំបាច់តំរូវអោយមានការចូលរួមពីមជ្ឈដ្ឋានទាំងអស់នៃប្រជាពលរដ្ឋនោះឡើយ ។

ក្នុងការគិតគូរអំពីយុទ្ធនាការជាក់ស្តែង ដើម្បីអនុវត្តយុទ្ធសាស្ត្រចំបង អ្នកយុទ្ធសាស្ត្រនយោបាយរើបម្រះត្រូវតែពិចារណាថា តើយុទ្ធនាការក្នុងដំណាក់ការដំបូង ដំណាក់ការកណ្តាល និងដំណាក់ការចុងក្រោយនៃការតស៊ូដ៏វែងឆ្ងាយ មានលក្ខណៈខុសគ្នាបែបណា ។

# ការតស៊ូសម្រាំង

នៅក្នុងដំណាក់ការដំបូងនៃការតស៊ូ យុទ្ធនាការផ្សេងៗដែលមានគោលបំណងជាក់ស្តែងខុសៗគ្នា អាចមានសារៈសំខាន់ណាស់ ។ យុទ្ធនាការសម្រាំងទាំងនោះអាចកើតមានឡើងជាបន្តបន្ទាប់គ្នា ។ ជួនកាល យុទ្ធនាការពីរឬបីមានរយៈកាលជាន់គ្នា ។

នៅក្នុងការរៀបចំយុទ្ធនាការដើម្បី"ការតស៊ូសម្រាំង" ជាចាំបាច់ គេត្រូវបញ្ជាក់អំពីបញ្ហា ឬក៏ការឈឺចាប់ណាមួយ ដែលជានិមិត្តរូបនៃការជិះជាន់ជាទូទៅរបស់របបផ្តាច់ការ ។ បញ្ហាទាំងនេះអាចជាទិសដៅដ៏ល្អប្រសើរ ដើម្បីធ្វើយុទ្ធនាការអោយបានសំរេចគោលបំណងតូចៗ នៃយុទ្ធសាស្ត្រចំបងទាំងមូល ។

ការសំរេចបាននូវគោលបំណងយុទ្ធសាស្ត្រតូចៗទាំងនេះ ត្រូវពឹងផ្អែកទៅលើសមត្ថភាពបច្ចុប្បន្ន ឬក៏អនាគតនៃកំលាំងប្រជាធិបតេយ្យ ។ ការនេះនឹងជួយអោយមានជោគជ័យមួយចំនួន ដែលជាការលើកទឹកចិត្ត និងជួយអោយមានការបង្វែរអំណាចបន្តិចម្តងៗទៅក្រុមតស៊ូ ក្នុងរយៈពេលយូរ ។

យុទ្ធសាស្ត្រតស៊ូសម្រាំងទាំងឡាយគួរតែផ្តោតទៅលើបញ្ហាសង្គមកិច្ច សេដ្ឋកិច្ច ឬនយោបាយណាមួយដ៏ច្បាស់លាស់ ។ គេអាចជ្រើសរើសបញ្ហាទាំងនេះជាគោលក្នុងយុទ្ធសាស្ត្រសម្រាំង ដើម្បីជំរុញផ្នែកខ្លះនៃប្រព័ន្ធសង្គមនិងនយោបាយ អោយផុតពីការគ្រប់គ្រងរបស់មេផ្តាច់ការ ដើម្បីទាញយកមកវិញនូវការគ្រប់គ្រងផ្នែកខ្លះ ដែលបច្ចុប្បន្ននេះ ស្ថិតនៅក្នុងកណ្តាប់ដៃមេផ្តាច់ការ ឬក៏ធ្វើមិនអោយមេផ្តាច់ការបានជោគជ័យតាមគោលបំណងណាមួយ ។ ប្រសិនបើគេអាចធ្វើទៅបាន យុទ្ធនាការនៃការតស៊ូសម្រាំង គួរតែវាយប្រហារអោយចំចំណុចខ្សោយមួយឬច្រើនរបស់របប

ផ្តាច់ការ ដូចដែលបានវែកញែកពីមុនរួចហើយ ។ ដូច្នេះ ពួកប្រជាធិបតេយ្យអាចបង្កើត អោយមានអានុភាពយ៉ាងខ្លាំងបំផុត ជាមួយនឹងសមត្ថភាព កំលាំងដែលគេមាន ។

ពីដើមដំបូងភ្លាមៗ ពួកអ្នកយុទ្ធសាស្ត្រត្រូវតែរៀបចំផែនការអោយបាន យ៉ាងហោចណាស់ យុទ្ធសាស្ត្រសំរាប់យុទ្ធនាការលើកទីមួយ ។ តើគោលបំណងតូចៗរបស់គេមានអ្វីខ្លះ ? តើគោលបំណងតូចៗទាំងនោះអាចជួយសំរេចយុទ្ធសាស្ត្រចំបងដែលគេបានរៀបចំរួចហើយតាមបែបបទណា ? ប្រសិនបើអាចធ្វើទៅបាន គេគួររៀបចំ យ៉ាងហោចណាស់ អោយមានទំរង់ទូទៅនៃយុទ្ធសាស្ត្រទាំងឡាយសំរាប់យុទ្ធនាការលើកទីពីរ ហើយប្រហែលជាលើកទីបីផងដែរ ។ យុទ្ធសាស្ត្រទាំងអស់នឹងត្រូវជាផ្នែកមួយនៃការអនុវត្តន៍យុទ្ធសាស្ត្រចំបងដែលគេបានជ្រើសរើស ហើយអនុវត្តទៅតាមការណែនាំជាទូទៅ ។

# ការតទល់ជានិមិត្តរូប

នៅពេលគេផ្តើមយុទ្ធនាការថ្មី ដើម្បីធ្វើអោយរបបផ្តាច់ការទន់ខ្សោយ សកម្មភាពនយោបាយលើកទីមួយប្រហែលជាមានទំហំតូច ។ គេគួររៀបចំសកម្មភាពទាំងនេះដើម្បីល្បងមើលសតិអារម្មណ៍របស់ប្រជាពលរដ្ឋ ហើយរៀបចំអ្នកទាំងនោះសំរាប់ការតស៊ូ ដែលចេះតែមាន តាមរយៈការមិនធ្វើសហការ និងនយោបាយរើបម្រះ ។

សកម្មភាពដំបូងប្រហែលមានទ្រង់ទ្រាយជាការប្រឆាំងជានិមិត្តរូប ឬមួយក៏ប្រហែលជាសកម្មភាពជានិមិត្តរូបនៃការមិនធ្វើសហការក្នុងរយៈពេលខ្លី ។ ប្រសិនបើចំនួនមនុស្ស ដែលចូលរួមក្នុងសកម្មភាពនេះ មានតិចតួច សកម្មភាពលើកដំបូងនេះ អាចមានលក្ខណះសាមញ្ញ ដូចជាការយកបាច់ផ្កាទៅដាក់កន្លែងនិមិត្តមួយដែលមានសារៈសំខាន់ ។ ផ្ទុយទៅវិញ ប្រសិនបើចំនួនមនុស្សដែលចូលរួមក្នុងសកម្មភាពមានចំនួនច្រើន គេអាចមូលមាត់គ្នាផ្អាកអ្វីៗដែលគេកំពុងធ្វើចំនួន៥នាទី ឬក៏ស្ថិតនៅក្នុងការស្ងៀមស្ងាត់ចំនួនប៉ុន្មាននាទី ។ នៅក្នុងស្ថានការណ៍ផ្សេងទៀត មនុស្សមួយចំនួនអាចធ្វើកូដកម្មអត់អាហារ ការប្រមូលផ្តុំគ្នាស្មឹងស្មាធិ៍សូត្រធម៌នៅទីកន្លែង

ដែលមានសារៈសំខាន់ ពួកនិស្សិតធ្វើពហិការមិនចូលថ្នាក់រយៈពេលខ្លីមួយ ឬក៏ការចូលទៅអង្គុយប្រឆាំងក្នុងការិយាល័យសំខាន់ណាមួយ មួយរយៈពេល ។ នៅក្រោមរបបផ្តាច់ការ សកម្មភាពណាខ្លាំងជាងនេះប្រហែលជាទទួលការបង្ក្រាបយ៉ាងខ្លាំងក្លា ។

អំពើជានិមិត្តរូបមួយចំនួនទៀត ដូចជា ការចូលទៅកាន់កាប់នៅមុខវិមានមេផ្តាច់ការ ឬក៏ទីចាត់ការរបស់ប៉ូលិសប្រហែលជាមានគ្រោះថ្នាក់ខ្លាំង ដូច្នេះហើយគេមិនគួរអនុវត្តបែបនេះ សំរាប់ផ្តើមយុទ្ធនាការដំបូងឡើយ ។ សកម្មភាពប្រឆាំងជានិមិត្តរូបនៅពេលដើមដំបូង ជារឿយៗ តែងទាក់ទាញអោយមានការចាប់អារម្មណ៍ពីមជ្ឈដ្ឋានជាតិ ឬអន្តរជាតិ ដូចជាការធ្វើបាតុកម្មធំនៅតាមផ្លូវធំៗ នៅប្រទេសភូមាក្នុងឆ្នាំ១៩៨៨ ឬក៏ការចូលកាន់កាប់ និងកូដកម្មអត់អាហាររបស់ពួកនិស្សិតនៅទីធ្លាធៀនណាមិន (Tiananmen Square) នៅទីក្រុងប៉េកាំង ឆ្នាំ១៩៨៩ ។ ការខូចខាតយ៉ាងដំណំក្នុងចំណោមពួកបាតុករក្នុងករណីទាំងពីរនេះ បានចង្អុលបង្ហាញអំពីការប្រុងប្រយ័ត្ន ដែលពួកធ្វើយុទ្ធសាស្ត្រត្រូវតែមានក្នុងការរៀបចំយុទ្ធនាការ ។ ថ្វីបើគេឃើញមានអានុភាពខាងសីលធម៌ និងចិត្តសាស្ត្រយ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ សកម្មភាពតែឯកឯងតែម្តងបែបនេះ មិនអាចរំលំរបបផ្តាច់ការបានទេ ពីព្រោះអំពើនេះ នៅតែមានលក្ខណៈជានិមិត្តរូបនៅឡើយ ហើយពុំអាចកែប្រែអំណាចរបបផ្តាច់ការបានទេ ។

ជាធម្មតា គេពុំអាចកាត់ផ្តាច់ប្រភពអំណាចរបស់មេផ្តាច់ការបានទាំងអស់ហើយយ៉ាងឆាប់រហ័ស នៅក្នុងវគ្គដំបូងនៃការតស៊ូនោះឡើយ ។ ការនេះតំរូវអោយប្រជាពលរដ្ឋស្ទើរតែទាំងអស់ ហើយនិងស្ថាប័នទាំងឡាយនៃសង្គមមនុស្ស ដែលពីមុនមកធ្លាប់តែស្តាប់បង្គាប់ អោយបដិសេធចោលរបបផ្តាច់ការទាំងស្រុង ហើយប្រឆាំងតទល់ភ្លាមៗ តាមរយៈការមិនសហការយ៉ាងដាច់ខាត ។ គេពុំទាន់ឃើញមានហេតុការណ៍បែបនេះកើតឡើងទេ ហើយគឺជាការដែលគេអាចបានជោគជ័យ ដោយលំបាកជាទីបំផុត ។ ដូច្នេះ ក្នុងករណីជាច្រើនឯទៀត យុទ្ធនាការនយោបាយរើបម្រះមិនសហការយ៉ាងឆាប់រហ័សមួយ គឺជាយុទ្ធសាស្ត្រដែលខ្វះការពិតជាក់ស្តែង សំរាប់បើកយុទ្ធនាការប្រឆាំងនឹងរបបផ្តាច់ការ ។

# ការបែងចែកការទទួលខុសត្រូវ

នៅក្នុងយុទ្ធនាការតស៊ូប្រឆាំង ជារឿយៗ បន្ទុកនៃការតស៊ូធ្លាក់ទៅលើផ្នែកមួយ ឬក៏ច្រើននៃប្រជាពលរដ្ឋ ។ ក្នុងយុទ្ធនាការបន្តបន្ទាប់ដែលមានគោលបំណងផ្សេងៗ បន្ទុកនៃការតស៊ូត្រូវផ្ទេរទៅក្រុមប្រជាពលរដ្ឋណាមួយ ។ ឧទាហរណ៍ ពួកនិស្សិតអាចធ្វើកូដកម្មអំពីបញ្ហាអប់រំ, អ្នកដឹកនាំនិងអ្នកមានជំនឿសាសនា អាចផ្តោតទៅលើសេរីភាពខាងជំនឿ, អ្នកធ្វើការនៅស្ថានីយរថភ្លើងអាចប្រឆាំង តាមការគោរពបទបញ្ជានិរភ័យយ៉ាងមធ្យ័តខ្លាំងពេកទៅ រហូតទាល់តែប្រព័ន្ធរថភ្លើងមានដំណើរការយឺតយ៉ាវ, ពួកអ្នកកាសែតប្រហែលជាអាចតទល់នឹងការត្រួតពិនិត្យតឹងតែង តាមការទុកប្រឡោះចំហចោលលើទំព័រកាសែត ដែលជាធម្មតា គេបោះពុម្ពអត្ថបទដែលរបបផ្តាច់ការហាមឃាត់, ឬមួយក៏ភ្នាក់ងារប៉ូលិសចេះតែរកចាប់មិនបានសមាជិកក្រុមតស៊ូប្រជាធិបតេយ្យណាម្នាក់ ដែលមេផ្តាច់ការចង់ចាប់ខ្លួន ។ យុទ្ធនាការតស៊ូបណ្តក់ទៅតាមបញ្ហា និងក្រុមប្រជាពលរដ្ឋ នឹងអនុញ្ញាតអោយមជ្ឈដ្ឋានប្រជាពលរដ្ឋខ្លះមានឱកាសសំរាក នៅពេលដែលការតស៊ូចេះតែបន្តទៅមុខ ។

ការតស៊ូសម្រាំងមានសារៈសំខាន់ជាពិសេស *ដើម្បីការពារ* វត្តមាន និងភាពស្វយ័តនៃស្ថាប័ននិងក្រុមសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយដែលឯករាជ ហើយដែលស្ថិតនៅក្រៅការត្រួតត្រារបស់របបផ្តាច់ការ ដូចដែលយើងបានពិគ្រោះពីមុនរួចហើយ ។ មជ្ឈមណ្ឌលអំណាចទាំងនេះផ្តល់នូវមូលដ្ឋានដែលប្រជាពលរដ្ឋអាចប្រើប្រាស់ ដាក់សំពាធ ឬក៏ជួយទប់ទល់នឹងការត្រួតត្រាផ្តាច់ការ ។ ក្នុងការតស៊ូនេះក្រុមទាំងនេះប្រហែលជា ស្ថិតនៅក្នុងចំណោមគោលដៅទីមួយសំរាប់វាយប្រហាររបស់របបផ្តាច់ការ ។

## ការតំរង់ទៅរកអំណាចពួកផ្តាច់ការ

នៅពេលដែលការតស៊ូពេលវែងឆ្ងាយមានដំណើរការផុតពីដំណាក់ការដំបូង ចូលទៅដល់ដំណាក់ការបន្ទាប់ អ្នកយុទ្ធសាស្ត្រត្រូវតែវិភាគមើល ថាតើគេអាចបន្ថយប្រភពអំណាចរបស់មេផ្តាច់ការត្រង់ណាទៀត ។ គោលបំណងនោះ គឺការប្រើមធ្យោបាយមិនធ្វើសហការរបស់ប្រជាពលរដ្ឋ ទៅបង្កើតអោយមានស្ថានការណ៍យុទ្ធសាស្ត្រ "ចំណេញ" សំរាប់កំលាំងប្រជាធិបតេយ្យ ។

នៅពេលដែលក្រុមតស៊ូប្រជាធិបតេយ្យកើនកំលាំងកាន់តែខ្លាំងឡើង អ្នកយុទ្ធសាស្ត្រនឹងរៀបចំអោយមានការមិនសហការ និងការរើបម្រះកាន់តែខ្លាំងឡើង ដើម្បីកាត់ផ្តាច់ប្រភពអំណាចរបបផ្តាច់ការ ជាមួយនឹងបំណងធ្វើអោយមានការរាំងស្ទះនយោបាយ ហើយនៅទីបញ្ចប់ របបផ្តាច់ការនឹងរលាយដោយឯង ។

គេត្រូវរៀបចំដោយប្រុងប្រយ័ត្នអំពីបែបបទ ដែលកំលាំងប្រជាធិបតេយ្យប្រើ ក្នុងការធ្វើអោយចុះខ្សោយការគាំទ្រ ដែលប្រជាពលរដ្ឋនិងក្រុមនានាធ្លាប់ផ្តល់ទៅអោយរបបផ្តាច់ការ ។ តើការគាំទ្រទាំងនេះ នឹងចុះខ្សោយតាមការបើកអោយគេឃើញនូវអំពើឃោរឃៅរបស់របបនេះ, តាមរយៈការបង្ហាញអោយគេឃើញនូវផលវិបាកសេដ្ឋកិច្ចដ៏មហន្តរាយនៃនយោបាយពួកមេផ្តាច់ការ, ឬក៏តាមរយៈការយល់ឃើញថ្មីមួយថារបបផ្តាច់ការនឹងត្រូវបញ្ចប់ ? យ៉ាងហោចណាស់ គេត្រូវពន្យល់ណែនាំយ៉ាងណា អោយអ្នកគាំទ្រមេផ្តាច់ការ ក្លាយទៅជាពួកអព្យាក្រឹតនៅក្នុងរាល់សកម្មភាពរបស់គេ ឬប្រសើរជាងនេះទៅទៀត ក្លាយទៅជាអ្នកគាំទ្រយ៉ាងសកម្មនៃចលនាដើម្បីប្រជាធិបតេយ្យ ។

នៅពេលគេរៀបចំផែនការ និងអនុវត្តនយោបាយរើបម្រះ និងមិនសហការជាការចាំបាច់បំផុត គេត្រូវយកចិត្តទុកដាក់ទៅលើអ្នកគាំទ្រ និងអ្នកជំនួយការសំខាន់ៗរបស់ពួកផ្តាច់ការ ដែលមានជាអាទិ៍ ពួកអ្នកជំនិត គណបក្សនយោបាយ ប៉ូលិស ហើយនិងមន្ត្រីរដ្ឋបាល ជាពិសេស ពួកយោធា ។

គេត្រូវពិនិត្យមើលអំពីកំរិតនៃការស្មោះត្រង់របស់ពួកយោធា ទាំងកូននិង

នាយទាហាន ទៅលើរបបផ្តាច់ការអោយបានច្បាស់លាស់ ហើយសំរេចថាតើពួកយោធាមានចំហាឬចំណុចខ្សោយនៅត្រង់ណា ដែលអានុភាពកំលាំងប្រជាធិបតេយ្យចូលជ្រួតជ្រាបបាន ។ តើកូនទាហានជាច្រើនមិនសប្បាយចិត្ត ដោយសារគេចាប់បង្ខំខ្លួនអោយចូលធ្វើទាហានមែនដែរឬទេ ? តើកូនទាហាន និងមេទាហានទាំងនោះអាចដកខ្លួនចេញពីរបបផ្តាច់ការ ដោយសារហេតុផលផ្ទាល់ខ្លួន គ្រួសារ និងនយោបាយ មែនដែរឬទេ ? តើកត្តាណាខ្លះដែលអាចធ្វើអោយកូនទាហាន និងមេទាហានទាំងនោះ ចុះខ្សោយ នៅចំពោះមុខការជ្រៀតជ្រែករបស់ពួកប្រជាធិបតេយ្យ ។

នៅក្នុងដំណាក់ការដំបូងនៃការតស៊ូរំដោះ គេគួរតែរៀបចំអោយមានយុទ្ធសាស្រ្តពិសេសមួយ ដើម្បីទាក់ទងជាមួយពួកទាហាន និងរដ្ឋបាលរបស់មេផ្តាច់ការ ។ តាមរយះការប្រើពាក្យ រូបភាពជានិមិត្តរូប និងសកម្មភាពនានា កំលាំងប្រជាធិបតេយ្យអាចអោយពួកទាហានទាំងនោះដឹងថា ការតស៊ូរំដោះនឹងមានសភាពស្វាហាប់ ប្តូរផ្តាច់ និងមានះ ។ គេគួរអោយពួកទាហានទាំងនោះយល់ថា ការតស៊ូមានលក្ខណះពិសេសដែលគេតាក់តែងឡើង ដើម្បីធ្វើអោយរបបផ្តាច់ការខ្សោយ មិនមែនដើម្បីគំរាមកំហែងដល់ជីវិតអ្នកទាំងនោះទេ ។ ការខិតខំខ្នះខ្នែងទាំងនេះ មានគោលបំណងធ្វើអោយពួកទាហានរបស់មេផ្តាច់ការធ្លាក់ទឹកចិត្ត ហើយនៅទីបំផុត ដកការស្មោះត្រង់និងការគោរពតាមបញ្ជា ហើយបែរមកគាំទ្រចលនាប្រជាធិបតេយ្យវិញ ។ គេអាចរៀបចំជាយុទ្ធសាស្រ្តប្រហាក់ប្រហែលគ្នានេះដែរ សំរាប់ក្រុមប៉ូលិស និងមន្រ្តីរដ្ឋបាល ។

ប៉ុន្តែគេមិនគួរបកស្រាយថា ការល្បួងទាក់ទាញរកសមានចិត្ត ហើយទីបំផុត ការមិនធ្វើតាមបញ្ជាក្នុងចំណោមកងកំលាំងពួកផ្តាច់ការ ជាការលើកទឹកចិត្តអោយពួកយោធាបញ្ចប់របបផ្តាច់ការ អោយឆាប់រហ័សតាមវិធានការយោធានោះទេ ។ ការធ្វើបែបនេះ ប្រហែលជាពុំអាចជួយអោយមានប្រជាធិបតេយ្យពិតប្រាកដបានឡើយ ដោយសារ ដូចដែលយើងបានពិចារណារួចហើយ ការធ្វើរដ្ឋប្រហារមានលទ្ធភាពតិចណាស់ ក្នុងការធ្វើអោយមានតុល្យភាពអំណាច រវាងក្រុមប្រជាពលរដ្ឋ និងអ្នកកាន់អំណាច ។ ដូច្នេះហើយ ជាការចាំបាច់ គេត្រូវធ្វើផែនការអំពីរបៀបទាក់ទាញអោយនាយទាហានដែលមានសមានចិត្ត យល់ថា គេមិនត្រូវការរដ្ឋប្រហារ

ឬក៏សង្គ្រាមស៊ីវិលប្រឆាំងនឹងរបបផ្តាច់ការនោះឡើយ ។

នាយទាហានដែលមានសមានចិត្ត អាចដើរតួយ៉ាងសំខាន់ ក្នុងការតស៊ូប្រជាធិបតេយ្យ ដូចជាការលាតត្រដាងការខកចិត្ត និងការមិនសហការក្នុងរង្វង់យោធា ការលើកទឹកចិត្តអោយធ្វើការងារគ្មានប្រសិទ្ធភាពដោយចេតនា ហើយនិងការមិនធ្វើតាមបញ្ជាពីលើយ៉ាងស្ងៀមស្ងាត់ ហើយនិងគាំទ្រការបដិសេធមិនចេញបង្ក្រាបពួកតស៊ូ ។ បុគ្គលិកយោធា ប្រហែលជាអាចផ្តល់ជំនួយអហិង្សាខ្លះទៅពួកប្រជាធិបតេយ្យ មានជាអាទិ៍ បើកច្រកអោយគេរត់គេចខ្លួនដោយសុវត្ថិភាព ផ្តល់ព័ត៌មានសំងាត់ ស្បៀងអាហារ ថ្នាំពេទ្យ ជាដើម ។

យោធាគឺជាប្រភពអំណាចយ៉ាងសំខាន់មួយសំរាប់ពួកផ្តាច់ការ ពីព្រោះពួកនេះអាចប្រើកងយោធា ដែលមានវិន័យនិងគ្រឿងសញ្ញវុធ ទៅវាយប្រហារ ដាក់ទណ្ឌកម្មទៅលើប្រជាពលរដ្ឋ ដែលមិនធ្វើតាមបញ្ជាគេ ។ *អ្នកយុទ្ធសាស្ត្រនយោបាយរើបម្រះគួរចងចាំថា ការបំបែករបបផ្តាច់ការ គឺជាការលំបាកណាស់ ឬក៏ធ្វើមិនកើត ប្រសិនបើពួកប៉ូលិស មន្ត្រីរដ្ឋបាល និងយោធានៅតែគាំទ្ររបបផ្តាច់ការពេញទំហឹង ហើយធ្វើតាមបញ្ជាពួកនេះ* ។ ដូច្នេះ យុទ្ធសាស្ត្រសំរាប់ធ្វើវិទ្ធង្សនា បំបែកការស្មោះត្រង់របស់កំលាំងពួកផ្តាច់ការ ត្រូវមានអាទិភាពយ៉ាងខ្ពស់ សំរាប់អ្នកយុទ្ធសាស្ត្រប្រជាធិបតេយ្យ ។

កំលាំងប្រជាធិបតេយ្យគួរចងចាំថា ការមិនសប្បាយចិត្ត និងការមិនគោរពតាមបញ្ជា ក្នុងចំណោមយោធានិងប៉ូលិស គឺជាគ្រោះថ្នាក់សំរាប់សមាជិកនៃក្រុមទាំងនោះ ។ ពួកទាហាននិងប៉ូលិសដឹងថា ការមិនធ្វើតាមបញ្ជាមេ និងការបះបោរក្នុងជួរ នឹងទទួលទោសជាទំងន់ ។ កំលាំងប្រជាធិបតេយ្យមិនគួរសុំអោយពួកទាហាននិងនាយទាហានបះបោរភ្លាមៗទេ ។ ផ្ទុយទៅវិញ ប្រសិនបើគេមានខ្សែរយៈទាក់ទងគេគួរពន្យល់អោយអ្នកទាំងនោះយល់ច្បាស់ថា មានបែបបទច្រើនណាស់ សំរាប់លាក់បំបាំងការមិនធ្វើតាមបញ្ជា ដែលគេអាចចាប់អនុវត្តជាលើកដំបូង ។ ឧទាហរណ៍ពួកប៉ូលិស និងទាហានអាចធ្វើតាមបញ្ជាទៅបង្ក្រាបពួកតស៊ូដោយគ្មានប្រសិទ្ធភាព, គេរកពុំឃើញអ្នកដែលមេផ្តាច់ការចង់ចាប់ខ្លួន, គេអាចព្រមានអ្នកតស៊ូអោយដឹងជា

មុនអំពីគំរោងការបង្ក្រាបណាមួយ ការចាប់ខ្លួន ឬក៏ការនិរទេសណាមួយ, ហើយនិង មិនផ្តល់ព័ត៌មានសំខាន់ៗទៅអោយមេបញ្ជាការ ។ នាយទាហានដែលមិនសប្បាយចិត្ត អាចធ្វើជាភ្លេច មិនបញ្ជូនបន្តទៅក្រោម បញ្ជាការសំរាប់ការបង្ក្រាបណាមួយ ។ ពួកទាហានអាចបាញ់កាំភ្លើងអោយផុតក្បាលពួកបាតុករ ។ ប្រហាក់ប្រហែលគ្នានេះដែរ មន្ត្រីរដ្ឋបាលអាចបាត់សំណុំរឿង និងពាក្យបញ្ជាផ្សេងៗ ធ្វើការដោយគ្មានប្រសិទ្ធភាព និងធ្វើជាមានជំងឺត្រូវសំរាកនៅផ្ទះរហូតដល់ពេលជាសះស្បើយ ។

# ការប្រែប្រួលយុទ្ធសាស្ត្រ

អ្នកយុទ្ធសាស្ត្រនយោបាយរើបម្រះនឹងត្រូវពិនិត្យវាយតំលៃជានិច្ច ទៅលើដំណើរការនិងលទ្ធផលយុទ្ធសាស្ត្រចំបង និងយុទ្ធសាស្ត្រនៃយុទ្ធនាការទាំងឡាយ ។ ការតស៊ូអាចមានដំណើរការមិនល្អប្រសើរ ខុសអ្វីដែលគេបានគ្រោងទុក ។ ក្នុងករណីបែបនេះ គេត្រូវពិនិត្យមើលការប្រែប្រួលក្នុងយុទ្ធសាស្ត្របែបណាដែលគេត្រូវការ ។ តើគេអាចធ្វើអ្វីខ្លះ ដើម្បីពង្រឹងកំលាំងតស៊ូ ហើយចាប់យកការតស៊ូដែលមានប្រៀបឡើងវិញ ? ក្នុងស្ថានភាពបែបនេះ គេត្រូវតែរកមើលបញ្ហាអោយឃើញ ហើយវិភាគតាមយុទ្ធសាស្ត្រម្តងទៀត ។ គេប្រហែលជាត្រូវផ្ទេរការទទួលខុសត្រូវទៅក្រុមផ្សេង ប្រមូលផ្តុំប្រភពអំណាចបន្ថែម ហើយនិងរៀបចំអោយមានសកម្មភាពជាជំរើសថ្មី ។ នៅពេលដែលគេធ្វើកិច្ចការទាំងនេះរួចរាល់ហើយ គេគួរអនុវត្តផែនការថ្មីនោះភ្លាម ។

ផ្ទុយទៅវិញ ប្រសិនបើដំណើរការតស៊ូនេះមានភាពល្អប្រសើរជាងអ្វីដែលគេបានគ្រោងទុក ហើយរបបផ្តាច់ការកំពុងតែរង្គោះរង្គើ មុនពេលវេលាដែលគេបានកំណត់ តើកំលាំងប្រជាធិបតេយ្យអាចទាញយកផលប្រយោជន៍ដែលបានលើសពីការគ្រោងទុកនោះ ទៅប្រើប្រាស់បែបណា ដើម្បីធ្វើអោយរបបផ្តាច់ការគាំងលែងមានដំណើរការតែម្តង ? យើងនឹងពិនិត្យវិភាគសំនួរនេះនៅក្នុងជំពូកជាបន្តខាងមុខ ។

# ជំពូកទី៩

# ការបំបែករបបផ្តាច់ការ

ឥទ្ធិពលនៃជោគជ័យជាបន្តបន្ទាប់នៃយុទ្ធនាការអហិង្សាដែលគេបានអនុវត្ត យ៉ាងហ្មត់ចត់ នឹងពង្រឹងការតស៊ូ ហើយរៀបចំពង្រីកផ្នែកទាំងឡាយនៃសង្គម ដែលរបបផ្តាច់ការពុំអាចគ្រប់គ្រងបាន ។ យុទ្ធនាការទាំងនោះនឹងផ្តល់ដែរ នូវបទពិសោធន៍សំខាន់ៗ អំពីរបៀបបដិសេធមិនធ្វើសហការ ហើយនិងរបៀបធ្វើនយោបាយរើបម្រះ ។ បទពិសោធន៍នេះនឹងជាជំនួយការយ៉ាងប្រសើរ នៅពេលដែលការរើបម្រះមិនធ្វើសហការ រាលដាលកាន់តែធំឡើងៗ ។

ដូចដែលយើងបានពិគ្រោះក្នុងជំពូកទី៣ ការធ្វើតាមបង្គាប់ សហប្រតិបត្តិការ និងការចុះញ៉ម ជាកត្តាសំខាន់ សំរាប់ធ្វើអោយពួកផ្តាច់ការមានអំណាច ។ ប្រសិនបើគ្មានការពាក់ព័ន្ធនឹងប្រភពអំណាចទាំងនោះទេ អំណាចពួកផ្តាច់ការនឹងចុះខ្សោយ ហើយនៅទីបំផុតនឹងត្រូវរលាយ ។ ដូច្នេះការដកយកការគាំទ្រទាំងនោះចេញ គឺជាសកម្មភាពចំបង ដើម្បីបំបែករបបផ្តាច់ការ ។ យើងគួរតែពិនិត្យឡើងវិញ អំពីបែបបទនយោបាយរើបម្រះដែលអាចមានអានុភាពទៅលើប្រភពអំណាចទាំងនោះ ។

សកម្មភាពទាំងឡាយដែលជានិមិត្តរូបនៃការរើបម្រះនិងការបដិសេធ គឺជាមធ្យោបាយមួយចំនួនក្នុងចំណោមមធ្យោបាយជាច្រើន សំរាប់ធ្វើអោយខ្សោយនូវ *អំណាចអាជ្ញាធរខាងនយោបាយ* និងភាពសមរម្យ ដែលជាភាពត្រឹមត្រូវតាមច្បាប់ របស់របបផ្តាច់ការ ។ នៅពេលដែលអំណាចរបបនេះកាន់តែខ្លាំង របបនេះក៏នឹង

បានទទួលការធ្វើតាមបញ្ជា និងសហការកាន់តែខ្លាំងដែរ ។ គេត្រូវបញ្ចេញការមិនសប្បាយចិត្ត តាមការធ្វើសកម្មភាពដ៏ច្បាស់លាស់ ដើម្បីគំរាមកំហែងរបបផ្តាច់ការនេះ ។ គេត្រូវដកយកចេញនូវសហការនិងការធ្វើតាមបញ្ជា ដើម្បីកាត់ផ្តាច់ប្រភពផ្សេងៗឯទៀតនៃអំណាចរបបផ្តាច់ការ ។

ប្រភពអំណាចសំខាន់ទី២ គឺ*ប្រភពធនធានមនុស្ស* - ចំនួន និងគុណសម្បត្តិនៃមនុស្សនិងក្រុមទាំងឡាយ ដែលស្តាប់តាមបញ្ជា ធ្វើសហការជាមួយ ឬក៏ជួយអ្នកគ្រប់គ្រងរដ្ឋ ។ ប្រសិនបើមួយភាគធំនៃប្រជាពលរដ្ឋមិនព្រមធ្វើសហការ របបនេះនឹងមានបញ្ហាធំ ។ ឧទាហរណ៍ : ប្រសិនបើមន្ត្រីរដ្ឋការលែងធ្វើការអោយមានប្រសិទ្ធភាពដូចមុន ឬក៏គេចនៅផ្ទះ ស្ថាប័នរដ្ឋបាលនឹងទទួលការប៉ះពាល់ជាខ្លាំង ។

ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើមនុស្ស និងក្រុមដែលមិនធ្វើសហការមានរួមបញ្ចូលទាំងអ្នកដែលធ្លាប់ពីមុនផ្តល់ដល់របបផ្តាច់ការនូវ*ចំណេះដឹង និងជំនាញការ* មេផ្តាច់ការនឹងឃើញថា លទ្ធភាពគេក្នុងការធ្វើអ្វីស្រេចតែចំណង់ចិត្តនឹងត្រូវចុះថយខ្សោយជាខ្លាំង ។ សូម្បីតែលទ្ធភាពគេសំរាប់ធ្វើការសំរេចចិត្តអោយបានស្រួល និងរៀបចំផែនការអោយមានប្រសិទ្ធភាព ប្រហែលជាត្រូវចុះអន់ដែរ ។

ប្រសិនបើអានុភាពផ្លូវចិត្តនិងមនោគមន៍វិជ្ជា ដែលគេហៅថា*កត្តាអរូបីយ៍* ដែលជាធម្មតាជំរុញអោយគេធ្វើតាមបញ្ជានិងជួយពួកផ្តាច់ការ ត្រូវគេធ្វើអោយចុះខ្សោយ ឬក៏អស់តែម្តង ប្រជាពលរដ្ឋច្បាស់ជានាំគ្នាលែងគោរព ហើយឈប់ធ្វើសហការ ។

ការដែលពួកផ្តាច់ការមាន*ធនធានសំភារៈ* ក៏ជាការពាក់ព័ន្ធដោយផ្ទាល់ទៅអំណាចរបស់គេដែរ ។ ប្រសិនបើការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ប្រព័ន្ធសេដ្ឋកិច្ច ដីធ្លី ធនធានធម្មជាតិ ការដឹកជញ្ជូន និងមធ្យោបាយទាក់ទងផ្សេងៗ ស្ថិតនៅក្នុងកណ្តាប់ដៃអ្នកតស៊ូ ប្រភពអំណាចដ៏សំខាន់មួយនេះរបស់ពួកផ្តាច់ការ នឹងចុះខ្សោយ ឬក៏បាត់បង់ ។ កូដកម្ម ពហិការ និងការកើនឡើងនៃភាពស្វយ័តក្នុងសេដ្ឋកិច្ច ទំនាក់ទំនងនឹងការដឹកជញ្ជូន នឹងធ្វើអោយរបបនេះទន់ខ្សោយ ។

ដូចដែលបានពិគ្រោះពីមុនរួចហើយ លទ្ធភាពពួកផ្តាច់ការក្នុងការគំរាម

កំហែងដាក់*ទណ្ឌកម្ម* ទៅលើក្រុមប្រជាពលរដ្ឋដែលមិនសហការ មិនធ្វើតាមបញ្ជា គឺជាប្រភពចំបងនៃអំណាចពួកផ្តាច់ការ ។ គេអាចធ្វើអោយប្រភពអំណាចនេះទន់ខ្សោយបានតាមរបៀបពីរយ៉ាង ។ ទីមួយ ប្រសិនបើប្រជាពលរដ្ឋបានរៀបចំខ្លួនរួចហើយ ដូចដែលក្នុងករណីសង្គ្រាម ដើម្បីទទួលយកផលវិបាកធ្ងន់ធ្ងរនៃការរើបម្រះ ប្រសិទ្ធភាពនៃការធ្វើទុក្ខទារុណកម្ម នឹងចុះខ្សោយខ្លាំង (គឺថា ការបង្ក្រាបរបស់ពួកផ្តាច់ការ នឹងពុំបានសំរេច ទទួលបាននូវការចុះញ៉មឡើយ) ។ ទីពីរ ប្រសិនបើកងកំលាំងប៉ូលិសនិងទាហានមិនសប្បាយចិត្ត គេប្រហែលជា តាមការផ្តុំគ្នាឬក៏ម្នាក់ៗ អាចជៀសវាង ឬបដិសេធមិនទទួលបញ្ជាទៅចាប់ខ្លួន ទៅធ្វើបាប ឬក៏ទៅបាញ់ពួកតស៊ូ ។ ប្រសិនបើពួកផ្តាច់ការលែងពឹងផ្អែកបានទៅលើកងកំលាំងប៉ូលិស និងទាហានក្នុងការបង្ក្រាបមហាជន របបផ្តាច់ការនេះនឹងទទួលការគំរាមកំហែងយ៉ាងខ្លាំង ។

ជាសង្ខេប ជោគជ័យទៅលើរបបផ្តាច់ការ ដែលមានមូលដ្ឋានមាំទាំ តំរូវអោយមានការមិនសហការ និងរើបម្រះ ដើម្បីបន្ថយនិងដកចេញ នូវប្រភពអំណាចរបស់របបនេះ ។ ប្រសិនបើគ្មានការពង្រីកពង្រឹងទៅលើប្រភពសំខាន់ៗនៃអំណាចទេនោះ របបផ្តាច់ការនឹងចុះខ្សោយ ហើយនៅទីបញ្ចប់ នឹងបែករលាយ ។ ដូច្នេះការរៀបចំផែនការយុទ្ធសាស្ត្រសំរាប់នយោបាយរើបម្រះដ៏មានប្រសិទ្ធភាព ប្រឆាំងនឹងរបបផ្តាច់ការ តំរូវអោយមានការផ្តោតទៅលើប្រភពអំណាចដ៏សំខាន់នៃពួកផ្តាច់ការ ។

# ការពង្រីកសេរីភាព

ជាមួយនឹងនយោបាយរើបម្រះ ក្នុងដំណាក់ការតស៊ូដោយសម្រាំង ការកើនឡើងនៃស្ថាប័នស្វយ័តខាងសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ នឹងពង្រីកបន្តិចម្តងៗ នូវ“ទីវាលប្រជាធិបតេយ្យ”របស់សង្គម ហើយនឹងធ្វើអោយការគ្រប់គ្រងរបស់របបផ្តាច់ការរួញតូច ។ នៅពេលដែលស្ថាប័នសង្គមស៊ីវិលកាន់តែមានកំលាំងខ្លាំងឡើង ទោះបីជាពួកផ្តាច់ការមានបំណងបែបណាក៏ដោយ ប្រជាពលរដ្ឋនឹងចេះតែកសាងបន្ថែមនូវអង្គការសង្គមឯករាជ ដែលស្ថិតនៅក្រៅការគ្រប់គ្រងរបស់របប

ផ្តាច់ការ ។ នៅពេលដែលរបបផ្តាច់ការធ្វើអន្តរាគមន៍ ដើម្បីផ្អាក"ការពង្រីកសេរីភាព" នេះ គេអាចអនុវត្តការតស៊ូអហិង្សា ដើម្បីការពារទីវាលថ្មីដែលគេទើបទទួលបាន ហើយរបបផ្តាច់ការនឹងប្រឈមមុខទៅនឹងរណសិរ្សមួយទៀតនៃការតស៊ូ ។

ទីបំផុត ការរួមបញ្ចូលគ្នារវាងការប្រឆាំងនិងការកសាងស្ថាប័នសង្គម អាចនាំអោយមានសេរីភាព*ជាបណ្តោះអាសន្ន* នាំទៅរកការដួលរលំនៃរបបផ្តាច់ការ ហើយនិងការចាត់តាំងជាផ្លូវការអោយមានប្រព័ន្ធប្រជាធិបតេយ្យ ។ គេមិនអាចបដិសេធការវិវត្តន៍បែបនេះបាន ពីព្រោះតុល្យភាពអំណាចនៅក្នុងសង្គមនេះ បានប្រែប្រួលយ៉ាងខ្លាំងណាស់ទៅហើយ ។

ប្រទេសប៉ូឡូញនៅទសវត្សរ៍១៩៧០និង១៩៨០ បានផ្តល់ជាឧទាហរណ៍យ៉ាងច្បាស់អំពីការទាមទារបន្តិចម្តងៗរបស់ពួកតស៊ូ យកតួនាទី និងស្ថាប័នរបស់សង្គម ។ ព្រះវិហារកាតូលិកបានទទួលការតាមធ្វើបាប ប៉ុន្តែពុំដែលស្ថិតនៅក្រោមការគ្រប់គ្រងពេញលេញរបស់ពួកកុម្មុយនីស្តទេ ។ នៅក្នុងឆ្នាំ១៩៧៦ ពួកបញ្ញវ័ន្ត និងកម្មករបានរួមគ្នាបង្កើតជាក្រុមតូចៗ ដូចជា គណៈកម្មការការពារកម្មករ ដើម្បីគាំទ្រ និងជំរុញគំនិតនយោបាយរបស់គេ ។ ការបង្កើតអោយមានសហជីពកម្មករឈ្មោះថា "សូលីដារីធី" (Solidarity [សាមគ្គី]) ដើម្បីធ្វើកូដកម្មអោយមានប្រសិទ្ធភាព បានបង្ខំអោយអាជ្ញាធរទទួលស្គាល់តាមផ្លូវច្បាប់នៅក្នុងឆ្នាំ១៩៨០ ។ ពួកកសិករ និស្សិត និងក្រុមឯទៀតជាច្រើនក៏បានរៀបចំបង្កើតជាអង្គការឯករាជរបស់គេដែរ ។ នៅពេលដែលពួកកុម្មុយនីស្តដឹងថា ក្រុមទាំងនេះបានកែប្រែអំណាចជាក់ស្តែង អង្គការ"សាមគ្គី" ក៏បានត្រូវគេហាមឃាត់លុបចេញ ហើយពួកកុម្មុយនីស្តក៏ប្រើរបៀបគ្រប់គ្រងតាមច្បាប់យោធា ។

សូម្បីតែនៅក្រោមរបបច្បាប់អាជ្ញាសឹក ដែលមានការចាប់ដាក់គុក និងការតាមធ្វើបាបយ៉ាងខ្លាំង ស្ថាប័នឯករាជថ្មីៗក្នុងសង្គមនៅតែមានដំណើរការទៅមុខ ។ ឧទាហរណ៍ កាសែត និងទស្សនាវដ្តីលួចលាក់រាប់ឡូ នៅតែចេញផ្សព្វផ្សាយ ។ រោងពុម្ពខុសច្បាប់បោះពុម្ពសៀវភៅរាប់រយក្បាល ក្នុងមួយឆ្នាំៗ នៅពេលដែលអ្នកនិពន្ធល្បីល្បាញ ធ្វើពហិការ មិនសរសេរអោយការឃោសនារបស់ពួកកុម្មុយនីស្ត និង

រោងពុម្ពរដ្ឋ ។ សកម្មភាពប្រហាក់ប្រហែលគ្នានេះ ក៏បានកើតមានឡើងក្នុងផ្នែកឯទៀតនៃសង្គមដែរ ។

នៅក្រោមរបបយោធារបស់លោក ឆារូសិលស្គី(Jaruselski) រដ្ឋាភិបាលយោធាកុម្មុយនីស្ត ក្នុងដំណាក់ការមួយ បានត្រូវគេចាត់ទុកថា អាចហក់លោតបានត្រឹមតែផ្នែកខាងលើនៃសង្គមប៉ុណ្ណោះ ។ មន្ត្រីរដ្ឋការនៅកាន់កាប់អគារការិយាល័យរដ្ឋាភិបាល ។ របបនេះអាចជិះជាន់សង្គមបាន តាមរយៈការដាក់ទណ្ឌកម្ម ការចាប់ខ្លួនអ្នកប្រឆាំង ការដាក់គុក ការរឹបអូសយកម៉ាស៊ីនបោះពុម្ព និងសកម្មភាពជិះជាន់ឯទៀតៗ ។ ប៉ុន្តែរបបផ្តាច់ការនេះនៅតែពុំអាចត្រួតត្រាសង្គមបាន ។ តាំងពីពេលនោះមក គេរង់ចាំតែពេលវេលា ដែលសង្គមអាចរំលំរបបនោះទាំងស្រុង ។

សូម្បីតែនៅពេលរបបផ្តាច់ការកាន់កាប់តំណែងរដ្ឋាភិបាលទាំងឡាយ ជួនកាល គេអាចរៀបចំអោយមានរដ្ឋាភិបាល“ទន្ទឹម”ប្រជាធិបតេយ្យ ។ រដ្ឋាភិបាលទន្ទឹមនេះនឹងមានដំណើរការកាន់តែខ្លាំងឡើង ជារដ្ឋាភិបាលប្រកួត ដែលបានទទួលការស្មោះត្រង់ ការគោរព និងសហការពីសំណាក់ប្រជាពលរដ្ឋនិងស្ថាប័នសង្គម ។ បន្ទាប់មក របបផ្តាច់ការនឹងបាត់បង់លក្ខណៈជារដ្ឋាភិបាលកាន់តែច្រើនឡើងៗ ។ នៅទីបំផុត រដ្ឋាភិបាលទន្ទឹមប្រជាធិបតេយ្យ ប្រហែលជាអាចចូលជំនួសរបបផ្តាច់ការពេញលេញ ដែលជាផ្នែកមួយនៃការកែប្រែទៅរកប្រព័ន្ធប្រជាធិបតេយ្យ ។ ដំណើរការជាបន្តទៀតនោះ គឺគេនឹងអនុម័តយករដ្ឋធម្មនុញ្ញមួយ ហើយរៀបចំអោយមានការបោះឆ្នោត ដែលជាដំណាក់ការមួយទៀត ក្នុងអន្តរកាលនេះ ។

# ការបំបែករបបផ្តាច់ការ

នៅពេលដែលស្ថាប័នសង្គមកំពុងតែកែប្រែ ចលនារើបម្រះនិងមិនសហការអាចមានកំរិតកាន់តែខ្លាំងឡើង ។ អ្នកយុទ្ធសាស្ត្រប្រជាធិបតេយ្យគួរតែគិតទុកអោយហើយថា គេនឹងទៅដល់ពេលវេលាដែលកំលាំងប្រជាធិបតេយ្យអាចមានដំណើរការហួសពីការតស៊ូដោយសម្រាំង ហើយគេអាចផ្តើមអោយមានការរើបម្រះពីសំណាក់

មហាជន ។ ក្នុងករណីជាច្រើនលើសលុប គេត្រូវការពេលវេលា ដើម្បីបង្កើតនិងពង្រីកពង្រឹងសមត្ថភាពក្រុមតស៊ូ ហើយការរីករាលដាលនៃការរើបម្រះមហាជន អាចកើតមានឡើង លុះត្រាណាតែគេខិតខំរាប់ឆ្នាំ ។ នៅក្នុងអន្តរកាលនេះ គេគួរតែផ្តើមយុទ្ធនាការសំរាប់ការតស៊ូសម្រាំង ដោយមានគោលបំណងនយោបាយកាន់តែសំខាន់ៗឡើង ។ ពេលនេះ ក្រុមប្រជាពលរដ្ឋកាន់តែច្រើនឡើង នៅក្នុងគ្រប់ស្រទាប់នៃសង្គម គួរតែចូលរួមចំណែក ។ នៅពេលដែលគេបង្កើនសកម្មភាពបែបនេះ ជាមួយនឹងការតាំងចិត្តដ៏ម៉ឺងម៉ាត់ និងវិន័យក្នុងនយោបាយរើបម្រះ ចំណុចខ្សោយផ្ទៃក្នុងរបស់របបផ្តាច់ការនឹងចេញរូបរាងកាន់តែច្បាស់ឡើង ។

ក្នុងពេលមួយ ការរួមបញ្ចូលគ្នារវាងនយោបាយរើបម្រះដ៏ខ្លាំងក្លា និងការកសាងស្ថាប័នឯករាជ នឹងទាក់ទាញអោយមានការយកចិត្តទុកដាក់ ពីសំណាក់អន្តរជាតិដែលគាំទ្រកំលាំងប្រជាធិបតេយ្យ ។ ការនេះប្រហែលជាធ្វើអោយមានការថ្កោលទោស ពហិការ និងការផ្តាច់សកម្មភាពអ្វីមួយពីសំណាក់អន្តរជាតិ ដើម្បីគាំទ្រកំលាំងប្រជាធិបតេយ្យ (ដូចជាក្នុងករណីប្រទេសប៉ូឡូញ) ។

អ្នកយុទ្ធសាស្ត្រគួរតែដឹងថា នៅក្នុងស្ថានការណ៍ខ្លះ ការដួលរលំនៃរបបផ្តាច់ការអាចកើតឡើងយ៉ាងឆាប់រហ័ស ដូចដែលបានកើតឡើងក្នុងប្រទេសអាឡឺម៉ង់ខាងកើត ក្នុងឆ្នាំ១៩៨៩ ។ ការនេះអាចកើតឡើង នៅពេលដែលប្រភពអំណាចបានត្រូវគេកាត់បន្ថយយ៉ាងខ្លាំង ដោយសារមហាជនទាំងមូលបានងើបឡើងប្រឆាំងនឹងរបបផ្តាច់ការ ។ ប៉ុន្តែដំណើរការនេះមិនមែនជាដំណើរការធម្មតា ម៉្លោះហើយ ជាការប្រសើរជាង ប្រសិនបើគេរៀបចំអោយមានការតស៊ូវែងអន្លាយ (ប៉ុន្តែគេគួរប្រុងប្រៀបខ្លួនជាស្រេច សំរាប់ការតស៊ូដ៏ខ្លីមួយ) ។

ក្នុងដំណើរការតស៊ូដើម្បីរំដោះ គេត្រូវតែធ្វើបុណ្យអបអរសាទរជ័យជំនះដែលគេទទួលបាន ថ្វីបើជ័យជំនះនោះ ជាជ័យជំនះលើបញ្ហាតូចតាចក៏ដោយ ។ គេត្រូវតែទទួលស្គាល់សរសើរអ្នកទាំងឡាយណា ដែលបានធ្វើអោយមានជោគជ័យនោះ ។ ការធ្វើពិធីបុណ្យអបអរសាទរដោយប្រុងប្រយ័ត្ននេះ អាចជាការជួយលើកទឹកចិត្តដែលគេត្រូវការសំរាប់ដំណាក់ការអនាគតនៃការតស៊ូ ។

# ការកាន់កាប់ជ័យជំនះដោយការទទួលខុសត្រូវ

អ្នកធ្វើផែនការសំរាប់យុទ្ធសាស្ត្រចំបងគួរតែគិតគូរទុកជាមុន អំពីបែបបទដែលអាចកើតឡើង និងអ្វីដែលគេចង់បាន ពាក់ព័ន្ធទៅនឹងការបញ្ចប់ការតស៊ូដោយជោគជ័យ ដើម្បីធ្វើយ៉ាងណាជៀសវាងកុំអោយរបបផ្តាច់ការថ្មីមួយទៀតកើតឡើងបាន ហើយនិងពង្រឹងការរៀបចំជាបន្តទៀត អោយមានប្រព័ន្ធប្រជាធិបតេយ្យស្ថិតស្ថេរ ។

ពួកប្រជាធិបតេយ្យគួរតែគិតគូរថា តើគេនឹងគ្រប់គ្រងការប្រែប្រួលពីរបបផ្តាច់ការទៅរដ្ឋាភិបាលបណ្តោះអាសន្ន តាមបែបបទណា នៅពេលចប់ការតស៊ូ ។ នៅពេលនោះ គេចង់បានរដ្ឋាភិបាលមួយដែលមានដំណើរការភ្លាមៗ ។ ប៉ុន្តែ រដ្ឋាភិបាលនេះមិនមែនជារដ្ឋាភិបាលចាស់ដែលមានបុគ្គលិកថ្មីនោះទេ ។ ជាការចាំបាច់ គេត្រូវគិតគូរថា តើគេត្រូវលប់ចោលផ្នែកណាមួយនៃរដ្ឋាភិបាលចាស់ (ដូចជាផ្នែកប៉ូលិសនយោបាយ) ដែលមានលក្ខណៈប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ហើយថាតើគេនឹងទុកផ្នែកណា ដែលគេអាចធ្វើអោយមានលក្ខណៈប្រជាធិបតេយ្យបន្ថែមទៀតនៅពេលក្រោយ ។ ការទុកចំហ មិនអោយមានរដ្ឋាភិបាលទាល់តែសោះ នឹងអាចបើកផ្លូវអោយមានការជ្រួលច្របល់ ឬក៏របបផ្តាច់ការថ្មីមួយ ។

គេគួរតែគិតសំរេចទុកជាមុន អំពីការគ្រប់គ្រងពួកមន្ត្រីជាន់ខ្ពស់នៃរបបផ្តាច់ការនៅពេលដែលអំណាចពួកនេះ ត្រូវបែកខ្ចាយ ។ ឧទាហរណ៍ តើគេនឹងកាត់ទោសពួកផ្តាច់ការដែរឬទេ ? តើគេនឹងអនុញ្ញាតអោយពួកនេះចាកចេញពីប្រទេសរហូតទៅឬយ៉ាងណា ? តើគេមានជំរើសណាផ្សេងទៀត ដែលស៊ីសង្វាក់គ្នាជាមួយនឹងនយោបាយរើបម្រះ ជាមួយនឹងសេចក្តីត្រូវការ សំរាប់កសាងប្រទេសឡើងវិញ ហើយនិងការកសាងលទ្ធិប្រជាធិបតេយ្យក្រោយជ័យជំនះ ? គេត្រូវជៀសវាងការបង្ហូរឈាមដែលអាចមានផលវិបាកខ្លាំង ទៅលើការរៀបចំអោយមានប្រព័ន្ធប្រជាធិបតេយ្យក្នុងពេលអនាគត ។

គេគួរតែរៀបចំផែនការជាក់ស្តែងមួយចំនួនទុកជាស្រេច ដើម្បីឆ្ពោះទៅរក

ប្រជាធិបតេយ្យ នៅពេលដែលរបបផ្តាច់ការកំពុងចុះខ្សោយ ឬក៏រលំ ។ ផែនការទាំងនេះ នឹងជួយបញ្ចៀសមិនអោយក្រុមណាមួយទៀត ឆ្លៀតឆក់យកអំណាចតាមការធ្វើរដ្ឋប្រហារ ។ គេក៏ត្រូវការផងដែរនូវផែនការរៀបចំអោយមានស្ថាប័នរដ្ឋាភិបាលសមស្របទៅនឹងរដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ ដែលអនុញ្ញាតអោយមានសេរីភាពបុគ្គលនិងសេរីភាពនយោបាយពេញលេញ ។ គេមិនគួរបណ្តោយអោយការប្រែប្រួលដែលគេឈ្នះបានយ៉ាងលំបាក បាត់បង់ទៅវិញ ដោយសារការខ្វះផែនការនោះទេ ។

នៅពេលដែលប្រឈមមុខជាមួយនឹងប្រជាពលរដ្ឋ ដែលយល់ដឹងអំពីអំណាចខ្លួនកាន់តែខ្លាំងឡើង ហើយនិងការរីកចំរើននៃក្រុមនិងស្ថាប័នឯករាជប្រជាធិបតេយ្យ (ជាកត្តាពីរដែលរបបផ្តាច់ការត្រួតត្រាមិនកើត) ពួកផ្តាច់ការនឹងយល់ច្បាស់ថាការផ្សងព្រេងរបស់គេនឹងត្រូវបរាជ័យ ។ ការបញ្ឈប់សកម្មភាពទាំងឡាយនៅក្នុងសង្គម ការធ្វើកូដកម្មទូទៅ ការសំងំនៅផ្ទះមិនទៅធ្វើការ ការដើរដង្ហែក្បួនប្រឆាំង ឬក៏សកម្មភាពឯទៀត នឹងធ្វើអោយអង្គការរបស់មេផ្តាច់ការទាំងឡាយ ចុះទន់ខ្សោយកាន់តែខ្លាំង ។ ជាលទ្ធផលនៃការរើបម្រះ និងការមិនធ្វើសហការដែលគេអនុវត្តឡើង ដោយមានការចូលរួមពីមហាជន ពួកផ្តាច់ការនឹងអស់អំណាច ហើយអ្នកប្រជាធិបតេយ្យនឹងបានជោគជ័យ ដោយមិនចាំបាច់ប្រើអំពើហិង្សា ។ របបផ្តាច់ការនឹងរលាយនៅចំពោះមុខប្រជាពលរដ្ឋដែលរើបម្រះ ។

ការខិតខំខ្នះខ្នែងទាំងប៉ុន្មាន នឹងមិនអាចបានជោគជ័យគ្រប់ពេលវេលាទេ ជាពិសេស មិនមែនជាការងាយស្រួល ហើយកម្រនឹងបានជោគជ័យអោយបានឆាប់រហ័សណាស់ ។ គេគួរចងចាំថា ការឈ្នះនិងការចាញ់សង្គ្រាមយោធាមានចំនួនស្មើគ្នា ។ ប៉ុន្តែនយោបាយរើបម្រះផ្តល់នូវលទ្ធភាពមែនទែនសំរាប់ជោគជ័យ ។ ដូចដែលបានកត់សំគាល់ពីមុនមកហើយ គេអាចពង្រឹងលទ្ធភាពនេះ តាមការបង្កើតអោយមានយុទ្ធសាស្ត្រចំបងប្រកបដោយគតិបណ្ឌិត ធ្វើផែនការយុទ្ធសាស្ត្រដោយហ្មត់ចត់ ការខិតខំប្រឹងប្រែងធ្វើការងារ និងការតស៊ូប្រកបដោយសេចក្តីក្លាហាននិងវិន័យ ។

# ជំពូកទី១០

# កិច្ចការជាមូលដ្ឋាន សំរាប់ប្រជាធិបតេយ្យរឹងប៉ឹង

មែនហើយ ការដួលរលំនៃរបបផ្តាច់ការ គឺជាបុព្វហេតុសំរាប់ការអបអរសាទរយ៉ាងខ្លាំងក្លាមួយ ។ ប្រជាពលរដ្ឋដែលបានរងទុក្ខវេទនាយ៉ាងយូរ ហើយបានតស៊ូដោយគ្រោះថ្នាក់ផងនោះ សមនឹងមានពេលសប្បាយរីករាយ សំរាកកំសាន្ត ហើយនិងមានការទទួលស្គាល់ជាផ្លូវការ ។ គេគួរតែមានមោទនភាពលើខ្លួនឯងនិងអ្នកឯទៀត ដែលបានតស៊ូជាមួយគ្នារហូតបានសេរីភាពនយោបាយ ។ អ្នកតស៊ូទាំងអស់ ពុំបានរស់រានមានជីវិតមកដល់ថ្ងៃជ័យជំនះនេះទេ ។ អ្នកនៅរស់ និងអ្នកបាត់បង់ជីវិតនឹងត្រូវគេចងចាំជាវីរជន ដែលបានជួយរៀបចំអោយមានសេរីភាពជាប្រវត្តិសាស្ត្រក្នុងប្រទេសរបស់គេ ។

ប៉ុន្តែគួរអោយស្តាយ ពីព្រោះពេលនេះ មិនមែនជាពេលដែលគេគួរបន្ធូរការប្រុងប្រយ័ត្ន ។ សូម្បីតែក្នុងកាលៈទេសៈដែលរបបផ្តាច់ការបែកខ្ចាយដោយសារនយោបាយរើបម្រះក៏ដោយ គេក៏ត្រូវមានការប្រុងប្រយ័ត្ន ដើម្បីបញ្ចៀសមិនអោយមានរបបជិះជាន់មួយថ្មីលេចចេញពីការច្របូកច្របល់ ក្រោយពីការដួលរលំនៃរបបផ្តាច់ការចាស់ ។ ពួកអ្នកដឹកនាំកំលាំងប្រជាធិបតេយ្យ គួរតែរៀបចំទុកជាមុនសំរាប់ការឆ្លងទៅរកលទ្ធិប្រជាធិបតេយ្យដោយសណ្តាប់ធ្នាប់ ។ គេនឹងត្រូវដោះដូរ

របចនាសម្ព័ន្ធរបបផ្តាច់ការ ។ គេត្រូវបង្កើតអោយមានមូលដ្ឋានរដ្ឋធម្មនុញ្ញ និងច្បាប់ ហើយនិងខ្នាតត្រឹមត្រូវ សំរាប់ប្រជាធិបតេយ្យរឹងប៉ឹងមួយដែលគេនឹងកសាង ។

គេមិនគួរយល់ថា ក្រោយពីការដួលរលំនៃរបបផ្តាច់ការ សង្គមដ៏ល្អមួយនឹងលេចចេញឡើងភ្លាមនោះទេ ។ ការបែកខ្ចាត់ខ្ចាយនៃរបបផ្តាច់ការ គឺគ្រាន់តែជាដំណាក់ការដំបូងសំរាប់បើកការខិតខំពង្រឹងសង្គម និងបំពេញសេចក្តីត្រូវការរបស់មនុស្សអោយបានសមរម្យ នៅក្រោមបរិយាកាសមួយ ដែលមានសេរីភាពជាងមុនតែប៉ុណ្ណោះ ។ បញ្ហានយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចដ៏ធ្ងន់ធ្ងរនឹងនៅមានបន្តរាប់ឆ្នាំទៅទៀត ដែលជាការតំរូវអោយមានការសហការពីមនុស្ស និងក្រុមទាំងអស់ ក្នុងការរកដំណោះស្រាយ ។ ប្រព័ន្ធនយោបាយថ្មីគួរតែផ្តល់ឱកាសអោយមនុស្សទាំងពួងដែលមានគំនិត និងមធ្យោបាយផ្សេងៗគ្នា ទៅបន្តការងារស្ថាបនា និងផែនការអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាទាំងឡាយក្នុងពេលអនាគត ។

# ការគំរាមកំហែងពីរបបផ្តាច់ការថ្មី

លោក អារីស្តូត(Aristotle) បានព្រមានជាយូរមកហើយថា "...របបផ្តាច់ការក៏អាចប្រែក្លាយទៅជារបបផ្តាច់ការផងដែរ..." ។[១៤] ភស្តុតាងប្រវត្តិសាស្ត្រជាច្រើនពីប្រទេសបារាំង (ពួកហ្សាក្កូបាំង[Jacobins] និងណាប៉ូឡេអុង [Napoleon]), រុស្ស៊ី (ពួកបុលសេវីក[Bolsheviks]), អ៊ីរ៉ង់ (អសាយ៉ាតូល្លាស[Ayatollah]) និងភូមា (ពួកយោធាស្លក[SLORC]) ហើយនិងទីផ្សេងទៀត ដែលមានអ្នកខ្លះនិងក្រុមខ្លះយល់ថា ការដួលរលំនៃរបបជិះជាន់មួយ គ្រាន់តែជាឱកាសអោយគេចូលជំនួសធ្វើជាម្ចាស់ថ្មីតែប៉ុណ្ណោះ ។ គេប្រហែលជាមានបុព្វហេតុផ្សេងៗគ្នា ប៉ុន្តែលទ្ធផលនោះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ របបផ្តាច់ការថ្មីនេះ ប្រហែលជាអាចកាន់តែសាហាវ ហើយត្រួតត្រារដ្ឋតឹងរឹងជាងរបបចាស់ទៅទៀត ។

ជួនកាល មុននឹងរបបផ្តាច់ការដួលរលំ សមាជិកនៃរបបចាស់ប្រហែល

---

[១៤] អារីស្តូត (Aristotle) *នយោបាយ* ភាគ ៥ ជំពូកទី ១២ ទំព័រទី ២៣៣ ។

ជាល្បែង"កាត់មុខ"ការតស៊ូ តាមរយៈរដ្ឋប្រហារដែលគេរៀបចំឡើង ដើម្បីឆក់យកជោគជ័យពីការតស៊ូនយោបាយរើបម្រះរបស់ប្រជាពលរដ្ឋ ។ គេអាចអះអាងថា គេបានរំលំរបបផ្តាច់ការ ប៉ុន្តែមែនទែនទៅ គេឆ្លៀតយកឱកាសតុបតែងរបបចាស់ អោយមានជារូបភាពថ្មីតែប៉ុណ្ណោះ ។

# ការទប់ស្កាត់រដ្ឋប្រហារ

គេមានមធ្យោបាយមួយចំនួន ដែលអាចធ្វើអោយរដ្ឋប្រហារប្រឆាំងនឹងសង្គមរំដោះថ្មី ទទួលបរាជ័យ ។ ជួនកាល ការដឹងជាមុនអំពីកំលាំងការពារនេះ អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីរារាំងមិនអោយមានការល្បងបែបនេះ ។ ការរៀបចំជាមុនអាចជួយអោយមានការជៀសវាង ។[១៥]

ក្រោយពីរដ្ឋប្រហារបានចាប់ផ្តើមភ្លាម ពួកបះបោរយោធាថ្មីត្រូវការភាពត្រឹមត្រូវតាមច្បាប់ គឺការទទួលស្គាល់ថា គេមានសិទ្ធិនយោបាយនិងសិទ្ធិត្រឹមត្រូវ ដើម្បីគ្រប់គ្រងរដ្ឋ ។ ដូច្នេះ គោលការណ៍ជាគ្រឹះសំរាប់ការពារប្រឆាំងនឹងរដ្ឋប្រហារ គឺការបដិសេធមិនអោយភាពត្រឹមត្រូវតាមច្បាប់ទៅពួកបះបោរយោធានេះ ។

ពួកបះបោរយោធានេះត្រូវការផងដែរអោយពួកអ្នកដឹកនាំស៊ីវិលនិងប្រជាពលរដ្ឋគាំទ្រ ស្ថិតក្នុងភាពច្របូកច្របល់ ឬក៏ស្ងៀមស្ងាត់ ។ ពួកបះបោរយោធាត្រូវការសហការពីសំណាក់ពួកអ្នកជំនាញការ ទីប្រឹក្សា មន្ត្រីរដ្ឋបាល និងចៅក្រម ដើម្បីពង្រឹងការត្រួតត្រាទៅលើសង្គមទាំងមូល ។ ពួកបះបោរក៏ត្រូវការអោយមនុស្សជាច្រើន ដែលកាន់កាប់ប្រព័ន្ធនយោបាយ ស្ថាប័នសង្គមនានា សេដ្ឋកិច្ច ប៉ូលិស និងយោធា ចុះញ៉មដោយស្ងាត់ស្ងៀម ហើយបន្តការងាររបស់គេជាធម្មតា ទៅតាមបទបញ្ជា និងផែនការរបស់ពួកបះបោរ ។

គោលការណ៍ជាគ្រឹះទី ២សំរាប់ការពារ ប្រឆាំងនឹងរដ្ឋប្រហារ គឺការតទល់

---

[១៥] ព័ត៌មានបន្ថែមអំពីការតស៊ូប្រឆាំងនឹងរដ្ឋប្រហារ សូមអាន ជីន សាប *ការប្រឆាំងនឹងរដ្ឋប្រហារ* (បូស្តុន ម៉ាសាឈូសិតៈ វិទ្យាស្ថានអាល់បឺត អាំងស្តាញ ឆ្នាំ២០០៣)

ជាមួយនឹងពួកបះបោរយោធា ដោយប្រើការរើបម្រះ និងមិនសហការ ។ គេត្រូវតែបដិសេធមិនអោយសហការនិងជំនួយដែលពួកនេះត្រូវការ ។ ជាចាំបាច់ គេអាចប្រើមធ្យោបាយតស៊ូដែលគេបានប្រើប្រឆាំងរបបផ្តាច់ការរួចទៅហើយ សំរាប់តទល់នឹងការគំរាមកំហែងថ្មី ប៉ុន្តែគេត្រូវអនុវត្តភ្លាមជាបន្ទាន់ ។ ប្រសិនបើគ្មានភាពត្រឹមត្រូវតាមច្បាប់និងសហការទេនោះ រដ្ឋប្រហារប្រហែលជាស្លាប់ ដោយការបង្អត់ខាងនយោបាយ ហើយឱកាសសំរាប់កសាងសង្គមប្រជាធិបតេយ្យ ក៏អាចមានឡើងវិញដែរ ។

# ការព្រាងរដ្ឋធម្មនុញ្ញ

ប្រព័ន្ធប្រជាធិបតេយ្យថ្មី តំរូវអោយមានរដ្ឋធម្មនុញ្ញមួយ ដែលបង្កើតអោយមានប្រព័ន្ធដែលគេចង់បានសំរាប់រដ្ឋាភិបាលប្រជាធិបតេយ្យ ។ រដ្ឋធម្មនុញ្ញគួរកំណត់អំពីគោលបំណងនៃរដ្ឋាភិបាល និងដាក់កំរិតដល់អំណាចរបស់រដ្ឋាភិបាល មធ្យោបាយ និងពេលវេលាសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមអ្នកធ្វើច្បាប់និងមន្ត្រីរដ្ឋការ សិទ្ធិជាមូលដ្ឋាននៃប្រជាពលរដ្ឋ ហើយនិងការពាក់ព័ន្ធរវាងរដ្ឋាភិបាលជាតិ និងប្រព័ន្ធគ្រប់គ្រងថ្នាក់ខាងក្រោមឯទៀតៗ ។

ចំពោះការគ្រប់គ្រងជាតិ ប្រសិនបើគេចង់អោយមានប្រជាធិបតេយ្យ គេត្រូវតែមានការបែងចែកអំណាចអោយច្បាស់លាស់ រវាងនីតិបញ្ញត្តិ (ក្រុមអ្នកធ្វើច្បាប់) នីតិប្រតិបត្តិ (ក្រុមអ្នកយកច្បាប់ទៅអនុវត្ត) និងតុលាការ (ក្រុមអ្នកកាត់ក្តី) ។ គេគួរតែបញ្ចូលការកំណត់យ៉ាងតឹងតែង ទៅលើសកម្មភាពរបស់ប៉ូលិស ភ្នាក់ងារស៊ើបការណ៍សំងាត់ យោធា ដើម្បីហាមឃាត់មិនអោយក្រុមទាំងនេះមានការលូកឡំតាមផ្លូវច្បាប់ណាមួយទៅក្នុងវិស័យនយោបាយ ។

ដើម្បីការពារលទ្ធិប្រជាធិបតេយ្យ និងជៀសវាងចរន្តនិងមធ្យោបាយផ្តាច់ការ រដ្ឋធម្មនុញ្ញគួរតែរៀបចំអោយមានជាប្រព័ន្ធសហព័ន្ធ ដែលរក្សាទុកបុព្វសិទ្ធិជាច្រើនសំរាប់រដ្ឋាភិបាលប្រចាំតំបន់រដ្ឋផ្សេងៗ និងការគ្រប់គ្រងស្រទាប់ក្រោម ។ នៅក្នុងស្ថានការណ៍ខ្លះ គេអាចពិនិត្យមើលប្រព័ន្ធប្រទេសស្វីស ដែលអនុញ្ញាតអោយតំបន់តូចៗ

មានបុព្វសិទ្ធិដ៏សំខាន់ ហើយនៅតែមានដំណើរការជាផ្នែកមួយនៃប្រទេសទាំងមូល ។

ប្រសិនបើលក្ខណៈទាំងនេះធ្លាប់មានរួចទៅហើយនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសដែលគេទើបតែរំដោះបាន គេអាចដាក់បញ្ចូលយកមកអនុវត្តវិញ ដោយមានការកែប្រែ ប្រសិនបើជាការចាំបាច់ ។ ប្រសិនបើគ្មានរដ្ឋធម្មនុញ្ញចាស់ត្រឹមត្រូវទេនោះ គេអាចអនុវត្តរដ្ឋធម្មនុញ្ញណាមួយជាបណ្តោះអាសន្នសិន ។ បើពុំដូច្នេះទេ គេត្រូវតាក់តែងរដ្ឋធម្មនុញ្ញថ្មី ។ គេត្រូវការពេលវេលា និងការគិតត្រិះរិះជាច្រើនសំរាប់សរសេររដ្ឋធម្មនុញ្ញថ្មី ។ ការចូលរួមពីប្រជាពលរដ្ឋក្នុងការធ្វើរដ្ឋធម្មនុញ្ញជាការប្រសើរ ហើយជាការចាំបាច់សំរាប់អនុម័តរដ្ឋធម្មនុញ្ញថ្មី ឬក៏ការកែប្រែត្រង់ណាមួយ ។ គេត្រូវមានការប្រយ័ត្នអោយមែនទែន អំពីការដាក់ចូលក្នុងរដ្ឋធម្មនុញ្ញ នូវការសន្យាណាមួយដែលគេមិនអាចអនុវត្តកើត ឬក៏មាត្រាណាមួយដែលតំរូវអោយអំណាចច្រើនផ្តុំទៅលើរដ្ឋាភិបាល ។ នេះគឺជាកត្តាពីរ ដែលអាចសំរួលអោយមានរបបផ្តាច់ការថ្មី ។

គេគួរតែប្រើពាក្យពេចន៍សាមញ្ញដែលប្រជាពលរដ្ឋភាគច្រើនអាចងាយយល់ ។ រដ្ឋធម្មនុញ្ញមិនគួរមានលក្ខណៈស្មុគស្មាញ ឬក៏ស្រពេចស្រពិល ដែលមានតែពួកអ្នកច្បាប់ឬក៏បញ្ញាជនដែលអាចអះអាងថាគេយល់ ។

# នយោបាយការពារជាតិតាមប្រជាធិបតេយ្យ

ប្រទេសសេរីក៏អាចប្រឈមមុខទៅនឹងការគំរាមកំហែងពីសំណាក់បរទេសដែលមានបំណងចង់គ្រប់គ្រងខាងសេដ្ឋកិច្ច នយោបាយ និងយោធាដែរ ។

ដើម្បីរក្សាទុកអោយបានលទ្ធិប្រជាធិតេយ្យផ្ទៃក្នុង គេគួរតែពិចារណាអំពីការប្រើគោលការណ៍គ្រឹះនៃនយោបាយរើបម្រះ ដើម្បីបំពេញសេចក្តីត្រូវការខាងការពារជាតិ ។[១៦] ដោយប្រគល់សមត្ថភាពតស៊ូទៅអោយប្រជាពលរដ្ឋជាទូទៅ ប្រទេសរំដោះហើយថ្មីៗ អាចជៀសវាងពុំចាំបាច់បង្កើតអោយមានកងកំលាំងយោធាខ្លាំងក្លា ដែល

---

[១៦] សូមអាន ជីន សាប *ការពារជាតិដោយពលរដ្ឋ : ប្រព័ន្ធសព្វាវុធក្រោយជំនាន់យោធា* ប្រ៊ិនស្តុន (Princeton) ញូវជឺស៊ី (New Jersey) រោងពុម្ពសាកលវិទ្យាល័យប្រ៊ិនស្តុន ឆ្នាំ ១៩៩៤ ។

អាចគំរាមកំហែងដល់ប្រជាធិបតេយ្យ ឬក៏តំរូវអោយមានធនធានសេដ្ឋកិច្ច ដែលគេត្រូវការសំរាប់បំណងផ្សេងៗទៀត ។

គេត្រូវចាំថា ក្រុមខ្លះនឹងបំភ្លេចមាត្រារដ្ឋធម្មនុញ្ញណាមួយ ដើម្បីរៀបចំខ្លួនគេអោយទៅជាពួកផ្តាច់ការថ្មី ។ ដូច្នេះ ប្រជាពលរដ្ឋនឹងមានតួនាទីជាអចិន្ត្រៃយ៍មួយក្នុងការអនុវត្តន៍នយោបាយរើបម្រះនិងមិនសហការ ដើម្បីរក្សានូវរចនាសម្ព័ន្ធ សិទ្ធិនិងបែបបទប្រជាធិបតេយ្យ ប្រឆាំងនឹងជនទាំងឡាយដែលចង់ទៅជាអ្នកផ្តាច់ការ ។

# ការទទួលខុសត្រូវដ៏ល្អប្រសើរ

អានុភាពនៃការតស៊ូអហិង្សា មិនត្រឹមតែធ្វើអោយពួកផ្តាច់ការចុះខ្សោយ ហើយរំលំអ្នកទាំងនោះទេ គឺថែមទាំងជួយអោយអ្នកដែលគេជិះជាន់ ក្លាយទៅជាអ្នកមានការទុកចិត្តលើខ្លួនឯងទៀតផង ។ មធ្យោបាយនេះ ធ្វើអោយអ្នកដែលធ្លាប់តែមានអារម្មណ៍ថា ខ្លួនឯងគ្រាន់តែជាកូនត្រី ឬក៏ជាអ្នករងគ្រោះ ទៅជាអ្នកមាន“អំណាច” ដោយផ្ទាល់ ដើម្បីទាមទារសេរីភាពនិងយុត្តិធម៌បន្ថែមដោយខ្លួនឯង ។ បទពិសោធន៍នៃការតស៊ូនេះ មានឥទ្ធិពលខាងចិត្តសាស្ត្រដ៏សំខាន់ ដែលជួយអោយមានការគោរពនិងទុកចិត្តលើខ្លួនឯងបន្ថែម ក្នុងចំណោមអ្នកដែលធ្លាប់តែយល់ថា គេធ្វើអ្វីមិនកើត ។

ផលប្រយោជន៍សំរាប់ពេលវែងឆ្ងាយមួយនៃការតស៊ូអហិង្សា ដើម្បីបង្កើតជារដ្ឋាភិបាលប្រជាធិបតេយ្យ គឺសង្គមទាំងមូលនឹងមានសមត្ថភាពបន្ថែម ដើម្បីដោះស្រាយបញ្ហាដែលចេះតែមានបន្ត និងបញ្ហាអនាគត ។ បញ្ហាទាំងនោះមានដូចជាការធ្វើផ្តេសផ្តាស និងអំពើពុករលួយរបស់រដ្ឋាភិបាលក្នុងពេលអនាគត ការធ្វើបាបលើក្រុមណាមួយ អយុត្តិធម៌ក្នុងសេដ្ឋកិច្ច និងការខ្វះគុណភាពប្រជាធិបតេយ្យនៃប្រព័ន្ធនយោបាយ ។ ប្រជាពលរដ្ឋដែលមានបទពិសោធន៍ ក្នុងការប្រើនយោបាយរើបម្រះប្រហែលជាមិនអាចចុះខ្សោយ នៅចំពោះមុខរបបផ្តាច់ការអនាគតនោះឡើយ ។

បន្ទាប់ពីការរំដោះនោះហើយ ការចេះដឹងអំពីការតស៊ូអហិង្សា នឹងផ្តល់នូវជំរើសនានា ដើម្បីការពារប្រជាធិបតេយ្យ សេរីភាពស៊ីវិល សិទ្ធិក្រុមភាគតិច និង

បុព្វសិទ្ធិនៃរដ្ឋាភិបាលប្រចាំតំបន់ រដ្ឋ និងស្រទាប់ក្រោម និងស្ថាប័នក្រៅរដ្ឋាភិបាល ។ ជំរើសទាំងនេះក៏ផ្តល់ដែរនូវមធ្យោបាយសំរាប់អោយមនុស្សម្នា និងក្រុមផ្សេងៗ សំដែងការមិនសប្បាយចិត្តយ៉ាងខ្លាំងណាមួយ ដោយសន្តិវិធី ទៅលើបញ្ហាដ៏សំខាន់ទាំងឡាយ ដែលជួនកាលអាចជំរុញក្រុមប្រឆាំងអោយទៅរកភេរវកម្ម ឬក៏សង្គ្រាមឆ្មក់ព្រៃ ។

គំនិតទាំងឡាយក្នុងការពិនិត្យវិភាគអំពីនយោបាយរើបម្រះ ឬក៏ការតស៊ូអហិង្សានេះ គឺសំរាប់ជួយអ្នក ឬក្រុមទាំងឡាយណា ដែលមានបំណងបំបាត់ការជិះជាន់ទៅលើប្រជាពលរដ្ឋ ហើយនិងរៀបចំអោយមានប្រព័ន្ធប្រជាធិបតេយ្យរឹងប៉ឹង ដែលគោរពសេរីភាពមនុស្ស និងសកម្មភាពរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើអោយសង្គមមានដំណើរជឿនលឿនទៅមុខ ។

គេមានសេចក្តីសន្និដ្ឋានសំខាន់ៗបី ដែលលេចចេញពីគំនិតទាំងនោះ ៖

- ការរំដោះពីរបបផ្តាច់ការជាការដែលគេអាចធ្វើទៅបាន
- ដើម្បីសំរេចការនេះ គេត្រូវអោយមានការត្រិះរិះដោយប្រុងប្រយ័ត្ន និងផែនការយុទ្ធសាស្ត្រ ហើយ
- គេត្រូវអោយមានការតាមដានដោយហ្មត់ចត់ ការខំខ្នះខ្នែងធ្វើការងារ និងការតស៊ូប្រកបដោយវិន័យ ។

ពាក្យដែលគេធ្លាប់និយាយថា “សេរីភាពមិនមែនបានមកដោយសេរីងាយស្រួល” គឺជាពាក្យពិត ។ គ្មានកំលាំងពីក្រៅណាមួយ នឹងអោយដល់ប្រជាពលរដ្ឋដែលស្ថិតនៅក្រោមការជិះជាន់ នូវសេរីភាពដែលគេចង់បានជាខ្លាំងនោះឡើយ ។ ប្រជាពលរដ្ឋនឹងត្រូវតែរៀនសូត្រអំពីរបៀប ដែលគេអាចឆក់យកសេរីភាពនេះ ដោយខ្លួនឯង ។ ការនេះមិនអាចងាយស្រួលទេ ។

ប្រសិនបើប្រជាពលរដ្ឋអាចយល់បានអំពីអ្វីដែលគេត្រូវការ ដើម្បីរំដោះខ្លួនគេនោះ គេអាចរៀបចំជាផែនការសកម្មភាព ដែលនៅទីបំផុត តាមរយៈការប្រឹងប្រែងយ៉ាងខ្លាំង នឹងអាចនាំមកនូវសេរីភាពរបស់គេ ។ បន្ទាប់មក ជាមួយនឹងការប្រយ័ត្នប្រយែង គេអាចកសាងជាប្រព័ន្ធប្រជាធិបតេយ្យមួយ ហើយរៀបចំកិច្ចការពារប្រព័ន្ធនោះអោយគង់វង្សផងដែរ ។ សេរីភាពដែលឈ្នះបានតាមការតស៊ូ

បែបនេះ អាចមានលក្ខណៈរឹងប៉ឹង ។ សេរីភាពបែបនេះ នឹងអាចស្ថិតស្ថេរបាន ដោយសារមានអ្នកដែលប្តូរផ្តាច់ទៅលើកិច្ចការពារ និងពង្រីកពង្រឹងសេរីភាពនេះអោយនៅជាបន្តទៅទៀត ។

# ឧបសម្ព័ន្ធ

# មធ្យោបាយនៃសកម្មភាពអហិង្សា

## មធ្យោបាយសំរាប់ការប្រឆាំងនឹងការណែនាំដោយអហិង្សា[១៧]

*ការសំដែងជាផ្លូវការ*

១ សុន្ទរកថាសាធារណៈ
២ សំបុត្រប្រឆាំង ឬក៏គាំទ្រ
៣ សេចក្តីប្រកាសរបស់អង្គការ និងស្ថាប័ននានា
៤ សេចក្តីថ្លែងការណ៍ដែលមានចុះហត្ថលេខា
៥ ការប្រកាសអំពីការកើតទុក្ខមិនសុខចិត្ត និងសកម្មភាពទៅអនាគត
៦ ការធ្វើញត្តិជាក្រុមតូចឬធំ

*ទំនាក់ទំនងជាមួយសាធារណជន*

៧ ពាក្យស្លោក រូបគំនូរ និងរូបសញ្ញា
៨ បដា ផ្ទាំងផ្សាយ និងទំនាក់ទំនងតាមរូបភាព
៩ ខិត្តប័ណ្ណ និងសៀវភៅ
១០ សារព័ត៌មាន និងទស្សនាវដ្តី

---

[១៧] បញ្ជីនេះ ជាមួយនិងនិយមន័យនិងឧទាហរណ៍ជាក់ស្តែង ស្រង់ចេញសៀវភៅ ជីន សាប *នយោបាយនៃសកម្មភាពអហិង្សា* ភាគទី២ *មធ្យោបាយសកម្មភាពអហិង្សា* បូសស្តុន ម៉ាសាឈូសិត : ផតទ័រ សាជិន ឆ្នាំ ១៩៧៣ ។

១១ ថាស វិទ្យុ និងទូរទស្សន៍

១២ ការប្រកាសតាមការសរសេរលើមេឃ ឬក៏លើដី

*ការសំដែងជាក្រុម*

១៣ ការបញ្ជូនជាគណៈប្រតិភូ

១៤ ការធ្វើជាអោយរង្វាន់ផ្សេងៗ

១៥ ការតស៊ូមតិជាក្រុម

១៦ ការលើកបដាជាក្រុមនៅមុខកន្លែងការងារ

១៧ ការធ្វើការបោះឆ្នោតក្រៅផ្លូវការ

*សកម្មភាពជានិមិត្តរូបសាធារណៈ*

១៨ ការតាំងទង់ជ័យ ឬក៏ការប្រើពណ៌ណាមួយជានិមិត្តរូបអ្វីមួយ

១៩ ការពាក់រូបផ្សេងៗ

២០ ការបន់ស្រន់សូត្រមន្ត

២១ ការប្រគល់អោយវត្ថុជានិមិត្តរូប

២២ ការស្រាតប្រឆាំង (ក្នុងទីសាធារណៈ)

២៣ ការបំផ្លាញទ្រព្យសម្បត្តិខ្លួនឯង

២៤ ការប្រើភ្លើងជានិមិត្តរូប

២៥ ការតាំងរូបថតមនុស្ស

២៦ ការគូររូបប្រឆាំង

២៧ រូបសញ្ញា និងឈ្មោះថ្មី

២៨ ការប្រើសំលេងជានិមិត្តរូប

២៩ ការទាមទារកាន់កាប់អ្វីមួយជានិមិត្តរូប

៣០ ការធ្វើកាយវិការចំអេសចំអាស

### *ការសង្កត់សង្កិនលើបុគ្គល*

៣១ “ការលង” ពួកមន្ត្រីរដ្ឋការ (មធ្យោបាយមួយដែលគេដើរតាមពួកមន្ត្រីរដ្ឋការ ហើយរំលឹកពួកនេះ អំពីអំពើអសីលធម៌របស់គេក្នុងការតាមបង្ក្រាបចលនាអ្វីមួយ ។ ជួនកាលគេនាំគ្នាដើរតាមមន្ត្រីទាំងនោះគ្រប់ទីកន្លែង ដើម្បីរំលឹកអំពីការស្វិតស្វាញរបស់ប្រជាពលរដ្ឋ)

៣២ ការរុកគួនមន្ត្រី (ផ្ទុយនឹងការ“លង” ដែលគេធ្វើឡើងដោយស្ងាត់ស្ងៀម និងថ្លៃថ្នូរ ក្នុងករណីនេះ គេនិយាយចំអកបញ្ឈឺមន្ត្រីរដ្ឋការដែលធ្វើតាមបញ្ជាពីលើ )

៣៣ ការប្រើភាពស្និទ្ធស្នាល (ផ្ទុយពីការធ្វើពហិការគេនាំគ្នាទៅបង្ហាញការស្និទ្ធស្នាល ចំពោះពួកទាហាន និងប៉ូលិស ដើម្បីពន្យល់អ្នកទាំងនោះអោយយល់អំពីបុព្វហេតុរបស់គេ)

៣៤ ការសូត្រធម៌ស្មឹងស្មាធិ៍

### *ល្ខោននិងភ្លេង*

៣៥ ឆាកកំប្លែង និងការលេងសើច

៣៦ ការសំដែងល្ខោន និងភ្លេង

៣៧ ចម្រៀង

### *ការដើរដង្ហែ*

៣៨ ការដើរជាក្បួន

៣៩ ការដើរជាក្រុម

៤០ ក្បួនសាសនា

៤១ ការធ្វើដំណើរទៅតំបន់ណាមួយដើម្បីសំដែងការគោរព

៤២ ក្បួនម៉ូតូ

### *ការរំលឹកវិញ្ញាណក្ខ័ន្ធអ្នកស្លាប់*

៤៣ ការកាន់ទុក្ខនយោបាយ

៤៤ ការសំដែងធ្វើជាពិធីបូជាសព

៤៥ ពិធីបូជាសពដែលមានលក្ខណៈជាបាតុកម្ម (ក្នុងស្ថានការណ៍នយោបាយមិនស្ថិតស្ថេរមួយ ពេលធ្វើបុណ្យសព ជាពិសេស នៅពេលដង្ហែក្បួនសពអ្នកដែលត្រូវគេធ្វើឃាតក្នុងការតស៊ូ គេយកឱកាសនេះទៅសំដែងការប្រឆាំង និងការដាក់ទោស)

៤៦ ការគោរពសពនៅទីប៉ាឆា

### *ការប្រជុំសាធារណៈ*

៤៧ កិច្ចប្រជុំ ដើម្បីប្រឆាំងឬក៏គាំទ្រ

៤៨ ការប្រជុំប្រឆាំង

៤៩ ការប្រជុំប្រឆាំងដោយលាក់បាំងគោលបំណង (គឺជាកិច្ចប្រជុំដែលគ្រាន់តែមានរូបភាពថា ជាការប្រជុំដែលមានការអនុញ្ញាតពីរបបផ្តាច់ការ)

៥០ កិច្ចប្រជុំប្រឆាំងតាមរបៀបបង្រៀន (កិច្ចប្រជុំបែបនេះមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចប្រជុំធ្វើបាតុកម្ម ប៉ុន្តែនៅក្នុងឱកាសនេះ គេមានវាគ្មិនដែលសុទ្ធតែជាអ្នកឯកទេសនៅក្នុងបញ្ហា ដែលពាក់ព័ន្ធ)

### *ការដកខ្លួននិងការបដិសេធ*

៥១ ការដើរចេញ

៥២ ការនៅស្ងៀមស្ងាត់

៥៣ ការបដិសេធមិនទទួលយសស័ក្តិ

៥៤ ការបែរខ្នងដាក់មនុស្សឬក្រុមណាមួយ

# មធ្យោបាយមិនសហការក្នុងសង្គម

*ការបំភ្លេចបុគ្គលណាមួយ*

៥៥ ពហិការពិសេស

៥៦ ពហិការសង្គម ដែលគេជ្រើសរើសទិសដៅ

៥៧ ពហិការតាមបែបលីស៊ីស្ត្រាតា(Lysistrata) (គឺជាការដែលភរិយានាំគ្នាមិនរួមរក្សជាមួយស្វាមី)

៥៨ ការកាត់កាល់ (បណ្តេញចេញពីក្រុមសាសនាណាមួយ)

៥៩ ពហិការតាមបែបសាសនា (ការសំរេចព្យួរកម្មវិធីបួងសួងក្នុងព្រះវិហារ ឬវត្តអារាម)

*ការមិនសហការក្នុងពិធីក្នុងសង្គម ទំនៀមទំលាប់ និងស្ថាប័ន*

៦០ ការព្យួរសកម្មភាពសង្គម ឬក៏កីឡា

៦១ ពហិការមិនចូលរួមក្នុងកិច្ចការសង្គម

៦២ កូដកម្មរបស់និស្សិត

៦៣ ការមិនស្តាប់បង្គាប់ក្នុងសង្គម

៦៤ ការដកចេញពីស្ថាប័នសង្គម

*ការដកខ្លួនចេញពីប្រព័ន្ធសង្គម*

៦៥ ការនៅក្នុងផ្ទះមិនទៅធ្វើការ

៦៦ ការមិនធ្វើការសហការដោយផ្ទាល់ខ្លួន

៦៧ ការរត់ចេញរបស់ពួកកម្មករ

៦៨ ការទៅរកទីជំរកសុវត្ថិភាព

៦៩ ការលាក់ខ្លួនជាក្រុម

៧០ ការចាកចេញពីស្រុក (ជាកិច្ចប្រឆាំងមួយដែលប្រជាពលរដ្ឋទាំងអស់នាំគ្នាចាកចេញពីស្រុក-ឃុំណាមួយ)

# មធ្យោបាយមិនសហការសេដ្ឋកិច្ច

## (១) ពហិការសេដ្ឋកិច្ច

*សកម្មភាពអ្នកទិញប្រើប្រាស់*

៧១ ពហិការរបស់អ្នកទិញ

៧២ ការមិនប្រើប្រាស់ទំនិញដែលគេធ្វើពហិការ

៧៣ ផែនការបន្ថយការប្រើប្រាស់ទំនិញណាមួយ

៧៤ ការមិនបង់ឈ្នួលផ្ទះ

៧៥ ការមិនព្រមជួល

៧៦ ពហិការរបស់អ្នកទិញទូទាំងប្រទេស

៧៧ ពហិការរបស់អ្នកប្រើប្រាស់ទូទាំងពិភពលោក

*សកម្មភាពអ្នកធ្វើការ និងផលិតករ*

៧៨ ពហិការរកម្មករ

៧៩ ពហិការអ្នកផលិតទំនិញ

*សកម្មភាពឈ្នួញកណ្តាល*

៨០ ពហិការរបស់អ្នកលក់ និងអ្នកចែកចាយទំនិញ

*សកម្មភាពម្ចាស់ក្រុមហ៊ុន និងអ្នកគ្រប់គ្រង*

៨១ ពហិការរបស់ពួកឈ្មួញ

៨២ ការបដិសេធមិនលក់ ឬមិនជួលផ្ទះ

៨៣ ការចាក់សោរមិនអោយចេញចូលកន្លែងណាមួយ

៨៤ ការបដិសេធមិនផ្តល់ជំនួយទៅរោងចក្រ ឬការងារណាមួយ

៨៥ កូដកម្មទូទៅរបស់ឈ្មួញ

*សកម្មភាពអ្នកគ្រប់គ្រងលុយកាក់*

៨៦ មិនដាក់លុយចូលធនាគារ

៨៧ បដិសេធមិនបង់កំរៃផ្សេងៗ

៨៨ បដិសេធមិនសងបំណុល ឬក៏ការប្រាក់

៨៩ ការកាត់ផ្តាច់លុយ ឬក៏លែងអោយខ្ចី

៩០ ការបដិសេធមិនទទួលលុយចូល

៩១ ការមិនទទួលលុយរដ្ឋការ

*សកម្មភាពរដ្ឋាភិបាល*

៩២ ការហាមឃាត់អ្វីមួយក្នុងស្រុក

៩៣ ការធ្វើបញ្ជីឈ្មួញ ដែលគេមិនសហការ

៩៤ ការហាមឃាត់របស់អ្នកលក់អន្តរជាតិ

៩៥ ការហាមឃាត់របស់អ្នកទិញអន្តរជាតិ

៩៦ ការព្យួរសកម្មភាពពាណិជ្ជកម្មអន្តរជាតិ

# មធ្យោបាយមិនសហការសេដ្ឋកិច្ច

## (២) កូដកម្ម

*កូដកម្មជានិមិត្តរូប*

៩៧ កូដកម្មប្រឆាំង

៩៨ ការដើរចេញពីការងារភ្លាមៗ

*កូដកម្មកសិកម្ម*

៩៩ កូដកម្មកសិករ

១០០ កូដកម្មកម្មករស្រែចំការ

*កូដកម្មរបស់ក្រុមពិសេស*

១០១ ការបដិសេធមិនធ្វើការរបស់កម្មករដែលគេបង្ខំ

១០២ កូដកម្មអ្នកទោស

១០៣ កូដកម្មសិប្បករ (គឺជាកូដកម្មរបស់ក្រុមអ្នកធ្វើការនៅក្នុងរបរសិប្បកម្មណាមួយ ឬក៏នៅក្នុងក្រុមហាងទំនិញ ក្នុងតំបន់ណាមួយ)

១០៤ កូដកម្មពួកអ្នកវិជ្ជាជីវៈ

*កូដកម្មឧស្សាហកម្មធម្មតា*

១០៥ កូដកម្មនៅតាមគ្រឹស្ថានជំនួញ

១០៦ កូដកម្មទៅតាមឧស្សាហកម្មនីមួយៗ

១០៧ ឧស្សាហកម្មដោយសមានចិត្ត

*កូដកម្មដោយកំណត់*

១០៨ កូដកម្មធម្មតា (ក្នុងកូដកម្មបែបនេះ កម្មករនាំគ្នាឈប់ម្តងម្នាក់ជាបន្តបន្ទាប់គ្នា ឬក៏ទៅរកការងារផ្សេង រហូតទាល់តែនិយោជកបានដឹងអំពីការកើតទុក្ខមិនសុខចិត្ត និងការទាមទាររបស់កម្មករ)

១០៩ កូដកម្មដោយចំពោះ (កូដកម្មនេះមានលក្ខណៈដូចកូដកម្មធម្មតា ប៉ុន្តែពួកសហជីពធ្វើកូដកម្មនៅក្នុងក្រុមហ៊ុនតែមួយ ដែលជាការធ្វើអោយក្រុមហ៊ុននេះចាញ់ប្រៀបក្រុមហ៊ុនប្រកួតឯទៀត)

១១០ កូដកម្មពន្យឺតការងារ

១១១ កូដកម្មដែលកំណត់ការងារទៅតាមក្បួនសុទ្ធសាធ

១១២ ការប្រាប់និយោជកថាឈឺធ្វើការមិនកើត

១១៣ កូដកម្មតាមការសុំលាលែង

១១៤ កូដកម្មដែលមានកំរិត

១១៥ កូដកម្មដោយជំរើស

*កូដកម្មទាក់ទងនឹងឧស្សាហកម្មច្រើន*

១១៦ កូដកម្មដែលក្លាយទៅជាទូទៅ (គឺជាការធ្វើកូដកម្មនៅក្នុងឧស្សាហកម្មមួយចំនួន ដោយសារមានបញ្ហាជាទូទៅ)

១១៧ កូដកម្មទូទៅ (គឺជាកូដកម្មដែលមានលក្ខណៈទូលំទូលាយ ដើម្បីធ្វើអោយជីវភាពសេដ្ឋកិច្ចនៅក្នុងតំបន់ណាមួយជាប់គាំង)

*ការរួមបញ្ចូលកូដកម្មនិងការបិទសកម្មភាពសេដ្ឋកិច្ច*

១១៨ កូដកម្ម*ហាថុល* (Hartal) (ការបិទហាងទំនិញ)

១១៩ ការបញ្ឈប់សកម្មភាពសេដ្ឋកិច្ច

# មធ្យោបាយនៃការមិនធ្វើសហការ

*ការបដិសេធអំណាចអាជ្ញាធរ*

១២០ ផ្អាក ឬក៏ការដកចេញភាពស្មោះត្រង់

១២១ ការបដិសេធមិនអោយមានការគាំទ្រពីសាធារណជន

១២២ សំណេរនិងសេចក្តីថ្លែងការណ៍ជំរុញអោយមានការប្រឆាំង

*ការមិនសហការរបស់ប្រជាពលរដ្ឋជាមួយរដ្ឋាភិបាល*

១២៣ ពហិការនៅក្នុងនីតិបញ្ញត្តិ (រដ្ឋសភា ព្រឹទ្ធសភា)

១២៤ ពហិការមិនចូលធ្វើការបោះឆ្នោត

១២៥ ពហិការមិនទទួលការងាររដ្ឋការ

១២៦ ពហិការមិនទាក់ទងនឹងក្រសួងរដ្ឋាភិបាលនានា

១២៧ ការដកចេញពីស្ថាប័នអប់រំរបស់រដ្ឋាភិបាល

១២៨ ពហិការមិនទាក់ទងនឹងអង្គការណាដែលរដ្ឋាភិបាលគាំទ្រ

១២៩ បដិសេធមិនផ្តល់ជំនួយដល់អ្នកដែលអនុវត្តច្បាប់ ដូចជាប៉ូលិសជាដើម

១៣០ ដកហូតយកផ្លាក់រូបសញ្ញាសំគាល់ផ្សេងៗរបស់ខ្លួន ដែលគេធ្លាប់ដាក់ជួយណែនាំសាធារណជន

១៣១ បដិសេធមិនទទួលមន្ត្រីរាជការដែលគេចាត់តាំង

១៣២ បដិសេធមិនព្រមរំលាយស្ថាប័នបច្ចុប្បន្ន

*ជំរើសក្រៅពីការធ្វើតាមបង្គាប់*

១៣៣ ការធ្វើតាមបង្គាប់ទាំងទើសទាល់ ឬក៏យឺតយ៉ាវ

១៣៤ ការមិនធ្វើតាមបង្គាប់ នៅពេលដែលគ្មានអ្នកតាមឃ្លាំមើល

១៣៥ ការមិនធ្វើតាមបង្គាប់ ពីសំណាក់ប្រជាពលរដ្ឋ

១៣៦ ការមិនធ្វើតាមបង្គាប់ដែលគេក្លែងមិនអោយដឹង

១៣៧ ការប្រកែកមិនព្រមបំបែកកិច្ចប្រជុំ

១៣៨ ការអង្គុយនៅមួយកន្លែង

១៣៩ ការមិនសហការក្នុងការចូលធ្វើទាហាន និងការនិរទេស

១៤០ ការលាក់ខ្លួន គេចខ្លួន ឬក៏ប្រើប័ណ្ណសំគាល់ខ្លួនក្លែងក្លាយ

១៤១ ការមិនគោរពតាមច្បាប់ដែលគ្មានលក្ខណៈត្រឹមត្រូវ

*សកម្មភាពដោយមន្ត្រីរដ្ឋាភិបាល*

១៤២ ការប្រកែកមិនទទួលជំនួយពីអ្នកជំនួយការរដ្ឋាភិបាល

១៤៣ ធ្វើអោយរាំងស្ទះខ្សែបញ្ជា និងព័ត៌មាន

១៤៤ ការបង្កើតឧបសគ្គអោយយឺតយ៉ាវ

១៤៥ ការមិនធ្វើសហការរដ្ឋបាលជាទូទៅ

១៤៦ ការមិនធ្វើសហការជាមួយតុលាការ

១៤៧ ការធ្វើការដោយគ្មានប្រសិទ្ធភាព និងការមិនសហការខ្លះរបស់ពួកអនុវត្ត ច្បាប់

១៤៨ ការបះបោរ

*សកម្មភាពរដ្ឋាភិបាលនៅក្នុងស្រុក*

១៤៩ ការជៀសវាង ឬក៏ពន្យាពេល ពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់

១៥០ ការមិនសហការរបស់អង្គភាពរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងអ្នកបោះឆ្នោត

សកម្មភាពរដ្ឋាភិបាលលើផ្នែកអន្តរជាតិ

១៥១ ការផ្លាស់ប្តូរបុគ្គលិកទូត

១៥២ ពន្យាពេល ឬក៏លុបចោលកម្មវិធីការទូត

១៥៣ ការមិនព្រមសំរេចទទួលស្គាល់តាមការទូត

១៥៤ ការផ្តាច់ចំណងទូត

១៥៥ ការដកខ្លួនចេញពីអង្គការអន្តរជាតិនានា

១៥៦ ការបដិសេធមិនអោយសមាជិកភាពក្នុងអង្គការអន្តរជាតិណាមួយ

១៥៧ ការបណ្តេញចេញពីអង្គការអន្តរជាតិណាមួយ

# មធ្យោបាយនៃអន្តរាគមន៏អហិង្សា

*អន្តរាគមន៏តាមផ្លូវចិត្ត*

១៥៨ ការសំដិលខ្លួន (គឺជាការសំដែងមតិណាមួយតាមការសំដិលខ្លួន អោយឈឺចាប់រងទុក្ខតាមរាងកាយ ដូចជាការសំដិលខ្លួនក្រោមកំដៅព្រះអាទិត្យ)

១៥៩ តំណមសីលធម៏ (គឺជាបែបបទធ្វើអន្តរាគមន៏តាមផ្លូវចិត្ត ។ ក្នុងអំពើនេះ គេបដិសេធម្ហូបអាហារ ដើម្បីសំរេចនូវគោលបំណងសង្គមឬនយោបាយណាមួយ)

ក- តំណមមិនទទួលសំពាធសីលធម៏

ខ- កូដកម្មអត់អាហារ

គ- តំណមតាមបែបសាត្យាក្រាហ្វី (Satyagraphi) (តាមសាសនាហិណ្ឌូដែលមហាត្មះគន្ធីអនុវត្ត)

១៦០ ការកាត់ទោសបញ្ច្រាស (ក្នុងករណីនេះ គេប្តូរតួនាទីរវាងអយ្យាការ និងកូនក្តីក្នុងការកាត់ទោសណាមួយ ។ ពួកកូនក្តីនឹងក្លាយទៅជាអយ្យាការ ហើយគេបង្វែរអោយទៅជាបាតុកម្មប្រឆាំងនឹងអ្វីមួយទៅវិញ)

១៦១ ការរំខានអហិង្សា

*អន្តរាគមន៍ដោយកាយវិការ*

១៦២ ការអង្គុយនៅមួយកន្លែង

១៦៣ ការឈរនៅមួយកន្លែង (ក្នុងករណីនេះ គេនាំគ្នាឈរយ៉ាងស្ងាត់ស្ងៀម ដោយមានសណ្តាប់ធ្នាប់ នៅកន្លែងលក់សំបុត្រណាមួយ ឬទ្វារចូលកន្លែងណាមួយជាដើម ដើម្បីទិញសំបុត្រ ឬចូលកន្លែងនោះ នៅពេលគេមិនព្រមលក់សំបុត្រ ឬក៏ហាមឃាត់មិនអោយចូល)

១៦៤ ការជិះយានជំនិះសាធារណៈខុសកន្លែងកំណត់ (គេប្រើមធ្យោបាយនេះជាទូទៅនៅក្នុងសហរដ្ឋអាមេរិក ក្នុងទសវត្ស១៩៦០ ប្រឆាំងនឹងការបែងចែកកន្លែងអង្គុយ សំរាប់ពួកស្បែកស និងពួកស្បែកខ្មៅ នៅតាមយានជំនិះសាធារណៈ)

១៦៥ ការង្វូតទឹកលើឆ្នេរដែលគេហាមឃាត់ (នៅក្នុងប្រទេសខ្លះ គេបានបែងចែកឆ្នេរសំរាប់ប្រជាពលរដ្ឋសមុទ្រទៅតាមពណ៌សម្បុរស្បែក)

១៦៦ ការកាន់កាប់ទីកន្លែង (ក្រុមអ្នកប្រឆាំងចូលទៅក្នុងទីកន្លែងមួយដែលមាននិមិត្តរូបសំខាន់ ពាក់ព័ន្ធនឹងការកើតទុក្ខមិនសុខចិត្តរបស់គេ ដូចជាការិយាល័យអ្នកដែលគេប្រឆាំង ។ គេនឹងក្រាញនៅទីនោះមួយរយៈពេលដែលគេច្រើនតែកំណត់ទុកជាមុន)

១៦៧ ការចូលបួងសួងក្នុងព្រះវិហារដែលគេហាមឃាត់ (នៅកន្លែងខ្លះ ពីដើមគេបែងចែក ទីកន្លែងសាសនាទៅតាមពណ៌សម្បុរ កន្លែងខ្លះទៀត គេបែងចែកវត្តអារាមទៅតាមគណបក្សនយោបាយ)

១៦៨ ការចូលលុកលុយដោយអហិង្សា

១៦៩ ការចូលលុកលុយតាមអាកាសដោយអហិង្សា

១៧០ ការចូលឈ្លានពានដោយអហិង្សា

១៧១ ការនិយាយកាត់ឬជាន់គេដោយអហិង្សា

១៧២ ការបង្កើតឧបសគ្គដោយអហិង្សា

១៧៣ ការចូលកាន់កាប់ដោយអហិង្សា

*អន្តរាគមន៍ខាងសង្គម*

១៧៤ ការរៀបចំអោយមានលំនាំសង្គមថ្មី

១៧៥ ការដាក់ជំនួយការអោយច្រើនហួស

១៧៦ ការធ្វើអោយដំណើរការយឺតយ៉ាវ
(ករណីនេះច្រើនតែពាក់ព័ន្ធទៅនឹងបញ្ហាសង្គម ឬក៏ជំនួញ)

១៧៧ ការរំខានអង្គប្រជុំ (គឺជាប្រភេទពិសេសនៃការធ្វើអន្តរាគមន៍អហិង្សា នៅពេលដែលគេរំខានកិច្ចប្រជុំ ការបួងសួងក្នុងវត្តអារាម ឬក៏ការប្រជុំផ្សេងៗទៀត)

១៧៨ ការលេងល្ខោនចំអក (ជាប្រភេទមួយទៀតនៃការធ្វើអន្តរាគមន៍សង្គម ដែលពាក់ព័ន្ធទៅនឹងការសំដែងល្ខោន ឬក៏ការសំដែងអ្វីមួយ ដើម្បីរំខានការថ្លែងសុន្ទរកថា សិក្ខាសាលាជាដើម)

១៧៩ ស្ថាប័នសង្គមជាជំរើសផ្សេងទៀត

១៨០ ប្រព័ន្ធទំនាក់ទំនងផ្សេងទៀត

*អន្តរាគមន៍សេដ្ឋកិច្ច*

១៨១ កូដកម្មបញ្ច្រាស (គឺជាការបង្កើតអោយមានឥទ្ធិពលខាងចិត្តសាស្ត្រ ។ ក្នុងករណីនេះ កម្មករធ្វើការកាន់តែខ្លាំងឡើង ហើយលើសពេលវេលាដោយពុំបានកំរៃបន្ថែម ។ គេធ្វើនេះដើម្បីទាមទារអោយឡើងប្រាក់ខែ ហើយនិយោជកពិបាកបដិសេធ ។)

១៨២ កូដកម្មនៅនឹងកន្លែង (ក្នុងករណីនេះ កម្មករផ្អាកការងារ ប៉ុន្តែក្រាញមិនទៅផ្ទះ ហើយបដិសេធមិនព្រមចេញពីកន្លែងធ្វើការ រហូតដល់គេបានសំរេចដូចបំណង)

១៨៣ ការរឹបអូសដីដោយអហិង្សា

១៨៤ ការរឹងទទឹងតទល់នឹងការឃាត់ឃាំង (នេះគឺជាទំនាស់អន្តរជាតិ ដែល

ប្រទេសនីមួយៗប្រហែលជាចង់ដាក់សំពាធនយោបាយ តាមការរារាំង មិនអោយអីវ៉ាន់សំខាន់បែបណាមួយ ចូលប្រទេសណា មួយទៀត ។ ការរឹងទទឹង និងការរារាំងនេះ មិនប្រើការគំរាមកំហែង ឬក៏កំលាំងយោធា គឺជាមធ្យោបាយអន្តរាគមន៍ខាងសេដ្ឋកិច្ចមួយ ដែលប្រទេសមួយទៀតអាចចូលមកគាំទ្រប្រទេសដែលកំពុងរងគ្រោះ ។)

១៨៥ ប្រាក់ក្លែងក្លាយដោយសារកត្តានយោបាយ

១៨៦ ការទិញម៉ៅ (ការនេះគឺជាការអន្តរាគមន៍មួយបែបដែលពាក់ព័ន្ធនឹងការម៉ៅទិញទំនិញអ្វីមួយ នៅក្នុងផ្សារអន្តរជាតិ ដើម្បីកុំអោយទំនិញនេះធ្លាក់ក្នុងកណ្តាប់ដៃសត្រូវ)

១៨៧ ការរឹបអូសយកទ្រព្យសម្បត្តិ

១៨៨ ការលក់ឥវ៉ាន់ក្នុងតំលៃថោកៗ

១៨៩ ការរកស៊ីដោយជំរើស

១៩០ ផ្សារជំរើសឯទៀត

១៩១ ប្រព័ន្ធដឹកជញ្ជូនឯទៀត

១៩២ ស្ថាប័នសេដ្ឋកិច្ចជំរើសឯទៀត

### *អន្តរាគមន៍នយោបាយ*

១៩៣ បន្ថែមប្រព័ន្ធរដ្ឋបាលអោយលើសកំរិត

១៩៤ ការបើកមុខភ្នាក់ងារសំងាត់

១៩៥ ការចង់អោយគេដាក់គុក

១៩៦ ការមិនគោរពតាមច្បាប់ដែល“អព្យាក្រឹត” (ជាធម្មតា គេនាំគ្នាមិនគោរពច្បាប់ ដែលគេយល់ថាមានលក្ខណៈអសីលធម៌ ឬខុស ។ ប៉ុន្តែក្នុងករណីនេះ គេនាំគ្នាមិនគោរពច្បាប់ដែលគេយល់ថា មិនមែនជាច្បាប់ខុសឬអសីលធម៌អ្វីទេ ។)

១៩៧ ការបន្តការងារដោយមិនសហការ (ក្នុងករណីនេះ មន្ត្រីរដ្ឋបាលនៅតែ

ក្រាញធ្វើកិច្ចការទៅតាមផែនការ  កម្មវិធីឬក៏មុខនាទីចាស់ដែលត្រឹមត្រូវតាមច្បាប់ ដោយធ្វើមិនដឹងមិនឮអំពីវិធានការថ្មី  របស់របបដែលទើបតែចូលកាន់កាប់រដ្ឋ)

១៩៨  រដ្ឋាភិបាលពេញច្បាប់  និងរដ្ឋាភិបាលទន្ទឹម

# អំពីអ្នកនិពន្ធ

លោក ជីន សាប បច្ចុប្បន្នជាអ្នកសិក្សាជាន់ខ្ពស់នៃវិទ្យាស្ថានអាល់បឺត អាញស្តែន នៅទីក្រុងប៊ូស្តុន (Boston) នៃរដ្ឋម៉ាសាឈូសិត (Massachusetts) ។ លោកមានបរិញ្ញាប័ត្រ និងមហាបរិញ្ញាប័ត្រ ពីសកលវិទ្យាល័យរដ្ឋអូហៃយ៉ូ (Ohio) និងបរិញ្ញាប័ត្របណ្ឌិត ផ្នែកទ្រឹស្តីនយោបាយ ពីសកលវិទ្យាល័យអកស្វឺត (Oxford) (ប្រទេសអង់គ្លេស) ។ លោកក៏បានទទួលដែរនូវសញ្ញាប័ត្របណ្ឌិតកិត្តិយសខាងច្បាប់ ពីមហាវិទ្យាល័យម៉ាន់ហាតតាន់ (Manhattan) និងបណ្ឌិតខាងកិច្ចបំរើមនុស្សធម៌ពី មហាវិទ្យាល័យរីវៀរ (Rivier) ។ លោកជាសាស្ត្រាចារ្យ (ចូលនិវត្តន៍) នៃមុខវិជ្ជាវិទ្យាសាស្ត្រនយោបាយ នៅសកលវិទ្យាល័យម៉ាសាឈូសេត ដាម៉ោត (Massachusetts Dartmouth) ។ លោកក៏បានបង្រៀនដែរ នៅសកលវិទ្យាល័យអូស្លូ (Oslo) សកលវិទ្យាល័យម៉ាសាឈូសេតក្នុងក្រុងប៊ូស្តុន ហើយជាអ្នកស្រាវជ្រាវជិត ៣០ឆ្នាំ នៅមជ្ឈមណ្ឌលសំរាប់បញ្ហាអន្តរជាតិនៃសកលវិទ្យាល័យហាវីត (Harvard) ។ សៀវភៅដែលលោកបានសរសេរជាភាសាអង់គ្លេសមានជាអាទិ៍ *នយោបាយនៃសកម្មភាពអហិង្សា* (១៩៧៣), *គន្ធី ជាអ្នកយុទ្ធសាស្ត្រនយោបាយ* (១៩៧៩), *អំណាចសង្គម និងសេរីភាពនយោបាយ* (១៩៨០), *ការមិនធ្វើអោយគេត្រួតអឺរ៉ុបបាន* (១៩៨៥), ហើយនិង *កិច្ចការពារដែលចេញពីរាស្ត្រ : ប្រព័ន្ធអាវុធក្រោយសម័យយោធា* (១៩៩០) ។ លោកកំពុងតែរៀបចំសៀវភៅសំខាន់មួយទៀត (២០០៣) *ការតស៊ូអហិង្សា : ការអនុវត្តន៍សតវត្សទី២០ និងផលអនាគតសតវត្សទី២១* ។ ស្នាដៃរបស់លោកបានត្រូវគេបកប្រែសំរួលទៅជាង ៣០ភាសា ។

# អំពីអ្នកបកប្រែ

អ៊ឹង ប៊ុនអាង បច្ចុប្បន្ននេះជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។ លោកមានបរិញ្ញាប័ត្រខាងសេដ្ឋសាស្ត្រ (BEc) ពីសកលវិទ្យាល័យជេមឃុគ (James Cook) និងមហាបរិញ្ញាប័ត្រខាងគ្រប់គ្រងជំនួញ(MBA) ពីសាកលវិទ្យាល័យឃ្វីនស្លិន (Queensland) នៃប្រទេសអូស្ត្រាលី ។ ក្នុងរវាងជាង២០ឆ្នាំកន្លងទៅនេះ លោកមានវិជ្ជាជីវៈ និងបទពិសោធន៍ការងារជាគណនេយ្យករសាធារណៈ ទីប្រឹក្សាជំនួញ និង បានច្បាប់អនុញ្ញាតពីអាជ្ញាធរអូស្ត្រាលី អោយប្រកបរបរជាទីប្រឹក្សាខាងចាត់ចែងលុយកាក់សាធារណជន ។ ក្នុងទសវត្ស១៩៩០ លោកបានបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ និងវប្បធម៌-អរិយធម៌ខ្មែរ នៅសកលវិទ្យាល័យបច្ចេកទេសអារអិមអាយធី (RMIT University of Technology) នៅក្នុងទីក្រុងម៉ែលប៊ន ។ លោកធ្លាប់ធ្វើជានាយកនៃកម្មវិធីវិទ្យុជាភាសាខ្មែរ ប្រចាំទីក្រុងម៉ែលបួននៃប្រព័ន្ធផ្សាយព័ត៌មានពិសេសប្រទេសអូស្ត្រាលី (SBS) ។ លោកបានបោះពុម្ពផ្សាយទស្សនាវដ្ដី "អ្នកនាំសារ" ជាភាសាខ្មែរក្នុងប្រទេសអូស្ត្រាលី និងផ្ដល់អត្ថបទខ្លីៗជាច្រើន ស្ដីអំពីបញ្ហានយោបាយ និងសេដ្ឋកិច្ចដល់ប្រព័ន្ធព័ត៌មានបរទេសនានា ។ កាលពីចុងទសវត្ស១៩៦០ លោកធ្លាប់សរសេរអត្ថបទស្រាវជ្រាវ នានាអោយកាសែត"មាតុភូមិ" និងក្រោយមកកាសែត"ប្រយោជន៍ខ្មែរ"ក្នុងទីក្រុងភ្នំពេញ ។